# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# សេវាកម្មទិញ-លក់មូលបត្ររបស់
# ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

កម្មសិក្សាពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី**


គាត់តែងឡើងដោយ

និស្សិតឈ្មោះ **ខុធ សុជាតា**

**ហ៊ុន សុធារី**

ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

២០១៣ជំនាន់ទី ១០

សាស្ត្រាចារ្យណែនាំ

លោកស្រី **ស៊ឹម វិច្ឆិកា**


ឆ្នាំចូលសិក្សា

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **វុធ សុជាតា** និង **ហ៊ុន សុធារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារឆ្នាំទី៤ ជំនាន់ទី១០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៣-២០១៧ ដែលបានធ្វើសារណាបញ្ចប់ការសិក្សាទៅលើប្រធានបទមួយដែលទាក់ទងនឹង "សេវាកម្មទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី" ។ យើងខ្ញុំទាំងពីរសូមធ្វើការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរដែលបានផ្ដល់កំណើត និងធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ផ្ដល់ក្ដីស្រលាញ់ និងផ្គត់ផ្គង់គ្រប់សព្វបែបយ៉ាងឲ្យពួកយើងបានសិក្សារៀនសូត្រមានចំណេះដឹង រហូតដល់យើងខ្ញុំទាំងអស់គ្នាបានមកដល់ថ្នាក់ឧត្ដមសិក្សានេះ។
- ឯកឧត្ដមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យព្រមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានខិតខំទាំងកម្លាំងកាយនិងកម្លាំងចិត្តដើម្បីអប់រំ ប្រៀនប្រដៅ បង្ហាត់បង្រៀន ណែនាំ និងផ្ដល់ចំណេះដឹងដ៏វិសេសវិសាលជាច្រើនសម្រាប់អភិវឌ្ឍន៍ខ្លួន ឲ្យក្លាយទៅជាបុគ្គលមួយរូបដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីជួយខ្លួនឯង និងក្លាយទៅជាបុគ្គលម្នាក់ដែលសង្គមត្រូវការ។
- ជាពិសេស យើងខ្ញុំទាំងពីរសូមអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី **ស៊ឹម ទិទ្ធិភា** ដែលបានដឹកនាំ ចង្អុលបង្ហាញ ក៏ដូចជាផ្ដល់នូវយោបល់ និងជួយកែតម្រូវនូវចំនុចខ្វះខាតមួយចំនួនដែលពួកយើងមាន នៅក្នុងការស្រាវជ្រាវទៅលើប្រធានបទមួយនេះ។
- មួយវិញទៀត យើងខ្ញុំសូមអរគុណដល់អ្នកស្រី **អ៊ុំ សុភ័ក្ត្រ** ដែលជាប្រធានផ្នែកឈ្មួញជើងសាមូលបត្រ ព្រមទាំងបុគ្គលិកនៅក្នុងក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ីទាំងអស់ដែលបានយកចិត្តទុកដាក់ ផ្ដល់ព័ត៌មាន និងបង្ហាត់បង្ហាញយើងខ្ញុំទាំងពីរ ក្នុងកំឡុងពេលចុះកម្មសិក្សាស្រាវជ្រាវកន្លងមកនេះ។
- លើសពីនេះទៀត យើងខ្ញុំទាំងពីរសូមថ្លែងអំណរគុណចំពោះរៀមច្បងជំនាន់មុនៗដែលបានបន្សល់ទុកនូវស្នាដៃដែលជាឯកសារសម្រាប់យើងខ្ញុំ ក៏ដូចជានិស្សិតជំនាន់ក្រោយដទៃទៀតធ្វើជាគំរូសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ជាចុងក្រោយ ក្រុមរបស់យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ ជូនចំពោះអ្នកមានគុណទាំងអស់ឲ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការដាក់ឲ្យដំណើរការក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាសញ្ញាវិជ្ជមានមួយសម្រាប់ប្រទេសកម្ពុជា និងជាពិសេសសម្រាប់សហគមន៍ធុរកិច្ចកម្ពុជាទាំងមូល។ ជាក់ស្តែង យើងឃើញថាទីផ្សារមូលបត្រ គឺជាវិស័យមួយទើបតែបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលជួយបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនសាជីវកម្មក្នុងការស្វែងរកដើមទុនបន្ថែម ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។ វិស័យមូលបត្របានក្លាយជាវិស័យដ៏សំខាន់មួយដើម្បីជួយជំរុញសេដ្ឋកិច្ចជាតិ និងជីវភាពរបស់ប្រជាជនកម្ពុជាតាមរយៈការវិនិយោគក្នុងវិស័យមួយនេះ។ យ៉ាងណាមិញ វិស័យមូលបត្រជាវិស័យមួយដែលមានភាពសាំញ៉ាំ និងស្មុគស្មាញជាងវិស័យផ្សេងទៀតនៅក្នុងវិស័យហិរញ្ញវត្ថុដែលធ្វើឲ្យសាធារណៈជន ឬវិនិយោគិននៃប្រទេសយើងមួយចំនួនមិនបានដឹង ឬយល់ច្បាស់ពីវិធីសាស្ត្រក្នុងការជួញដូរ។ ហេតុដូចនេះហើយទើបធ្វើឲ្យវិស័យមួយនេះមានការវិវត្តយឺតយ៉ាវ ជាលទ្ធផលការយល់ដឹងពីដំណើរការនៃការជួញដូរមូលបត្រ គឺជាគន្លឹះមួយដ៏សំខាន់សម្រាប់អភិវឌ្ឍវិស័យមួយនេះឲ្យកាន់តែរីកចំរើនទៅមុខ និងគន្លឹះដ៏សំខាន់សម្រាប់វិនិយោគិនដើម្បីជាទុនសម្រាប់ធ្វើការវិនិយោគ និងស្វែងរកប្រាក់ចំណេញ។

ដោយយល់ឃើញពីសារៈសំខាន់នៃដំណើរការនៃការជួញដូរមូលបត្រក្នុងវិស័យមូលបត្រទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ "សេវាកម្មទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញស៊ីយ្យូរីធី ភីអិលស៊ី" មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបង្ហាញដល់មិត្តនិស្សិតទាំងអស់ក៏ដូចជាវិនិយោគិនដែលមានបំណង់ចង់ស្វែងយល់ ឬចង់ធ្វើការវិនិយោគក្នុងទីផ្សារនេះឲ្យបានស្វែងយល់កាន់តែច្បាស់ ថាតើនិតិវិធីនៃការជួញដូរមូលបត្រក្នុងផ្សារមូលបត្រកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្តេច? តើវិនិយោគិន ក៏ដូចជាក្រុមហ៊ុនមូលបត្រត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះដើម្បីចូលប្រលូកក្នុងទីផ្សារនេះបាន?

យើងខ្ញុំសង្ឃឹមថារបាយការណ៍ចុះកម្មសិក្សារបស់យើងខ្ញុំដែលបានចងក្រងនេះ នឹងចូលរួមចំណែកក្នុងការចែករំលែកចំណេះដឹងជូនដល់មិត្តនិស្សិត និងសាធារណជនទាំងអស់ឲ្យបានជ្រាបនូវចំនេះដឹងបន្ថែមទៀតពីដំណើរការនៃការជួញដូរមូលបត្រ និងលក្ខខណ្ឌតម្រូវផ្សេងៗដើម្បីធ្វើការជួញដូរ។

យើងខ្ញុំសូមអភ័ទោសចំពោះកំហុសខុសឆ្គងទាំងឡាយណាដែលបានកើតឡើងដោយប្រការណាមួយ និងសូមស្វាគមន៍ចំពោះរាល់មតិរិះគុណនានាពីសំណាក់មិត្តអ្នកអានគ្រប់រូប ដើម្បីធ្វើការកែលម្អរបាយការណ៍មួយនេះឲ្យកាន់តែមានអត្ថន័យពេញលេញ និងល្អប្រសើរ។

# មាតិកា

**ទំព័រ**

បញ្ជីអក្សរកាត់ ........ vi

បញ្ជីរូបភាព ........ vii

## សេចក្តីផ្តើម

១. បុព្វហេតុនៃការស្រាវជ្រាវ ........ ០១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ០២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ០២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ០២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ០២

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ០៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ០៣

## ជំពូកទី១
## រំលឹកទ្រឹស្តីៈ ទីផ្សារមូលបត្រ

១.១. ទីផ្សារមូលបត្រ ........ ០៦

១.១.១. ប្រវត្តិទីផ្សារមូលបត្រ ........ ០៦

១.១.២. និយមន័យទីផ្សារមូលបត្រ ........ ០៧

១.១.៣. ប្រភេទទីផ្សារមូលបត្រ ........ ០៧

១.១.៣.១. ទីផ្សារដំបូង ........ ០៧

១.១.៣.២. ទីផ្សារបន្ទាប់ ........ ០៨

១.១.៤. រចនាសម្ព័ន្ធទីផ្សារមូលបត្រ ........ ០៩

១.២. ឧបករណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់ក្នុងទីផ្សារមូលបត្រ ........ ១០

១.២.១. មូលបត្រកម្មសិទ្ធិ ........ ១០

១.២.១.១. ភាគហ៊ុនធម្មតា ........ ១០

១.២.១.២. ភាគហ៊ុនបុរិមា ........ ១០

១.២.២. មូលបត្របំណុល ........ ១១

១.២.២.១. សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល ........ ១១

១.២.២.២. បណ្ណរតនាគារ ឬរដ្ឋាភិបាល ........ ១១

១.២.២.៣. បណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល ............................................. ១២
១.២.២.៤. សញ្ញាបណ្ណខេត្ត-ក្រុង ................................................................. ១២
១.២.២.៥. សញ្ញាបណ្ណសាជីវកម្ម................................................................. ១២
១.២.២.៦. សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ ................................................. ១២
១.២.២.៧. សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ ...........................................១៣
១.២.២.៨. សញ្ញាបណ្ណដែលអាចប្តូរបាន .......................................................១៣
១.២.២.៩. សញ្ញាបណ្ណមានការធានា ............................................................១៣
១.២.២.១០. លិខិតទទួលយករបស់ធនាគារិក ..................................................១៣
១.២.២.១១. កិច្ចសន្យាធានាទិញ...................................................................១៤
១.២.២.១២. ផលបត្រពាណិជ្ជកម្ម ..................................................................១៤
១.២.២.១៣. វិញ្ញាបនបត្រដាក់ផ្ញើរ...................................................................១៤
១.២.២.១៤. សញ្ញាបណ្ណដែលមានអត្រាគូប៉ុងប្រែប្រួល.......................................១៥
១.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ............................................................១៥
១.៣. តួនាទីនៃទីផ្សារមូលបត្រ ...........................................................................................១៦
១.៤. គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ច ........................................ ១៧

## ជំពូកទី២

## វិស័យមូលបត្រនៅកម្ពុជា

២.១. ការវិវដ្តនៃវិស័យមូលបត្រនៅកម្ពុជា..............................................................................១៩
២.២. តួអង្គសំខាន់ៗនៅក្នុងវិស័យមូលបត្រនៅកម្ពុជា ............................................................ ២០
២.២.១. និយ័តករមូលបត្រ ................................................................................... ២០
២.២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ...................................................................... ២២
២.២.៣. វិនិយោគិនមូលបត្រ......................................................................................២៣
២.២.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ........................................................................ ២៤
២.២.៥. អន្តរការីមូលបត្រ.......................................................................................... ២៤
២.២.៥.១. ក្រុមហ៊ុនធានាទិញមូលបត្រ ...................................................... ២៤
២.២.៥.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ...................................................... ២៥
២.២.៥.៣. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ................................................. ២៦
២.២.៥.៤. ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ........................................................ ២៦

២.៣. តួអង្គដទៃទៀតក្នុងវិស័យមូលបត្រ ........ ២៦
២.៣.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់នឹងមូលបត្រ ........ ២៦
២.៣.២. ភ្នាក់ងារបញ្ជិកាមូលបត្រ ........ ២៧
២.៣.៣. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ........ ២៧
២.៣.៤. ភ្នាក់ងារទូទាត់ ........ ២៨
២.៣.៥. ក្រុមហ៊ុនគណនេយ្យករជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ ........ ២៨
២.៣.៦. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ និងអ្នកវាយតម្លៃឯករាជ្យ ........ ២៩
២.៣.៧. ភ្នាក់ងារដាក់ពិន្ទុឥណទាន ........ ៣០
២.៤. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ........ ៣០

## ជំពូកទី៣

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

៣.១. ប្រវត្តិរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ........ ៣៤
៣.២. ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ........ ៣៤
៣.២.១. ទីតាំងភូមិសាស្ត្រ ........ ៣៤
៣.២.២. ស្លាកសញ្ញា ........ ៣៦
៣.៣. ចក្ខុវិស័យ និងទស្សនៈវិស័យ ........ ៣៦
៣.៣.១. ចក្ខុវិស័យ ........ ៣៦
៣.៣.២. ទស្សនៈវិស័យ ........ ៣៧
៣.៤. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ........ ៣៨
៣.៥. សេវាកម្មរបស់ក្រុមហ៊ុន ........ ៣៨
៣.៥.១. សេវាកម្មធានាទិញមូលបត្រ ........ ៣៩
៣.៥.២. សេវាកម្មឈ្មួញជើងសាមូលបត្រ ........ ៤០
៣.៥.៣. សេវាកម្មពាណិជ្ជករមូលបត្រ ........ ៤០
៣.៥.៤. សេវាកម្មប្រឹក្សាវិនិយោគ ........ ៤០
៣.៥.៥. សេវាកម្មឈ្មួញជើងសាឧបករណ៍និស្សន្ទ ........ ៤១
៣.៦. ផ្សេងៗ ........ ៤១

# ជំពូកទី៤

# សេវាកម្មទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី


៤.១. និយមន័យនៃការទិញ-លក់មូលបត្រ.......................................................................................... ៤២

៤.២. លក្ខខណ្ឌតម្រូវដើម្បីទទួលបានអាជ្ញាបណ្ណជាឈ្មួញជើងសាមូលបត្រ ......................... ៤២

៤.៣. តួនាទីរបស់ឈ្មួញជើងសាមូលបត្រ ..........................................................................................៤៤

៤.៤. ដំណើរការបើកគណនី និងដំណើរការជួញដូរ.............................................................................៤៥

៤.៤.១. វិធីបើកគណនី...................................................................................................................៤៥

៤.៤.១.១. អត្តសញ្ញាណវិនិយោគិន .............................................................................................៤៦

៤.៤.១.២. ការបើកគណនីជួញដូរ...................................................................................................៤៧

៤.៤.២. ដំណើរការជួញដូរ ............................................................................................................៤៨

៤.៥. វិធានប្រតិបត្តិការក្នុងការទិញ-លក់មូលបត្រ .................................................................................៤៩

៤.៥.១. ពេលវេលាជួញដូរ.............................................................................................................៤៩

៤.៥.២. ព័ត៌មានត្រូវផ្តល់ ...............................................................................................................៥០

៤.៥.៣. ការដាក់បញ្ជា ...................................................................................................................៥០

៤.៥.៤. ការអនុវត្តការជួញដូរ និងការជូនដំណឹង..............................................................................៥១

៤.៥.៥. វិធីសាស្ត្រទូទាត់សាច់ប្រាក់ និងមូលបត្រ .............................................................................៥១

៤.៥.៦. វិធីសាស្ត្រផ្ទូរផ្តង ................................................................................................................៥១

៤.៥.៧. សុពលភាពនៃការបញ្ជាទិញ-លក់ .........................................................................................៥៤

៤.៥.៨. ដែនបំរែបំរួលថ្លៃ ...............................................................................................................៥៤

៤.៥.៩. ឯកតាគម្លាតថ្លៃ និងឯកតាជួញដូរ .......................................................................................៥៤

៤.៥.១០. កាលបរិច្ឆេទ អិចឌីវីដឺនដ៍ ឬអិចរាយថ៍ ..............................................................................៥៥

៤.៥.១១. ពន្ធលើផលចំណេញមូលធន ការប្រាក់ និងភាគលាភ ...........................................................៥៥

៤.៥.១២. របៀបដាក់ប្រាក់ ...............................................................................................................៥៥

៤.៥.១៣. របៀបដកប្រាក់ .................................................................................................................៥៦

៤.៥.១៤. ការទទួលបានព័ត៌មានទីផ្សារ.............................................................................................៥៦

៤.៦. វិធីសាស្ត្រគណនាកម្រៃជើងសា ..................................................................................................... ៥៧

៤.៧. ក្រមសីលធម៌វិជ្ជាជីវៈរបស់ឈ្មួញជើងសាមូលបត្រ.........................................................................៥៨

៤.៧.១. គោលការណ៍ទូទៅនៃអាជីវកម្ម ...........................................................................................៥៨

៤.៧.២. គណនីអតិថិជន ..........................................................................................................៥៩
៤.៧.៣. ការផ្ដល់ប្រឹក្សាវិនិយោគ ..............................................................................................៥៩
៤.៧.៤. ការជៀសវាងទំនាស់ផលប្រយោជន៍ទាក់ទងនឹងការផ្ដល់ប្រឹក្សាវិនិយោគ ..........៦០
៤.៧.៥. ការហាមឃាត់លើការជំរុញឲ្យមានការជួញដូរច្រើនហួសហេតុ.........................៦១
៤.៧.៦. ការអនុវត្តការជួញដូរមូលបត្រ.........................................................................................៦១
៤.៧.៦.១. បញ្ជាទិញ-លក់ .................................................................................................៦១
៤.៧.៦.២. បញ្ជាតាមប្រព័ន្ធអេឡិកត្រូនិច ឬតាមមធ្យោបាយផ្សេងទៀត............៦១
៤.៧.៦.៣. បុគ្គលដែលមានសិទ្ធិបញ្ជា ............................................................ ៦២
៤.៧.៦.៤. ការហាមឃាត់ការបញ្ជាដែលផ្ទុយនឹងច្បាប់.................................... ៦២
៤.៧.៦.៥. ការអនុវត្តប្រសើរបំផុត .................................................................. ៦២
៤.៧.៦.៦. ការហាមឃាត់ការជួញដូរមុន ...........................................................៦៣
៤.៧.៦.៧. អតិភាពរបស់អតិថិជន....................................................................៦៣
៤.៧.៧. ការផ្ដល់ព័ត៌មានទៅកាន់អតិថិជន......................................................................................៦៣
៤.៧.៨. អាកប្បកិរិយាដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម................................៦៤
៤.៧.៨.១. ការហាមឃាត់ចំពោះភ្នាក់ងារដែលមិនមានអាជ្ញាបណ្ណ .....................៦៤
៤.៧.៨.២. ការធានាទិញមូលបត្រ និងការសម្ងាត់នៃព័ត៌មាន.............................៦៤
៤.៧.៨.៣. ការហាមឃាត់ការទូទាត់សងលើការខាតបង់ ..................................៦៥
៤.៧.៨.៤. ការហាមឃាត់លើការផ្ដល់ឲ្យ និងការទទួលអំណោយនិង
អត្ថប្រយោជន៍ផ្សេងៗ.........................................................................................៦៥
៤.៨. ការជួញដូរតាម Online .........................................................................................................៦៦
៤.៩. ការវិភាគ SWOT.....................................................................................................................៦៧

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្ដីសន្និដ្ឋាន.........................................................................................................................៦៩
២. អនុសាសន៍ ..............................................................................................................................៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ម.ក. | គណៈកម្មាការមូលបត្រកម្ពុជា |
| SECC | Securities Exchange and Commission of Cambodia |
| ផ.ម.ក | ផ្សារមូលបត្រកម្ពុជា |
| CSX | Cambodia Stock Exchange |
| IPO | Initial Public Offering (ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈជាលើកដំបូង) |
| PPS | Phnom Penh Security Plc. (ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី) |
| PWSA | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| GTI | ក្រុមហ៊ុនហ្គ្រេនធ្វីន |
| PPSP | ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ |
| PPAP | ក្រុមហ៊ុនកំពង់ផែស្វយ័តភ្នំពេញ |
| PAS | ក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងព្រះសីហនុ |

# បញ្ជីរូបភាព


**រូបភាពទី១៖** រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា.............................. ២១

**រូបភាពទី២៖** ផែនទីទីតាំងរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី មើលតាមរយៈ Google Map .............................. ៣៥

**រូបភាពទី៣៖** អាគារ VTrust ដែលក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ីស្ថិតនៅជាន់ទី២ .... ៣៦

**រូបភាពទី៤៖** ស្លាកសញ្ញារបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី .............................. ៣៦

**រូបភាពទី៥៖** រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី .............................. ៣៨

**រូបភាពទី៦៖** ដំណើរការនៃការបើកគណនីជួញដូរ.............................. ៤៦

**រូបភាពទី៧៖** ការស្នើអត្តសញ្ញាណវិនិយោគិន.............................. ៤៧

**រូបភាពទី៨៖** ប័ណ្ណគំរូ .............................. ៤៨

**រូបភាពទី៩៖** ដំណើរការជួញដូរ.............................. ៤៩

**រូបភាពទី១០៖** ពេលវេលានៃការជួញដូរ .............................. ៥០

**រូបភាពទី១១៖** បំរែបំរួលឯកតាកម្លាតថ្លៃ .............................. ៥៥

**រូបភាពទី១២៖** ការគណនាកម្រៃជើងសា .............................. ៥៧

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. បុព្វហេតុនៃការសិក្សាស្រាវជ្រាវ

ប្រទេសជាច្រើននៅលើពិភពលោកកំពុងមានការរីកចំរើនយ៉ាងខ្លាំង ស្របពេលជាមួយគ្នានេះ ប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលមានការរីកចំរើនគួរកត់សំគាល់ផងដែរ។ ដើម្បីឲ្យប្រទេសមួយមានការអភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ចជាវិស័យចំបងមួយដែលបានរួមចំណែកយ៉ាងសកម្ម។ រដ្ឋាភិបាលក្នុងប្រទេសនីមួយៗតែងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះវិស័យមួយនេះ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការ ក៏ដូចជាយុទ្ធសាស្ត្រដើម្បីពង្រឹង និងស្តារសេដ្ឋកិច្ចនៅក្នុងប្រទេសរបស់ខ្លួន។

ទាក់ទិននឹងការអភិវឌ្ឍន៍វិស័យមួយនេះ ដោយអនុលោមតាមផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ របស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជាបាននឹងកំពុងបង្កើតក្របខ័ណ្ឌ ច្បាប់ និងបទប្បញ្ញត្តិសម្រាប់ពង្រីកវិស័យហិរញ្ញវត្ថុប្រកបដោយតម្លាភាព សុក្រឹត្យភាព ព្រមទាំងបង្កើតភាពរឹងមាំនៃវិស័យដ៏សំខាន់មួយនេះ។ វិស័យហិរញ្ញវត្ថុចែកចេញជា វិស័យពីរសំខាន់គឺ វិស័យធនាគារ និងវិស័យមិនមែនធនាគារ ដែលវិស័យមិនមែនធនាគារមានដូចជា វិស័យធានារ៉ាប់រង និងវិស័យមូលបត្រ។ យ៉ាងណាមិញ វិស័យធនាគារ និងវិស័យមូលបត្រជាវិស័យដែលបំពេញឲ្យគ្នាទៅវិញទៅមកក្នុងការពង្រឹងវិស័យហិរញ្ញវត្ថុ។ វិស័យមូលបត្រ គឺជាវិស័យដែលថ្មីមួយសំរាប់ប្រទេសកម្ពុជាយើងដែលទើបតែបង្កើតឡើងនៅឆ្នាំ ២០១១ ក្នុងទិសដៅបំពេញចន្លោះខ្វះខាត នៃផ្នែកហិរញ្ញវត្ថុរបស់កម្ពុជាដោយប្រមូលមូលធនពីកន្លែងដែលលើសទៅកន្លែងដែលខ្វះ និងផ្តល់នូវជម្រើសសំរាប់ការវិនិយោគ។

បើយើងក្រឡេកមើលទៅប្រទេសរីកចម្រើនមួយចំនួនធំនៅលើពិភពលោក យើងសង្កេតឃើញថា វិស័យមូលបត្របានដើរតួនាទីយ៉ាងសំខាន់សំរាប់ក្រុមហ៊ុនសាជីវកម្ម សហគ្រាស នឹងរាជរដ្ឋាភិបាលក្នុងការបង្កើនដើមទុនដើម្បីយកទៅវិនិយោគ ឬអភិវឌ្ឍន៍បន្ថែម។ ជាងនេះទៅទៀតយើងសង្កេតឃើញថា ការជួញដូរមូលបត្រនៅលើពិភពលោក ពិតជាមានសកម្មភាពមមាញឹកពីសំណាក់វិនិយោគិន ដែលធ្វើឲ្យទីផ្សារភាគហ៊ុនមានការរីកចម្រើនយ៉ាងខ្លាំង។ ផ្ទុយមកវិញ បើយើងក្រឡេកមកមើលប្រទេសកម្ពុជា យើងឃើញថាការជួញដូរមូលបត្រនៅមានកំរិតដោយសារតែប្រជាជនយើងមួយចំនួនធំមិនទាន់យល់ថាអ្វីជាការជួញដូរមូលបត្រ និងនីតិវិធីក្នុងការជួញដូរមូលបត្រនៅឡើយទេ។ ដោយហេតុនេះហើយទើបក្រុមរបស់យើងខ្ញុំសំរេចចិត្តជ្រើសរើសប្រធានបទ សេវាកម្ម

ទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងទទួលបានចំណេះដឹងបន្ថែម និងស្វែងយល់ឲ្យកាន់តែច្បាស់ពីចំណុចសំខាន់មួយចំនួនដែលទាក់ទង នឹងនីតិវិធីនៃការទិញនិងលក់មូលបត្រ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ ដូចដែលយើងខ្ញុំបានរៀបរាប់ខាងលើទីផ្សារមូលបត្រ ឬទីផ្សារភាគហ៊ុនជាទីផ្សារថ្មីមួយសំរាប់វិនិយោគិននៅក្នុងប្រទេសកម្ពុជា ដូចនេះវិនិយោគិនមួយចំនួនធំ នៅតែមានភាពស្រពិចស្រពិលក្នុងការវិនិយោគ និងជួញដូរនៅក្នុងវិស័យមួយនេះ។ ដើម្បីជំរុញឲ្យវិស័យមួយនេះកាន់តែមានការរីកចម្រើន វិនិយោគិនត្រូវតែយល់ច្បាស់ពីនិតិវិធីក្នុងការជួញដូរមូលបត្រ។ ដូចនេះតើវិនិយោគិនត្រូវគោរពតាមនីតិវិធីអ្វីខ្លះដើម្បីធ្វើការទិញ-លក់មូលបត្របាន? ហើយតើក្រុមហ៊ុនមូលបត្រត្រូវការលក្ខខណ្ឌតម្រូវអ្វីខ្លះដើម្បីក្លាយជាឈ្មួញជើងសាមូលបត្រ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចំបងនៃការសិក្សាលើប្រធានបទនេះ គឺដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីៈ

- ប្រវត្តិ និងស្ថាភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី
- សិក្សាអំពីលក្ខខណ្ឌដើម្បីក្លាយជាឈ្មួញជើងសាមូលបត្រ
- ស្វែងយល់ពីតួនាទីជាអ្នកទិញ-លក់មូលបត្រ
- សិក្សាអំពីនីតិវិធីនៃការជួញដូរមូលបត្រ
- ស្វែងយល់ពីការកំណត់កម្រៃជើងសាមូលបត្រ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយសារតែរយៈពេលនៃការសិក្សាស្រាវជ្រាវមានដែនកំណត់ ដូចនេះដើម្បីឲ្យដំណើរការនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំប្រព្រឹត្តិទៅបានយ៉ាងល្អ និងកាន់តែមានភាពច្បាស់លាស់ ក្រុមរបស់យើងខ្ញុំបានផ្តោតលើចំណុចសំខាន់មួយចំនួនប៉ុណ្ណោះ ដែលទាក់ទងទៅនឹងដំណើរការនៃការទិញ-លក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះបានផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍មិនត្រឹមតែចំពោះយើងខ្ញុំជាអ្នកស្រាវជ្រាវប៉ុណ្ណោះទេ វាថែមទាំងផ្តល់ប្រយោជន៍សំរាប់វិនិយោគិនក្នុងវិស័យ

មូលបត្រសម្រាប់សាធារណៈជនទូទៅ សិស្សនិស្សិត និងអ្នកចង់សិក្សាយល់ដឹងបន្ថែមពីដំណើរការនៃការទិញ-លក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី។

ការស្រាវជ្រាវទៅលើប្រធានបទនេះនឹងផ្តល់អត្ថប្រយោជន៍មួយចំនួនដូចជា៖

- ផ្តល់ឱកាសឲ្យយើងខ្ញុំដឹងពីការអនុវត្តជាក់ស្តែងអំពីការជួញដូរមូលបត្រកម្មសិទ្ធិ
- រំលឹកឡើងវិញនូវទ្រឹស្តីដែលបានសិក្សាកន្លងមក
- ផ្តល់ជាឯកសារសម្រាប់វិនិយោគិន ដែលមានបំណងចង់វិនិយោគលើមូលបត្រកម្មសិទ្ធិដែលជាវិស័យដ៏ថ្មីស្រឡាងមួយ
- ជួយឲ្យក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី មានឱកាសផ្សព្វផ្សាយសេវាកម្មរបស់ខ្លួន
- រក្សាទុកជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានលើកឡើងខាងលើ ក្រុមរបស់យើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រគុណភាពសម្រាប់ស្រាវជ្រាវ។ ចំណែកឯទិន្នន័យដែលយើងយកមកប្រើប្រាស់ គឺផ្អែកលើទិន្នន័យចំនួន២ប្រភេទដែលរួមមាន៖

- ទិន្នន័យចំបង (Primary data) ជាទិន្នន័យដែលទទួលបានតាមរយៈ៖

- ការចុះកម្មសិក្សាដោយផ្ទាល់នៅក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី
- ការណែនាំពីសាស្ត្រាចារ្យដឹកនាំ

- ទិន្នន័យទីពីរ (Secondary data) ជាទិន្នន័យដែលទទួលបានតាមរយៈ៖

- ឯកសារសារណា ឬរបាយការណ៍សិក្សារបស់និស្សិតជំនាន់មុន
- ការស្វែងរកទិន្នន័យតាមរយៈប្រព័ន្ធអ៊ីនធឺណិត
- ការអានសៀវភៅ និងព័ត៌មានផ្សេងៗ
- ស្វែងរកឯកសារទាំងឡាយដែលទាក់ទងនិងប្រធានបទនេះ នៅក្នុងគេហទំព័ររបស់គណៈកម្មាការមូលបត្រកម្ពុជាដូចជា ច្បាប់ អនុក្រឹត្យ ប្រកាស បទប្បញ្ញត្តិ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទមួយនេះ ក្រុមរបស់យើងខ្ញុំបានបែងចែកជា៦ដំណាក់កាលដែលមាន៤ជំពូកធំៗដូចខាងក្រោម៖

- **សេចក្តីផ្តើម**

- **ជំពូកទី១៖** ទ្រឹស្តីផ្សេងៗដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ ដែលមានដូចជា ប្រវត្តិទីផ្សារមូលបត្រ និយមន័យ ប្រភេទទីផ្សារមូលបត្រ ឧបករណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់ក្នុងទីផ្សារមូលបត្រ តួនាទី ព្រមទាំងគុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រ
- **ជំពូកទី២៖** សិក្សាអំពីស្ថានភាពទូទៅនៃទីផ្សារមូលបត្រនៅប្រទេសកម្ពុជា រួមមានការវិវដ្តនៃវិស័យមូលបត្រនៅកម្ពុជា តួអង្គសំខាន់ៗដែលចូលរួមក្នុងវិស័យមូលបត្រ និងតួអង្គដទៃទៀតក្នុងវិស័យមូលបត្រ
- **ជំពូកទី៣៖** ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី គឺធ្វើការសិក្សាទៅលើប្រវត្តិ ទីតាំងភូមិសាស្ត្រ ចក្ខុវិស័យ ទស្សនៈវិស័យ រចនាសម្ព័ន្ធ និងសេវាកម្មរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី
- **ជំពូកទី៤៖** សិក្សាស៊ីជម្រៅអំពីសេវាកម្មទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូ្យរីធី ភីអិលស៊ី
- **សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

ខាងក្រោមនេះជារចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ដែលបង្ហាញពីដំណើរការនៃការសិក្សាស្រាវជ្រាវទាំងមូលៈ



# ជំពូកទី១
# រំលឹកទ្រឹស្តី៖ ទីផ្សារមូលបត្រ

# ជំពូកទី១

# រំលឹកទ្រឹស្តី ៖ ទីផ្សារមូលបត្រ

## ១.១ ទីផ្សារមូលបត្រ

### ១.១.១ ប្រវត្តិទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ឬទីផ្សារភាគហ៊ុន គឺជាទីផ្សារដែលសំខាន់សម្រាប់សេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្ន។ ទីផ្សារមូលបត្រ ឬទីផ្សារភាគហ៊ុនត្រូវបានគេដឹងថាវាមានប្រវត្តិតាំងពីយូលង់ណាស់មកហើយ គឺនៅពេលដែលប្រទេសនីមួយៗនៅលើពិភពលោក ចាប់ផ្តើមមានទំនាក់ទំនងពាណិជ្ជកម្មជាមួយគ្នា។ ខណៈពេលដែលពាណិជ្ជករចង់ធ្វើការពង្រីកអាជីវកម្មរបស់ខ្លួនឲ្យកាន់តែធំមានន័យថាពួកគេត្រូវចំណាយដើមទុនកាន់តែច្រើន ដែលតម្រូវឲ្យគាត់ស្វែងរកដៃគូដើម្បីធ្វើការបន្តាក់ទុនជាមួយគ្នា។ ជាលទ្ធផល វិនិយោគិននីមួយៗបានយកមូលធនរបស់ខ្លួនដែលនៅសល់ទៅបន្តាក់ទុនរួមគ្នា ហើយក្លាយជាដៃគូពាណិជ្ជកម្មជាមួយគ្នា។ ក្រុមហ៊ុន The Dutch East India Companyគឺជាក្រុមហ៊ុនមួយដែលធ្វើការបោះផ្សាយលក់ភាគហ៊ុនដំបូងគេបង្អស់នៅក្នុងឆ្នាំ ១៦០២ ការបោះផ្សាយលក់ភាគហ៊ុននេះ គឺជាវិធីសាស្ត្រដែលអាចឲ្យអ្នកវិនិយោគមានភាពងាយស្រួលក្នុងការទិញ-លក់ភាគហ៊ុន។

គំនិតនៃការបោះផ្សាយភាគហ៊ុនលក់នេះបានទទួលជោគជ័យ ហើយគំនិតនេះបានផ្សព្វផ្សាយដល់ប្រទេសធំៗមួយចំនួនដូចជា ប្រទេសព័រទុយហ្គាល់, អេស្ប៉ាញ, បារាំង, និងបន្តទៅដល់ប្រទេសអង់គ្លេសបន្ថែមទៀត។ ដូចនេះនាកំឡុងពេលនោះការបោះផ្សាយភាគហ៊ុនលក់ គឺជាវិធីដ៏ល្អក្នុងការប្រមូលទុន។ ការប្រមូលទុនបែបនេះ ជាវិធីសាស្ត្រដ៏ល្អក្នុងការអភិវឌ្ឍន៍ប្រទេសក៏ដូចជាធ្វើឲ្យមានការរីកចម្រើននៃផ្នែកឧស្សាហកម្ម។ ដោយសារតែទំហំនៃការជួញដូរភាគហ៊ុនមានការកើនឡើង ដូចនេះវាតម្រូវឲ្យមានការរៀបចំទីផ្សារមួយសម្រាប់ធ្វើការជួញដូរ ដើម្បីបង្កភាពងាយស្រួលដល់វិនិយោគិន។ ជាលទ្ធផល ហាងកាហ្វេមួយនៅក្នុងទីក្រុងឡុងដ៍បានក្លាយជាទីតាំងមួយសម្រាប់វិនិយោគិនធ្វើការទិញ-លក់ភាគហ៊ុន ហើយនៅក្នុងឆ្នាំ ១៧៧៣ ហាងកាហ្វេនោះត្រូវបានគេប្តូរឈ្មោះទៅជា "ទីផ្សារភាគហ៊ុន"។ ចាប់ពីពេលនោះមកទីផ្សារភាគហ៊ុនដំបូងគេដែលមានឈ្មោះថា " The London Stock Exchange " ត្រូវបានបង្កើតឡើង។

ក្រោយមកទៀតគំនិតទាំងអស់នេះបានសាយភាយដល់ប្រទេសអាមេរិច ដែលប្រជាជនអាមេរិចស្គាល់ថា Wall Street គឺជាទីផ្សារភាគហ៊ុនរបស់ពួកគេ។ ទីផ្សារ Wall Street ត្រូវបានបង្កើតឡើងនៅក្នុងថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ១៧៩២ នៅកែងផ្លូវ Wall Street។ នៅក្នុងទីផ្សារ Wall Street

ឈ្មួញជើងសាចំនួន ២៤នាក់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង " Buttonwood Agreement " នៅផ្លូវ ៦៨ ក្នុងទីក្រុងញូវយ៉ក ក្រោមដើមឈើមួយឈ្មោះថា Buttonwood ។ ថ្ងៃទី ០៨ ខែមិនា ឆ្នាំ ១៨១៧ ទីផ្សារ Wall Street ត្រូវបានផ្តូរឈ្មោះទៅជា New York Stock and Exchange Board ហើយបានប្តូរទីតាំងទៅផ្លូវ៤០វិញ ។ ទីផ្សារភាគហ៊ុនដែលកំណត់អនាគតនៃសេដ្ឋកិច្ចពិភពលោកបានចាប់បដិសន្ធិ[1]។

### ១.១.២ និយមន័យទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើនូវប្រតិបត្តិការទិញ-លក់មូលបត្រគ្រប់ប្រភេទ និងឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត។ បើតាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន "សំដៅដល់ទីផ្សារ ឬកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ"។ ទីផ្សារមូលបត្រអាចជាទីផ្សាររូបីឬ ជាទីផ្សារអរូបីដែលជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច[2]។

### ១.១.៣ ប្រភេទទីផ្សារមូលបត្រ

ទីផ្សារមូលបត្រចែកចេញជាពីរប្រភេទគឺៈ ទីផ្សារដំបូង និងទីផ្សារបន្ទាប់។

#### ១.១.៣.១ ទីផ្សារដំបូង (Primary Markets)

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានគេបោះផ្សាយលក់ជាលើកដំបូងធ្វើការ ជួញដូរ។ ទីផ្សារដំបូង ត្រូវបានជួយសម្រួលដោយក្រុមអ្នកធានាទិញមូលបត្រ និងធនាគារវិនិយោគដែលជាអ្នកកំណត់ចន្លោះថ្លៃមូលបត្រសម្រាប់លក់ទៅឲ្យវិនិយោគិន។ នៅក្នុងទីផ្សារនេះ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន និងមូលបត្របំណុលឲ្យទៅសាធារណៈជនជាលើកដំបូង ហើយអ្នកទិញគឺបានទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ ដែលជាក្រុមហ៊ុនសាជីវកម្ម ឬជារដ្ឋាភិបាល។ វិនិយោគិនដែលទិញមូលបត្រនៅទីផ្សារដំបូង មិនចាំបាច់ចំណាយលើកំរៃជើងសាទៅឲ្យឈ្មួញជើងសានោះទេ ព្រោះកំរៃជើងសាបានបូកបញ្ចូលនៅក្នុងតម្លៃរបស់ភាគហ៊ុនរួចហើយ។ ដូចនេះវិនិយោគិនដែលទិញ-លក់មូលបត្រនៅទីផ្សារដំបូងចំណាយទុនអស់តិចជាងនៅទីផ្សារបន្ទាប់។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រត្រូវបង់ទៅឲ្យក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនោះនឹងក្លាយជាអ្នកកាន់កាប់ភាគហ៊ុនដំបូងគេក្នុងក្រុមហ៊ុនបោះផ្សាយនោះ។ ដំណើរការលក់ភាគហ៊ុនទៅឲ្យសាធារណជនជាលើកដំបូងត្រូវគេហៅថាជាការនាំក្រុមហ៊ុន

[1] Laura Bramble. *How the Stock Market Was Started & by Whom.* Retrieved from http://smallbusiness.chron.com/stock-market-started-whom-14745.html

[2] សៀវ សុស៊ីខា, ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ (ភ្នំពេញៈ ២០១៧), slide ៤។

ទៅកាន់សាធារណៈ។ នេះមានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគិនដំបូង ឬស្ថាបនិកទៀតហើយ។ ក្រុមហ៊ុនដែលលក់ភាគហ៊ុនរបស់ខ្លួនទៅកាន់សាធារណជន ត្រូវបានគេសន្មតថា "សំណើលក់មូលបត្រជាសាធារណៈកើតមានឡើង"។ ចំពោះដំណើរការនៃការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា "សំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (Initial Public Offering) ឬ IPO"[3]។

**១.១.៣.២. ទីផ្សារបន្ទាប់** (Secondary Markets)

ទីផ្សារបន្ទាប់ ឬយើងអាចហៅម្យ៉ាងទៀតថា "ទីផ្សារភាគហ៊ុន" គឺជាទីកន្លែងសម្រាប់វិនិយោគិនជួញដូរមូលបត្រដែលពួកគាត់កាន់កាប់ស្រាប់ ឬជាកន្លែងដែលមូលបត្រត្រូវបានធ្វើការជួញដូរបន្ទាប់ពីធ្វើការជួញដូរនៅទីផ្សារដំបូងរួចហើយ។ ទីផ្សារភាគហ៊ុនទីក្រុងញូយ៉ក ទីផ្សារភាគហ៊ុនណាស់ដា និងទីផ្សារភាគហ៊ុនធំៗផ្សេងទៀតនៅលើពិភពលោក គឺជាទីផ្សារបន្ទាប់ដែលមានភាពមរមាញឹកក្នុងការជួញដូរមូលបត្រ។ វិនិយោគិនធ្វើការជួញដូរមូលបត្រដោយផ្ទាល់ ពោលគឺនៅក្នុងទីផ្សារបន្ទាប់ វិនិយោគិនធ្វើការជួញដូរមូលបត្រដោយមិនមានការអន្តរាគមន៍ពីក្រុមហ៊ុនបោះផ្សាយនោះទេ។ ឧទាហរណ៍ជាក់ស្តែង ប្រសិនបើអ្នកទិញភាគហ៊ុនរបស់ក្រុមហ៊ុនម៉ៃក្រូស៊ប គឺអ្នកធ្វើការទិញលក់ជាមួយវិនិយោគិនដទៃដែលមានភាគហ៊ុននៅក្នុងក្រុមហ៊ុនម៉ៃក្រូស៊ប។ ឯក្រុមហ៊ុនម៉ៃក្រូស៊ប មិនចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការនេះទេ។

ទីផ្សារបន្ទាប់ត្រូវបានបែងចែកចេញជាពីរប្រភេទគឺ ទីផ្សារដេញថ្លៃ និងទីផ្សារជួញដូរ។ នៅក្នុងទីផ្សារដេញថ្លៃវិនិយោគិនជាបុគ្គល ឬវិនិយោគិនជាស្ថាប័នដែលមានបំណងចង់ជួញដូរមូលបត្រត្រូវប្រជុំគ្នានៅកន្លែងមួយ ហើយធ្វើការប្រកាសនៅតម្លៃដែលពួកគេមានបំណងចង់ទិញ និងលក់។ ការធ្វើបែបនេះ គឺដើម្បីប្រមូលផ្តុំវិនិយោគិនទាំងអស់មកស្តាប់នូវតម្លៃដែលពួកគេសំរេចជួញដូរ។ ដូចនេះតាមទ្រឹស្តី តម្លៃនៃមូលបត្រត្រូវធ្វើការព្រមព្រៀងគ្នាអោយបានច្បាស់លាស់ដើម្បីឈានទៅដល់ការកំណត់តម្លៃមួយដែលមានការយល់ព្រមរវាងអ្នកលក់ និងអ្នកទិញ។

ចំណែកឯនៅក្នុងទីផ្សារទិញ-លក់វិញ វិនិយោគិនដែលមានបំណងចង់ទិញ-លក់មូលបត្រមិនបាច់ធ្វើការប្រជុំគ្នាដើម្បីកំណត់ថ្លៃទិញ-លក់នោះទេ។ វិនិយោគិនអាចចូលរួមក្នុងផ្សារទិញ-លក់បានតាមរយៈប្រព័ន្ធអេឡិចត្រូនិច (ទូរស័ព្ទចល័ត ឬម៉ាស៊ីនទូរសារ)។ អ្នកលក់មានសន្និធិនៅក្នុងដៃសំរាប់អ្នកទិញដែលចូលរួមក្នុងទីផ្សារទិញលក់នេះ។ អ្នកលក់រកប្រាក់ចំណេញបានតាមរយៈគម្លាតថ្លៃមូលបត្រក្នុងប្រតិបត្តិការទិញ-លក់មូលបត្រ។ ឧទាហរណ៍នៃទីផ្សារទិញ-លក់ គឺទីផ្សារភាគហ៊ុន

[3] បៀន សាំង, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ* (ភ្នំពេញៈ បណ្ណាគារសន្តិភាព, ២០១១), ១៦។

ណាស់ដា ជាទីផ្សារដែលកំណត់ថ្លៃទិញ-លក់មូលបត្រដល់អ្នកលក់ និងអ្នកទិញ។ តម្លៃប្រកួតប្រជែងរបស់អ្នកជួញដូរ នឹងផ្តល់នូវតម្លៃល្អមួយសំរាប់វិនិយោគិនក្នុងការវិនិយោគ[4]។

### ១.១.៤ រចនាសម្ព័ន្ធទីផ្សារមូលបត្រ

**ដ្យាក្រាមទី១៖** ការបង្ហាញពីលក្ខណៈទូទៅនៃរចនាសម្ព័ន្ធនៅក្នុងទីផ្សារមូលបត្រ




[4] Investopedia. ( 2017, March). *A Look At Primary And Secondary Markets.* Retrieved from http://www.investopedia.com/articles/02/101102.asp#ixzz4cdJbnSYZ

## ១.២ ឧបករណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់ក្នុងទីផ្សារមូលបត្រ

ឧបករណ៍ហិរញ្ញវត្ថុ គឺជាកិច្ចព្រមព្រាងស្របច្បាប់ដែលតម្រូវឲ្យភាគីម្ខាងធ្វើការបង់ប្រាក់ ឬជារបស់មានតម្លៃ ឬជាកិច្ចសន្យាក្រោមលក្ខខ័ណ្ឌជាក់លាក់ណាមួយទៅឲ្យភាគីម្ខាងទៀតដើម្បីទទួលបានការប្រាក់ ទទួលសិទ្ធិ និងដើម្បីទទួលបានការពារការខាតបង់នានា។ ឧបករណ៍ហិរញ្ញវត្ថុដែលប្រើប្រាស់ក្នុងទីផ្សារមូលបត្រមានដូចជា៖ មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ។

### ១.២.១ មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាប្រភេទមូលបត្រមួយដែលបញ្ជាក់ពីភាពជាម្ចាស់នៃក្រុមហ៊ុនដែលតំណាងឲ្យការទទួលបានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងទទួលបានប្រាក់ចំណេញមួយផ្នែកទៅតាមសមាមាត្រនៃចំនួនភាគហ៊ុនដែលវិនិយោគិនមាន។ មូលបត្រកម្មសិទ្ធិជាទូទៅត្រូវបានបោះផ្សាយ និងជួញដូរក្នុងទំរង់ជាភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា[5]។

#### ១.២.១.១ ភាគហ៊ុនធម្មតា ឬភាគហ៊ុនមានសិទ្ធិបោះឆ្នោត

ភាគហ៊ុនធម្មតា ឬភាគហ៊ុនមានសិទ្ធិបោះឆ្នោត គឺជាប្រភេទភាគហ៊ុនដែលបញ្ជាក់ពីសិទ្ធិជាម្ចាស់នៃក្រុមហ៊ុនសាជីវកម្ម។ វិនិយោគិនដែលកាន់កាប់ភាគហ៊ុនប្រភេទនេះមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល, មានសិទ្ធិកំណត់គោលនយោបាយនៅក្នុងក្រុមហ៊ុនសាជីវកម្ម, និងទទួលបានការទូទាត់ភាគលាភ, ចំនេញមូលធន, ឬកម្រៃផ្សេងៗទៀត។ ភាគហ៊ុនធម្មតា គឺជាប្រភេទមូលបត្រទីមួយ ដែលក្រុមហ៊ុនបោះផ្សាយលក់ ហើយក៏ជាប្រភេទមូលបត្រដែលទទួលបានសិទ្ធិក្នុងការទូទាត់ចុងក្រោយគេដែរ។ នៅពេលដែលក្រុមហ៊ុនមួយក្ស័យធន អ្នកកាន់កាប់មូលបត្រផ្សេងៗទៀតរបស់ក្រុមហ៊ុនដូចជាសញ្ញាបណ្ណ និងភាគហ៊ុនបុរិមានឹងទទួលបានការទូទាត់សងមុនភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ដូចនេះហើយភាគហ៊ុនិក មានសិទ្ធិបោះឆ្នោតអាចនឹងមិនទទួលបានអ្វីទាំងអស់សម្រាប់ភាគហ៊ុនរបស់ពួកគេ នៅពេលដែលក្រុមហ៊ុនបោះផ្សាយមានជួបបញ្ហាក្ស័យធន ឬក៏ត្រូវបានបង្ខំឲ្យធ្វើការជម្រះបញ្ជី។

#### ១.២.១.២ ភាគហ៊ុនបុរិមា

ភាគហ៊ុនបុរិមា ជាទូទៅមិនមានសិទ្ធិបោះឆ្នោតដើម្បីជ្រើសរើសក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនទេ។ ភាគហ៊ុននេះមានសិទ្ធិទទួលបានការបែងចែកភាគលាភ ឬក៏ទាមទារសិទ្ធិទទួលផលលើទ្រព្យសកម្មទាំងឡាយរបស់ក្រុមហ៊ុនក្នុងករណីជួបប្រទះស្ថានភាពក្ស័យធន មុនពេលធ្វើ

---

[5] បៀន សាំង, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ* (ភ្នំពេញ៖ បណ្ណាគារសន្តិភាព, ២០១១), ៣៥។

ការទូទាត់ឲ្យភាគហ៊ុនិក ដែលជាភាគហ៊ុនមានសិទ្ធិបោះឆ្នោតប៉ុន្តែនៅក្រោយម្ចាស់បំណុលដែលកាន់កាប់សញ្ញាបណ្ណ ដែលបោះផ្សាយដោយក្រុមហ៊ុន។ ភាគហ៊ុនបុរិមា អាចត្រូវបានបោះផ្សាយក្នុងទម្រង់មួយដែលគេស្គាល់ថាជាភាគហ៊ុនបុរិមាដែលអាចប្តូរបាន។ នេះមានន័យថា ភាគហ៊ុនបុរិមាអាចត្រូវបានគេប្តូរទៅជាភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។

**១.២.២ មូលបត្របំណុល**

មូលបត្របំណុល គឺជាមូលបត្រដែលបោះផ្សាយដោយរដ្ឋាភិបាល ឬក្រុមហ៊ុនសាជីវកម្មក្នុងគោលបំណងដើម្បីគៀងគររកមូលធនបន្ថែមដើម្បីធ្វើការអភិវឌ្ឍន៍លើគំរោងផ្សេងៗ។ វិនិយោគិនដែលទិញមូលបត្របំណុលនឹងក្លាយជាម្ចាស់បំណុលនៃក្រុមហ៊ុនសាជីវកម្ម ដែលនឹងទទួលបានការប្រាក់ និងប្រាក់ដើមត្រលប់មកវិញនៅពេលវេលាជាក់លាក់ណាមួយដែលបានកំណត់នៅក្នុងមូលបត្រ។ ជាទូទៅមូលបត្របំណុលមានហានិភ័យទាបជាងមូលបត្រកម្មសិទ្ធិ ពីព្រោះមូលបត្រប្រភេទនេះនឹងទទួលបានការទូទាត់សងមុនគេបង្អស់ ក្នុងករណីបើក្រុមហ៊ុនក្ស័យធន[6]។

**១.២.២.១ សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល** (Treasury Bonds)

សញ្ញាបណ្ណរតនាគារ ឬរដ្ឋាភិបាល គឺជាមូលបត្របំណុលរយៈពេលវែងរបស់រាជរដ្ឋាភិបាលដែលមានអត្រាការប្រាក់ថេរ ហើយមានឥណប្រតិទាន (Maturity Date) ច្រើនជាង ១០ឆ្នាំ។ បណ្ណរតនាគារនេះជាធម្មតាត្រូវបង់ការប្រាក់ទៅឲ្យវិនិយោគិនរៀងរាល់៦ខែម្តង។ សញ្ញាបណ្ណរយៈពេលវែងខ្លះអាចទិញត្រឡប់មកវិញ មុនពេលឥណប្រតិទានរបស់សញ្ញាបណ្ណមកដល់ មានន័យថាក្រុមហ៊ុនបោះផ្សាយសញ្ញាបណ្ណមានសិទ្ធិបង់ផ្តាច់ លើតម្លៃសញ្ញាបណ្ណមុនកាលបរិច្ឆេទឥណប្រតិទានមកដល់។ ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីកាលបរិច្ឆេទទាំងពីរនៅពេលចុះបញ្ជីរបស់សញ្ញាបណ្ណ[7]។

**១.២.២.២ បណ្ណរតនាគារ ឬរដ្ឋាភិបាល** (Treasury Note)

បណ្ណរតនាគារ ឬរដ្ឋាភិបាល គឺជាមូលបត្របំណុលរដ្ឋាភិបាលដែលមានរយៈពេលមធ្យមចាប់ពី ១ឆ្នាំទៅដល់ ១០ឆ្នាំ ហើយត្រូវបានបោះផ្សាយឡើងដោយនាយកដ្ឋានរតនាគារជាតិនៃប្រទេសមួយ។ ជាធម្មតាវិនិយោគិនដែលទិញបណ្ណរតនាគារនេះទទួលបានការប្រាក់ជារៀងរាល់ ៦ ខែម្តង[8]។

---

[6] Investopedia. *Bond*. Retrieved from http://www.investopedia.com/terms/b/bond.asp

[7] សៀវ សុស៊ីខា, ប្រភេទមូលបត្រ (ភ្នំពេញ៖ ២០១៧), slide ១៧។

[8] សៀវ សុស៊ីខា, ប្រភេទមូលបត្រ (ភ្នំពេញ៖ ២០១៧), slide ១៦។

### ១.២.២.៣ បណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល (Treasury Bill)

បណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល គឺជាមូលបត្របំណុលដែលមានរយៈពេលខ្លីបំផុត ត្រូវបានបោះផ្សាយដោយមានកាលបរិច្ឆេទតណាប្រតិទានចាប់ពី ៤, ១៣, ២៦, ៥២ សប្តាហ៍។ បណ្ណបំណុលប្រភេទនេះ ផ្តល់ប្រាក់ចំណេញដល់វិនិយោគិនតិចជាងបណ្ណបំណុលផ្សេងៗទៀតរបស់រដ្ឋាភិបាល។ ស្រដៀងគ្នានឹងសញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ, វិនិយោគិនដែលទិញបណ្ណបំណុលរតនាគារ ឬរដ្ឋាភិបាល មិនទទួលបានការប្រាក់ទេ ប៉ុន្តែវិនិយោគិនទិញមូលបត្រប្រភេទនេះនូវតម្លៃអប្បហារ (Discount) មានន័យថាទិញនូវតម្លៃទាបជាងតម្លៃចារឹក( Par Value)[9]។

### ១.២.២.៤ សញ្ញាបណ្ណខេត្ត-ក្រុង (Municipal Bonds)

សញ្ញាបណ្ណខេត្ត-ក្រុង គឺជាសញ្ញាបណ្ណដែលបោះផ្សាយឡើងដោយអាជ្ញាធរក្នុងតំបន់។ គោលបំណងនៃការបោះផ្សាយសញ្ញាបណ្ណប្រភេទនេះ គឺដើម្បីបង្កើនមូលធនសម្រាប់គម្រោងអភិវឌ្ឍន៍ជាក់លាក់ណាមួយ ដែលទាក់ទងនឹងការកសាងរចនាសម្ព័ន្ធក្នុងតំបន់របស់ខ្លួនដូចជា៖ ការកសាងសាលារៀន, ផ្លូវថ្នល់, មន្ទីរពេទ្យ, និងប្រព័ន្ធផ្លូវទឹកជាដើម។ ការទិញសញ្ញាបណ្ណខេត្ត-ក្រុងមួយនេះនឹងផ្តល់ឲ្យវិនិយោគិននូវអត្ថប្រយោជន៍មួយគឺ ការលើកលែងពន្ធលើការប្រាក់[10]។

### ១.២.២.៥ សញ្ញាបណ្ណសាជីវកម្ម (Corporate Bond)

សញ្ញាបណ្ណសាជីវកម្ម គឺជាសញ្ញាបណ្ណដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម។ មូលហេតុដែលក្រុមហ៊ុនសាជីវកម្មធ្វើការបោះផ្សាយសញ្ញាបណ្ណប្រភេទនេះ គឺដើម្បីទទួលបានហិរញ្ញប្បទានសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។ ជាធម្មតា អត្រាគូប៉ុងនៃសញ្ញាបណ្ណប្រភេទនេះខ្ពស់ជាងមូលបត្របំណុលដទៃទៀត ប៉ុន្តែសញ្ញាបណ្ណសាជីវកម្មមានហានិភ័យខ្ពស់ជាងសញ្ញាបណ្ណរដ្ឋាភិបាល។ ជាទូទៅវិនិយោគិនគឺរំពឹងទទួលប្រាក់ចំនួលថេរជារៀងរាល់៦ខែ ហើយទទួលបាននូវតម្លៃចារឹកនៃសញ្ញាបណ្ណនៅពេលដែលវាដល់កាលបរិច្ឆេទកំណត់[11]។

### ១.២.២.៦ សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ (Junk Bonds)

សញ្ញាបណ្ណមានអត្រាទិន្នផលខ្ពស់ គឺជាសញ្ញាបណ្ណដែលទទួលបានប្រាក់ចំនេញខ្ពស់ជាងសញ្ញាបណ្ណផ្សេងទៀត។ ជាទូទៅសញ្ញាបណ្ណប្រភេទនេះ មានហានិភ័យខ្ពស់ដោយសារតែ

[9] Investopedia. (March 31, 2015). What the difference between a treasury bond and a treasury note and a treasury bill (T-bill)?. Retrieved from http://www.investopedia.com/ask/answers/033115/what-are-differences-between-treasury-bond-and-treasury-note-and-treasury-bill-tbill.asp

[10] Investopedia. *Municipal Bond*. Retrieved from http://www.investopedia.com/terms/m/municipalbond.asp

[11] Fidelity. *Corporate Bond.* Retrieved from https://www.fidelity.com/fixed-income-bonds/individual-bonds/corporate-bonds/overview

ចំណាត់ថ្នាក់ឥណទាននៃក្រុមហ៊ុនដែលបោះផ្សាយសញ្ញាបណ្ណប្រភេទនេះគឺក្រោមBB មានន័យថាលទ្ធភាពបង់សងនៃក្រុមហ៊ុនបោះផ្សាយមានកំរិតទាប។ ហើយតម្លៃនៃសញ្ញាបណ្ណនេះប្រែប្រួលខ្លាំងអាស្រ័យលើសមិទ្ធផលរបស់ក្រុមហ៊ុនបោះផ្សាយ[12]។

**១.២.២.៧ សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ** (Zero Coupon Bonds)

សញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យ គឺជាសំដៅលើសញ្ញាបណ្ណដែលបោះផ្សាយលក់ក្នុងតម្លៃអប្បហានៃតម្លៃចារឹករបស់សញ្ញាបណ្ណ ហើយពេលដល់កាលបរិច្ឆេទកំណត់អ្នកវិនិយោគនឹងទទួលបានទឹកប្រាក់តាមតម្លៃចារឹករបស់សញ្ញាបណ្ណនោះត្រលប់មកវិញ។ មានន័យថាសញ្ញាបណ្ណដែលមានខ័ណ្ឌបណ្ណសូន្យមិនផ្តល់ការប្រាក់ឲ្យវិនិយោគិនទេ តែអ្នកវិនិយោគអាចទទួលប្រាក់ចំណេញតាមរយៈការទិញសញ្ញាបណ្ណនៅតម្លៃអប្បហារ ហើយទទួលបានការបង់សងនៅតម្លៃចារឹក។

**១.២.២.៨ សញ្ញាបណ្ណដែលអាចប្តូរបាន** (Convertible Bonds)

សញ្ញាបណ្ណដែលអាចប្តូរបាន គឺជាប្រភេទសញ្ញាបណ្ណដែលបោះផ្សាយភ្ជាប់ជាមួយនឹងលក្ខខណ្ឌដែលអនុញ្ញាត ឲ្យអ្នកជាម្ចាស់កម្មសិទ្ធិសញ្ញាបណ្ណនេះទទួលបាននូវសិទ្ធិពិសេសមួយគឺអាចផ្ទេរសញ្ញាបណ្ណរបស់ខ្លួនទៅជាបណ្ណភាគហ៊ុនធម្មតា ឬភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅពេលជាក់លាក់ណាមួយ។ ប្រភេទសញ្ញាបណ្ណនេះមានអត្រាគូប៉ុងទាបជាងសញ្ញាបណ្ណធម្មតា[13]។

**១.២.២.៩ សញ្ញាបណ្ណមានការធានា** (Warrant Bonds)

សញ្ញាបណ្ណមានការធានា សំដៅដល់មូលបត្របំណុលដែលអនុញ្ញាតឲ្យអ្នកកាន់កាប់មូលបត្រនោះមានសិទ្ធិក្នុងការទិញមូលបត្រកម្មសិទ្ធិរបស់បុគ្គលបោះផ្សាយក្នុងតម្លៃ និងតាមកាលបរិច្ឆេទដែលបានកំណត់ជាក់លាក់។ អត្រាគូប៉ុងនៅលើសញ្ញាបណ្ណប្រហែលតិចជាងសញ្ញាបណ្ណដែលគ្មានការធានាពីព្រោះតែវិនិយោគិនដែលទិញសញ្ញាបណ្ណប្រភេទនេះ និងទទួលបានផលប្រយោជន៍នៃការទិញភាគហ៊ុននូវតម្លៃពិសេសណាមួយ។

**១.២.២.១០ លិខិតទទួលយករបស់ធនាគារិក** (Bankers' Acceptance)

លិខិតទទួលយករបស់ធនាគារិក គឺជាកម្ចីរយៈពេលខ្លីដែលធនាគារ ផ្តល់ឲ្យវិនិយោគិនជាមួយកិច្ចសន្យាមួយសងត្រលប់មកវិញ។ លិខិតទទួលយករបស់ធនាគារិកមានលក្ខណៈស្រដៀងនឹងT-Billsដែរគឺធ្វើការជួញដូរក្នុងតម្លៃអប្បហានៃតម្លៃចារឹកនៅក្នុងទីផ្សារបន្ទាប់។ ធនាគារអាចលក់

---

[12] សៀវ សុស៊ីខា, ប្រភេទមូលបត្រ (ភ្នំពេញ៖ ២០១៧), slide 20។

[13] បៀន សាំង, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ* (ភ្នំពេញ៖ បណ្ណាគារសន្តិភាព, ២០១១), ៣១,៣៣។

ឧបករណ៍នេះទៅឲ្យវិនិយោគិនដទៃទៀត ឬធនាគារផ្សេងទៀត ប៉ុន្តែមុនពេលលក់ធនាគារត្រូវបញ្ជាក់ឲ្យច្បាស់ថាអ្នកទិញឧបករណ៍នេះមិនប្រឈមមុខនិងហានិភ័យឥណទាន[14]។

**១.២.២.១១ កិច្ចសន្យាធានាទិញ** (Repurchase Agreement)

កិច្ចសន្យាធានាទិញ គឺជាកម្ចីរយៈពេលខ្លីសម្រាប់ពាណិជ្ជករនៅក្នុងមូលបត្ររបស់រដ្ឋាភិបាល។ កិច្ចសន្យាធានាទិញប្រៀបដូចជាវត្ថុបញ្ចាំរយៈពេលខ្លីដែលម្ចាស់កិច្ចសន្យាលក់កិច្ចសន្យាទៅឲ្យអ្នកទិញដើម្បីទទួលបានប្រាក់ បន្ទាប់មកអ្នកលក់នឹងទិញយកកិច្ចសន្យានោះមកវិញនៅថ្ងៃបន្ទាប់។ ពាក្យថាថ្ងៃបន្ទាប់នោះ អាចជាថ្ងៃស្អែក ឬសប្តាហ៍ក្រោយ។ តម្លៃដែលទិញយកកិច្ចសន្យានោះមកវិញខ្ពស់ជាងតម្លៃដែលបានលក់កិច្ចសន្យា។ ចន្លោះតម្លៃនៃការទិញ-លក់របស់កិច្ចសន្យាគឺជាប្រាក់ចំនេញដែលអ្នកទិញទទួលបាន។ កិច្ចសន្យាធានាទិញត្រូវបានប្រើប្រាស់ដោយស្ថាប័នដែលត្រូវការប្រាក់ក្នុងរយៈពេលខ្លីហើយលឿន និងមានហានិភ័យតិច[15]។

**១.២.២.១២ ផលបត្រពាណិជ្ជកម្ម** (Commercial Papers)

ផលបត្រពាណិជ្ជកម្ម គឺជាបណ្ណបំណុលរយៈពេលខ្លីដែលចេញផ្សាយដោយក្រុមហ៊ុនសាជីវកម្ម។ ក្រុមហ៊ុនសាជីវកម្មដែលបោះផ្សាយផលបត្រពាណិជ្ជកម្ម ជាទូទៅត្រូវមានចំណាត់ថ្នាក់ឥណទានខ្ពស់ ដើម្បីផ្តល់ទំនុកចិត្តដល់វិនិយោគិន និងដើម្បីឲ្យក្រុមហ៊ុនអាចកាត់បន្ថយចំនាយលើការប្រាក់ដែលត្រូវផ្តល់ឲ្យវិនិយោគិន។ ផលបត្រពាណិជ្ជកម្ម មានកាលបរិច្ឆេទឥណាប្រតិទានតិចជាង ឬស្មើ២៧០ថ្ងៃ ប៉ុន្តែប្រសិនបើផលបត្រពាណិជ្ជកម្ម មានកាលបរិច្ឆេទឥណាប្រតិទានលើសពី២៧០ថ្ងៃ ក្រុមហ៊ុនសាជីវកម្មដែលបោះផ្សាយត្រូវទៅចុះបញ្ជីនៅផ្សារមូលបត្រជាមុនសិន[16]។

**១.២.២.១៣ វិញ្ញាបនបត្រដាក់ផ្ញើរ** (Certificate of Deposits)

វិញ្ញាបនបត្រដាក់ផ្ញើរ គឺជាកិច្ចសន្យាដែលចេញដោយធនាគារ។ ធនាគារបោះផ្សាយវិញ្ញាបនបត្រប្រភេទនេះ ដើម្បីបញ្ជាក់ពីការដាក់ផ្ញើររយៈពេលថេរ ហើយបញ្ជាក់ពីអត្រាការប្រាក់និងកាលបរិច្ឆេទកំណត់ជាក់លាក់។ ការដាក់បញ្ញើមានរយៈពេលកំណត់នេះ ប្រសិនបើយើងដាក់ក្នុងរយៈពេលកាន់តែយូរយើងនឹងទទួលបានអត្រាការប្រាក់កាន់តែខ្ពស់។ ប៉ុន្តែការដាក់ផ្ញើបែបនេះ

[14] សៀវ សុស៊ីខា, ប្រភេទមូលបត្រ (ភ្នំពេញ៖ ២០១៧), slide ១១។

[15] Investopedia. *Repurchase Agreement*. Retrieved from http://www.investopedia.com/video/play/repurchase-agreement/

[16] Investopedia. *Commercial Papers*. Retrieved from http://www.investopedia.com/video/play/commercial-paper/

គឺមានការដាក់កំហិតដល់ម្ចាស់បញ្ញើក្នុងការដកមូលធនតាមតម្រូវការ ហើយបើទោះបីជាវាអាចដកប្រាក់បានក៏ការដកប្រាក់នេះនឹងមានការផាកពិន័យដែរ[17]។

**១.២.២.១៤ សញ្ញាបណ្ណដែលមានអត្រាគូប៉ុងប្រែប្រួល** ( Floating Rate Bonds )

សញ្ញាបណ្ណដែលមានអត្រាគូប៉ុងប្រែប្រួល ជាប្រភេទសញ្ញាបណ្ណដែលមានការប្រាក់ប្រែប្រួលតាមអត្រាការប្រាក់នៅលើទីផ្សារ។ នៅពេលដែលអត្រាការប្រាក់ទីផ្សារកើនឡើងអត្រាគូប៉ុងគឺកើនឡើង ប៉ុន្តែនៅពេលដែលអត្រាការប្រាក់ទីផ្សារថយចុះ អត្រាគូប៉ុងគឺថយចុះដែរ[18]។

**១.២.៣ ឧបករណ៍និស្សន្ទ ឬ ឧបករណ៍ដេរីវេទីវ**

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ គឺជាកិច្ចសន្យាជួញដូរឧបករណ៍ហិរញ្ញវត្ថុរវាងភាគីពីរដែលលម្អិតពីលក្ខខណ្ឌផ្សេងៗ ក្នុងការជួញដូរដូចជា បរិមាណ និងថ្លៃដោយត្រូវទូទាត់នៅពេលកំណត់ដែលបង្ហាញនៅក្នុងកិច្ចសន្យា។

មូលបត្រដេរីវេទីវ គឺជាប្រភេទមូលបត្រដែលមានលក្ខណៈស្មុកស្មាញបន្តិច ដែលទាមទារឲ្យវិនិយោគិនធ្វើការស្វែងយល់ពីរបៀបនៃការជួញដូរ និងអត្ថប្រយោជន៍ដែលទទួលបានព្រមទាំងហានិភ័យនៃការជួញដូរមូលបត្រប្រភេទនេះ។ ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវមានច្រើនប្រភេទដូចជា forward contracts, future contracts, swap contracts និង option contracts។

- Forward Contracts គឺជាការព្រមព្រៀងដែលអ្នកលក់សន្យានិងផ្តល់បរិមាណឧបករណ៍ហិរញ្ញវត្ថុទៅអោយអ្នកទិញតាមពេលវេលា និងតម្លៃដែលបានកំណត់។ តម្លៃនៅក្នុង Forward Contracts ត្រូវបានកំណត់នៅថ្ងៃដំបូងនៃការជួញដូរទោះបីជាឧបករណ៍ហិរញ្ញវត្ថុត្រូវផ្ទេរឲ្យអ្នកទិញនាពេលអនាគតក៏ដោយ។ Forward Contracts ភាគច្រើនគឺជាការព្រមព្រៀងជាលក្ខណៈឯកជន និងមិនត្រូវបានជួញដូរក្នុងទីផ្សារភាគហ៊ុនទេ។ ទីផ្សារ Forward Contracts គឺជាទីផ្សារដែលធំព្រោះថាមានក្រុមហ៊ុនសាជីវកម្មធំៗជាច្រើននៅលើពិភពលោកប្រើប្រាស់វាដើម្បីការពាររូបិយវត្ថុ និងហានិភ័យអត្រាការប្រាក់។ ប៉ុន្តែដោយសារព័ត៌មានលំអិតដែលមាននៅក្នុង Forward Contracts ត្រូវបានរក្សាជាសម្ងាត់ចំពោះតែភាគីអ្នកលក់ និងភាគីអ្នកទិញ ដូចនេះហើយទើបទំហំនៃទីផ្សារនេះពិបាកក្នុងការប៉ាន់ស្មាន។ ជាធម្មតា Forward Contracts មានហានិភ័យខ្ពស់ជាង Future Contracts។

[17] Nerdwallet. (February 24, 2017). *What Is a CD (Certificate of Deposit)?*. Retrieved from https://www.nerdwallet.com/blog/banking/cd-certificate-of-deposit/

[18] សៀវ សុស៊ីខា, ប្រភេទមូលបត្រ (ភ្នំពេញ៖ ២០១៧), slide ២១។

- Future Contracts មានលក្ខណៈស្រដៀងនឹង Forward Contracts ដែរ។ វាជាកិច្ចសន្យាផ្លូវច្បាប់មួយដែលអ្នកលក់សន្យានឹងប្រគល់ឧបករណ៍ហិរញ្ញវត្ថុ ទៅអោយអ្នកទិញតាមពេលវេលា និងតម្លៃដែលបានកំណត់តាមអ្វីដែលបានចរចាជាមួយគ្នារួចហើយ។ Future Contracts ជាកិច្ចសន្យាដែលមានលក្ខណៈស្តង់ដារ និងត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារមូលបត្រ ដែលមានសភាផាត់ទាត់ (Clearinghouse) ធ្វើជាអន្តរការីរវាងអ្នកលក់និងអ្នកទិញ។ តួនាទីចំបងរបស់សភាផាត់ទាត់ គឺបំបាត់នូវហានិភ័យទូទាត់រវាងភាគីទាំងពីរ។ ទាំងភាគីខាងអ្នកលក់ និងអ្នកទិញនៃ Future Contracts តម្រូវឲ្យតំកល់ប្រាក់កក់នៅក្រុមហ៊ុនឈ្មួញជើងសាមូលបត្រជាមុនសិន។
- Swap Contracts គឺជាកិច្ចសន្យាឯកជនដែលវិនិយោគិនទាំងពីរភាគគីធ្វើការផ្លាស់ប្តូររូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀតទៅតាមទំរង់ដែលបានកំណត់។ ឧទាហរណ៍ៈ ក្រុមហ៊ុនមួយធ្វើអាជីវកម្មនៅអាមេរិច ត្រូវការទិញលុយយ៉េន និងក្រុមហ៊ុនមួយទៀតប្រកបអាជីវកម្មនៅជប៉ុន ត្រូវការលុយដុល្លាអាមេរិច។ ដូចនេះភាគីទាំងពីរអាចប្រើប្រាស់ Swap Contracts ដើម្បីផ្លាស់ប្តូររូបិយប័ណ្ណរបស់ពួកគេនៅក្នុងអត្រា, ចំនួន, និងពេលវេលាជាក់លាក់ណាមួយដែលបានកំណត់ជាមួយគ្នា។
- Option Contracts ចែកចេញជាពីរប្រភេទគឺ Call Options និង Put Options។ វិនិយោគិនទិញប្រតិបត្តិការ Call Options ដើម្បីទិញភាគហ៊ុននៅក្នុងតម្លៃ និងពេលវេលាជាក់លាក់មួយ។ ចំណែក Put Options វិញ វិនិយោគិនទិញប្រតិបត្តិការនេះ ដើម្បីលក់ភាគហ៊ុននៅក្នុងតម្លៃ និងពេលវេលាជាក់លាក់មួយ។ វិនិយោគិនដែលទិញ Call Options និងទទួលបានប្រាក់ចំណេញ នៅពេលដែលភាគហ៊ុនឡើងថ្លៃ ឯPut Options វិនិយោគិន និងទទួលបានប្រាក់ចំណេញ នៅពេលដែលភាគហ៊ុនចុះថ្លៃ[19]។

## ១.៣. តួនាទីនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានមុខងារសំខាន់ពីរយ៉ាង គឺៈ

- **មុខងារបង្កើតដើមទុន** (Capital formation) ទីផ្សារមូលបត្រ គឺជាទីកន្លែងដែលផ្តុំទៅដោយវិនិយោគិនទាំងអស់គ្រប់លំដាប់ថ្នាក់ ដែលមានទុននៅសល់ដើម្បីធ្វើការវិនិយោគនៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណា ដែលពួកគាត់ស្រលាញ់ពេញចិត្ត

[19] ZACKS. *Types of Derivative Securities.* Retrieved from http://finance.zacks.com/types-derivative-securities-4362.html

ដែលក្រុមហ៊ុនបោះផ្សាយមូលបត្រនោះមានបំណងស្វែងរកដើមទុនបន្ថែម សំរាប់បង្រីកអាជីវកម្មរបស់ខ្លួនតាមរយៈការលក់ភាគហ៊ុន ឬបណ្ណបំណុល។

- **មុខងារសន្ទនីយភាព** (Liquidity) គឺជាលទ្ធភាពក្នុងការលក់ឧបករណ៍ហិរញ្ញវត្ថុក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រនឹងផ្តល់សន្ទនីយភាពតាមរយៈការផ្តល់កន្លែងជួញដូរដោយមានតាំងនៅទីកន្លែងផ្ទាល់ និងតាមប្រព័ន្ធអេឡិចត្រូនិច ដែលក្នុងនោះអ្នកលក់ និងអ្នកទិញជួបគ្នាដើម្បីព្រមព្រៀងតម្លៃនិងធ្វើការជួញដូរមូលបត្រ[20]។

## ១.៤ គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ច

ទីផ្សារមូលបត្រ ជាទីផ្សារមួយដែលមានអត្ថប្រយោជន៍សំរាប់វិនិយោគិនក្នុងការប្រមូលទុនដើម្បីធ្វើអាជីវកម្មរបស់ពួកគេ ហើយទីផ្សារនេះក៏ជាផ្នែកមួយដែលជួយជម្រុញសេដ្ឋកិច្ចជាតិអោយមានការរីកចំរើនផងដែរ។ ខាងក្រោមនេះជាគុណសម្បត្តិរបស់ទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិៈ

- ទីផ្សារមូលបត្រ ជួយជំរុញឲ្យមហាជនបង្កើនការសន្សំ និងកៀរគរមូលធនដែលនូវសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយមួយប្រមែប្រមូលកៀរគរនូវប្រភពមូលធន ដែលនូវទំនេរតូចៗមិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។
- ទីផ្សារមូលបត្រគឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។
- ទីផ្សារមូលបត្រជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងគ្រួសារមានចរាចរ ឬចលនារស់រវើក។
- ទីផ្សារមូលបត្របង្កើននូវទំលាប់នៃការវិនិយោគ។

ទន្ទឹមនឹងនេះដែរ ទីផ្សារមូលបត្រក៏មានគុណវិបត្តិខ្លះៗចំពោះសេដ្ឋកិច្ចជាតិដែរៈ

[20] បៀន សាំង, *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ* (ភ្នំពេញៈ បណ្ណាគារសន្តិភាព, ២០១១), ៨។

- ការឆក់ឱកាសកេងចំនេញក្នុងការទិញ-លក់ ៖ គឺជាការជួញដូរមួយ ដែលមានការគិតគូរយ៉ាងម៉ត់ដើម្បីទទួលបានផលចំនេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់នេះ អាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្នដោយរំពឹងទុកថានាពេលអនាគត នឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់របៀបនេះ នឹងបង្កឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើឲ្យភាពងាយស្រួលនៅពេលពួកគេត្រូវរ៉ូវគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារមានពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬលើស ហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ។
- ការជួញដូរផ្ទៃក្នុង៖ មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លាតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម្បីធ្វើការជួញដូរភាគហ៊ុនស្វែងរកចំណេញរបស់ខ្លួន ដែលមានឥទ្ធិពលដល់ភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ (ព័ត៌មានសំងាត់)។
- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ៖ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឲ្យ ឬអាចបណ្តាលឲ្យមានលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការធ្វើផែនការជួញដូរដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រ។
- សេចក្តីថ្លែង ឬផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែលនាំឲ្យមានការយល់ខុសធ្ងន់ធ្ងរដែលបណ្តាលឲ្យសាធារណជនទិញ-លក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ឬថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។
- ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រ តម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់មានតម្លាភាពនិងអភិបានកិច្ចសាជីវកម្មល្អដែលទាំងនោះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែង ក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន[21]។

[21] អ៊ឹង អ៊ូ, គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រដល់សេដ្ឋកិច្ច (ភ្នំពេញ៖ ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០១២)។

# ជំពូកទី២
# វិស័យមូលបត្រនៅកម្ពុជា

# ជំពូកទី២

# វិស័យមូលបត្រនៅកម្ពុជា

## ២.១. ការវិវឌ្ឍនៃវិស័យមូលបត្រនៅកម្ពុជា

ផ្សារមូលបត្រកម្ពុជាដែលបានចេញជារូបរាងដូចសព្វថ្ងៃ ត្រូវបានបង្កើតឡើងដោយឆ្លងកាត់ការរៀបចំគម្រោងអស់រយៈពេលប្រមាណជាជាង ១៥ឆ្នាំ ហើយនៅទីបំផុតផ្សារមូលបត្រត្រូវបានដាក់ឲ្យដំណើរការ និងអនុញ្ញាតឲ្យមានការដាក់ជួញដូរមូលបត្រនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២។ តើហេតុអ្វីបានជាការបង្កើតផ្សារមូលបត្រមួយត្រូវចំណាយពេលអស់យូរយ៉ាងនេះ ហើយផ្សារមូល-បត្រនេះត្រូវបានកើតឡើងយ៉ាងដូចម្តេចដែរ?

គម្រោងបង្កើតផ្សារមូលបត្រនៅកម្ពុជា ចាប់ផ្តើមរៀបចំឡើងនៅឆ្នាំ១៩៩៥ ប៉ុន្តែដោយសារប្រព័ន្ធធនាគារនៅកម្ពុជាមិនទាន់មានភាពរឹងមាំនៅឡើយ ម្យ៉ាងទៀតដោយសារមានការរំខានខាងផ្នែកនយោបាយ និងវិបត្តិហិរញ្ញវត្ថុនៅអាស៊ីក្នុងឆ្នាំ១៩៩៧ ទើបធ្វើឲ្យគម្រោងនេះត្រូវបានពន្យារពេល ហើយរាជរដ្ឋាភិបាលកម្ពុជាបានទុកគម្រោងនេះជាគម្រោងអាទិភាព។ នៅឆ្នាំ១៩៩៨ រាជរដ្ឋា-ភិបាលកម្ពុជាចាប់ផ្តើមធ្វើកំណែទម្រង់ប្រព័ន្ធធនាគារ ជាលទ្ធផលកំណែទម្រង់ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើន និងអភិវឌ្ឍន៍ជាលំដាប់។ រហូតមកដល់ឆ្នាំ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ទៅលើទស្សនៈវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ ហើយបន្ទាប់មកនាឆ្នាំ ២០០៦ ទស្សនៈវិស័យនេះត្រូវបានធ្វើបច្ចុប្បន្នភាពទៅជាយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥។ យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍវិស័យហិរញ្ញវត្ថុឲ្យកាន់តែរឹងមាំ និងបែកចែកធនធានហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចឲ្យប្រើប្រាស់ដោយមានប្រសិទ្ធិភាព។

នៅថ្ងៃ១០ ខែមករា ឆ្នាំ២០០៧ ច្បាប់ស្តីពីមូលបត្ររដ្ឋត្រូវបានបង្កើតឡើង បន្ទាប់មកយើងសង្កេតឃើញថាច្បាប់ អនុក្រឹត ប្រកាស និងសេចក្តីសម្រេចផ្សេងៗមួយចំនួនដែលពាក់ព័ន្ធទៅនឹងទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ ជាមួយគ្នានេះដែរ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើង បន្ទាប់ពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួចនៅក្នុងឆ្នាំ២០០៩។ រហូតដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១០ គណៈកម្មការមូលបត្រកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនចំនួន ១៥ ដើម្បីប្រកបអាជីវកម្មមូលបត្រដែលក្នុងនោះមានក្រុមហ៊ុនចំនួន០៧ ជាក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនចំនួន០២ ជាក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនចំនួន០៤ ជាក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ និងក្រុមហ៊ុនចំនួន០២

ជាក្រុមហ៊ុនផ្តល់ទីប្រឹក្សាវិនិយោគ។ ក្រោយមកទៀតនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ គណៈកម្មការមូលបត្រក៏បានបន្តផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមួយចំនួនទៀតដូចជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករផាត់ទាត់ និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ ភ្នាក់ងារទូទាត់សាច់ប្រាក់ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ក្រៅពីនេះក៏មានក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវាក្នុងវិស័យមូលបត្រផងដែរ[22]។

នៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ វិធានប្រតិបត្តិនានារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាត្រូវបានអនុម័តជាបន្តបន្ទាប់រហូតដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ផ្សារមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលកម្ពុជា ជាតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកាន់កាប់ភាគហ៊ុន ៥៥ភាគរយ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េដែលមានភាគហ៊ុន៤៥ភាគរយ។ នាដំណាក់កាលបន្ទាប់យើងសង្កេតឃើញថាផ្សារមូលបត្រកម្ពុជាមានសកម្មភាពទៅមុខជាលំដាប់តាមរយៈការធ្វើការផ្សព្វផ្សាយឲ្យសាធារណៈជនបានយល់ដឹង ពីវិស័យដ៏ថ្មីមួយនេះ។

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ផ្សារមូលបត្រកម្ពុជា ក៏ចាប់ផ្តើមមានដំណើរការក្នុងការលក់ភាគហ៊ុនរដ្ឋមួយដែលនឹងគ្រោងចុះបញ្ជីនៅលើទីផ្សារមូលបត្រ គឺរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រោយមកក្រុមហ៊ុនជាបន្តបន្ទាប់បានធ្វើការចុះបញ្ជីដើម្បីលក់ភាគហ៊ុនរបស់ខ្លួន ក្នុងគោលបំណងប្រមូលទុនពង្រីកអាជីវកម្មរបស់ខ្លួន ដែលក្នុងពេលបច្ចុប្បន្ននេះមានក្រុមហ៊ុនចំនួន ៥ គឺៈ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) ក្រុមហ៊ុនហ្គ្រេនធ្វីន (GTI) ក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSP) ក្រុមហ៊ុនកំពង់ផែស្វយ័តភ្នំពេញ (PPAP) និងក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS) ។

## ២.២. តួអង្គសំខាន់ៗនៅក្នុងវិស័យមូលបត្រនៅកម្ពុជា

វិស័យមូលបត្រនៅក្នុងប្រទេសមួយ អាចដំណើរការទៅបានប្រកបដោយប្រសិទ្ធិភាព ព្រោះមានការចូលរួមពីសំណាក់តួអង្គសំខាន់ៗជាច្រើន។ តួអង្គដែលចូលរួមក្នុងវិស័យមូលបត្រនៅកម្ពុជារួមមានៈ

### ២.២.១. និយ័តករមូលបត្រ

និយ័តករមូលបត្រ គឺជាតួអង្គស្នូលក្នុងវិស័យមូលបត្រ។ និយ័តករមូលបត្រ គឺសំដៅទៅលើគណៈកម្មការមូលបត្រកម្ពុជា ឬហៅកាត់ថា គ.ម.ក។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដើម្បីជានា

[22] សៀវ សុស៊ីខា, កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា (ភ្នំពេញៈ២០១៧), Slide ៤-១៣។

ឲ្យបាននូវការទុកចិត្តពីសំណាក់សាធារណៈជនមកលើទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ គ.ម.ក. ជាស្ថាប័ននិយ័តករមូលបត្រតែមួយគត់ ដែលមានតួនាទីក្នុងការរៀបចំបទប្បញ្ញត្តិនានាសម្រាប់គ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ត្រឹមត្រូវ រក្សាអោយមានទំនុកចិត្ត និងការពារអ្នកវិនិយោគ។

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលប្រកាសឲ្យដាក់ប្រើនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលមានប្រធាន០១ (មួយ) រូប និងសមាជិក ០៨ (ប្រាំបី) រូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។ សមាជិក គ.ម.ក. មានអាណត្តិរយៈពេល ០៥ (ប្រាំ) ឆ្នាំ។ រចនាសម្ព័ន្ធចាត់តាំងរបស់ គ.ម.ក. មាន៖

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ

៣. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ

៤. នាយកដ្ឋានកិច្ចការគតិយុត្ត

៥. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ

៦. នាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាលអភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ

**រូបភាពទី១៖** រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា



គណៈកម្មការមូលបត្រកម្ពុជាជាតួអង្គស្នូលក្នុងវិស័យមូលបត្រមានមុខងារដូចជា[23]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ
- ដាក់ឲ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាត ជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់
- ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាបណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិក អ្នកចូលរួម និងវិនិយោគិន
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតការគោរពនយោបាយសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា
- បំពេញលក្ខខណ្ឌផ្សេងៗទៀតដែលចែងក្នុងអនុក្រឹត្យ ។

### ២.២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាក្រុមហ៊ុនដែលបង្កើតឡើងតាមរយៈការចូលភាគហ៊ុនគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនិងក្រុមហ៊ុនផ្សារមូលបត្ររបស់ប្រទេសកូរ៉េ ដែលភាគីកម្ពុជាមានភាគហ៊ុនចំនួន ៥៥ភាគរយ ចំណែកឯភាគីកូរ៉េមានភាគហ៊ុនចំនួន៤៥ភាគរយ[24]។ ការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺមានការចុះអនុស្សរណៈយោគយល់គ្នារវាងឧបនាយករដ្ឋមន្ត្រី គាត ឈន់ តំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងឯកឧត្តម ដុក ស៊ូ ហាន់ ឧបនាយករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកូរ៉េនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ នៅទីក្រុង Hyderabad ប្រទេសឥណ្ឌាក្នុងឱកាសប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនៃអាស៊ាន+៣ និងការប្រជុំ ADBប្រចាំឆ្នាំ។ ផ្សារមូលបត្រកម្ពុជាបង្កើតឡើងដោយមានចក្ខុវិស័យនិងបេសសកម្មច្បាស់លាស់។ ចក្ខុវិស័យរបស់ផ្សារមូលបត្រកម្ពុជា គឺដើម្បីកសាងនូវមហាវិថីហិរញ្ញវត្ថុសម្រាប់កម្ពុជា។ ចំណែកឯបេសកកម្មរបស់ផ្សារមូលបត្រកម្ពុជាគឺ៖

- ដើម្បីសម្រួលដល់ការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា

[23] គ.ម.ក.,ច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, មាត្រា៧

[24] គេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា, ប្រវត្តិរបស់ផ្សារមូលបត្រកម្ពុជា

- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រ ដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយ ដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ម្យ៉ាងទៀតផ្សារមូលបត្រកម្ពុជា មានតួនាទី និងទទួលបានការអនុញ្ញាតពី គ.ម.ក. ឲ្យធ្វើជាប្រតិបត្តិករ ៣ សំខាន់ៗដូចជា៖ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។

❖ **ប្រតិបត្តិករផ្សារមូលបត្រ៖** ប្រតិបត្តិករផ្សារមូលបត្រ គឺជាកន្លែងដែលមូលបត្រត្រូវបានទិញ និងលក់ជាកន្លែងដែលផ្តល់ការអនុញ្ញាតឲ្យក្រុមហ៊ុនបោះផ្សាយទាំងអស់អាចចុះបញ្ជីលក់មូលបត្ររបស់ខ្លួននៅលើទីផ្សារ។ ជានិយ័តជួរមុខក្នុងការគ្រប់គ្រងនូវដំណើរការជួញដូរមូលបត្រក្នុងផ្សារមូលបត្រ ។

❖ **ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ៖** ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រត្រួតពិនិត្យខាងអ្នកលក់ (ថាតើមានមូលបត្រគ្រប់គ្រាន់សម្រាប់លក់ឬទេ) និងត្រួតពិនិត្យខាងអ្នកទិញ (ថាតើមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទិញឬទេ) ដើម្បីបញ្ចៀសនូវហានិភ័យការទូទាត់ ។

❖ **ប្រតិបត្តិកររក្សាទុកមូលបត្រ៖** ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់កន្លែងដាក់ផ្ញើរមូលបត្រ។ ការដាក់ផ្ញើរមូលបត្រ គឺជាដំណើរការនៃការផ្ទេររវាងគណនី (Book-entry) (ការកត់ត្រាឥណពន្ធ/ឥណទាន ក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវន្ត។

### ២.២.៣. វិនិយោគិនមូលបត្រ

វិនិយោគិនមូលបត្រ ឬវិនិយោគិនសាធារណៈ សំដៅដល់សាធារណៈជននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ នឹងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិប្រតិស្រុត ដែលមិនមែនជាសមាការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិ

បុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិប្រតិស្រុតនោះ[25]។ តាមន័យទូទៅវិនិយោគិនមូលបត្រ សំដៅទៅលើអ្នកដែលធ្វើប្រតិបត្តិការទិញ លក់មូលបត្រក្នុងគោលបំណងស្វែងរកប្រាក់ចំណេញតាមរយៈការវិនិយោគរបស់ខ្លួន។ វិនិយោគិននៅលើទីផ្សារមូលបត្រចែកចេញជាពីរប្រភេទ គឺវិនិយោគិនជាបុគ្គល និងវិនិយោគិនជាស្ថាប័ន។ វិនិយោគិនជាលក្ខណៈបុគ្គល គឺសំដៅលើវិនិយោគិនដែលធ្វើការទិញ-លក់ភាគហ៊ុនក្នុងទំហំតូច ដើម្បីទទួលបានប្រាក់ចំណេញផ្ទាល់ខ្លួន ចំណែកឯវិនិយោគិនជាស្ថាប័ន គឺសំដៅដល់ក្រុមហ៊ុនវិនិយោគធំៗ ដែលធ្វើការទិញ-លក់ភាគហ៊ុនក្នុងទំហំធំ ឬក្នុងចំនួនទឹកប្រាក់ច្រើន។

### ២.២.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រ

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រអាចជាស្ថាប័នសាធារណៈ ឬក្រុមហ៊ុនឯកជនដែលស្វែងរកទុននៅលើទីផ្សារមូលបត្រតាមរយៈការលក់ភាគហ៊ុនរបស់ខ្លួន ។ តាមនិយមន័យក្នុងអនុក្រឹត្យស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ក្រុមហ៊ុនបោះផ្សាយមូលបត្រ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ឬនីតិបុគ្គលប្រតិស្រុតដែលស្នើសុំ ឬបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្រុមហ៊ុនធ្វើការបោះផ្សាយមូលបត្រ ក្នុងគោលបំណងប្រមូលមូលធនពីវិនិយោ-គិនសាធារណៈ ទៅបំពេញតម្រូវការក្នុងការពង្រីកអាជីវកម្មរបស់ខ្លួន។

### ២.២.៥. អន្តរការីមូលបត្រ

អន្តរការីមូលបត្រ គឺជាអង្គភាព ឬបុគ្គលទាំងឡាយដែលប្រមូលផ្តុំការវិនិយោគហើយបង្ហាញឬណែនាំក្រុមហ៊ុនបោះផ្សាយទៅកាន់ទីផ្សារមូលបត្រ។ អន្តរការីទីផ្សារមូលបត្រ ជាតួអង្គសំខាន់នៅក្នុងទីផ្សារដំបូង និងទីផ្សារបន្ទាប់ ដែលមានតួនាទីផ្តល់នូវលក្ខណៈងាយស្រួល និងផ្តល់នូវអត្ថប្រយោជន៍ចំពោះក្រុមហ៊ុនបោះផ្សាយ និងវិនិយោគិនក្នុងការទិញ-លក់មូលបត្រ។ អន្តរការីមូលបត្រមានដូចជា៖ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ និងក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

#### ២.២.៥.១. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ គឺសំដៅលើក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពីគណៈ-កម្មការមូលបត្រកម្ពុជា និងមានឯកទេសក្នុងការធានាទិញមូលបត្រ។ ក្រុមហ៊ុនធានាទិញមូលបត្រផ្តល់នូវសេវាកម្មដូចខាងក្រោម[26]៖

[25] គ.ម.ក.,ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ, ប្រការ២ និយមន័យ
[26] គ.ម.ក.,ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ, ប្រការ៥

- ផ្តល់ប្រឹក្សាសំខាន់លើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការប្រាក់តម្លៃមូលបត្រ(Pricing)ការកំណត់ទំហំទឹកប្រាក់ (Issue amount) នឹងចំនួនមូលបត្រ (Number of securities to be issued) នៃសំណើបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលា នៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution timeline) ជាដើម។
- ទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយមូលបត្រគោលដៅចែកចាយ ឬលក់បន្ត។
- ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

នាពេលបច្ចុប្បន្នក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាមានដូចជា៖

១. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី Phnom Penh Securities Plc.

២. យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី Yuanta Securities (Cambodia) Plc.

៣. អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក RHB Indochina Securities PLC.

៤. កាណា ស៊ីឃ្យូរីធី អិលធីឌី Cana Securities Ltd.

៥. កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី Campu Securities Plc.

៦. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី SBI Royal Securities Plc.

**២.២.៥.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ**

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ គឺជាអន្តរការីដែលទិញ ឬលក់មូលបត្រដោយប្រើគណនីផ្ទាល់ខ្លួន និងរ៉ាប់រងហានិភ័យដោយខ្លួនឯង។ នាពេលបច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រដែលទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាមានដូចជា៖

១. ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី Golden Fortune (Cambodia) Securities Plc.

**២.២.៥.៣. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ**

អាជីវកម្មជើងសាមូលបត្រ គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងសា។ នាពេលបច្ចុប្បន្ន ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រដែលទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាមានដូចជា៖

១. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ACLEDA Securities Plc.

២. ខេប ស៊ីឃ្យូរីធី លីមីធីត CAB Securities Limited.

៣. ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី Cambodia-Vietnam Securities Plc.

**២.២.៥.៤. ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ**

អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគរួមមាន៖

- ការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រដល់អ្នកវិនិយោគសាធារណៈ ដោយទទួលបាននូវកម្រៃសេវា។
- ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រ ជូនដល់អ្នកវិនិយោគសាធារណៈ។

នាពេលបច្ចុប្បន្នក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលទទួលអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជាមានដូចជា៖

១. អង្គរ ឃែភីថល អ៊ែតវ៉ាយហ្សឺរ Angkor Capital Advisors Co., Ltd.

២. អេហ្វ.យូ.ជី.អាយ ហ្គោល F.U.G.I GOLD Co., Ltd.

## ២.៣. តួអង្គដទៃទៀតក្នុងវិស័យមូលបត្រ

### ២.៣.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent) ជាធនាគារដែលទទួលអាជ្ញាបណ្ណជាធនាគារពាណិជ្ជ និងទទួលបានការទទួលស្គាល់ដោយ គ.ម.ក. សម្រាប់ផ្តល់សេវាទូទាត់សាច់ប្រាក់ក្នុងវិស័យមូលបត្រ។ សព្វថ្ងៃនេះ នៅក្នុងប្រទេសកម្ពុជាយើងមានតែធនាគារចំនួនបីប៉ុណ្ណោះ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ជាភ្នាក់ងារទូទាត់សាច់ប្រាក់ គឺ៖

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី

២. ធនាគារ កាណាឌីយ៉ា ភីអិលស៊ី

៣. ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី។

### ២.៣.២. ភ្នាក់ងារបញ្ជិកាមូលបត្រ

ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) មានតួនាទីតែនៅក្នុងទីផ្សារដំបូងប៉ុណ្ណោះ ដែលទាក់ទងនឹងការធ្វើបរិវិសកម្មមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រ សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ឲ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយក្នុងក្របខណ្ឌនៃការបោះផ្សាយលក់មូលបត្រ ។ ភ្នាក់ងារនេះបំពេញតួនាទីដូចខាងក្រោម[27]៖

- គ្រប់គ្រងឲ្យបានត្រឹមត្រូវនូវដំណើរការនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រស្របតាមនីតិវិធីបោះផ្សាយលក់មូលបត្រ។
- កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រក្រោយពេលធ្វើការបែងចែកមូលបត្រ ត្រូវបានបញ្ចាប់នៅទីផ្សារដំបូង។
- ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រជូនក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក. ។
- ជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រដោយបញ្ជាក់ពីភាពជាម្ចាស់ លើមូលបត្រដែលបានធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។
- សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

### ២.៣.៣. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Transfer Agents) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ឲ្យផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ក្រោយពេលមូលបត្រត្រូវបានបែងចែកទៅឲ្យអ្នកធ្វើបរិវិសកម្មដូចខាងក្រោម៖

- រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្ររួមទាំងព័ត៌មានលំអិតរបស់កម្មសិទ្ធិករមូលបត្រឲ្យបានត្រឹមត្រូវជាមួយនឹងកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ។
- រដ្ឋបាលកិច្ចទាក់ទងនិងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ ស្ថិតិ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនិងសកម្មភាពរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។
- រៀបចំការងារពាក់ព័ន្ធនឹងកម្មសិទ្ធិករមូលបត្រ ដែលត្រូវផ្តល់ដោយក្រុមហ៊ុនបោះផ្សាយដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ ការបង់ការប្រាក់ជាដើម។

[27] គ.ម.ក.,ប្រកាសស្តីពីការទទួលស្គាល់ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់, ប្រការ២ និយមន័យ

- បញ្ជូនរបាយការណ៍និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយ ទៅកម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធ នឹងសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។
- សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

### ២.៣.៤. ភ្នាក់ងារទូទាត់

ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ឲ្យផ្ដល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម៖

- គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀតដែលត្រូវផ្ដល់ឲ្យកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធ តាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ។
- ធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ។
- បញ្ជូនព័ត៌មានចំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតទៅកម្មសិទ្ធិករមូលបត្រ និងរៀបចំឯកសារពាក់ព័ន្ធនឹងការទូទាត់ទាំងនោះជូនទៅក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក. តាមការចាំបាច់។
- សេវាពាក់ព័ន្ធដទៃទៀតដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

នាពេលបច្ចុប្បន្ននេះ ក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណពី គ.ម.ក. ជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់មូលបត្រ មានដូចជា៖

១. ធនាគារ អេស៊ីលីដា ភីអិលស៊ី

២. ក្រុមហ៊ុន ត្រាយខ័រ ស៊ីយូរីធី ភីអិលស៊ី

### ២.៣.៥. ក្រុមហ៊ុនគណនេយ្យករជំនាញផ្ដល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ

ក្រុមហ៊ុនគណនេយ្យករជំនាញផ្ដល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យ (Professional Accounting Firms and External Auditors) ជាក្រុមហ៊ុនដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ក្នុងការផ្ដល់នូវសវនកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។ ក្រុមហ៊ុនគណនេយ្យករជំនាញផ្ដល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យមានតួនាទី៖

- ធានាថាក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រអនុវត្តនូវស្តង់ដារគណនេយ្យត្រឹមត្រូវ។

- ផ្តល់នូវរបាយការណ៍គណនេយ្យដែលអាចជឿជាក់បាន។
- ផ្តល់នូវសុវត្ថិភាពខាងគ្រប់គ្រងគណនេយ្យ។

ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ និងសវនករឯករាជ្យដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. មានដូចជា៖

១. ក្រុមហ៊ុន ប្រាយវែតធ័រហោរខូភើស៍ (ខេមបូឌា)

២. ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា

៣. ក្រុមហ៊ុន ប៊ីឌីអូ ខេមបូឌា លីមីធីត

៤. ក្រុមហ៊ុន អ៊ីនស៍ អេន យ៉ាំង ខេមបូឌា អិលធីឌី

៥. អង្គរស៊ីធីហ្វាយ អឹខោនធិន ណេតវើក អឹមស៊ី មីឡានវ៉ូឌ (ខេមបូឌា) ខូអិលធីឌី

៦. ហ្គ្រេន ថនតុន (ខេមបូឌា) លីមីធីត

### ២.៣.៦. ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ និងអ្នកវាយតម្លៃឯករាជ្យ

ក្រុមហ៊ុនវាយតម្លៃឯករាជ្យ សំដៅដល់ក្រុមហ៊ុនសេវាកម្មវាយតម្លៃអចលនវត្ថុដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។ អ្នកវាយតម្លៃឯករាជ្យ សំដៅដល់បុគ្គលិករបស់ក្រុមហ៊ុនសេវាកម្មវាយតម្លៃអចលនវត្ថុដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[28]។ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ និងអ្នកវាយតម្លៃឯករាជ្យ (Asset Valuation Firms and Professional Valuators) សំដៅលើក្រុមហ៊ុនដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. សម្រាប់ការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។ ក្រុមហ៊ុនប្រភេទនេះមានតួនាទី៖

- ធានាថាទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងអ្នកចូលរួមដទៃទៀត មិនមានការបន្លើសក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ធានានូវភាពត្រឹមត្រូវនៃការវាយតម្លៃទ្រព្យសកម្មដោយយោងតាមការណែនាំ និងបទដ្ឋានវាយតម្លៃផ្សេងៗ។

ក្រុមហ៊ុនដែលផ្តល់សេវាវាយតម្លៃក្នុងវិស័យមូលបត្រ និងអ្នកវាយតម្លៃឯករាជ្យដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. មានដូចជា៖

១. ក្រុមហ៊ុន វីត្រាស់ អាប់ព្រេហ្សល ខូអិលធីឌី

---

[28] គ.ម.ក.,ប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យមូលបត្រ, ប្រការ២ និយមន័យ

២. ក្រុមហ៊ុន រៀល អេសស្តេត វី អឹម ស៊ី ខេមបូឌា អិលធីឌី

៣. ស៊ីប៊ី រីចឆាត អ៊ីលីស (ខេមបូឌា) ខមភេនី លីមីធីត

**២.៣.៧. ភ្នាក់ងារដាក់ពិន្ទុឥណទាន**

ភ្នាក់ងារដាក់ពិន្ទុឥណទាន (Credit Rating Agents) ត្រូវជាក្រុមហ៊ុនដែលទទួលស្គាល់ពី គ.ម.ក. សម្រាប់ការផ្តល់សេវាដាក់ពិន្ទុឥណទានសល់ក្រុមហ៊ុនបោះផ្សាយ[29]។ ភ្នាក់ងារដាក់ពិន្ទុឥណទានផ្តល់នូវសេវាដាក់ពិន្ទុឥណទានក្នុងវិស័យមូលបត្រដែលអាចទុកចិត្តបាន និងថែទាំនូវប្រតិបត្តិការដាក់ពិន្ទុឥណទាន និងមានឧបករណ៍ជំរុញផ្សេងៗដែលមានសុវត្ថិភាពគ្រប់គ្រងប្រព័ន្ធដែលអាចប្រើប្រាស់បាន និងការគ្រប់គ្រងហានិភ័យផ្សេងៗ។ បច្ចុប្បន្ននេះយើងមិនទាន់មានភ្នាក់ងារដាក់ពិន្ទុឥណទាននោះទេ ដោយសារតែយើងមិនទាន់មានការបោះផ្សាយលក់មូលបត្របំណុលនៅឡើយ។

**២.៤. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ**

មុននឹងមូលបត្រត្រូវបានលក់ទៅឲ្យវិនិយោគិនសាធារណៈ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវរៀបចំយន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដែលមាន១២ដំណាក់កាល ដូចខាងក្រោម[30]៖

**ដំណាក់កាលទី១៖ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈ**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនទៅ គ.ម.ក. ដែលលិខិតមានខ្លឹមសារ ០៣ចំណុចគឺ៖

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

[29] សៀវ សុស៊ីខា, កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា (ភ្នំពេញ៖២០១៧), Slide ៦៥។

[30] គេហទំព័រគណកម្មការមូលបត្រកម្ពុជា, គោលការណ៍ណែនាំស្តីពី "យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង"។

៣. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

**ដំណាក់កាលទី២៖ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ**

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រត្រូវផ្តល់សេវា ដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគ.ម.ក.។

**ដំណាក់កាលទី៣៖ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លើកដំបូង (IPO Team)**

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀតដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូល-បត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

**ដំណាក់កាលទី៤៖ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)**

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ។

**ដំណាក់កាលទី៥៖ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ដំណាក់កាលទី៦៖ ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ពី គ.ម.ក.**

ក្រោយពីទទួលបានការបញ្ជាក់លទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មានមុន នឹងផ្តល់ការអនុញ្ញាត ជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

**ដំណាក់កាលទី៧៖ ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពីគ.ម.ក.ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**ដំណាក់កាលទី៨៖ ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រ តាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើទីផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**ដំណាក់កាលទី៩៖ ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ដោយធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជារួចដាក់ជូន គ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**ដំណាក់កាលទី១០៖ ការធ្វើបរិវិសកម្មមូលបត្រ (Subscription)**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូក៣ និងជំពូក៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ដំណាក់កាលទី១១៖ ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះជូនគ.ម.ក.។

**ដំណាក់កាលទី១២៖ ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលជោគជ័យ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បន្ទាប់ពីមូលបត្រទទួលបានការចុះបញ្ជីជាផ្លូវការរួចមក វិនិយោគិនសាធារណៈអាចមានសិទ្ធិធ្វើការទិញ-លក់មូលបត្រនៅលើទីផ្សារមូលបត្របានហើយ។ ការទិញ-លក់មូលបត្រមិនមែនដូចការទិញ-លក់ទំនិញធម្មតានោះទេ វិនិយោគិនត្រូវធ្វើការទិញតាមរយៈក្រុមហ៊ុនលក់មូលបត្រដែលទាមទារអោយវិនិយោគិនបំពេញនូវលក្ខខណ្ឌចាំបាច់តម្រូវមួយចំនួន មុននឹងពួកគេអាចធ្វើការជួញដូរមូលបត្របាន។ លក្ខខណ្ឌតម្រូវក្នុងដំណើរការទិញ-លក់មូលបត្ររបស់វិនិយោគិនសាធារណៈនឹងត្រូវបានបកស្រាយនៅជំពូកក្រោយជាបន្តបន្ទាប់។

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី គីអិលសុី

# ជំពូកទី៣

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

## ៣.១. ប្រវត្តិរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ជាក្រុមហ៊ុនមូលបត្រមួយដែលមានបទពិសោធន៍ និងជំនាញយ៉ាងច្បាស់លាស់ទាក់ទងទៅនឹងទីផ្សារមូលបត្រ។ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០០៩ គឺជាក្រុមហ៊ុនមូលបត្រមួយដែលបានបង្កើតដំបូងគេបង្អស់នៅប្រទេសកម្ពុជា ដែលមានស្ថាបនិកជាជនជាតិចិនតៃវ៉ានដែលមានបទពិសោធន៍ និងជំនាញខ្ពស់ខាងវិស័យមូលបត្រ។ ជាមួយគ្នានេះផងដែរ នាពេលបច្ចុប្បន្នក្រុមហ៊ុនមានដើមទុនចំនួន ១៥លានដុល្លារអាមេរិក ហើយក្រុមហ៊ុននេះ គឺជាក្រុមហ៊ុនមូលបត្រមួយដ៏ធំ និងមានការលូតលាស់យ៉ាងលឿននៅកម្ពុជា។ ទាំងអ្នកគ្រប់គ្រង់ និងបុគ្គលជាន់ខ្ពស់ដ៏ទៃទៀតរបស់ក្រុមហ៊ុនសុទ្ធតែបានទទួលវគ្គបណ្តុះបណ្តាលពីបរទេសដូចជាៈ តៃវ៉ាន់, វៀតណាម, ប៊ែលហ្ស៊ិក, បារាំង, និងស្ថាប័នក្នុងស្រុកជាច្រើនផ្សេងៗទៀត។ លើសពីនេះទៀតក្រុមហ៊ុនមួយនេះក៏ជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនមូលបត្រទាំង៦ ដែលបានទទួលអាជ្ញាប័ណ្ណជា "អ្នកធានាទិញមូលបត្រ" ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ។ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ត្រូវបានអនុញ្ញាតឲ្យដំណើរការធ្វើនូវសេវាកម្មពេញលេញទាំងអស់ខាងវិស័យមូលបត្រនៅកម្ពុជា មានដូចជា ភ្នាក់ងារធានាទិញមូលបត្រ ឈ្មួញជើងសាមូលបត្រ ពាណិជ្ជករមូលបត្រ ទីប្រឹក្សាវិនិយោគ ក្រុមវិនិយោគផ្សេងៗ និងសេវាផ្ទេរមូលបត្រ។ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី បានធ្វើអាជីវកម្មស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ដែលមានវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មលេខ Co.១៤២៧KH/២០០៩ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ដែលចេញដោយក្រសួងពាណិជ្ជកម្ម នឹងទទួលបានអាជ្ញាបណ្ណធ្វើអាជីវកម្មធានាទិញមូលបត្រលេខ ០០៧ គ.ម.ក/ក.ធ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ចេញដោយគណៈកម្មការមូលបត្រកម្ពុជា។

នៅឆ្នាំ ២០១៦ កន្លងទៅនេះ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ជាក្រុមហ៊ុនមួយដែលទទួលបានចំណាត់ថ្នាក់លេខមួយដែលមានអតិថិជនធ្វើការជួញដូរច្រើនជាងគេ ដោយគិតជាចំនួនសន្លឹកហ៊ុនមានចំនួន ១,១៨០,៨១៨ហ៊ុន។

## ៣.២. ស្ថានភាពទូទៅរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

### ៣.២.១. ទីតាំងភូមិសាស្ត្រ

ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ៖

- មានការិយាល័យស្ថិតនៅ៖ អាគារ VTrust ជាន់ទី2 ផ្លូវឆេកូស្លូវ៉ាគី (169) រាជធានីភ្នំពេញ (ទល់មុខវិទ្យាល័យបាក់ទូក) ។
- ថ្ងៃធ្វើការ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ។
- ម៉ោងធ្វើការ៖ ឈ្មួញជើងសា ៧:៣០ ដល់ ១២:០០ និង ១៣:០០ ដល់ ១៦:៣០។
  បុគ្គលិកទូទៅ ៨:០០ ដល់ ១២:០០ និង ១៣:០០ ដល់ ១៧:០០។
- គេហៈទំព័រ ៖ www.pps.com.kh
- Email ៖ info@pps.com.kh




**រូបភាពទី២៖** ផែនទីទីតាំងរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី មើលតាមរយៈ Google Map ។



**រូបភាពទី៣៖** អាគារ VTrust ដែលក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ីស្ថិតនៅជាន់ទី២។

### ៣.២.២. ស្លាកសញ្ញា

**រូបភាពទី៤៖** ស្លាកសញ្ញារបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។

## ៣.៣. ចក្ខុវិស័យ និងទស្សនៈវិស័យ

### ៣.៣.១. ចក្ខុវិស័យ

ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី មានចក្ខុវិស័យចង់ក្លាយជាក្រុមហ៊ុនមូលបត្រមួយដែលជាជំរើសដ៏ល្អបំផុត ដែលផ្តល់សេវាយ៉ាងសំបូរបែបទាក់ទងនឹងវិស័យមូលត្រសម្រាប់អតិថិជន។

### ៣.៣.២. ទស្សនៈវិស័យ

ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី បានកសាងកេរ្តិ៍ឈ្មោះរបស់ខ្លួនតាមរយៈការផ្តល់សេវាយ៉ាងជោគជ័យជូនដល់អតិថិជន និងមានភាពប៉ិនប្រសប់ប្រកបដោយវិជ្ជាជីវៈរបស់បុគ្គលិកនៅក្នុងក្រុមហ៊ុន ។ សរសរគ្រឹះសំខាន់ៗទាំង ៤ របស់ក្រុមហ៊ុនគឺ ៖

- សេចក្តីសុច្ចរិត ៖ ក្រុមហ៊ុនខិតខំរក្សាឲ្យបាននូវវិជ្ជាជីវៈខ្ពស់ផ្តល់ការប្រឹក្សាដែលត្រឹមត្រូវនឹងអាចជឿជាក់បានព្រមទាំងផ្តល់ការគ្រប់គ្រងកិច្ចការសំខាន់ៗជាមួយភាពក្លាហាន និងស្មោះត្រង់។ "ធ្វើអ្វីដែលត្រឹមត្រូវ" គឺជាគោលការណ៍សំខាន់របស់ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី និងជាស្នូលសំខាន់របស់វប្បធម៌ក្រុមហ៊ុន។
- ការសាងទំនុកចិត្ត ៖ ក្រុមហ៊ុនអោយតម្លៃ និងលើកតំកើនសារៈសំខាន់នៃអ្វីដែលត្រឹមត្រូវ និងផ្តល់តម្លាភាពនូវអ្វីដែលក្រុមហ៊ុនធ្វើ។ សីលធម៌នេះបានកំនត់ និងកសាងជំនឿចិត្តដល់សាធារណៈជនដើម្បីអោយទុកចិត្តលើសេវាកម្មដែលក្រុមហ៊ុនបានផ្តល់ជូន។
- ការទទួលខុសត្រូវ ៖ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ទទួលខុសត្រូវរាល់សកម្មភាពរបស់ក្រុមហ៊ុន និងធ្វើការសំរេចចិត្តដែលអាចបង្កើនអត្ថប្រយោជន៍ដ៏ច្រើនបំផុតតាមតែធ្វើទៅបានសំរាប់ភាគហ៊ុនិក អតិថិជន និងបុគ្គលពាក់ព័ន្ធទាំងឡាយ ។
- វិជ្ជាជីវៈនិយម ៖ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី បានដំណើរការដោយមានអ្នកជំនាញអាជីពផ្សេងៗជាច្រើនរូប ដែលប្តេជ្ញាចិត្តក្នុងការផ្តល់សេវាដែលមានគុណភាពខ្ពស់ទៅកាន់អតិថិជនរបស់ខ្លួន។ ក្រុមហ៊ុនមានមោទនៈភាពដោយនាំមកនូវបុគ្គលិកមានសមត្ថភាពវ័យក្មេងដែលទទួលបានការជ្រើសរើស និងហ្វឹកហ្វឺន វិជ្ជាជីវៈពីបរទេស ដូចជា តៃវ៉ាន់ អាមេរិច បារាំង បេលសិច ថៃ និងកម្ពុជា។

## ៣.៤. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន

**រូបភាពទី៥៖** រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។




## ៣.៥. សេវាកម្មរបស់ក្រុមហ៊ុន

ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី ជាក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណជាអ្នកធានាទិញមូលបត្រដែលមានសិទ្ធិផ្តល់សេវាកម្មយ៉ាងពេញលេញក្នុងវិស័យនេះជូនអតិថិជនមានដូចជា៖

- សេវាកម្មធានាទិញមូលបត្រ
- សេវាកម្មឈ្មួញជើងសាមូលបត្រ
- សេវាកម្មឈ្មួញកណ្តាល
- សេវាកម្មប្រឹក្សាវិនិយោគ

- សេវាកម្មឈ្មួញជើងសាឧបករណ៍និស្សន្ទ ។

### ៣.៥.១. សេវាកម្មធានាទិញមូលបត្រ

សេវាកម្មធានាទិញមូលបត្រ គឺសំដៅដល់ក្រុមហ៊ុនជាអ្នកជួយរៀបចំឯកសារគ្រប់សព្វបែបយ៉ាងដើម្បីជួយក្រុមហ៊ុនដែលមានបំណងចង់ប្រមូលដើមទុនបន្ថែម ដើម្បីពង្រីកអាជីវកម្មតាមរយៈការបោះផ្សាយភាគហ៊ុនរបស់ខ្លួនលក់ទៅឲ្យសាធារណៈជន។ ក្រុមហ៊ុនធានាទិញមូលបត្រនឹងធានាទិញរាល់ភាគហ៊ុនទាំងអស់ដែលនៅសល់ ក្នុងករណីភាគហ៊ុនដែលបានបោះផ្សាយលក់ទៅឲ្យសាធារណៈជននៅសល់ក្នុងតម្លៃដែលបានកំណត់ ទៅតាមអ្វីដែលបានចចារគ្នាជាមួយក្រុមហ៊ុនបោះផ្សាយ។ សេវាកម្មធានាទិញមូលបត្រមានដូចខាងក្រោម៖

- ប្រឹក្សាទៅលើការលក់មូលបត្រដូចជា តម្លៃ ចំនួនមូលបត្រ និងពេលវេលាបែងចែក។
- សាងរចនាសម្ព័ន្ធ និងដាក់ឲ្យដំនើរការនូវការដាក់លក់មូលបត្រកម្មសិទ្ធិ សម្រាប់គៀរគរហិរញ្ញវត្ថុដើម្បីអាជីវកម្មការទិញយកក្រុមហ៊ុនដទៃ និងការបង្កើតយុទ្ធសាស្ត្រអាជីវកម្មដទៃទៀត។
- បង្កើនដើមទុន (Capital raising in private equity) ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី និងធ្វើការជាមួយក្រុមហ៊ុនបោះផ្សាយ ដើម្បីស្វែងរកដំណោះស្រាយសំរាប់មុខជំនួញដោយក្រុមហ៊ុនអាចបោះផ្សាយមូលបត្រទាំងទីផ្សារឯកជន និងទីផ្សារសាធារណៈ ។
- ការបោះផ្សាយមូលបត្រជាសាធារណៈលើកដំបូង (IPO) ជួយដោះស្រាយបញ្ហាហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបោះផ្សាយ។ ក្រុម IPO ជួយរៀបចំឯកសារស្នើទៅគណៈកម្មការមូលបត្រកម្ពុជា និងស្វែងរកអតិថិជន។ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី នឹងជួយក្រុមហ៊ុនបោះផ្សាយបង្កើតនូវគោលនយោបាយនៃភាពជាម្ចាស់ភាគហ៊ុន និងគោលនយោបាយច្បាប់ការគ្រប់គ្រងគណនេយ្យ។
- ការបោះផ្សាយមូលបត្រក្នុងទីផ្សារទីពីរ (SPO) ជួយក្នុងការបោះផ្សាយមូលបត្រជាលើកទីពីរក្នុងទីផ្សារបន្ទាប់ នៅពេលដែលក្រុមហ៊ុនត្រូវការដើមទុនបន្ថែមទៀតបន្ទាប់ពីការធ្វើIPO ។ ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ផ្តល់នូវការប្រឹក្សាមូលបត្រដែលសមស្របសំរាប់ក្រុមហ៊ុនបោះផ្សាយ ដូចជាភាគហ៊ុនធម្មតា ភាគហ៊ុនបុរិមា ប័ណ្ណបំណុលដែលអាចប្តូរបាន។ល។

### ៣.៥.២. សេវាកម្មឈ្មួញជើងសាមូលបត្រ

ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី បានជួយសំរួលដល់ការទិញ-លក់មូលបត្រកម្មសិទ្ធិ ក្នុងនាមជាអ្នកទទួលបញ្ជាពីអតិថិជន។ ជាមួយគ្នានេះដែរក្រុមហ៊ុនក៏បានដាក់ឲ្យដំណើរការនូវប្រព័ន្ធជួញដូរ តាមប្រព័ន្ធអនឡាញដែលអាចផ្តល់នូវភាពងាយស្រួលមួយកំរិត ទៀតដល់អតិថិជនក្នុងការជួញដូរ ។ ក្រុមហ៊ុននឹងផ្តល់សេវាកម្មឈ្មួញជើងសាដូចខាងក្រោមៈ

- បើកគណនីជួញដូរមូលបត្រជូនអតិថិជន
- ទទួលបញ្ញើមូលបត្រ
- ធ្វើការទូទាត់ និងផាត់ទាត់មូលបត្រ
- ផ្តល់កម្ចីមូលបត្រ
- ជួយអតិថិជនក្នុងការទិញ លក់ និងផ្ទេរមូលបត្រ
- ផ្តល់ប្រភេទទំនិញ និងសេវាហិរញ្ញវត្ថុ ជាច្រើនតាមរយៈប្រព័ន្ធជួញដូរតាម អេឡិចត្រូនិច។

### ៣.៥.៣. សេវាកម្មពាណិជ្ជករមូលបត្រ

សេវាកម្មពាណិជ្ជករមូលបត្រ ឬឈ្មួញកណ្តាលសំដៅដល់ក្រុមហ៊ុនធ្វើការទិញ-លក់មូលបត្រនៅក្នុងគណនីរបស់ក្រុមហ៊ុនផ្ទាល់ និងទទួលយកហានិភ័យជួញដូរដោយខ្លួនឯង ។

- ប្រកាសលក្ខខណ្ឌសំខាន់ៗ សម្រាប់កិច្ចព្រមព្រៀងទិញ លក់មូលបត្រ រួមមាន តម្លៃ ចំនួនអប្បរមា និងអតិបរមារបស់មូលបត្រដើម្បីជួញដូរ។
- ទទួលយកហានិភ័យជួញដូរដោយខ្លួនឯង។

### ៣.៥.៤. សេវាកម្មប្រឹក្សាវិនិយោគ

ក្រុមហ៊ុនផ្តល់សេវាប្រឹក្សាវិនិយោគដោយបុគ្គលិក ដែលមានជំនាញច្បាស់លាស់ និងបទពិសោធន៍ដល់វិនិយោគិនក្នុងការសំរេចចិត្តមុននឹងធ្វើការវិនិយោគ។ ជាមួយនឹងបទពិសោធន៍ដែលក្រុមហ៊ុនមានកន្លងមក ពួកយើងធ្វើការវិភាគនឹងផ្តល់ប្រឹក្សាដល់វិនិយោគិន ដើម្បីឲ្យវិនិយោគិនអាចទាញយកផលចំណេញពីការជួញដូរមូលបត្រនៅទីផ្សារភាគហ៊ុន ជាជាងឲ្យទីផ្សារភាគហ៊ុនយកផលចំណេញពីគាត់វិញ។ ក្រុមហ៊ុនផ្តល់ការប្រឹក្សាហិរញ្ញវត្ថុពាក់ព័ន្ធ នឹងការវិនិយោគមូលបត្រ សេវាកម្មសន្សំដោយអត្រាប្រកួតប្រជែង និងធ្វើការផ្សព្វផ្សាយជាសាធារណៈលើការវិភាគវិនិយោគមូលបត្រទៅអ្នកវិនិយោគ។

### ៣.៥.៥. សេវាកម្មឈ្មួញជើងសាឧបករណ៍និស្សន្ទ

វិនិយោគិនអាចធ្វើការជួញដូររូបិយប័ណ្ណបរទេស, មាស, ប្រេង, អត្រាប្តូរប្រាក់, និងឧបករណ៍ផ្សេងទៀតជាច្រើនតាមរយៈក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី។ ក្រុមហ៊ុននឹងផ្តល់កាវិនិយោគមួយដែលសុវត្ថិភាព និងប្រសិទ្ធភាពបំផុតឲ្យអតិថិជន។ លើសពីនេះទៀតក្រុមហ៊ុននឹងផ្តល់ការទូទាត់លុយយ៉ាងងាយស្រួល និងមានសុវត្ថិភាពបំផុតតាមរយៈការតាមប្រព័ន្ធអនឡាញទៅគ្រប់ទីកន្លែង។

## ៣.៦. ផ្សេងៗ

- ផ្តល់យោបល់ និងពិគ្រោះយោបល់លើការបែងចែកភាគលាភ និងរៀបចំកិច្ចប្រជុំភាគហ៊ុនិក និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។
- អភិវឌ្ឍន៍គោលនយោបាយផ្ទៃក្នុងរបស់ក្រុមហ៊ុន បទបញ្ញត្តិ និងបញ្ហាហិរញ្ញវត្ថុ ដូចជាការធ្វើផែនការហិរញ្ញវត្ថុ រចនាសម្ព័ន្ធ។ល។

# ជំពូកទី៤
# សេវាកម្មទិញ-លក់
# មូលបត្ររបស់
# ក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី
# ភីអិលស៊ី

# ជំពូកទី៤

# សេវាកម្មទិញ-លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី

## ៤.១. និយមន័យនៃការទិញ-លក់មូលបត្រ

ការទិញ-លក់មូលបត្រ ឬការជួញដូរមូលបត្រគឺជាការវិនិយោគតាមរយៈមូលបត្របំណុល ឬមូលបត្រកម្មសិទ្ធិ ដែលគ្រោងនិងទទួលបានប្រាក់ចំណេញនាពេលបច្ចុប្បន្ន និងអនាគត។ ការទិញ និងលក់មូលបត្រ ជាការជួញដូរមូលបត្រពីក្រុមហ៊ុនបោះផ្សាយទៅកាន់វិនិយោគិន ឬការជួញដូរវវាងវិនិយោគិនម្នាក់ទៅវិនិយោគិនម្នាក់ទៀត។ ក្រុមហ៊ុនដែលបោះផ្សាយមូលបត្រលក់ ត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនបោះផ្សាយ ឯអ្នកទិញមូលបត្រគឺជាវិនិយោគិន។ ជាទូទៅមូលបត្រតំណាងឲ្យការវិនិយោគ និងជាមធ្យោបាយដែលរាជរដ្ឋាភិបាល ក្រុមហ៊ុនសាជីវកម្ម និងសហគ្រាសបង្កើនដើមទុនថ្មីរបស់ខ្លួន។ ជាឧទាហរណ៍ ក្រុមហ៊ុនអាចរកលុយបានច្រើននៅពេលដែលពួកគេបោះផ្សាយលក់ភាគហ៊ុនជាសាធារណៈលើកដំបូង (IPO) ជាជាងការទៅខ្ចីហិរញ្ញប្បទានតាមរយៈកម្ចីធនាគារ។

ក្នុងការទិញ-លក់មូលបត្រ ឈ្មួញជើងសា និងវិនិយោគិនត្រូវគោរពតាមច្បាប់ និងលក្ខខណ្ឌតម្រូវរៀងៗខ្លួន។ ជាពិសេសគឺក្រុមហ៊ុនមូលបត្រដែលផ្តល់សេវាកម្មខាងផ្នែកមូលបត្រត្រូវតែទទួលបានអាជ្ញាប័ណ្ណ និងធានាថាពួកគេត្រូវបានបណ្តុះបណ្តាល ដើម្បីអនុវត្តតាមច្បាប់ដែលកំណត់ដោយគណៈកម្មការមូលបត្រ។

## ៤.២. លក្ខខណ្ឌតម្រូវដើម្បីទទួលបានអាជ្ញាបណ្ណជាឈ្មួញជើងសាមូលបត្រ

ដោយសារតែក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី ជាក្រុមហ៊ុនមួយដែលបានទិញអាជ្ញាបណ្ណជាក្រុមហ៊ុនធានាទិញមូលបត្រពេញលេញ ដូចនេះមានន័យថាគាត់អាចប្រកបអាជីវកម្មបានដូចជាអ្នកធានាទិញមូលបត្រ (Underwriter) ឈ្មួញជើងសាមូលបត្រ (Brokerer) ពាណិជ្ជករមូលបត្រ (Dealer) និងជាអ្នកប្រឹក្សាវិនិយោគ (Investment Advisor) ផងដែរ។

- លក្ខខណ្ឌតម្រូវមូលធន (ក្រុមហ៊ុនធានាទិញមូលបត្រ)
    - មូលធនអប្បបរមា ៖ ៤០ ពាន់លានរៀល (១០ លានដុល្លារ)
    - មូលធនសុទ្ធអប្បបរមា៖ ២ ពាន់លានរៀល

- ឧបករណ៍តម្កល់ធានាអាជីវកម្មៈ ៤ ពាន់លានរៀល

• លក្ខខណ្ឌតម្រូវមូលធន ( ក្រុមហ៊ុនជើងសាមូលបត្រ)

- មូលធនអប្បបរមា ៖ ៦ ពាន់លានរៀល (១.៥ លានដុល្លារ)
- មូលធនសុទ្ធអប្បបរមាៈ ៣០០ លានរៀល
- ឧបករណ៍តម្កល់ធានាអាជីវកម្មៈ ១ ពាន់លានរៀល

• លក្ខខណ្ឌតម្រូវផ្សេងទៀតដែលមិនមែនជាមូលធន ដើម្បីទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ (មាត្រា ៤០ នៃអានុក្រឹត្យ និងប្រការ១៧នៃប្រកាស) ៖

១. បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាក្រុមហ៊ុនមូលធន ឬក្រុមសហាកម្មសិទ្ធិដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត ឬជាបុគ្គលដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

២. បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ឬត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់សម្រាប់ជាសមាជិក និងជាអ្នកចូលរួមក្នុងទីផ្សារនៃប្រតិបត្តករទីផ្សារមូលបត្រលើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។

៣. អភិបាលរបស់ក្រុមហ៊ុនមូលធន ឬសហាកម្មសិទ្ធិករ របស់ក្រុមហ៊ុនសហាកម្មសិទ្ធិដែលបានដាក់ពាក្យស្នើសុំៈ

- មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬប្រសិនបើអភិបាលឬសហាកម្មសិទ្ធិករណាម្នាក់ធ្លាប់ត្រូវបានប្រកាសក្ស័យធនមិនត្រូវមានរយៈពេលតិចជាង ៥ឆ្នាំឡើង គិតមកដល់កាលបរិច្ឆេទដែលក្រុមហ៊ុនមូលធន ឬក្រុមសហាកម្មសិទ្ធិនោះបានដាក់ពាក្យស្នើសុំ។
- មិនធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនមូលធន ឬក្រុមសហាកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហាកម្មសិទ្ធិ ដែលធ្លាប់ត្រូវបានបដិសេធការផ្តល់អាជ្ញាបណ្ណឲ្យធ្វើជាក្រុមហ៊ុនមូលបត្រដោយអគ្គនាយកនៃ គ.ម.ក. ឬស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង គ.ម.ក. លើកលែងតែមានការអនុញ្ញាតពី គ.ម.ក.។
- មិនធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនមូលធន ឬក្រុមសហាកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហាកម្មសិទ្ធិដែលអជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ ត្រូវបានដកហូតយកវិញដោយអគ្គ

នាយកនៃ គ.ម.ក. ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង គ.ម.ក. លើកលែងតែមានការអនុញ្ញាតពី គ.ម.ក.។

៤. អភិបាលរបស់ក្រុមហ៊ុនមូលធន ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហកម្មសិទ្ធិ និងនិយោជិកគ្រប់រូប ដែលបំពេញភារកិច្ចពាក់ព័ន្ធនឹងការកាន់អាជ្ញាបណ្ណ ត្រូវតែមានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

៥. យ៉ាងហោចណាស់មានអភិបាល ឬសហកម្មសិទ្ធិករម្នាក់ និងនិយោជិតម្នាក់មានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលអាជ្ញាបណ្ណ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ក្រុមហ៊ុនមូលធន។

៦. បុគ្គលដាក់ពាក្យស្នើសុំ ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ឬឧបករណ៍តម្កល់ធានាផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

៧. បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានមូលធនសុទ្ធអប្បបរមា និងរចនាសម្ព័ន្ធមូលធនដែលត្រូវកំណត់ដោយ គ.ម.ក ទៅតាមប្រភេទអាជីវកម្មនីមួយៗរបស់ក្រុមហ៊ុនមូលបត្រ។

៨. បុគ្គលដាក់ពាក្យស្នើសុំត្រូវមានអាគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងមានបំពាក់ឧបរណ៍គ្រប់គ្រាន់ ដើម្បីផ្តល់សេវាកម្មសមស្របដល់អតិថិជន។

៩. បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានប្រព័ន្ធ ឧបករណ៍ និងសម្ភារៈគ្រប់គ្រាន់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវរបស់ប្រតិបត្តិករដែលអ្នកដាក់ពាក្យស្នើសុំនោះជាសមាជិកឬអ្នកចូលរួមក្នុងទីផ្សារ។

## ៤.៣. តួនាទីរបស់ឈ្មួញជើងសាមូលបត្រ

ឈ្មួញជើងសាមូលបត្រមានតួនាទីជួយសំរួលដល់អតិថិជនចំពោះប្រតិបត្តិការទិញលក់មូលបត្រនៅក្នុងផ្សារភាគហ៊ុន ។ តួនាទីប្រចាំថ្ងៃរបស់ឈ្មួញជើងសារមូលបត្រមានដូចជា៖

- មុនពេលបើកផ្សារ ម៉ោង ៧:៣០-៨:០០ ព្រឹក

  ១. រៀបចំរបាយការណ៍សង្ខេបនៅក្នុងការប្រជុំ

  ២. ពិនិត្យមើលទិន្នន័យនៅក្នុងកម្មវិធី PPS iTrader/Website ថាតើតួលេខដែលបានបញ្ចូលត្រឹមត្រូវហើយឬនៅ

  ៣. ពិនិត្យមើលថាប្រព័ន្ធជួញដូរមានដំណើរការត្រឹមត្រូវឬទេ

- ម៉ោងជួញដូរ ៨:០០-១១:៣០ ព្រឹក

១. ធ្វើការទទួលបញ្ជាទិញ ឬលក់របស់អតិថិជន

២. ទាក់ទងទៅអតិថិជនដើម្បីបញ្ជាក់ការទិញ ឬលក់របស់អតិថិជន

៣. សរសេរវិក័យប័ត្របញ្ជាក់ពីការទិញ ឬលក់មូលបត្រ

៤. ផ្ញើរបាយការណ៍ទីផ្សារចុងក្រោយទៅឲ្យអតិថិជន

៥. ពិនិត្យមើលពីការបញ្ចូលទិន្នន័យទីក្នុង PPS iTrader/Website

៦. ដំណើរការការដកប្រាក់ (ប្រសិនបើមាន)

៧. បើកគណនីជូនអតិថិជន ឬជួបអតិថិជន

៨. ជួយបំពេញសំណើបែបបទជួញដូររបស់បុគ្គលិក (ប្រសិនបើមាន)

- ម៉ោង ១:០០-៤:៣០ ល្ងាច

១. ផ្ញើរបាយការណ៍ប្រតិបត្តិការដែលមាន

២. រៀបចំបញ្ជីឈ្មោះអតិថិជនដែលត្រូវជួប

៣. ទៅជួបអតិថិជន

៤. ទំនាក់ទំនងទៅអតិថិជន យ៉ាងហោចណាស់ឲ្យបាន៥នាក់ក្នុងមួយថ្ងៃ (១០០នាក់ក្នុងមួយខែ)

## ៤.៤. ដំណើរការបើកគណនី និងដំណើរការជួញដូរ

### ៤.៤.១.វិធីបើកគណនី

វិនិយោគិនដែលមានបំណងចង់វិនិយោគក្នុងទីផ្សារមូលបត្រកម្ពុជា ត្រូវមានអត្តសញ្ញាណវិនិយោគិន (Invester ID) ពីគ.ម.ក។ ការស្នើសុំអត្តសញ្ញាណវិនិយោគិន អាចធ្វើបានតាមរយៈក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី (ដោយមិនគិតថ្លៃសេវា) ឬអាចធ្វើការស្នើសុំនៅ គ.ម.ក.ដោយផ្ទាល់។ បន្ទាប់ពីទទួលបានអត្តសញ្ញាវិនិយោគិន (Invester ID) ទើបក្រុមហ៊ុនអាចធ្វើការបើកគណនីជួញដូរជូនវិនិយោគិនបាន។ វិនិយោគិនអាចបើកគណនីជួញដូរមូលបត្រ បានតែមួយប៉ុណ្ណោះនៅក្រុមហ៊ុនមូលបត្រមួយ។




**រូបភាពទី៦៖** ដំណើរការនៃការបើកគណនីជួញដូរ។

**៤.៤.១.១ អត្តសញ្ញាណវិនិយោគិន** ( Invester ID )

អត្តសញ្ញាណវិនិយោគិនមានពីរប្រភេទសម្រាប់៖

- រូបវន្តបុគ្គល(បុគ្គលទូទៅ) ៖ អាចជាជនជាតិខ្មែរ ឬជនបរទេស។
- នីតិបុគ្គល (ក្រុមហ៊ុន) ៖ អាចជាក្រុមហ៊ុនខ្មែរ ឬបរទេស។

តម្លៃស្នើសុំអត្តសញ្ញាណវិនិយោគិន ពីគ.ម.ក.

- រូបវន្តបុគ្គល ២០០០០ រៀល
- នីតិបុគ្គល ៥០០០០ រៀល។

ឯកសារតម្រូវ៖

- រូបវន្តបុគ្គល ៖

- អត្តសញ្ញាណបណ្ណខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)
- រូបថត ៤ X ៦ ចំនួន ២សន្លឹក
- និង លេខគណនីធនាគារ (ធនាគារណាក៏បាន)។

- នីតិបុគ្គល ៖

- លក្ខន្តិកៈក្រុមហ៊ុន
- បណ្ណប៉ាតង់, អាជ្ញាបណ្ណ
- អត្តសញ្ញាណបណ្ណខ្មែរអ្នកតំណាង ឬ លិខិតឆ្លងដែន (សម្រាប់ជនបរទេស)
- រូបថត ៤ X ៦ របស់អ្នកតំណាង
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់និតិបុគ្គល
- បញ្ជីឈ្មោះអភិបាលសាជីវកម្ម
- បញ្ជីឈ្មោះអ្នកមានសិទ្ធិ ឬ អ្នកចូលរួមសំរេចចិត្តវិនិយោគ
- លិខិតផ្ទេរសិទ្ធិ និងលិខិតផ្សេងៗទៀត។

- អត្តសញ្ញាណវិនិយោគិនមានសុពលភាព ១០ឆ្នាំគិតកាលបរិច្ឆេទផ្តល់លេខអត្តសញ្ញាណវិនិយោគិន ដោយគណៈកម្មការមូលបត្រកម្ពុជា។ ហើយវិនិយោគិនត្រូវដាក់ពាក្យស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិន មុនពេលអស់សុពលភាពរយៈពេល ០៣ខែ។



**រូបភាពទី៧៖** ការស្នើអត្តសញ្ញាណវិនិយោគិន។

### ៤.៤.១.២. ការបើកគណនីជួញដូរ

គណនីជួញដូរក៏មាន ពីរប្រភេទដែរ សម្រាប់រូបវន្តបុគ្គល និងនិតិបុគ្គល។ ក្រុមហ៊ុនផ្តល់ការបើកគណនីជួញដូរដោយឥតគិតថ្លៃ ជូនអតិថិជនទាំងពីរប្រភេទ។

ជាទូទៅអត្តសញ្ញាណវិនិយោគិន និងទទួលបាន ៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីការចុះឈ្មោះ។ បន្ទាប់ពីទទួលបានអត្តសញ្ញាណវិនិយោគិន និងលេខគណនីជួញដូរ ឈ្មួញជើងសានឹង

ធ្វើប័ណ្ណវិនិយោគិនមួយដែលមានព័ត៌មានចាំបាច់មួយចំនួនសម្រាប់ធ្វើការវិនិយោគ ព្រមទាំងការដាក់ប្រាក់ និងដកប្រាក់។




**រូបភាពទី៨៖** ប័ណ្ណគំរូ។

### ៤.៤.២. ដំណើរការជួញដូរ

ដំណើរការនៃការជួញដូរមាន ៨ ដំណាក់កាល៖

1. វិនិយោគិនបើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រមួយ (T-1)។ ក្រុមហ៊ុនមូលបត្រអាចជួយស្នើសុំអត្តសញ្ញាណវិនិយោគិនពី គ.ម.ក. សម្រាប់អតិថិជនរបស់ខ្លួន។
2. វិនិយោគិនបង្គាប់ទៅក្រុមហ៊ុនមូលបត្រ ឲ្យដាក់បញ្ជាទិញឬលក់(T+0) ជាលាយលក្ខណ៍អក្សរ ដោយពាក្យសំដី ឬដោយមធ្យោបាយអេឡិចត្រូនិចនានា។
3. បន្ទាប់ពីបានពិនិត្យថាមានសាច់ប្រាក់ ឬមូលបត្រគ្រប់គ្រាន់នៅក្នុងគណនីរបស់អតិថិជន និងបានបង្កក់ទុកនូវសាច់ប្រាក់ និងបរិមាណមូលបត្រយ៉ាងហោច១០០%រួចហើយ អ្នកតំណាងទីផ្សារនិងដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក (T+0)។
4. បញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន (T+0)។
5. ផ.ម.ក. ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ (T+0)។
6. ក្រុមហ៊ុនមូលបត្របញ្ជាក់អំពីលទ្ធផលនៃការជួញដូរជាមួយអតិថិជនរបស់ខ្លួន (T+0)។
7. វិនិយោគិនបង់ប្រាក់ឬផ្ទេរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ ជាក់ស្តែង គឺក្រុមហ៊ុនមូល

បត្រប្រើប្រាស់សាច់ប្រាក់ ឬមូលបត្ររបស់អតិថិជន ដែលបានបង្កកទុកដើម្បីបង់ប្រាក់ ឬផ្ទេរមូលបត្រ ដោយមិនចាំបាច់សុំការអនុញ្ញាតពីអតិថិជនទៀតឡើយ។

8. ក្រុមហ៊ុនមូលបត្រធ្វើការបង់ប្រាក់ឬប្រគល់មូលបត្រក្នុងនាមអតិថិជនរបស់ខ្លួននៅ ផ.ម.ក.។




**រូបភាពទី៩៖** ដំណើរការជួញដូរ។

## ៤.៥. វិធានប្រតិបត្តិការក្នុងការទិញ-លក់មូលបត្រ

### ៤.៥.១. ពេលវេលាជួញដូរ

វិនិយោគិនអាចធ្វើការជួញដូរមូលបត្របានចាប់ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាក់ជាសាធារណៈតែប៉ុណ្ណោះ។

សម្រាប់ផ្សារមូលបត្រកម្ពុជា យើងបើកឲ្យវិនិយោគិនចាប់ផ្តើមធ្វើការទិញ-លក់បាន ចាប់ពីម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ១១:៣០ព្រឹក ដែលបែងចែកជាវគ្គផ្អែកលើវិធីសាស្ត្រនៃការដេញថ្លៃដូចខាងក្រោម៖

- វគ្គជួញដូរដោយប្រើវិធីសាស្ត្រដេញថ្លៃដោយថ្លៃតែមួយ (Single-Price-Auction)៖ វគ្គបើកចាប់ផ្តើមពីម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ០៩:០០ព្រឹក ដែលការជួញដូរត្រូវអនុវត្តនៅ

ម៉ោង ០៩:០០ព្រឹក និងវគ្គបិទចាប់ផ្តើមពីម៉ោង ១១:០០ព្រឹក រហូតដល់ម៉ោង ១១:៣០ព្រឹក ដែលការជួញដូរត្រូវអនុវត្តនៅម៉ោង ១១:៣០ព្រឹក។

- វគ្គជួញដូរដោយប្រើវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple-Price-Auction) ៖ វគ្គជួញដូរនិរន្តរ៍ (Continuos Trading) ចាប់ផ្តើមពីម៉ោង ០៩:០០ព្រឹក ដល់ម៉ោង ១១:០០ ព្រឹកហើយការអនុវត្តការជួញដូរត្រូវធ្វើឡើងភ្លាមៗនៅពេលអាចផ្គូរផ្គងបាន។
- រូបិយប័ណ្ណសម្រាប់ជួញដូរមូលបត្រនៅផ្សារមូលបត្រកម្ពុជា គឺខ្មែររៀល។




**រូបភាពទី១០៖** ពេលវេលានៃការជួញដូរ។

### ៤.៥.២. ព័ត៌មានត្រូវផ្តល់

នៅពេលវិនិយោគិនធ្វើការជួញដូរមូលបត្រ វិនិយោគិនត្រូវផ្តល់ព័ត៌មានចំបាច់មួយចំនួនទៅកាន់ឈ្មួញជើងសាមូលបត្រដូចខាងក្រោម៖

- ឈ្មោះ វិនិយោគិន
- អត្តសញ្ញាណវិនិយោគិន និង លេខគណនីជួញដូរ
- ប្រភេទមូលបត្រ
- ប្រភេទបញ្ជា ៖ ទិញ ឬ លក់
- បរិមាណ និងតម្លៃ

### ៤.៥.៣. ការដាក់បញ្ជា (សំណើទិញ ឬលក់មូលបត្រ)

ការបញ្ជាទិញ ឬលក់នីមួយៗអាចត្រូវបានបញ្ចូលចូលប្រព័ន្ធរបស់ផ.ម.ក លុះត្រាតែ៖

- បញ្ជាលក់ ៖ អ្នកវិនិយោគត្រូវមានមូលបត្រគ្រប់គ្រាន់ (១០០%) ក្នុងគណនីមូលបត្រ។
- បញ្ជាទិញ ៖ អ្នកវិនិយោគត្រូវមានសាច់ប្រាក់គ្រប់គ្រាន់ (១០០%) សម្រាប់ប្រតិបត្តិការ ។

ការលុបបញ្ជាទិញ/លក់ អាចធ្វើបានតែចំពោះបញ្ជាដែលមិនទាន់បានអនុវត្តឬ ផ្គូរផ្គងប៉ុណ្ណោះ។

### ៤.៥.៤. ការអនុវត្តការជួញដូរ និងការជូនដំណឹង

- ប្រព័ន្ធជួញដូររបស់ ផ.ម.ក ធ្វើការផ្គូរផ្គង និងអនុវត្តលើសំណើដែលបានទទួលដោយកំណត់តាមគោលការណ៍ដេញថ្លៃ បន្ទាប់មកឈ្មួញជើងសាររបស់លោកអ្នកនឹងជូនដំណឹងស្តីពីលទ្ធផលជួញដូរនេះក្នុងថ្ងៃតែមួយ (ជាទូទៅ ៥ ទៅ ១០ នាទី បន្ទាប់ពីការផ្គូរផ្គង)។
- វិនិយោគិនអាចស្នើឈ្មួញជើងសា ផ្ញើព័ត៌មានតុល្យការ(Balance)នៃទឹកប្រាក់ និងមូលបត្រតាមរយ: Email ឬ ទទួលឯកសារបាននៅក្រុមហ៊ុន។
- វិនិយោគិនក៏អាចត្រួតពិនិត្យតុល្យការមូលបត្រ និងទឹកប្រាក់តាមរយ:គេហទំព័ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីយ្យូរីធី ភីអិលស៊ី ឬភីភីអេសបានដែរ។

### ៤.៥.៥. វិធីសាស្ត្រទូទាត់សាច់ប្រាក់ និងមូលបត្រ

វិធីសាស្ត្រទូទាត់ T+២: ពីរថ្ងៃ បន្ទាប់ពីថ្ងៃជួញដូរ (ទទួលបានហ៊ុន ឬអាចដកសាច់ប្រាក់បាន)។ ឧទាហរណ៍៖ ជួញដូរនៅថ្ងៃច័ន្ទ នឹងត្រូវបានទូទាត់ សាច់ប្រាក់ និងមូលបត្រនៅព្រឹកថ្ងៃពុធ។

<u>ចំណុចពិសេស</u>

ជាមួយនឹងវិធីសាស្ត្រថ្មី "ការជួញដូរមុនការទូទាត់" វិនិយោគិនអាចប្រើប្រាស់៖

- មូលបត្រដែលត្រូវទទួលបានពីការបញ្ជាទិញដែលជោគជ័យ ដើម្បីលក់ចេញវិញបានភ្លាមៗ
- សាច់ប្រាក់ដែលទទួលបានពីការបញ្ជាលក់ដែលជោគជ័យ ដើម្បីទិញមូលបត្របន្តទៀតបានភ្លាមៗ។

### ៤.៥.៦. វិធីសាស្ត្រផ្គូរផ្គង

- **គោលការណ៍ដេញថ្លៃ៖** រាល់ការជួញដូរត្រូវប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយថ្លៃតែមួយ (Single-Price-Auction) និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple-Price-Auction)។

❖ វិធីសាស្ត្រដេញថ្លៃដោយថ្លៃតែមួយ (Single-Price-Auction)

គោលការណ៍៖

១. បញ្ជាទាំងអស់ត្រូវជួញដូរនៅថ្លៃតែមួយ និងត្រូវរង់ចាំដល់ម៉ោងជួញដូរ។

២. ថ្លៃផ្គូរផ្គងជាថ្លៃដែលអាចផ្គូរផ្គងនៅបរិមាណច្រើនបំផុត។

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ 300 | 10,400 | ❸ 700 100 |
| ❷ 200 | 10,300 | |
| ❹ 100 | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ០៩:០០ ឬ ១១:៣០)៖

600 x 10,400 រៀល = 6,240,000 រៀល។

❖ វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple-Price-Auction)

គោលការណ៍៖

១. បញ្ជានីមួយៗអាចជួញដូរនៅថ្លៃច្រើនខុសៗគ្នា និងអាចជួញដូរបានភ្លាមៗនៅពេលដែលមានបញ្ជាត្រូវគ្នា។

២. នៅពេលបញ្ជាទិញ និងលក់ត្រូវគ្នាថ្លៃផ្គូរផ្គងត្រូវជ្រើសយកថ្លៃរបស់បញ្ជាដែលទទួលបនមុន។

| បញ្ជាលក់ | ថ្លៃ | បញ្ជាទិញ |
|---|---|---|
| | 10,500 | |
| ❶ ~~300~~ | 10,400 | ❸ ~~700~~ 100 |
| ❷ ~~200~~ | 10,300 | |
| ❹ ~~100~~ | 10,200 | |
| | 10,100 | |
| 600 | សរុប | 700 |

ដល់ម៉ោងជួញដូរ (ម៉ោង ០៩:០០ ឬ ១១:០០)៖

1. 200 x 10,300 រៀល = 2,060,000 រៀល (ភ្លាមៗ)
2. 300 x 10,400 រៀល = 3,120,000 រៀល (ភ្លាមៗ)
3. 100 x 10,400 រៀល = 1,040,000 រៀល (ភ្លាមៗ)

6,220,000 រៀល

- **អាទិភាពនៃបញ្ជាទិញ-លក់**

❖ ថ្លៃ

- បញ្ជាលក់ក្នុងថ្លៃទាប មានអាទិភាពជាង បញ្ជាលក់ក្នុងថ្លៃខ្ពស់
- បញ្ជាទិញក្នុងថ្លៃខ្ពស់ មានអាទិភាពជាង បញ្ជាទិញក្នុងថ្លៃទាប

❖ ពេលវេលា

- ក្នុងករណីតម្លៃបញ្ជាដូចគ្នា បញ្ជាទិញ ឬលក់មុន មានអាទិភាព

- **បញ្ជាព្រមពេលគ្នា៖** សំដៅដល់ការបញ្ជាលក់ ត្រូវបានផ្គូរផ្គងនៅដែនថ្លៃខាងក្រោម (-៥%នៃថ្លៃមូលដ្ឋាន) ឬការបញ្ជាទិញ ត្រូវបានផ្គូរផ្គង នៅដែនថ្លៃខាងលើ (+៥% នៃថ្លៃមូលដ្ឋាន)

➢ ចំណាំ៖

- ការបញ្ជារបស់អតិថិជន មានអាទិភាពជាងការបញ្ជារបស់សមាជិក (ស្ថាប័នដែលចុះបញ្ជីនៅ ផ.ម.ក.)

- បញ្ជាទិញ ឬលក់មានបរិមាណច្រើនជាងមានអាទិភាព
- លទ្ធផលនៃការបែងចែក ក្នុងករណីបញ្ជាព្រមពេលគ្នា:
  - ១០០ ដង នៃឯកតាជួញដូរ
  - ៥០០ ដង នៃឯកតាជួញដូរ
  - ១០០០ ដង នៃឯកតាជួញដូរ
  - ៥០% ដង នៃឯកតាជួញដូរ
  - បរិមាណដែលនៅសល់ទាំងអស់ត្រូវផ្តល់អាទិភាព។

### ៤.៥.៧. សុពលភាពនៃការបញ្ជាទិញ-លក់

ការបញ្ជាទិញ-លក់ មានសុពលភាពចាប់ពីបានបញ្ចូលក្នុងប្រព័ន្ធមូលបត្រកម្ពុជា រហូតដល់ពេលផ្គូផ្គងនៅក្នុងថ្ងៃតែមួយ។

### ៤.៥.៨. ដែនបំរែបំរួលថ្លៃ

- ម៉ោងជួញដូរដំបូងនៅថ្ងៃជួញដូរដំបូងនៅផ្សារមូលបត្រកម្ពុជាក្រោយពី IPO ត្រូវនៅចន្លោះពី ៩០% ទៅ ១៥០% នៃថ្លៃ IPO (បង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មានដែលសុំការអនុញ្ញាតពីគណ:កម្មាការមូលបត្រកម្ពុជា)
- ±៥% នៃថ្លៃមូលដ្ឋានប្រចាំថ្ងៃ។ ក្នុងករណីថ្លៃមូលដ្ឋានតិចជាង ១០០០៛ ដែនបំរែបំរួលគឺ ± ១០៛
- ថ្លៃមូលដ្ឋាន គឺជាថ្លៃបិទទីផ្សារនៅថ្ងៃម្សិលមិញ ឬថ្លៃបិទផ្សារចុងក្រោយ
- ក្នុងករណីមានសិទ្ធិកម្មសិទ្ធិករមូលបត្រដូចជា ការបង្កើនឬបន្ថយមូលធន ការបែងចែកភាគលាភជាភាគហ៊ុន ការបំបែកភាគហ៊ុន។ល។ នោះថ្លៃមូលដ្ឋាននិងត្រូវបានគណនាដោយស្វ័យប្រវត្តិដោយប្រព័ន្ធរបស់ផ្សារមូលបត្រកម្ពុជា តាមរយ:ការប្រើប្រាស់នូវរូបមន្តមួយជាក់លាក់។
- ក្នុងករណីថ្លៃមូលបត្រដែលបានគណនាទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវបង្គត់ឡើងឲ្យស្មើនឹងឯកសារគម្លាតថ្លៃ។

### ៤.៥.៩. ឯកតាគម្លាតថ្លៃ និងឯកតាជួញដូរ

បំរែបំរួលឯកតាកម្លាតថ្លៃ បង្ហាញដូចខាងក្រោម៖

| ចន្លោះថ្លៃ | ឯកតាគម្លាតថ្លៃ (៛) | ដាក់តម្លៃខុស (៛) | ដាក់តម្លៃត្រូវ (៛) |
|---|---|---|---|
| ទាបជាង ៤,០០០ ៛ | ១០ | ២,៥៥៥; ៣,០១២ | ២,៥៥០ ឬ ២,៥៦០; ៣,០១០ ឬ ៣,០១០ |
| ៤,០០០ ៛≤ ថ្លៃ < ២០,០០០៛ | ២០ | ៤,២១០; ១៩,៥២៥ | ៤,២០០ ឬ ៤,២២០; ១៩,៥២០ ឬ ១៩,៥៤០ |
| ២០,០០០៛ ≤ ថ្លៃ < ៤០,០០០៛ | ៥០ | ២០,១១០; ៣៥,៥៣០ | ២០,១០០ ឬ ២០,១៥០; ៣៥,៥០០ ឬ ៣៥,៥៥០ |
| ៤០,០០០៛ ≤ ថ្លៃ < ១០០,០០០៛ | ១០០ | ៥០,៧២០; ៩០,៤៥០ | ៥០,៧០០ ឬ ៥០,៨០០; ៩០,៤០០ ឬ ៩,៥០០ |
| ១០០,០០០៛ ≤ ថ្លៃ < ២០០,០០០៛ | ២០០ | ១៥០,៥០០;១២៥,៣០០ | ១៥០,៤០០ ឬ ១៥០,៦០០; ១២៥,២០០ ឬ ១២៥,៤០០ |
| ២០០,០០០៛ ≤ ថ្លៃ< ៤០០,០០០៛ | ៥០០ | ៣០០,១០០; ៣៥០,២០០ | ៣០០,០០០ ឬ ៣០០,៥០០;៣៥០,០០០ ឬ ៣៥០,៥០០ |
| ច្រើនជាង ៤០០,០០០ ៛ | ១,០០០ | ៦២០,៥០០; ៨៥២,១០០ | ៦២០,០០០ ឬ ៦២១,០០០; ៨៥២,០០០ ឬ៨៥៣,០០០ |

**រូបភាពទី១១៖** បំរែបំរួលឯកតាគម្លាតថ្លៃ។

### ៤.៥.១០. កាលបរិច្ឆេទ អិចឌីវីដឺនដ៍ ឬអិចរាយថ៍

កាលបរិច្ឆេទ អិចឌីវីដឺនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) គឺកាលបរិច្ឆេទជួញដូរនៅរយៈកាល ០១ថ្ងៃមុនកាលបរិច្ឆេទ ប្រកាសបញ្ជីឈ្មោះភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ (Record Date)។

### ៤.៥.១១. ពន្ធលើផលចំណេញមូលធន, ការប្រាក់ និងភាគលាភ

បីឆ្នាំដំបូងរាប់ចាប់ពីផ្សារមូលបត្រផ្តើមដំណើរការ (១៨ មេសា ២០១២), រដ្ឋាភិបាលកាត់បន្ថយពន្ធ ៥០% លើពន្ធធម្មតា។

| | *ផលចំណេញមូលធន* | *ភាគលាភ* | *ការប្រាក់* |
|---|---|---|---|
| *និវាសនជន* | ពុំទាន់កំនត់ | 0% | ៧,៥% |
| *អនិវាសនជន(រស់នៅទឹកដីកម្ពុជាតិចជាង១៨២ថ្ងៃ)* | ពុំទាន់កំនត់ | ៧% | ៧% |

### ៤.៥.១២. របៀបដាក់ប្រាក់

លោកអ្នកអាចប្រើគណនីធនាគារណាក៏បានសំរាប់ផ្ទេរប្រាក់ចូលគណនីរបស់មក ភីភីអេស។ បច្ចុប្បន្នវិនិយោគិនអាចដាក់ប្រាក់សុទ្ធដោយផ្ទាល់ឬផ្ទេរចូលលេខគណនីធនាគារ ដូចខាងក្រោម៖

- ឈ្មោះគណនី Phnom Penh Securities Cash Collection AC

- ធនាគារ កាណាឌីយ៉ា
- លេខគណនី 001-001-568189
- SWIFT Code : CADI KH PP

លោកអ្នកអាចអញ្ជើញទៅធនាគារកាណាឌីយ៉ាសាខាណាក៏បាន ដើម្បីធ្វើការដាក់ប្រាក់ដោយផ្តល់ព័ត៌មានដូចជា៖

- ឈ្មោះវិនិយោគិន
- អត្តសញ្ញាណវិនិយោគិន និងលេខគណនីជួញដូរទៅកាន់បុគ្គលិកធនាគារដើម្បីសំគាល់ថានេះជាការដាក់ទឹកប្រាក់របស់លោកអ្នកសំរាប់ជួញដូរ។ (ព័ត៌មានទាំងអស់នេះមាននៅក្នុងប័ណ្ណវិនិយោគិនដែលអ្នកទទួលបានពីភីភីអេស។)

ប្រសិនបើលោកអ្នកមានគណនីនៅធនាគារ កាណាឌីយ៉ារួចហើយ សូមផ្តល់ព័ត៌មានមកឈ្មួញជើងសា ដើម្បីយើងអាចតភ្ជាប់គណនីនោះមកគណនីជួញដូររបស់ភីភីអេសតែម្តង។

### ៤.៥.១៣. របៀបដកប្រាក់

- អតិថិជនអាចផ្តល់ដំណឹងជាមុនតាមទូរស័ព្ទ ឬ Email មកកាន់ឈ្មួញជើងសា។
- បន្ទាប់មកសូមអញ្ជើញមកកាន់ភីភីអេសដើម្បីបំពេញពាក្យទំរង់សុំដកប្រាក់។ សំរាប់អតិថិជននៅក្រៅប្រទេសអាចបំពេញព័ត៌មានតម្រូវផ្សេងៗ និងផ្ញើរតាមរយៈ Email។ ដំណើរការបន្ទាប់យើងនឹងជូនដំណឹងបន្ថែមតាមរយៈ Email។
- ការបំពេញពាក្យសុំដកប្រាក់នៅ ភីភីអេស អាចប្រើរយៈពេល ០៥ ទៅ១៥នាទី។
- ជំរើស៖ អាចដកជាប្រាក់សុទ្ធ ផ្ទេរចូលគណនីធនាគារ កាណាឌីយ៉ារបស់លោកអ្នក ឬធ្វើជាមូលប្បទានបត្រចូលធនាគារផ្សេងៗដែលជាគណនីរបស់អតិថិជនផ្ទាល់។

### ៤.៥.១៤. ការទទួលបានព័ត៌មានទីផ្សារ

ជារៀងរាល់ថ្ងៃវិនិយោគិនរបស់ភីភីអេស និងទទួលបាន៖

- របាយការណ៍បិទផ្សារ និងព័ត៌មានសង្ខេបសេដ្ឋកិច្ច ពាណិជ្ជកម្មទាំងជាតិ និងអន្តរជាតិ
- ព័ត៌មានទាន់ហេតុការណ៍តាម Email និងតាមរយៈទូរស័ព្ទ

- តាមដានការប្រែប្រួលតំលៃមូលបត្រភ្លាមៗតាម Internet ឬទូរស័ព្ទដៃ Smart Phone ដូចជា iPhone, iPad, Android Operating System (ទទួលបានការប្រើប្រាស់ដោយឥតគិតថ្លៃ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៣)។
- ការបញ្ជាទិញ លក់តាមរយៈ Website (Web trading) របស់ក្រុមហ៊ុន។ (សំរាប់ព័ត៌មានលំអិត សូមមើលវិធីប្រើប្រាស់ និងទំនាក់ទំនងមកកាន់ក្រុមហ៊ុនយើងខ្ញុំ)។
- លោកអ្នកក៏អាចតាមដានព័ត៌មានមូលបត្រតាម គេហទំព័រផ្សារមូលបត្រកម្ពុជា និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

## ៤.៦. វិធីសាស្ត្រគណនាកម្រៃជើងសា

ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី ធ្វើការគិតកម្រៃជើងសាក្នុងមួយប្រតិបត្តិការចំពោះអតិថិជនរបស់ខ្លួនស្មើនឹង ០,៦៧% ដែលក្រុមហ៊ុននឹងទទួលបាន ០,៥% និង ០,១៧% ទៀតនឹងផ្តល់ឲ្យទៅផ្សារមូលបត្រកម្ពុជា និងគណៈកម្មការមូលបត្រកម្ពុជា។ កម្រៃជើងសាដែលក្រុមហ៊ុននឹងធ្វើការគិតថ្លៃពីអតិថិជនជាអប្បបរមាគឺ ៤០០០រៀល និងចំនួនហ៊ុនដែលអតិថិជនអាចជួញដូរបានជាអប្បបរមាគឺ ១ហ៊ុន។

ក្នុងនោះផងដែរ ក្នុងឆ្នាំ ២០១២ និង២០១៣ ផ្សារមូលបត្រកម្ពុជាក៏បញ្ចុះថ្លៃសេវា ៥០% របស់ខ្លួនពី ០,១៥% មក ០,០៧៥% ។ សេវាទូទាត់ផាត់ទាត់ និងចុះបញ្ជីក៏បានបញ្ចុះតំលៃសេវារបស់ខ្លួន៥០%ផងដែរ។

តារាងខាងក្រោមនេះជាតារាងកំម្រៃជើងសាបន្ទាប់ពីការបញ្ចុះតម្លៃ៖

| ប្រភេទកំរៃសេវា | យកជា % ក្នុងមួយប្រតិបត្តិការ | |
|---|---|---|
| សេវាជួញដូរ នៅ ផ.ម.ក | 0,0៧៥% | កំរៃសេវា យកដោយប្រតិបត្តិករដ៏ទៃ |
| សេវាទូទាត់ផាត់ទាត់ | 0,0២៥% | |
| សេវាចុះបញ្ជី | 0,0៥0% | |
| Compensation Fund | 0,00% | |
| សេវា គ.ម.ក | 0,0២0% | កំរៃយកដោយគ.ម.ក |
| សេវាឈ្មួញជើងសា PPS | 0,៥% ឬ *អបប្បរមា* ៤000 រៀល សំរាប់ តំលៃជួញដូរតិចជាង ៦00000 រៀល | |
| សរុបថ្លៃសេវា | *0,៦៧% ឬ អបប្បរមា ៤000 រៀល* សំរាប់ តំលៃជួញដូរតិចជាង ៦00000 រៀល | |

**រូបភាពទី១២៖** ការគណនាកម្រៃជើងសា។

## ៤.៧. ក្រមសីលធម៌វិជ្ជាជីវៈរបស់ឈ្មួញជើងសាមូលបត្រ

### ៤.៧.១. គោលការណ៍ទូទៅនៃអាជីវកម្ម

ដើម្បីឲ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាអតិបរមា និងធានាឲ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវក្នុងការជួញដូរមូលបត្រនៅលើទីផ្សារ ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណត្រូវៈ

- មានភាពសុចរិត និងធ្វើការប្រកួតប្រជែងដោយស្មោះត្រង់។
- ដំណើរការអាជីវកម្មប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់។
- យកចិត្តទុកដាក់ចំពោះការគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចការទទួលខុសត្រូវឲ្យមានប្រសិទ្ធភាពខ្ពស់ដោយការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យដែលសមស្រប។
- មានធនធានមនុស្ស និងបំពាក់ឧបករណ៍គ្រប់គ្រាន់ ព្រមទាំងមាននីតិវិធីដែលចាំបាច់សម្រាប់ធ្វើអាជីវកម្ម។
- រក្សាលក្ខខណ្ឌតម្រូវហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។
- បំពេញកាតព្វកិច្ចយ៉ាងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងប្រាក់របស់អតិថិជនឲ្យបានល្អ។
- បំពេញភារកិច្ចដោយគិតដល់ប្រយោជន៍អតិថិជនជាចម្បង។
- ផ្តល់ប្រឹក្សាវិនិយោគទៅអតិថិជនឲ្យបានត្រឹមត្រូវ។
- ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជនធ្វើការសម្រេចចិត្ត។
- ប្រុងប្រយ័ត្នកុំឲ្យមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន។
- គោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ គ.ម.ក. ។
- រក្សារការសម្ងាត់រាល់ព័ត៌មានរបស់អតិថិជន និងមិនត្រូវផ្សព្វផ្សាយដល់តតិយជនលើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមាន

សមត្ថកិច្ចពី គ.ម.ក ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អតិថិជន។

### ៤.៧.២. គណនីអតិថិជន

មុនពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ឬក្នុងនាមអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវ៖

- បំពេញកាតព្វកិច្ចតាមច្បាប់ ក្នុងការសិក្សាឲ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន និងបំពេញតាមទម្រង់សុំបើកគណនីដែលមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។
- បំពេញ និងចុះកិច្ចព្រមព្រៀងជាមួយអតិថិជន ដោយអនុលោមតាមមាត្រា៥៤នៃអនុក្រឹត្យ និងប្រការ ៦នៃប្រកាសនេះ។
- ក្រុមហ៊ុនមូលបត្រត្រូវចាត់តាំងអ្នកគ្រប់គ្រងគណនី ដើម្បីទទួលខុសត្រូវការអនុញ្ញាតឲ្យបើកគណនីថ្មី និងគ្រប់គ្រងប្រតិបត្តិការគណនី។

ដើម្បីជៀសវាងការប្រើប្រាស់គណនីអតិថិជនដោយគ្មានការអនុញ្ញាត ក្រុមហ៊ុនមូលបត្រត្រូវ៖

- មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ចំពោះការកែប្រែទិន្នន័យរបស់អតិថិជន។ ការស្នើសុំកែប្រែព័ត៌មានផ្ទាល់របស់អតិថិជន ឬសេចក្តីណែនាំលើការទូទាត់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។
- ធានាថាគ្រប់ប្រតិបត្តិការលក់ ត្រូវបានទូទាត់ទៅឲ្យអតិថិជនជាអ្នកលក់ដោយមិនត្រូវទូទាត់ឲ្យបុគ្គលណាផ្សេងទេ លើកលែងតែមានការអនុញ្ញាតដែលមានចែងក្នុងប្រការ៩៩នៃប្រកាសនេះ។

### ៤.៧.៣. ការផ្តល់ប្រឹក្សាវិនិយោគ

ការផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជនត្រូវ៖

- ធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល។
- ធ្វើឡើងដោយផ្អែកលើព័ត៌មានដែលផ្តល់ដោយអតិថិជន ហើយត្រូវមានហេតុផលជាមូលដ្ឋានឆ្លុះ។
- មុនពេលផ្តល់ប្រឹក្សាវិនិយោគ ក្រុមហ៊ុនទទួលបានអជ្ញាបណ្ណ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវគោរពតាមគោលការណ៍ ស្គាល់អតិថិជនរបស់ខ្លួន(Know-Your-Client)

ដោយស្វែងយល់អតិថិជនតាមរយៈការពិគ្រោះយោបល់ដោយផ្ទាល់ និងតាមទម្រង់ពាក្យស្នើសុំការផ្តល់ប្រឹក្សាវិនិយោគ ដើម្បីទទួលបានព័ត៌មានអតិថិជនដូចខាងក្រោម៖

- ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីត្រូវការរបស់អតិថិជន
- គោលដៅវិនិយោគរបស់អតិថិជន
- ឥរិយាបទអតិថិជនបំពោះហានិភ័យដែលអាចកើតមាន និង
- បទពិសោធន៍ និងចំណេះដឹងនៃការវិនិយោគរបស់អតិថិជន។

### ៤.៧.៤. ការជៀសវាងទំនាស់ផលប្រយោជន៍ទាក់ទងនឹងការផ្តល់ប្រឹក្សាវិនិយោគ

ក្រុមហ៊ុនទទួលអាជ្ញាបណ្ណត្រូវធានាថាក្រុមហ៊ុនផ្ទាល់ និងភ្នាក់ងាររបស់ខ្លួន៖

- ត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវទំនាស់ផលជាសក្តានុពលរបស់ខ្លួនដែលអាចជះឥទ្ធិពលដល់ការផ្តល់ប្រឹក្សាវិនិយោគមិនលំអៀង មុនផ្តល់ប្រឹក្សាដល់អតិថិជននោះ។
- ត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរ មុននឹងផ្តល់ប្រឹក្សាវិនិយោគអំពីអត្ថប្រយោជន៍ដែលពាក់ព័ន្ធនឹងថ្លៃ ឬការជួញដូរមូលបត្រណាមួយដែលក្រុមហ៊ុនបានទទួលដោយសារហេតុផលពិសេសដូចខាងក្រោម៖
  - កំពុងផ្តល់ ឬនឹងផ្តល់សេវាកម្មធានាទិញមូលបត្រដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលដែលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។
  - កំពុងផ្តល់ ឬនឹងផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងការរួមបញ្ចូល និងការទិញដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលដែលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។
  - កាន់កាប់មូលបត្រច្រើនជាង ០១ ភាគរយនៃក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។
  - កំពុងជួញដូរ ឬនឹងជួញដូរមូលបត្រនោះដោយខ្លួនឯងផ្ទាល់។
- មិនត្រូវទទួលផលប្រយោជន៍សេដ្ឋកិច្ច ឬផលប្រយោជន៍ផ្សេងទៀតពីក្រុមហ៊ុនដែលបោះផ្សាយមូលបត្រពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សាវិនិយោគ ឬបុគ្គលដែលពាក់ព័ន្ធនឹង

ក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ លើកលែងតែមានការជូនដំណឹងជាមុនពីផលប្រយោជន៍នោះដល់អតិថិជន។

### ៤.៧.៥. ការហាមឃាត់លើការជំរុញឲ្យធ្វើឲ្យការជួញដូរច្រើនហួសហេតុ

ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវជំរុញឲ្យអតិថិជនជួញដូរមូលបត្រច្រើនហួសហេតុពីភាពចាំបាច់ដែលសមល្មមសម្រាប់ផលប្រយោជន៍អតិថិជន ដោយគិតលើកត្តាមួយចំនួនដូចខាងក្រោម៖

- កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗដែលបង់ដោយអតិថិជន។
- គោលដៅវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ សេចក្តីត្រូវការ និងស្ថានភាពជាក់ស្តែងរបស់អតិថិជន។
- កម្រិតនៃការយល់ដឹងរបស់អតិថិជនលើហានិភ័យដែលអាចកើតមានឡើង ចំពោះការជួញដូរមូលបត្រដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍វិនិយោគរបស់អតិថិជន។
- សុពលភាពនៃការផ្តល់ប្រឹក្សាចំពោះការជួញដូរនីមួយៗ។

### ៤.៧.៦. ការអនុវត្តការជួញដូរមូលបត្រ

#### ៤.៧.៦.១. បញ្ជាទិញ-លក់

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវអនុវត្តបញ្ជាទិញ-លក់ពីអតិថិជនឲ្យបានត្រឹមត្រូវទាន់ពេលវេលា និងមិនលំអៀង។ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រអាចអនុវត្តបញ្ជាទិញ-លក់របស់អតិថិជន ក្នុងនាមអតិថិជនបានលុះត្រាតែ៖

- ទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជនដើម្បីអនុវត្តប្រតិបត្តិការជួញដូរ
- អតិថិជនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរក្នុងករណីជាបញ្ជាទិញ
- អតិថិជនត្រូវមានមូលបត្រគ្រប់គ្រាន់សម្រាប់ការទូទាត់ ក្នុងករណីជាបញ្ជាលក់ត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ឬថតសម្លេងតាមប្រព័ន្ធអេឡិកត្រូនិច។

#### ៤.៧.៦.២. បញ្ជាតាមប្រព័ន្ធអេឡិកត្រូនិច ឬតាមមធ្យោបាយផ្សេងទៀត

នៅពេលទទួលបញ្ជាតាមប្រព័ន្ធអេឡិកត្រូនិចតាមសម្លេង ឬជាសារអេឡិកត្រូនិច ឬតាមមធ្យោបាយផ្សេងទៀត ក្រុមហ៊ុនត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមទាំងអស់ដូចខាងក្រោម៖

- ត្រូវឲ្យអតិថិជនយល់ដឹងនូវការបញ្ជា និងការអនុវត្តបញ្ជាតាមមធ្យោបាយបញ្ជានីមួយៗ
- ធ្វើការបញ្ជាក់ឲ្យច្បាស់លាស់ថា បុគ្គលដែលបញ្ជានោះពិតជាមានសិទ្ធិក្នុងការបញ្ជា។

**៤.៧.៦.៣. បុគ្គលដែលមានសិទ្ធិបញ្ជា**

ក្រុមហ៊ុនទទួលបញ្ជាតែពីបុគ្គលដែលមានសិទ្ធិដូចខាងក្រោម៖

- អតិថិជនជាម្ចាស់គណនី
- អ្នកតំណាងដែលអតិថិជនបានជ្រើសរើសជាលាយលក្ខណ៍អក្សរនៅពេលបើគណនី ឬនៅពេលបន្ទាប់
- បុគ្គលដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការបញ្ជាតាមលិខិតផ្ទេរសិទ្ធិ។

**៤.៧.៦.៤. ការហាមឃាត់ការទទួលបញ្ជាដែលផ្ទុយនឹងច្បាប់**

ក្រុមហ៊ុនមិនត្រូវទទួលបញ្ជាដូចខាងក្រោម៖

- ការជួញដូររបស់អតិថិជនល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- អតិថិជនមិនអាចទូទាត់ការជួញដូរបាន
- អតិថិជនមិនមានបំណងជួញដូរពិតប្រាកដ។

**៤.៧.៦.៥. ការអនុវត្តប្រសើរបំផុត**

ក្រុមហ៊ុនមូលបត្រត្រូវធ្វើការដោយប្រឹងប្រែង និងប្រុងប្រយ័ត្នដើម្បីទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់បញ្ជារបស់អតិថិជន។ ដើម្បីឲ្យទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់អតិថិជនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រត្រូវពិចារណាលើកត្តាដូចខាងក្រោម៖

- ថ្លៃ និងបរិមាណនៃការលក់ចុងក្រោយ និងការជួញដូរពីមុន
- ទិសដៅឡើងចុះនៃទីផ្សារចំពោះមូលបត្រនោះ
- ទំហំនៃសំណើទិញ និងសំណើលក់
- ទំហំនៃគំលាត និង
- សន្ទនីយភាពនៃមូលបត្រនោះ។

នៅពេលក្រុមហ៊ុនមូលបត្រទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនត្រូវបញ្ជូនបញ្ជានោះទៅកាន់ទីផ្សារតាមលក្ខខណ្ឌនៃបញ្ជាភ្លាម និងមិនត្រូវបង្អបញ្ជា ដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ឬដាក់ បញ្ជាជាកញ្ចប់។

**៤.៧.៦.៦. ការហាមឃាត់ការជួញដូរមុន**

មុនពេលអនុវត្តបញ្ជារបស់អតិថិជន ចំពោះការទិញលក់មូលបត្រដែលរំពឹងថាមានផលប៉ះពាល់លើថ្លៃទីផ្សារនៃមូលបត្រនោះ ក្រុមហ៊ុនទទួលបញ្ជាពីអតិថិជនមិនត្រូវ៖

- បញ្ជូនបញ្ជាក្នុងគណនីក្រុមហ៊ុន ឬបញ្ជាមិនមែនអតិថិជនទៅក្នុងទីផ្សារចំពោះការទិញ-លក់មូលបត្រពាក់ព័ន្ធនោះ
- បញ្ចុះបញ្ចូលបុគ្គលផ្សេងទៀតឲ្យបញ្ជាទិញ-លក់មូលបត្រពាក់ព័ន្ធនោះ
- ផ្តល់ដំណឹងពីបញ្ជារបស់អតិថិជន ទៅឲ្យបុគ្គលផ្សេងទៀតដែលមិនពាក់ព័ន្ធជាចំបាច់ជាមួយនឹងដំណើរការអាជីវកម្ម និងគោរពតាមលក្ខខណ្ឌតម្រូវទាក់ទងនឹងការរក្សាការសម្ងាត់របស់អតិថិជន។

**៤.៧.៦.៧. អតិភាពរបស់អតិថិជន**

- ក្រុមហ៊ុនមូលបត្រត្រូវផ្តល់អទិភាពដល់បញ្ជាក្នុងគណនីអតិថិជន មុនបញ្ជាផ្សេងទៀតចំពោះមូលបត្រដូចគ្នា និងថ្លៃដូចគ្នា
- នៅពេលដែលអតិថិជនបញ្ជាទិញមូលបត្រ ក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ជាទិញមូល-បត្រ នោះដោយប្រើគណនីផ្ទាល់របស់ក្រុមហ៊ុន ឬគណនីមិនមែនអតិថិជនក្នុងថ្លៃដូចឬទាបជាង មុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត
- នៅពេលដែលអតិថិជនបញ្ជាលក់មូលបត្រ ក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ជាលក់មូល-បត្រ នោះដោយប្រើគណនីផ្ទាល់របស់ក្រុមហ៊ុន ឬគណនីមិនមែនអតិថិជនក្នុងថ្លៃដូចឬខ្ពស់ ជាងមុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត
- នៅពេលក្រុមហ៊ុនមូលបត្រជួញដូរមូលបត្រជាមួយអតិថិជនជាគូភាគី ក្រុមហ៊ុនមិនត្រូវផ្តល់លក្ខខណ្ឌជួញដូរមិនសមហេតុផលទៅកាន់អតិថិជន ដោយមិនបានដឹងពីស្ថានភាពទីផ្សារ និងចំណាយការជួញដូររបស់អតិថិជន។

**៤.៧.៧. ការផ្តល់ព័ត៍មានទៅកាន់អតិថិជន**

- ក្រុមហ៊ុនមូលបត្រត្រូវផ្តល់ព័តិមានជាលាយលក្ខណ៍អក្សរ ទៅកាន់អតិថិជនមុននឹងអនុវត្តការជួញដូរមូលបត្ររបស់អតិថិជន៖
  - សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ

- កម្រៃជើងសា និងពន្ធដែលត្រូវបង់ព្រមទាំងវិធីសាស្ត្រគណនា
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍

- ក្រុមហ៊ុនមូលបត្រ មិនត្រូវផ្តល់ព័ត៌មានប្រាសចាកពីការពិត ឬបំផ្លើសអំពីដំណើរការវិនិយោគ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់យុទ្ធសាស្ត្រនៃការជួញដូរវិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរដែលអាចនាំឲ្យអតិថិជនយល់ខុស
- នៅពេលការបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនឲ្យបានឆាប់បំផុតនៅថ្ងៃធ្វើប្រតិបត្តិការទាំងនោះ។ ក្រុមហ៊ុនត្រូវមានការព្រមព្រៀងជាមួយអតិថិជនជាមុនអំពីវិធីសាស្ត្រនៃការជូនដំណឹង
- ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជនអំពីរបាយការណ៍ ប្រតិបត្តិការប្រចាំខែក្នុងរយៈពេល០៧ថ្ងៃនៃថ្ងៃធ្វើការនៃខែបន្ទាប់។ សម្រាប់គណនីដែលគ្មានសកម្មភាពជួញដូរ ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននូវរបាយការណ៍គណនីយ៉ាងហោចមួយដងរៀងរាល់ ០៦ខែ។

### ៤.៧.៨. អាកប្បកិរិយាដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម

#### ៤.៧.៨.១. ការហាមឃាត់ចំពោះភ្នាក់ងារដែលមិនមានអាជ្ញាបណ្ណ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ មិនត្រូវអនុញ្ញាតឲ្យបុគ្គលណាមួយធ្វើជាភ្នាក់ងារក្នុងនាមក្រុមហ៊ុនឡើយ លើកលែងតែបុគ្គលនោះបំពេញតាមលក្ខខណ្ឌ៖

- បានទទួលអាជ្ញាបណ្ណជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ
- បានប្រឡងបញ្ចប់វគ្គសិក្សាជំនាញវិជ្ជាជីវៈមូលបត្រ
- និងមិនមែនជាភ្នាក់ងារនៃក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគដទៃទៀត។

#### ៤.៧.៨.២. ការធានាទិញមូលបត្រ និងការសម្ងាត់នៃព័ត៌មាន

- ក្រុមហ៊ុនមូលបត្រមិនត្រូវយកព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួន ឬណែនាំតតិយជនឲ្យជួញដូរមូលបត្រទាំងនោះឡើយ
- នៅពេលដែលក្រុមហ៊ុនមូលបត្រ ទទួលបានអាជ្ញាបណ្ណសម្រាប់ធ្វើអាជីវកម្មធានាទិញមូលបត្រព្រមទាំងអាជីវកម្មមូលបត្រផ្សេងទៀត ក្រុមហ៊ុនត្រូវបែងចែកផ្នែកនីមួយៗឲ្យ

ដាច់ដោយឡែកពីគ្នាស្របតាមប្រភេទអាជីវកម្ម ដើម្បីបែងចែកការទទួលខុសត្រូវច្បាស់លាស់ ប្រយោជន៍នានាឲ្យបានថាព័ត៌មានសម្ងាត់មិនត្រូវបានបែងចែករំលែករវាងផ្នែកនីមួយៗ

- នៅពេលផ្នែកធានាទិញមូលបត្រ នៃក្រុមហ៊ុនមូលបត្របានធ្វើការធានាទិញមូលបត្រ ផ្នែកផ្តល់ប្រឹក្សាវិនិយោគមិនត្រូវផ្តល់ប្រឹក្សាឲ្យជួញដូរមូលបត្រនោះទេ ក្នុងកំឡុងពេលចាប់ពីចុះកិច្ចសន្យាធានាទិញមូលបត្រជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ រហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចសន្យាធានាទិញ
- បុគ្គលដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយមិនត្រូវកាន់កាប់តំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬកាន់កាប់ភាគហ៊ុនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយផ្សេងទៀត។

**៤.៧.៨.៣. ការហាមឃាត់ការទូទាត់សងលើការខាតបង់**

ទោះបីដោយផ្ទាល់ឬដោយប្រយោលក្តីក្រុមហ៊ុនមូលបត្រនិងភ្នាក់ងាររបស់ខ្លួនមិនត្រូវ៖

- ផ្តល់ដល់អតិថិជននូវការធានាប្រាក់ចំណេញអប្បបរមា ដែលពាក់ព័ន្ធនឹងការវិនិយោគមូលបត្រ ឬជួញដូរមូលបត្រ
- ឬទូទាត់សងទាំងអស់ឬមួយផ្នែកនៃការខាតបង់ដែលកើតឡើងដោយសារការវិនិយោគមូលបត្ររបស់អតិថិជនតាមគ្រប់រូបភាពណាក៏ដោយ រាប់បញ្ចូលទាំងការផ្តល់ជាប្រាក់ ឬការបញ្ចុះកម្រៃជើងសា ឬថ្លៃសេវា ឬការអនុវត្តប្រតិបត្តិការមូលបត្រណាមួយ។

**៤.៧.៨.៤. ការហាមឃាត់លើការផ្តល់ឲ្យនិងការទទួលអំណោយ និងអត្ថប្រយោជន៍ផ្សេងៗ**

ក្រុមហ៊ុនទទួលអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្តល់ឲ្យ ឬទទួលគ្រឿងលើកទឹកចិត្ត អំណោយ ឬអត្ថប្រយោជន៍ផ្សេងៗទៅ ឬពីអតិថិជនសក្តានុពលលើកលែងតែក្នុងករណីដូចខាងក្រោម៖

- អត្ថប្រយោជន៍ដែលបាននោះមិនប៉ះពាល់ដល់ឯករាជ្យភាពរបស់អ្នកទទួល

- អត្ថប្រយោជន៍នោះត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដោយបុគ្គលិកជំនាញផ្នែកច្បាប់មុនពេលទទួល ឬផ្តល់ឲ្យ។

**៤.៨. ការជួញដូរតាម** Online.

ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី ជាក្រុមហ៊ុនដំបូងគេដែលផ្តល់ឲ្យអតិថិជននូវភាពងាយស្រួលតាមរយៈការជួញដូរ Online។ ដើម្បីជួញដូរ Online អតិថិជនត្រូវអនុវត្តតាម៤ជំហានដូចខាងក្រោម៖

**ជំហានទី១៖** អតិថិជនត្រូវទាញយក កិច្ចព្រមព្រៀង ដើម្បីយល់ពីលក្ខខណ្ឌផ្សេងៗក្នុងការប្រើប្រាស់សេវាកម្ម។ បន្ទាប់មក អតិថិជន ត្រូវអញ្ជើញមកកាន់ក្រុមហ៊ុន ដើម្បីចុះហត្ថលេខា ឬផ្ញើ E-mail មកកាន់ឈ្មួញជើងសាររបស់អ្នក ឬផ្ញើមកកាន់ info@pps.com.kh ដោយបញ្ជាក់ថា៖

- បាទ/នាងខ្ញុំ នាមត្រកូលជាមួយអត្តសញ្ញាណវិនិយោគិន D12345678901 និងលេខគណនីជួញដូរ 001111 បានអាន និងយល់កិច្ចព្រមព្រៀងនេះ។
- ដូច្នេះ ខ្ញុំបាទ/នាងខ្ញុំ យល់ស្របក្នុងការប្រើប្រាស់សេវានេះរបស់ក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី ភីអិលស៊ី។

**ជំហានទី២៖** ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី និងផ្ញើ Web link និងលេខសំងាត់បណ្តោះអាសន្នទៅកាន់អតិថិជន។

**ជំហានទី៣៖** អតិថិជនត្រូវចូលទៅកាន់ E-mail របស់អ្នក បន្ទាប់មកចុច link ដែលបានផ្ញើឲ្យដើម្បីផ្លាស់ប្តូរលេខសំងាត់។ ឧទាហរណ៍ លេខសំងាត់យ៉ាងតិច៦ខ្ទង់ដោយលាយ អក្សរតូច ធំ លេខ និងសញ្ញាពិសេស (ឧ: Pps01@)។

**ជំហានទី៤៖** អតិថិជនត្រូវចូលទៅកាន់វែបសាយ PPS ហើយជ្រើសរើស *ជួញដូរតាមរយៈអ៊ិនធឺណេត*

1. បញ្ចូលលេខគណនី ឬអ៊ីម៉ែល ឬ Investor ID
2. បញ្ចូលលេខសំងាត់ផ្ទាល់ខ្លួន
3. Log In

## ៤.៩. ការវិភាគ SWOT

ក្រោយពីបានចុះធ្វើកម្មសិក្សាស្រាវជ្រាវនៅក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី អស់រយៈពេលពីរខែ ក្រោមប្រធានបទ សេវាកម្មទិញ លក់មូលបត្ររបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី រួចមកក្រុមយើងខ្ញុំសង្កេតឃើញថា ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី មានចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងដូចខាងក្រោម៖

❖ **ចំណុចខ្លាំង**

- ជាក្រុមហ៊ុនមូលបត្រដែលបានបង្កើតឡើងមុនគេបង្អស់នៅកម្ពុជា ក្នុងឆ្នាំ២០០៩ ដែលផ្តល់សេវាកម្មពេញលេញដល់អតិថិជន ទាក់ទងនិងវិស័យមូលបត្រដូចជា៖ សេវាធនាទិញមូលបត្រ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសាមូលបត្រ និងផ្តល់ប្រឹក្សាវិនិយោគ។
- ជាក្រុមហ៊ុនដែលមានបទពិសោធន៍ និងការយល់ដឹងយ៉ាងច្រើនពីទីផ្សារមូលបត្រ។
- បុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី សុទ្ធតែទទួលបានអាជ្ញាប័ណ្ណ និងការហ្វឹកហ្វឺនពីអន្តរជាតិ។
- បុគ្គលិកមានភាពរួសរាយរាក់ទាក់ និងមានក្រមសីលធម៌ យកចិត្តទុកដាក់ចំពោះអតិថិជន។
- មានទំនាក់ទំនងល្អជាមួយនិងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនិងអាជីវកម្ម។
- ទទួលបានទំនុកចិត្តពីអតិថិជនទាំងក្នុង និងក្រៅស្រុក។
- មានសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗដែលទាក់ទងនិងចំណេះដឹងក្នុងវិស័យមូលបត្រដល់អតិថិជន។
- មានកម្មវិធីជួញ ដូរតាមប្រព័ន្ធអ៊ីនធឺណែតដំបូងគេនៅកម្ពុជា (PPS iTrader) ដែលបង្កភាពកាន់តែងាយស្រួលដល់អតិថិជន។

❖ **ចំណុចខ្សោយ**

- PPS iTrader ពេលខ្លះដំណើរការមិនសូវល្អ ធ្វើឲ្យអតិថិជនពិបាក Log in។
- ការផ្តល់ព័ត៌មានទៅកាន់អតិថិជននៅមានកម្រិត។
- ដំណើរការនៃការបើកគណនីជូនអតិថិជនចំណាយពេលយូរ។

❖ **ឱកាស**

- មានដើមទុនច្រើនសំរាប់ពង្រីកទំហំអាជីវកម្មរបស់ខ្លួន។

- មានបច្ចេកទេសទំនើបៗក្នុងការប្រកួតប្រជែង។
- ជាក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនជាច្រើន និងអតិថិជនសក្តានុពល។
- មានជំនាញច្បាស់លាស់ក្នុងការផ្តល់សេវាដល់អតិថិជន និងមានអតិថិជនស្គាល់ច្រើន។

❖ **ការគំរាមកំហែង**

- ទទួលការគំរាមកំហែងនៅពេលដែលស្ថានភាពនយោបាយ និងស្ថានភាពសេដ្ឋកិច្ចមានការប្រែប្រួល។
- មានការប្រកួតប្រជែងជាមួយក្រុមហ៊ុនដទៃ ដែលធ្វើអាជីវកម្មដូចគ្នា។
- វិនិយោគិនមួយចំនួនធំ មិនទាន់មានការជ្រាបច្បាស់ពីវិស័យមូលបត្រនៅឡើយទេ
- ទីផ្សារមូលបត្រកម្ពុជា មិនទាន់មានសន្ទនីយភាព។

# សេចក្ដីសន្និដ្ឋាន និង
# អនុសាសន៍

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីទទួលការអនុញ្ញាតឲ្យចុះកម្មសិក្សានៅក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី អស់រយៈពេលពីរខែរួចមក ជាលទ្ធផលក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍ជាច្រើនទាក់ទងនឹងវិស័យមូលបត្រ ជាពិសេសគឺដំណើរការក្នុងទិញ-លក់មូលត្រតែម្តង។ ប្រតិបត្តិការក្នុងការទិញ-លក់មូលបត្រគឺជាចំណុចស្នូលមួយ ដែលនាំឲ្យកើតមានដំណើរការជួញដូរមូលបត្រ។ ប្រសិនបើវិនិយោគិនមិនបានយល់ច្បាស់ពីដំណើរការជួញដូរមូលបត្រ នោះពួកគេមិនអាចធ្វើការជួញដូរមូលបត្របានឡើយ។ ដំណើរការនៃការទិញ-លក់មូលបត្រមានលក្ខណៈខុសប្លែកពីការទិញលក់ទំនិញដទៃ ព្រោះទាមទារឲ្យឆ្លងកាត់ឈ្មួញជើងសាមូលបត្រ ដោយមិនអាចទិញដោយខ្លួនឯងផ្ទាល់បានទេ។ ប្រតិបត្តិការទីផ្សារមូលបត្រកម្ពុជាបានធ្វើឡើងនៅលើទីផ្សារដំបូង និងទីផ្សារបន្ទាប់។ ទីផ្សារដំបូង ជាជំហ៊ានដំបូងនៃដំណើរការបោះផ្សាយលក់មូលបត្រ របស់ក្រុមហ៊ុនបោះផ្សាយដោយមានការចូលរួមពីក្រុមហ៊ុនធានាទិញ និងក្រុមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ក្នុងនោះមានដូចជាក្រុមហ៊ុនគណនេយ្យ ជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម ដើម្បីរៀបចំឯកសារស្នើសុំការអនុញ្ញាតបោះផ្សាយពីគណៈកម្មការមូលបត្រកម្ពុជា។ បន្ទាប់ពីទទួលជោគជ័យក្នុងការបោះផ្សាយលក់មូលបត្រជាលើកដំបូងមក មូលបត្រត្រូវបានលក់ទៅកាន់ទីផ្សារបន្ទាប់។

ដំណើរការក្នុងការទិញ ឬលក់មូលបត្រនៅទីផ្សារបន្ទាប់ត្រូវឆ្លងកាត់ដំណាក់មួយចំនួន។ ជំហ៊ានដំបូងវិនិយោគិនដែលមានបំណងចង់ទិញមូលបត្រ ត្រូវជ្រើសរើសក្រុមហ៊ុនមូលបត្រមួយដែលខ្លួនចង់ធ្វើការវិនិយោគ។ បន្ទាប់មកវិនិយោគិន តម្រូវឲ្យមានអត្តសញ្ញាណវិនិយោគិនមួយដើម្បីមានសិទ្ធិក្នុងការជួញដូរ។ តាមរយៈក្រុមហ៊ុនភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី អតិថិជន មិនចាំបាច់ស្មុគស្មាញនិងបញ្ហានេះនោះទេ ព្រោះថាក្រុមហ៊ុនជាអ្នករៀបចំបើកគណនីជូនអតិថិជនដោយគ្រាន់តែតម្រូវឲ្យអតិថិជនផ្តល់ជូនក្រុមហ៊ុននូវ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, រូបថត ៤x៦ ចំនួន២សន្លឹក, លេខគណនីធនាគារ (ធនាគារណាក៏បាន), និងថវិកាចំនួន២០០០០រៀលសម្រាប់អតិថិជនជារូបវន្តបុគ្គល។ ចំណែកឯអតិថិជនជានីតិបុគ្គលវិញ ក្រុមហ៊ុនតម្រូវឲ្យមាន បណ្ណប៉ាតង់ ឬអាជ្ញាបណ្ណ, អត្តសញ្ញាណបណ្ណខ្មែរអ្នកតំណាង, រូបថត ៤x៦ របស់អ្នកតំណាងចំនួន២សន្លឹក , វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គល, បញ្ជីឈ្មោះអភិបាលសាជីវកម្ម, បញ្ជីឈ្មោះអ្នកមានសិទ្ធិ ឬអ្នកចូលរួមសំរេចចិត្តវិនិយោគ, លិខិតផ្ទេរសិទ្ធិ និងលិខិតផ្សេងៗទៀត។ ការស្នើសុំអត្តសញ្ញាណ

វិនិយោគិនត្រូវចំណាយពេលប្រាំថ្ងៃ បន្ទាប់ពីទទួលបានអត្តសញ្ញាណវិនិយោគិន អតិថិជនអាចធ្វើការទិញ-លក់មូលបត្រតាមរយៈក្រុមហ៊ុនបានតែម្តង។ ចំពោះម៉ោងជួញដូរមូលបត្រវិញក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី ចាប់ផ្តើមជួញដូរទៅតាមពេលវេលាកំណត់របស់ផ្សារមូលបត្រកម្ពុជា គឺចាប់ផ្តើមនូវម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ១១:៣០ព្រឹក។ វិធីសាស្ត្រនៃការដេញថ្លៃមានពីរប្រភេទគឺ វគ្គជួញដូរដោយប្រើវិធីសាស្ត្រដេញថ្លៃដោយថ្លៃតែមួយ (Single-Price-Auction) វគ្គបើកចាប់ផ្តើមពីម៉ោង ៨:០០ព្រឹក រហូតដល់ម៉ោង ០៩:០០ព្រឹក ដែលការជួញដូរត្រូវអនុវត្តនៅម៉ោង ០៩:០០ព្រឹក និងវគ្គបិទចាប់ផ្តើមពីម៉ោង ១១:០០ព្រឹក រហូតដល់ម៉ោង ១១:៣០ព្រឹក ដែលការជួញដូរត្រូវអនុវត្តនៅម៉ោង ១១:៣០ព្រឹក។ មួយទៀតគឺ វគ្គជួញដូរដោយប្រើវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple-Price-Auction) ឬវគ្គជួញដូរនិរន្តរ៍ (Continuos Trading) ចាប់ផ្តើមពីម៉ោង ០៩:០០ព្រឹក ដល់ម៉ោង ១១:០០ ព្រឹកហើយការអនុវត្តការជួញដូរត្រូវធ្វើឡើងភ្លាមៗនៅពេលអាចផ្គូផ្គងបាន។ វិនិយោគិនអាចធ្វើការជួញដូរមូលបត្របានចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាក់ជាសាធារណៈតែប៉ុណ្ណោះ ចំណែកឯរូបិយប័ណ្ណសម្រាប់ជួញដូរមូលបត្រនៅក្នុងផ្សារមូលបត្រកម្ពុជាគឺ ខ្មែររៀល។ មួយវិញទៀត ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី គិតកម្រៃជើងសាក្នុងការទិញ-លក់មូលបត្រពីអតិថិជនចំនួន ០.៦៧% ក្នុងមួយលើក ឬតិចបំផុត ៤០០០រៀល ហើយអតិថិជនអាចមានសិទ្ធិធ្វើការជួញដូរមូលបត្រចាប់ពី ១ហ៊ុន។

សរុបសេចក្តីមក ក្រុមយើងខ្ញុំសង្កេតឃើញថា ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី ជាក្រុមហ៊ុនមួយដែលមានវិជ្ជាជីវៈស៊ីជម្រៅលើវិស័យមូលបត្រ ដែលតែងមានអតិថិជនធ្វើការជួញដូរជារៀងរាល់ថ្ងៃ។ ចំណែកឯប្រតិបត្តិការទិញ-លក់មូលបត្រវិញគឺមានលក្ខណៈងាយស្រួល ព្រោះថាក្រុមហ៊ុនបានផ្តល់នូវសេវាកម្មយ៉ាងសំបូរបែបដល់អតិថិជន ក៏ដូចជាយកចិត្តទុកដាក់គោរពតាមក្រមសីលធម៌វិជ្ជាជីវៈការងារបានយ៉ាងខ្ជាប់ខ្ជួន។

## ២. អនុសាសន៍

ដើម្បីជំរុញឲ្យការជួញដូរមូលបត្រនៅក្នុងក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី កាន់តែមានដំណើរការទៅមុខប្រកបដោយភាពជោគជ័យ និងរលូន ក៏ដូចជាទាក់ទាញអតិថិជនបន្ថែមទៀតនោះ ក្រុមរបស់យើងខ្ញុំសូមចូលរួមផ្តល់នូវមតិយោបល់មួយចំនួនដូចខាងក្រោមៈ

- ក្រុមហ៊ុនគួររិះរកវិធីសាស្ត្រក្នុងការបង្កលក្ខណៈងាយស្រួល ឆាប់រហ័ស និងសុវត្ថិភាពដល់វិនិយោគិនក្នុងដំណើរការទិញ-លក់មូលបត្រ ព្រមទាំងកែសម្រួលកម្មវិធី PPS iTrader ឲ្យមានដំណើរការកាន់តែល្អប្រសើរសម្រាប់អតិថិជនធ្វើការប្រើប្រាស់។
- ក្រុមហ៊ុនគួរតែបង្កើនការផ្តល់ព័ត៌មានដែលមានការទាក់ទងនឹងភាគហ៊ុន ទៅកាន់អតិថិជនឲ្យបានឆាប់រហ័ស ព្រោះថាព័ត៌មានទាំងនោះមានសារៈសំខាន់សម្រាប់អតិថិជនក្នុងការសំរេចចិត្តទិញ និងលក់ភាគហ៊ុន។
- ក្រុមហ៊ុនគួរតែជំរុញឲ្យប្រតិបត្តិការនៃការបើកគណនីមានដំណើរកាន់តែលឿន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងបញ្ញត្តិផ្សេងៗទាក់ទងនឹងវិស័យមូលបត្រ

- ច្បាប់ស្តីពី ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧
- ប្រកាសស្តីពី ការទទួលស្គាល់ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ លេខ០០៩/១០ គ.ម.ក/ប្រ.ក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០
- ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ លេខ០០៩ គ.ម.ក. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩
- ប្រកាសស្តីពី ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យមូលបត្រ លេខ ០១២/១០ គ.ម.ក. ប្រ.ក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០
- ប្រកាសស្តីពី ក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ លេខ០០៨/១១ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១
- គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង លេខ០០១ គ.ម.ក/គ.ណ.ន ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១១
- គោលការណ៍ណែនាំស្តីពី យន្តការនៃការទទួលបញ្ជាជួញដូរមូលបត្រ លេខ១៥២ គ.ម.ក/គ.ណ.ន. ចុះថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៤

## សៀវភៅ និងអត្ថបទសិក្សាស្រាវជ្រាវផ្សេងៗ


- បៀន សាំង. *មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ.* ភ្នំពេញ៖ បណ្ណាគារសន្តិភាព, ២០១១។
- អ៊ឹង អ៊ូ. *គុណសម្បត្តិ និងគុណវិបត្តិនៃទីផ្សារមូលបត្រដល់សេដ្ឋកិច្ច.* ភ្នំពេញ, ២០១២។
- សៀវ សុស៊ីខា. *ទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ.* ភ្នំពេញ, ២០១៧។
- សៀវ សុស៊ីខា. *កិច្ចដំណើរការអភិវឌ្ឍទីផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា.* ភ្នំពេញ, ២០១៧។

**សិក្ខាសាលា និងបទបង្ហាញទាក់ទងវិស័យមូលបត្រ**

- សន្ទរកថារបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងពិធីសម្ពោធក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (១១ កក្កដា ២០១១)។

**ឯកសារផ្សេងៗ**

- ឯកសារផ្តល់ព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងសេវាកម្មរបស់ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។

**គេហទំព័រ**

- គេហទំព័រ គណៈកម្មការមូលបត្រកម្ពុជា
  www.secc.gov.kh
- គេហទំព័រ ផ្សារមូលបត្រកម្ពុជា
  www.csx.com.kh
- គេហទំព័រ ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី
  www.pps.com.kh
- Investopedia. *Bond*.
  Retrieved from http://www.investopedia.com/terms/b/bond.asp
- Investopedia. (March 31, 2015). *What the difference between a treasury bond and a treasury note and a treasury bill ( T-bill)?*.
  Retrieved from http://www.investopedia.com/ask/answers/033115/what-are-differences-between-treasury-bond-and-treasury-note-and-treasury-bill-tbill.asp
- Investopedia. *Municipal Bond*.
  Retrieved from http://www.investopedia.com/terms/m/municipalbond.asp
- Fidelity. *Corporate Bond.*
  Retrieved from https://www.fidelity.com/fixed-income-bonds/individual-bonds/corporate-bonds/overview
- Investopedia. *Repurchase Agreement*.
  Retrieved from http://www.investopedia.com/video/play/repurchase-agreement/
- Investopedia. *Commercial Papers*.
  Retrieved from http://www.investopedia.com/video/play/commercial-paper/
- Nerdwallet. (February 24, 2017). *What Is a CD (Certificate of Deposit)?*.
  Retrieved from https://www.nerdwallet.com/blog/banking/cd-certificate-of-deposit/
- ZACKS. *Types of Derivative Securities.*
  Retrieved from http://finance.zacks.com/types-derivative-securities-4362.html

- Laura Bramble. *How the Stock Market Was Started & by Whom.* Retrieved from http://smallbusiness.chron.com/stock-market-started-whom-14745.html
- Investopedia. ( 2017, March). *A Look At Primary And Secondary Markets.* Retrieved from http://www.investopedia.com/articles/02/101102.asp#ixzz4cdJbnSYZ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ:.......១៥២.........គ.ម.ក/ភ.ណ.ទ.

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០១៤*

# គោលការណ៍ណែនាំ

# ស្តីពី

# យន្តការនៃការទទួលបញ្ជាជួញដូរមូលបត្រ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ប្រកាសលេខ ០០៦/១១ គមក ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ និងប្រកាសលេខ ០០៨ គមក ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង និងធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាជួញដូរមូលបត្រ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) សូមធ្វើការណែនាំនូវយន្តការនៃការទទួលបញ្ជាទិញ លក់ កែប្រែ ឬលុបការជួញដូរមូលបត្រ ដូចខាងក្រោម÷

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រអាចទទួលបញ្ជាទិញ លក់ កែប្រែ ឬលុបការជួញដូរមូលបត្រតាមរយៈឯកសារជាលាយលក្ខណ៍អក្សររបស់អតិថិជន ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល។ បញ្ជាដែលទទួលពីអតិថិជនត្រូវមានព័ត៌មានលម្អិតដូចជា÷

- ឈ្មោះមូលបត្រ
- បរិមាណ
- ថ្លៃ
- ប្រភេទបញ្ជា (ទិញ លក់ កែប្រែ ឬលុប)
- លេខអត្តសញ្ញាណវិនិយោគិន
- លេខបញ្ជាដើមក្នុងករណីជាបញ្ជាកែប្រែឬលុប
- លេខគណនីជួញដូរ
- ពេលវេលា
- កាលបរិច្ឆេទនៃការដាក់បញ្ជា

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Tempory Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phnone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

មុននឹងទទួលបុគ្គលណាម្នាក់ជាអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវចុះកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមួយអតិថិជន តាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។ ក្រុមហ៊ុនមូលបត្រ និងអតិថិជនត្រូវចុះកិច្ចព្រមព្រៀងបន្ថែមជាលាយលក្ខណ៍អក្សរអំពីការដាក់បញ្ជាតាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល តាមទម្រង់ដូចមានក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ ។

មុនចុះហត្ថលេខាជាមួយអតិថិជន ភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនត្រូវពន្យល់ពីខ្លឹមសារនៃកិច្ចព្រមព្រៀងដល់អតិថិជន និងត្រូវពន្យល់លម្អិតអំពីវិធីសាស្ត្រនៃការដាក់បញ្ជាទាំងអស់ និងហានិភ័យដែលអាចកើតមានពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការដាក់បញ្ជានីមួយៗដល់អតិថិជន។

ពេលទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវផ្ទៀងផ្ទាត់ថាបុគ្គលដែលដាក់បញ្ជាតាមវិធីសាស្ត្រនីមួយៗពិតជាបុគ្គលដែលមានសិទ្ធិក្នុងការដាក់បញ្ជាទិញ លក់ កែប្រែ ឬលុប។ ជាមួយគ្នានោះផងដែរ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវបញ្ជាក់ដោយផ្ទាល់ជាមួយអតិថិជនអំពីការបញ្ជានោះ ចំពោះការដាក់បញ្ជាដោយផ្ទាល់នៅក្រុមហ៊ុនមូលបត្រ។ ចំពោះបញ្ជាតាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវធ្វើការផ្ទៀងផ្ទាត់តាមរយៈទូរស័ព្ទជាមួយអតិថិជនអំពីការបញ្ជានោះ។ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវបំពេញបណ្ណបញ្ជា (order slip) ជាលាយលក្ខណ៍អក្សរដោយមានភស្តុតាងនៃការបញ្ជាដោយឡែកចំពោះការដាក់បញ្ជាដោយផ្ទាល់នៅក្រុមហ៊ុន បណ្ណបញ្ជាត្រូវមានហត្ថលេខារបស់អតិថិជន។ បន្ថែមពីនេះ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវថតសម្លេងទុកនូវរាល់ការបញ្ជាតាមរយៈការហៅទូរស័ព្ទ។

បណ្ណបញ្ជាទាំងអស់ត្រូវមានហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលបញ្ជា និងប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬអ្នកគ្រប់គ្រងសាខា។ ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវដាក់បង្ហាញពីព័ត៌មានសម្ងាត់របស់អតិថិជនពាក់ព័ន្ធនឹងការដាក់បញ្ជា ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្មទៅឱ្យបុគ្គលណាមួយឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មាននោះ។

នៅពេលការបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត ក្រុមហ៊ុនមូលបត្រ តាមរយៈភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ខ្លួនត្រូវជូនដំណឹងដល់អតិថិជនឱ្យបានឆាប់បំផុតនៅថ្ងៃធ្វើប្រតិបត្តិការទាំងនោះ ហើយការជូនដំណឹងនោះត្រូវបញ្ចូលព័ត៌មានដូចជា÷

- ប្រភេទមូលបត្រ
- បរិមាណ

- ថ្លៃក្នុងមួយឯកតា
- តម្លៃសរុប
- កាលបរិច្ឆេទនៃការជួញដូរ
- កម្រៃជើងសា
- ថ្លៃសេវា
- លាភការផ្សេងៗ
- ពន្ធទាក់ទងនឹងការជួញដូរដែលត្រូវបង់ដោយអតិថិជន
- ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលធ្វើសកម្មភាពជួញដូរក្នុងនាមអតិថិជន
- សេចក្តីបញ្ជាក់ក្រុមហ៊ុនមូលបត្រធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុន ឬក្នុងនាមអតិថិជន
- បញ្ជាដែលផ្អែកលើការអនុវត្តប្រសើរបំផុត ឬបញ្ជាដែលផ្អែកលើការចង្អុលបង្ហាញរបស់អតិថិជន

ក្រុមហ៊ុនមូលបត្រត្រូវមានការព្រមព្រៀងជាមុនជាមួយអតិថិជនអំពីវិធីសាស្រ្តនៃការជូនដំណឹងនេះដូចជាតាមប្រៃសណីយ៍ ការបញ្ជូនទៅដោយផ្ទាល់ តាមរយៈទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល។

ក្រុមហ៊ុនមូលបត្រត្រូវរក្សាទុកក្នុងទម្រង់ដើមមិនអាចកែប្រែបាន នូវភស្តុតាងនៃរាល់បញ្ជាតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល និងភស្តុតាងនៃរាល់ការជូនដំណឹងដល់អតិថិជនអំពីព័ត៌មាននៃការអនុវត្តបញ្ជាក្នុងរយៈពេលយ៉ាងតិច ១០ឆ្នាំ។

គណៈកម្មការមូលបត្រកម្ពុជា

# ឧបសម្ព័ន្ធស្ដីពីទម្រង់នៃកិច្ចព្រមព្រៀងបន្ថែមលើកិច្ចព្រមព្រៀងអតិថិជន

## ស្ដីពីការដាក់បញ្ជាតាមរយៈទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីមែល

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវបានភ្ជាប់ជាមួយ និងជាផ្នែកមួយនៃកិច្ចព្រមព្រៀងអតិថិជន រវាងក្រុមហ៊ុនមូលបត្រ........................ភ្នាក់ងារក្រុមហ៊ុនមូលបត្រទទួលបានអាជ្ញាបណ្ណ..............និង អតិថិជន ................................ ដែលបានចុះនៅថ្ងៃទី ......... ខែ.........ឆ្នាំ .........។

### ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម

### ប្រការ ១.- វិធីសាស្ត្រក្នុងការដាក់បញ្ជា

អតិថិជនយល់ព្រមដាក់បញ្ជាតាមរយៈ ÷

□ ទូរស័ព្ទ÷ លេខទូរស័ព្ទដាក់បញ្ជា........ លេខទូរស័ព្ទទទួលបញ្ជា....... ពាក្យសម្ងាត់.......។

□ សារទូរស័ព្ទ÷ លេខទូរស័ព្ទដាក់បញ្ជា...... លេខទូរស័ព្ទទទួលបញ្ជា....... ពាក្យសម្ងាត់....។

□ ទូរសារ÷ លេខទូរសារដាក់បញ្ជា....... លេខទូរសារទទួលបញ្ជា....... ពាក្យសម្ងាត់.........។

□ អ៊ីមែល÷ អាសយដ្ឋានអ៊ីមែលដាក់បញ្ជា.... អាសយដ្ឋានអ៊ីមែលទទួលបញ្ជា....ពាក្យសម្ងាត់....។

អតិថិជនយល់ព្រមប្រគល់សិទ្ធិតាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ដើម្បីដាក់បញ្ជា...................ក្នុងនាមអតិថិជនដល់បុគ្គលឈ្មោះ.........................ភេទ...............ថ្ងៃខែឆ្នាំកំណើត.............លេខអត្តសញ្ញាណបណ្ណ/ លិខិតឆ្លងដែន................................ផុតសុពលភាពនៅថ្ងៃទី....ខែ.....ឆ្នាំ.........អាសយដ្ឋាន........................................................។

អ្នកតំណាងរបស់អតិថិជនដែលទទួលបានសិទ្ធិអាចដាក់បញ្ជាតាមរយៈ÷

□ ទូរស័ព្ទ÷ លេខទូរស័ព្ទដាក់បញ្ជា........ លេខទូរស័ព្ទទទួលបញ្ជា....... ពាក្យសម្ងាត់.......។

□ សារទូរស័ព្ទ÷ លេខទូរស័ព្ទដាក់បញ្ជា..... លេខទូរស័ព្ទទទួលបញ្ជា...... ពាក្យសម្ងាត់......។

□ ទូរសារ÷ លេខទូរសារដាក់បញ្ជា...... លេខទូរសារទទួលបញ្ជា........ ពាក្យសម្ងាត់.........។

□ អ៊ីមែល÷ អាសយដ្ឋានអ៊ីមែលដាក់បញ្ជា.... អាសយដ្ឋានអ៊ីមែលទទួលបញ្ជា.... ពាក្យសម្ងាត់....។

### ប្រការ ២.-វិធីសាស្ត្រក្នុងការជូនដំណឹងអំពីព័ត៌មាននៃការអនុវត្តបញ្ជា

អតិថិជនយល់ព្រមឱ្យក្រុមហ៊ុនជូនដំណឹងដល់អតិថិជនអំពីព័ត៌មាននៃការអនុវត្តបញ្ជាតាមរយៈ ÷

□ ប្រៃសណីយ៍

□ ការបញ្ជូនទៅដោយផ្ទាល់

□ ទូរស័ព្ទ

□ សារទូរស័ព្ទ

□ ទូរសារ

□ អ៊ីម៉ែល

ប្រការ ៣.- លាភការ

(តារាងតម្លៃលាភការបន្ថែម ប្រសិនបើមាន)

ប្រការ ៤.- កាតព្វកិច្ចរបស់ក្រុមហ៊ុន

ក្រុមហ៊ុនធានាឱ្យមាននូវយន្តការប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបញ្ជាពីអតិថិជន តាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល។

ក្រុមហ៊ុនត្រូវផ្ដល់ព័ត៌មានដល់អតិថិជនអំពីហានិភ័យផ្សេងៗ ដែលអាចកើតមានពេលដាក់បញ្ជា តាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល និងក្រុមហ៊ុនត្រូវទទួលខុសត្រូវលើហានិភ័យនៃការរអាក់រអួលប្រព័ន្ធទូរស័ព្ទ ឬអ៊ីនធើណែត ផ្ទៃក្នុងរបស់ក្រុមហ៊ុន ក្នុងពេលទទួលបញ្ជារបស់អតិថិជនតាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល។

ក្រុមហ៊ុនធានាកាត់បន្ថយជាអតិបរមានូវហានិភ័យដែលអាចកើតមានឡើងពាក់ព័ន្ធនឹងការបញ្ជា តាមរយៈ ទូរស័ព្ទ សារទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល។

ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមដល់អតិថិជន ក្នុងករណីក្រុមហ៊ុនដឹងថាមានបុគ្គលដែលមិនបាន ទទួលសិទ្ធិបញ្ជា ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

ប្រការ ៥.- កាតព្វកិច្ចរបស់អតិថិជន

អតិថិជនត្រូវទទួលស្គាល់ថាបានសិក្សា និងយល់ដឹងច្បាស់លាស់អំពីហានិភ័យដែលអាចកើត មានឡើងក្នុងការដាក់បញ្ជាតាមវិធីសាស្ត្រដែលបានជ្រើសរើសដូចមានក្នុងប្រការ ១ នៃកិច្ចព្រមព្រៀង បន្ថែមនេះ។

អតិថិជនត្រូវទទួលស្គាល់ថាលេខទូរស័ព្ទសម្រាប់ការហៅទូរស័ព្ទ លេខទូរស័ព្ទសម្រាប់បញ្ជូន សារទូរស័ព្ទ លេខទូរសារ និង/ឬអាសយដ្ឋានអ៊ីម៉ែលសម្រាប់ដាក់បញ្ជាដែលបានផ្ដល់ជូនក្រុមហ៊ុនដូចក្នុង ប្រការ ១ នៃកិច្ចព្រមព្រៀងបន្ថែមនេះ ពិតជាត្រឹមត្រូវប្រាកដមែន ហើយអតិថិជនទទួលខុសត្រូវលើ រាល់ការបញ្ជាតាមរយៈលេខទូរស័ព្ទសម្រាប់ការហៅទូរស័ព្ទ លេខទូរស័ព្ទសម្រាប់បញ្ជូនសារទូរស័ព្ទ លេខទូរសារ និង/ឬអាសយដ្ឋានអ៊ីម៉ែលនេះ។

អតិថិជនយល់ព្រមឱ្យក្រុមហ៊ុនថតសម្លេងទុកជាភស្តុតាងពេលអតិថិជនដាក់បញ្ជា ឬពេលក្រុមហ៊ុនជូនដំណឹងអំពីព័ត៌មាននៃការអនុវត្តបញ្ជា តាមរយៈការហៅទូរស័ព្ទ។

អតិថិជនត្រូវជូនដំណឹងភ្លាមដល់ក្រុមហ៊ុន ក្នុងករណីអតិថិជនដឹងថាមានបុគ្គលដែលមិនបានទទួលសិទ្ធិបញ្ជា ប្រើប្រាស់ព័ត៌មានសម្ងាត់របស់អតិថិជនដើម្បីដាក់បញ្ជា។

## ប្រការ ៦.- ច្បាប់ចម្លងនៃកិច្ចព្រមព្រៀងបន្ថែម

កិច្ចព្រមព្រៀងបន្ថែមនេះធ្វើឡើងជា ២ (ពីរ) ច្បាប់ ដែលមានឈ្មោះ ត្រា និងហត្ថលេខា ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនបានផ្តល់ឱ្យអតិជនមួយច្បាប់ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

## ប្រការ ៧.- សុពលភាពនៃកិច្ចព្រមព្រៀងអតិថិជន

កិច្ចព្រមព្រៀងអតិថិជនដែលបានចុះនៅថ្ងៃទី.....ខែ......ឆ្នាំ.........នៅតែមានសុពលភាពអនុវត្ត។

ដើម្បីឱ្យកិច្ចព្រមព្រៀងបន្ថែមនេះមានសុពលភាព ភាគីទាំងពីរព្រមព្រៀងគ្នាដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃខាងក្រោម÷

| | |
|---|---|
| ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា (ករណីជាស្ថាប័ន)របស់អតិថិជន<br><br><br>កាលបរិច្ឆេទចុះថ្ងៃទី........ ខែ........... ឆ្នាំ............ | ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា របស់ក្រុមហ៊ុន<br><br><br>កាលបរិច្ឆេទចុះថ្ងៃទី........ ខែ........ ឆ្នាំ............ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:......០០១...........គ.ម.ក/ន.ណ.ន

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១១

# គោលការណ៍ណែនាំ
# ស្តីពី
# យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក)** សូមធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

**១-** *ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុច ដូចខាងក្រោម:

១-គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២-គម្រោងពេលវេលារំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣-ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

*២- ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

*៣- ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

*៤- ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

*៥- ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

***៦- ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.***

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក.។ គ.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

***៧- ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)***

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក. ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

***៨- ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា***

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

***៩- ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក.***

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូនគ.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

*១០- ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

*១១- ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយ-ការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្លាមជូន **គ.ម.ក.**។

*១២- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឲ្យអ្នកធ្វើបរិវិស-កម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**គណៈកម្មការមូលបត្រកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ.......០០៨/១១...គ.ម.ក ប្រ.ក.

# ប្រកាស
# ស្តីពី
# ក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់បទប្បញ្ញត្តិអំពីក្រមសីលធម៌វិជ្ជាជីវៈក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ការអនុវត្តប្រសើរបំផុត** (Best Execution) : សំដៅដល់កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានសម្រាប់អតិថិជននូវថ្លៃប្រសើរបំផុតចំពោះទំហំ និងប្រភេទនៃការជួញដូរពាក់ព័ន្ធនឹងបញ្ជាដែលទទួលពីអតិថិជន។

**គណនីឆន្ទានុសិទ្ធិ** (Discretionary Account) : សំដៅដល់គណនីរបស់អតិថិជនដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមានឆន្ទានុសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តទិញ ឬលក់មូលបត្រដោយមិនចាំបាច់ទទួលបានបញ្ជាពីអតិថិជន។

**ការត្រួតពិនិត្យផ្ទៃក្នុង** (Internal Control) : សំដៅដល់ប្រព័ន្ធ គោលនយោបាយ នីតិវិធី វិធាន និងការត្រួតពិនិត្យផ្ទៃក្នុងផ្សេងទៀតដែលអនុវត្តដើម្បីធានានូវការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

**គ.ម.ក.** (SECC) : សំដៅដល់គណៈកម្មការមូលបត្រកម្ពុជា។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ** (Licensed Firm) : សំដៅដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើអាជីវកម្មមូលបត្រដូចមានកំណត់ក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ** (Licensed Representative) : សំដៅដល់ភ្នាក់ងារដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើភ្នាក់ងាររបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ។

**លក្ខខណ្ឌអាជ្ញាបណ្ណ** (License Conditions) : សំដៅដល់លក្ខខណ្ឌ ឬការកម្រិតផ្សេងទៀតដែល គ.ម.ក. បានដាក់ទៅលើលក្ខខណ្ឌអាជ្ញាបណ្ណរបស់ក្រុមហ៊ុន។

**ប្រឹក្សាវិនិយោគ** (Investment Advice) : សំដៅដល់ប្រឹក្សា ឬសេចក្តីថ្លែងយោបល់ ឬរបាយការណ៍ណាមួយដែល ÷

១- មានគោលបំណងជះឥទ្ធិពលដល់បុគ្គលម្នាក់ ឬច្រើននាក់ក្នុងការធ្វើសេចក្តីសម្រេចចិត្តលើមូលបត្រ ឬប្រភេទនៃមូលបត្រណាមួយ។

២- អាចមានគោលបំណងជះឥទ្ធិពលដូចមានចែងក្នុងចំណុច (១) ខាងលើ។

**ប្រតិបត្តិការមូលបត្រ** (Securities Transaction) : សំដៅលើការជួញដូរ ការលក់ ឬការដោះដូរមូលបត្រ។

**អនុក្រឹត្យ** (Anukret) : សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**កម្មវិធីប្រព័ន្ធជួញដូរ** (System Trading Program) : សំដៅដល់កម្មវិធីផ្នែកទន់របស់កុំព្យូទ័រដែលមិនគិតទៅដល់សេចក្តីវិនិច្ឆ័យដោយខ្លួនឯងរបស់អតិថិជនឡើយ ប៉ុន្តែវាផ្តល់នូវព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តលើប្រភេទជួញដូរ ពេលវេលានៃប្រតិបត្តិការ និងការដាក់តម្លៃជួញដូរជាដើម។

**ការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ** (Merit Based Payment) : សំដៅដល់ការទូទាត់ដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណទទួលពីអតិថិជននៅក្នុងសំណងសម្រាប់សេវាកម្មរបស់ខ្លួន ដែលត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណេញបានមកពីការវិនិយោគរបស់អតិថិជននោះ។

**បញ្ជាមិនមែនអតិថិជន** (Non-Client Order) : សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដែលទទួលបានពី ឬផ្តួចផ្តើមដោយក្រុមហ៊ុនមូលបត្រសម្រាប់គណនីរបស់ ÷

១-សហកម្មសិទ្ធិករ អភិបាល បុគ្គលិកជាន់ខ្ពស់ ឬបុគ្គលដែលមានតំណែងប្រហាក់ប្រហែល ឬបុគ្គលមានគុណវុឌ្ឍិប្រហាក់ប្រហែលនៃក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ឬ

២- និយោជិតនៃក្រុមហ៊ុនមូលបត្រ ប៉ុន្តែមិនរាប់បញ្ចូលគណនីក្រុមហ៊ុន។

**បញ្ជា** (Order) : សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រ។

**គណនីក្រុមហ៊ុន** (Principal Account) : សំដៅដល់គណនីដែលក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធនៃក្រុមហ៊ុនមូលបត្រកាន់កាប់នូវផលប្រយោជន៍ផ្ទាល់ ឬមិនផ្ទាល់ជាជាងផលប្រយោជន៍កម្រៃជើងសាដែលទទួលពីប្រតិបត្តិការ។

**បុគ្គលិកជាន់ខ្ពស់** (Senior Staff) : សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងសវនកម្មផ្ទៃក្នុង។

## ជំពូកទី ២
## គោលការណ៍អាជីវកម្ម

**ប្រការ ៣.-គោលការណ៍ទូទៅនៃអាជីវកម្ម**

ដើម្បីឱ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាអតិបរមា និងធានាឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវក្នុងការជួញដូរមូលបត្រនៅលើទីផ្សារ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណត្រូវ ÷

១-មានភាពសុចរិតក្នុងការប្រកបអាជីវកម្ម និងធ្វើការប្រកួតប្រជែងដោយស្មោះត្រង់។

២-ដំណើរការអាជីវកម្មប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់។

៣-យកចិត្តទុកដាក់ចំពោះការគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចការទទួលខុសត្រូវឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យដែលសមស្រប។

៤-មានធនធានមនុស្ស និងមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ព្រមទាំងមាននីតិវិធីដែលចាំបាច់សម្រាប់ប្រកបអាជីវកម្ម។

៥- រក្សាលក្ខខណ្ឌតម្រូវហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៦-បំពេញកាតព្វកិច្ចយ៉ាងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងប្រាក់របស់អតិថិជនឱ្យបានល្អ។

៧- បំពេញភារកិច្ចដោយគិតដល់ផលប្រយោជន៍របស់អតិថិជនជាចម្បង។

៨-ផ្តល់ប្រឹក្សាវិនិយោគទៅអតិថិជនឱ្យបានត្រឹមត្រូវ ដោយស្វែងយល់ឱ្យបានច្បាស់ពីព័ត៌មានរបស់អតិថិជន។

៩- ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជនធ្វើការសម្រេចចិត្ត។

១០-ប្រុងប្រយ័ត្នកុំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន។ ក្នុងករណី មិនអាចចៀសវាងបាន ក្រុមហ៊ុនត្រូវជូនដំណឹងជាមុនដល់អតិថិជននោះ ឬមានវិធានការសមស្របដើម្បីការពារដល់ផលប្រយោជន៍អតិថិជន។

១១- គោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ គ.ម.ក. និងត្រូវធានាថារាល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគរបស់ក្រុមហ៊ុនគោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

១២- រក្សាការសម្ងាត់ និងធានាថារាល់ភ្នាក់ងារបានទទួលអាជ្ញាបណ្ណ រក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន និងមិនត្រូវផ្សព្វផ្សាយដល់តតិយជន លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ច គ.ម.ក. ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អតិថិជន។

## ជំពូកទី ៣
## គណនីអតិថិជន

### ប្រការ ៤.- ការបើកគណនីអតិថិជន

អតិថិជនអាចបើកគណនីសម្រាប់ប្រតិបត្តិការជួញដូរមូលបត្របានមួយប៉ុណ្ណោះ នៅក្រុមហ៊ុនមូលបត្រមួយ។

មុនពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ឬក្នុងនាមអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវ ÷

១-បំពេញកាតព្វកិច្ចតាមច្បាប់ក្នុងការសិក្សាឱ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន និងបំពេញតាមទម្រង់សុំបើកគណនីដែលមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

២-បំពេញ និងចុះកិច្ចព្រមព្រៀងជាមួយអតិថិជន ដោយអនុលោមតាមមាត្រា ៥៤ នៃអនុក្រឹត្យ និងប្រការ ៦ នៃប្រកាសនេះ។

### ប្រការ ៥.- ការអនុម័តការបើកគណនី

ក្រុមហ៊ុនមូលបត្រត្រូវចាត់តាំងអ្នកគ្រប់គ្រងគណនី ដើម្បីទទួលខុសត្រូវលើការអនុញ្ញាតឱ្យបើកគណនីថ្មី និងគ្រប់គ្រងប្រតិបត្តិការគណនី។

អតិថិជនអាចធ្វើប្រតិបត្តិការដំបូងលើគណនីនេះបាន លុះត្រាតែគណនីនេះត្រូវបានអនុញ្ញាតឱ្យបើកមុនយ៉ាងហោច ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ។

អ្នកគ្រប់គ្រងគណនីត្រូវធ្វើការអនុញ្ញាតលើការបើកគណនីជាលាយលក្ខណ៍អក្សរ និងត្រូវរក្សាកំណត់ត្រានៃការអនុញ្ញាត។

### ប្រការ ៦.-កិច្ចព្រមព្រៀងអតិថិជន

កិច្ចព្រមព្រៀងអតិថិជនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាត្រឹមត្រូវរវាងអតិថិជន និងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណតាមទម្រង់កិច្ចព្រមព្រៀងអតិថិជនកំណត់ដោយ គ.ម.ក. ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ ភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនត្រូវពន្យល់ពីខ្លឹមសារនីមួយៗនៃកិច្ចព្រមព្រៀងដល់អតិថិជនមុនចុះហត្ថលេខាជាមួយអតិថិជន។

កិច្ចព្រមព្រៀងអតិថិជនត្រូវមាននិទ្ទេសអប្បរមាដូចខាងក្រោម ÷

១-ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជន ដោយភ្ជាប់មកជាមួយនូវឯកសារថតចំលងជាភស្តុតាងដូចជាអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន អត្តសញ្ញាណវិនិយោគិនដែលទទួលបានពី គ.ម.ក. វិញ្ញាបនបត្រ

ចុះបញ្ជីពាណិជ្ជកម្ម ឯកសារស្តីអំពីសាជីវកម្ម ឬឯកសារផ្លូវការផ្សេងទៀតដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជន។

២-នាមករណ៍ និងអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

៣-ស្ថានភាពអាជ្ញាបណ្ណបច្ចុប្បន្នរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ហើយត្រូវផ្តល់ព័ត៌មានអំពីប្រភេទអាជីវកម្មក្នុងក្របខណ្ឌនៃអាជ្ញាបណ្ណក្រុមហ៊ុនទទួលបាន។

៤-កាតព្វកិច្ចផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមករវាងក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងអតិថិជនអំពីរាល់ការកែប្រែព័ត៌មានដែលមានចែងក្នុងកិច្ចព្រមព្រៀងជាសារវន្ត។

៥-ការពិពណ៌នាពីប្រភេទសេវាកម្មដែលផ្តល់ជូនអតិថិជន ឬសេវាកម្មផ្សេងទៀតដែលមានសម្រាប់អតិថិជន។

៦-ការពិពណ៌នាពីចំណាយផ្សេងៗ និងមូលដ្ឋានសម្រាប់ទូទាត់ដែលជាបន្ទុករបស់អតិថិជន រួមមានកម្រៃជើងសាមូលបត្រ និងថ្លៃសេវាផ្សេងៗទៀត។

៧-សេចក្តីថ្លែងដែលបញ្ជាក់នូវកាលៈទេសៈណាដែលក្រុមហ៊ុនមូលបត្រធ្វើការជួញដូរក្នុងនាមក្រុមហ៊ុន (Principal) និងកាលៈទេសៈផ្សេងទៀតដែលក្រុមហ៊ុនមូលបត្រនឹងដើរតួជាភ្នាក់ងារ (Agent) របស់អតិថិជន ក្នុងករណីក្រុមហ៊ុនមូលបត្រទទួលអាជ្ញាបណ្ណជាពាណិជ្ជករមូលបត្រ និងជើងសាមូលបត្រ។

៨- សេចក្តីថ្លែងព័ត៌មានហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រដែលអតិថិជននឹងធ្វើការជួញដូរ។

៩-របាយការណ៍ដែលអតិថិជនត្រូវទទួលបាន និងវិធីសាស្ត្រនៃការទទួលរបាយការណ៍ និងការជូនដំណឹងអំពីប្រតិបត្តិការជួញដូរមូលបត្រ។

១០-សេចក្តីលម្អិតពីនីតិវិធីនៃការតវ៉ារបស់អតិថិជន។

១១-សេចក្តីលម្អិតពីផលប្រយោជន៍ ឬទំនាក់ទំនងណាមួយដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និង/ឬ ភ្នាក់ងាររបស់ខ្លួន។

១២-សេចក្តីលម្អិតអំពីបែបបទដែលបញ្ជារបស់អតិថិជនត្រូវបានទទួលយក រួមមាននីតិវិធីសម្រាប់បញ្ជា ការបង្គាប់ផ្សេងទៀតដែលនឹងត្រូវអនុវត្ត របៀបដែលអតិថិជនធ្វើការកែប្រែនូវបញ្ជាដែលនឹងត្រូវអនុវត្ត និងសេចក្តីលម្អិតនៃបុគ្គលដែលត្រូវតែងតាំងដោយអតិថិជនធ្វើជាភ្នាក់ងារ ឬតាមលិខិតផ្ទេរសិទ្ធិក្នុងការធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងារក្រុមហ៊ុនត្រូវអនុវត្តតាមកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិនេះ និងកិច្ចព្រមព្រៀងអតិថិជន ហើយកិច្ចព្រមព្រៀងមិនត្រូវមានការលុបចោល ឬដាក់កម្រិតលើសិទ្ធិរបស់អតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលទទួលស្គាល់ដោយច្បាប់។

**ប្រការ ៧.- ការបន្លំសិទ្ធិប្រើប្រាស់គណនីអតិថិជន**

ការប្រើប្រាស់គណនីអតិថិជនដោយគ្មានការអនុញ្ញាតត្រូវបានហាមឃាត់។

ដើម្បីចៀសវាងការប្រើប្រាស់គណនីអតិថិជនដោយគ្មានការអនុញ្ញាត ក្រុមហ៊ុនមូលបត្រត្រូវ ÷

១-មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ចំពោះការកែប្រែទិន្នន័យរបស់អតិថិជន។ ការស្នើសុំកែប្រែព័ត៌មានផ្ទាល់របស់អតិថិជន ឬសេចក្ដីណែនាំលើការទូទាត់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ក្រុមហ៊ុនត្រូវមានកិច្ចខិតខំយ៉ាងសមស្របដើម្បីធានាថា សំណើកែប្រែនេះបានធ្វើឡើងដោយអតិថិជនពិតប្រាកដមែន។

២-ធានាថាគ្រប់ប្រតិបត្តិការលក់ត្រូវបានទូទាត់ទៅឱ្យអតិថិជនជាអ្នកលក់ និងមិនត្រូវទូទាត់ឱ្យបុគ្គលណាផ្សេងទេ វៀរលែងតែមានការអនុញ្ញាតដែលមានចែងក្នុងប្រការ ៤៤ នៃប្រកាសនេះ។

## ជំពូកទី ៤
## ការផ្ដល់ប្រឹក្សាវិនិយោគ

**ប្រការ ៨.- ការផ្ដល់ប្រឹក្សាវិនិយោគ**

ការផ្ដល់ប្រឹក្សាវិនិយោគដល់អតិថិជនត្រូវ ÷

១-ធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល និង

២-ធ្វើឡើងដោយផ្អែកលើព័ត៌មានដែលផ្ដល់ឱ្យដោយអតិថិជន ហើយត្រូវមានហេតុផលជាមូលដ្ឋានឆ្លុះបញ្ចាំងនូវព័ត៌មានគោលដូចមានកំណត់ក្នុងកថាខណ្ឌទី ២ នៃប្រការនេះ។

មុនពេលផ្ដល់ប្រឹក្សាវិនិយោគ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគត្រូវគោរពតាមគោលការណ៍ [ស្គាល់អតិថិជនរបស់ខ្លួន (Know-Your-Client)] ដោយព្យាយាមស្វែងយល់ពីអតិថិជនតាមរយៈការពិគ្រោះយោបល់ដោយជួបផ្ទាល់ និងបំពេញតាមទម្រង់ពាក្យស្នើសុំការផ្ដល់ប្រឹក្សាវិនិយោគដែលមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីទទួលបាននូវព័ត៌មានអតិថិជនដូចខាងក្រោម ÷

១-ស្ថានភាពហិរញ្ញវត្ថុ និងសេចក្ដីត្រូវការរបស់អតិថិជន

២-គោលដៅវិនិយោគរបស់អតិថិជន

៣-ឥរិយាបទអតិថិជនចំពោះហានិភ័យដែលអាចកើតមាន និង

៤-បទពិសោធន៍ និងចំណេះដឹងនៃការវិនិយោគរបស់អតិថិជន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរជាមួយអតិថិជនអំពីព័ត៌មានដែលទទួលបាន និងត្រូវគ្រប់គ្រងថែរក្សាព័ត៌មាននោះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវមានវិធានការសមស្រប ដើម្បីធានាថាព័ត៌មានដែលទទួលបានពីអតិថិជនដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះមានលក្ខណៈបច្ចុប្បន្នភាព។ ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារទទួលបានអាជ្ញាបណ្ណបានដឹងថាមានការផ្លាស់ប្តូរនូវព័ត៌មានរបស់អតិថិជនព័ត៌មានរបស់អតិថិជនដែលប្រមូលបានក្នុងកថាខណ្ឌទី ២ នៃប្រការនេះត្រូវធ្វើបច្ចុប្បន្នកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំជាលាយលក្ខណ៍អក្សរជារៀងរាល់ឆ្នាំទៅអតិថិជន ឱ្យជូនដំណឹងដល់ក្រុមហ៊ុន ប្រសិនបើព័ត៌មានរបស់អតិថិជនមានការកែប្រែ។

ករណីអតិថិជនបដិសេធមិនព្រមផ្តល់ព័ត៌មានដែលមានលក្ខណៈបច្ចុប្បន្នភាពរបស់ខ្លួន តាមការស្នើសុំរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ក្រុមហ៊ុន ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគនឹងផ្តល់ប្រឹក្សាវិនិយោគដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យក្រុមហ៊ុនតែប៉ុណ្ណោះ។ ស្របតាមកថាខណ្ឌទី ១ ដល់ ទី ៥ នៃប្រការនេះ ករណីក្រុមហ៊ុនដឹងថាការផ្តល់ប្រឹក្សាវិនិយោគផ្អែកលើព័ត៌មានមិនពេញលេញ ឬមិនត្រឹមត្រូវ ក្រុមហ៊ុនត្រូវដាស់តឿនអតិថិជន ក្នុងពេលដំណាលគ្នាដែលក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ ថាមុននឹងអនុវត្តប្រឹក្សានោះ អតិថិជនគួរគិតពិចារណាលើភាពសមស្របនៃការផ្តល់ប្រឹក្សាចំពោះស្ថានភាពពាក់ព័ន្ធរបស់ខ្លួន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគមិនត្រូវផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជនដូចមានចែងក្នុងកថាខណ្ឌទី ៦ នៃប្រការនេះ ចំពោះមូលបត្រដូចខាងក្រោម ៖

១- មូលបត្រដែលមិនបានចុះបញ្ជីលក់នៅទីផ្សារមូលបត្រប្រតិស្រុត។

២- មូលបត្រដែលស្ថិតក្រោមការចាត់វិធានការរដ្ឋបាល ឬស្ថិតក្រោមការស៊ើបអង្កេត។

៣- សញ្ញាបណ្ណសាជីវកម្មដែលមានហានិភ័យខ្ពស់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវដាក់ឱ្យដាច់ដោយឡែកនូវគណនីអតិថិជនដែលមិនមាន ឬមានបទពិសោធន៍តិចតួចលើប្រតិបត្តិការមូលបត្រ ហើយពឹងផ្អែកទាំងស្រុងទៅលើប្រឹក្សាវិនិយោគដែលផ្តល់ឱ្យដោយក្រុមហ៊ុននឹងត្រូវពិនិត្យជាទៀងទាត់នូវស្ថានភាពនៃការជួញដូររបស់អតិថិជនទាំងនោះ ដើម្បីធានាថាប្រឹក្សាវិនិយោគដែលផ្តល់ដោយភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវបានធ្វើឡើងស្របតាមប្រកាសនេះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងអនុវត្តត្រួតពិនិត្យផ្ទៃក្នុង ដើម្បីគោរពតាមគោលការណ៍ដែលមានក្នុងប្រការនេះ។

## ប្រការ ៩.- ការចៀសវាងទំនាស់ផលប្រយោជន៍ទាក់ទងនឹងការផ្តល់ប្រឹក្សាវិនិយោគ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាថាក្រុមហ៊ុនផ្ទាល់ និងភ្នាក់ងាររបស់ខ្លួន ៖

១- ត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវទំនាស់ផលប្រយោជន៍ជាសក្តានុពលរបស់ខ្លួនដែលអាចជះឥទ្ធិពលដល់ការផ្តល់ប្រឹក្សាវិនិយោគមិនលំអៀង មុនផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជននោះ។

២-ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនមុននឹងផ្តល់ប្រឹក្សាវិនិយោគអំពីអត្ថប្រយោជន៍ដែលមានពាក់ព័ន្ធនឹងថ្លៃ ឬការជួញដូរមូលបត្រណាមួយដែលក្រុមហ៊ុន និង/ឬភ្នាក់ងាររបស់ខ្លួនបានទទួលដោយសារហេតុផលពិសេសដូចខាងក្រោម ៖

ក-កំពុងផ្តល់ ឬនឹងផ្តល់សេវាកម្មធានាទិញមូលបត្រដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។

ខ-កំពុងផ្តល់ ឬនឹងផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងការរួមបញ្ចូល និងទិញដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។

គ-កាន់កាប់មូលបត្រច្រើនជាង ០១ (មួយ) ភាគរយនៃក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។

ឃ-កំពុងជួញដូរ ឬនឹងជួញដូរមូលបត្រនោះដោយក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងាររបស់ខ្លួន។

៣-មិនត្រូវទទួលផលប្រយោជន៍សេដ្ឋកិច្ច ឬផលប្រយោជន៍ផ្សេងទៀតពីក្រុមហ៊ុនបោះផ្សាយមូលបត្រដែលពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សាវិនិយោគ ឬពីបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ លើកលែងតែមានការជូនដំណឹងជាមុនពីផលប្រយោជន៍នោះដល់អតិថិជន។

**ប្រការ ១០.- ការហាមឃាត់លើការជំរុញឱ្យធ្វើការជួញដូរច្រើនហួសហេតុ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវជំរុញឱ្យអតិថិជនជួញដូរមូលបត្រច្រើនហួសហេតុពីភាពចាំបាច់ដែលសមល្មមសម្រាប់ផលប្រយោជន៍អតិថិជន ដោយគិតពិចារណាលើកត្តាដូចខាងក្រោម ៖

១-កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗដែលបង់ដោយអតិថិជន។

២- គោលដៅវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ សេចក្តីត្រូវការ និងស្ថានភាពជាក់ស្តែងរបស់អតិថិជន។

៣-កម្រិតនៃការយល់ដឹងរបស់អតិថិជនលើហានិភ័យដែលអាចកើតមានឡើង ចំពោះការជួញដូរមូលបត្រដោយផ្អែកលើចំណេះដឹង និង/ឬបទពិសោធន៍វិនិយោគរបស់អតិថិជន។

៤-សុពលភាពនៃការផ្តល់ប្រឹក្សាចំពោះការជួញដូរនីមួយៗ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវជ្រើសរើសយកគណនីដែលត្រូវបានជំរុញឱ្យមានការជួញដូរច្រើនហួសហេតុ និងត្រូវពិនិត្យគណនីអតិថិជននោះ ដើម្បីធានាថាការផ្តល់ប្រឹក្សាវិនិយោគបានអនុវត្តតាមគោលការណ៍ស្របតាមប្រកាសនេះ។ ក្នុងគោលបំណងនេះ ក្រុមហ៊ុនត្រូវរៀបចំត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ធ្វើការជ្រើសរើសគណនីដែលមានការជួញដូរច្រើនហួសហេតុមកធ្វើអធិការកិច្ច។

**ប្រការ ១១.- គណនីឧទ្ទានុសិទ្ធិ**

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ខ្លួន មិនត្រូវធ្វើប្រតិបត្តិការគណនីឧទ្ទានុសិទ្ធិ ដោយគ្មានការអនុញ្ញាតពី គ.ម.ក.។ ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវទិញ ឬលក់មូលបត្រជំនួសអតិថិជនតាមតែបញ្ជាទិញ-លក់របស់អតិថិជនពាក់ព័ន្ធស្របតាមប្រកាសនេះ។

## ជំពូកទី ៥
## ការអនុវត្តការជួញដូរមូលបត្រ

**ប្រការ ១២.- បញ្ជាទិញ-លក់**

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវអនុវត្តបញ្ជាទិញ-លក់ពីអតិថិជនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងមិនលំអៀង។

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រអាចអនុវត្តបញ្ជាទិញ-លក់របស់អតិថិជន ក្នុងនាមអតិថិជនបានលុះត្រាតែ ÷

១-ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជន ដើម្បីអនុវត្តប្រតិបត្តការជួញដូរ។

២-អតិថិជនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរមូលបត្រ ក្នុងករណីជាបញ្ជាទិញ។

៣-អតិថិជនមានមូលបត្រគ្រប់គ្រាន់សម្រាប់ការទូទាត់ ក្នុងករណីជាបញ្ជាលក់។

បញ្ជាទិញ-លក់អាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ ឬជាសម្លេង ឬជាសារអេឡិកត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។ នៅពេលទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិចដើម្បីផ្ទៀងផ្ទាត់បញ្ជារបស់អតិថិជន។ កំណត់ត្រានៃបញ្ជានោះ ត្រូវរក្សាជាប្រចាំថ្ងៃ និងយ៉ាងហោចណាស់ត្រូវបង្ហាញពីឈ្មោះរបស់អតិថិជន ព័ត៌មានលម្អិតនៃបញ្ជា និងកាលបរិច្ឆេទ និងពេលវេលានៃការដាក់បញ្ជា។

ក្រុមហ៊ុនមូលបត្រត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់គ្រប់គ្រងបញ្ជាទិញ-លក់របស់អតិថិជនឱ្យបានត្រឹមត្រូវ អនុលោមតាមប្រការនេះ។

**ប្រការ ១៣.- បញ្ជាតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀត**

បន្ថែមពីលើលក្ខខណ្ឌតម្រូវដែលមានចែងនៅប្រការ ១២ ក្រុមហ៊ុនមូលបត្រដែលទទួលបញ្ជាពីអតិថិជនតាមរយៈប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬជាសារអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់ ក្រុមហ៊ុនមូលបត្រត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមទាំងអស់ដូចខាងក្រោម ÷

១-ត្រូវឱ្យអតិថិជនយល់ដឹងនូវដំណើរការបញ្ជា និងការអនុវត្តបញ្ជាតាមមធ្យោបាយបញ្ជានីមួយៗ។

២-ធ្វើការបញ្ជាក់ឱ្យច្បាស់លាស់ថា បុគ្គលដែលបញ្ជានោះពិតជាមានសិទ្ធិក្នុងការបញ្ជា។

នៅពេលក្រុមហ៊ុនមូលបត្រអនុវត្តប្រតិបត្តិការជួញដូរតាមរយៈប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់ ក្រុមហ៊ុនត្រូវធានាថាប្រព័ន្ធនោះស្របតាមវិធាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ រួមទាំងលក្ខខណ្ឌតម្រូវទាក់ទងនឹងការរក្សាការសម្ងាត់របស់អតិថិជន។

ក្រុមហ៊ុនមូលបត្រត្រូវបង្កើតវិធានការសមស្រប ដើម្បីចៀសវាងស្ថានភាពដែលបញ្ជាមិនអាចត្រូវបានអនុវត្ត ដោយសារកត្តាមិនប្រក្រតីនៃប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬជាសារអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់។

**ប្រការ ១៤.- បុគ្គលដែលមានសិទ្ធិបញ្ជា**

ក្រុមហ៊ុនមូលបត្រត្រូវទទួលបញ្ជាតែពីបុគ្គលដែលមានសិទ្ធិដូចខាងក្រោម ÷

១-អតិថិជនជាម្ចាស់គណនី។

២-អ្នកតំណាងដែលអតិថិជនបានជ្រើសរើសជាលាយលក្ខណ៍អក្សរនៅពេលបើកគណនី ឬអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយអតិថិជននៅពេលបន្ទាប់ទៀត។

៣-បុគ្គលដែលបានទទួលសិទ្ធិស្របច្បាប់ក្នុងការបញ្ជាតាមលិខិតផ្ទេរសិទ្ធិ។

**ប្រការ ១៥.- ការហាមឃាត់ការទទួលបញ្ជាដែលផ្ទុយនឹងច្បាប់**

ក្រុមហ៊ុនមូលបត្រមិនត្រូវទទួលបញ្ជាដូចខាងក្រោម ÷

១-ពេលក្រុមហ៊ុនដឹងថាការជួញដូររបស់អតិថិជនល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២-ក្រុមហ៊ុនមានមូលដ្ឋានបង្ហាញថា អតិថិជនមិនអាចទូទាត់ការជួញដូរបាន ដោយពិនិត្យលើប្រវត្តិនៃការជួញដូរ ឬចំនួនមូលបត្រដែលអតិថិជនមាន និងស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន។

៣-ពេលដែលមើលឃើញថា អតិថិជនមិនមានបំណងជួញដូរពិតប្រាកដ ដោយពិនិត្យមើលលើកត្តាដូចខាងក្រោម ÷

ក-ចំនួន និងទំហំជួញដូរជាមធ្យមនៃមូលបត្រចុះបញ្ជីលក់ នៅពេលបោះផ្សាយ។

ខ-ការបែងចែកភាពជាម្ចាស់កម្មសិទ្ធិនៃភាគហ៊ុនរបស់ក្រុមហ៊ុនដែលធ្វើការបោះផ្សាយមូលបត្រចុះបញ្ជី។

គ-ទំហំនៃទ្រព្យសម្បត្តិដាក់តម្កល់របស់អតិថិជន និងវិធីនៃការជួញដូរ។

ឃ-ស្ថានភាពនៃការដាក់តម្លៃនៅពេលបញ្ជា។

## ប្រការ ១៦.- ការអនុវត្តប្រសើរបំផុត

លើកលែងតែមានការណែនាំពីអតិថិជនទាក់ទងនឹងបញ្ជាទៅតាមថ្លៃទីផ្សារ ឬបញ្ជាកម្រិតថ្លៃ ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវធ្វើការដោយប្រឹងប្រែង និងប្រុងប្រយ័ត្នដើម្បីទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់បញ្ជារបស់អតិថិជន។ ដើម្បីទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់អតិថិជន ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវពិចារណាលើកត្តាដូចខាងក្រោម ÷

- ថ្លៃ និងបរិមាណ (Volume) នៃការលក់ចុងក្រោយ និងការជួញដូរពីមុន (Previous Trades)
- ទិសដៅឡើងចុះនៃទីផ្សារចំពោះមូលបត្រនោះ
- ទំហំ (Size) នៃសំណើទិញ និងសំណើលក់
- ទំហំនៃគំលាត (Spread) និង
- សន្ទនីយភាពនៃមូលបត្រនោះ។

នៅពេលក្រុមហ៊ុនមូលបត្រទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនត្រូវបញ្ជូនបញ្ជានោះទៅកាន់ទីផ្សារតាមលក្ខខណ្ឌនៃបញ្ជាភ្លាម និងមិនត្រូវបង្អួរបញ្ជា ដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ឬដាក់បញ្ជាជាកញ្ចប់។

ក្រុមហ៊ុនមូលបត្រអាចធ្វើការកែប្រែវិធីសាស្ត្រនៃបញ្ជា ដូចជាពេលវេលានៃការបញ្ជូនបញ្ជាទៅកាន់ទីផ្សារ និងវិធីសាស្ត្រនៃការដាក់ថ្លៃទិញ-លក់ និងអាចប្រតិបត្តិការបញ្ជាជាកញ្ចប់ ដោយដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ក្នុងករណីដែលក្រុមហ៊ុនទទួលបានការយល់ព្រមជាមុនជាលាយលក្ខណ៍អក្សរពីអតិថិជនលើការផ្លាស់ប្តូរវិធីសាស្ត្រនៃបញ្ជា ឬអនុវត្តន៍បញ្ជាជាកញ្ចប់ក្នុងគោលបំណងអនុវត្តប្រតិបត្តិការឱ្យបានប្រសើរបំផុត និងត្រូវអនុវត្តតាមការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងការកែប្រែវិធីសាស្ត្របញ្ជា ឬបញ្ជាជាកញ្ចប់ និងបញ្ជាក់ថាបានអនុវត្តការត្រួតពិនិត្យនេះដោយត្រឹមត្រូវ។

## ប្រការ ១៧.- ការហាមឃាត់ការជួញដូរមុន

មុនពេលអនុវត្តបញ្ជារបស់អតិថិជន ចំពោះការទិញ ឬលក់មូលបត្រដែលរំពឹងថាមានផលប៉ះពាល់លើថ្លៃទីផ្សារនៃមូលបត្រនោះ ក្រុមហ៊ុនទទួលបញ្ជាពីអតិថិជនមិនត្រូវ ÷

១-បញ្ជូនបញ្ជាក្នុងគណនីក្រុមហ៊ុន ឬបញ្ជាមិនមែនអតិថិជនទៅក្នុងទីផ្សារ ចំពោះការទិញ-លក់មូលបត្រពាក់ព័ន្ធនោះ

២-បញ្ចុះបញ្ចូលបុគ្គលផ្សេងទៀតឱ្យបញ្ជាទិញ-លក់មូលបត្រពាក់ព័ន្ធនោះ និង

៣-ផ្តល់ដំណឹងពីបញ្ជារបស់អតិថិជនទៅឱ្យបុគ្គលផ្សេងទៀតដែលមិនពាក់ព័ន្ធជាចាំបាច់ជាមួយនឹងដំណើការអាជីវកម្ម និងគោរពតាមលក្ខខណ្ឌតម្រូវទាក់ទងនឹងការរក្សាការសម្ងាត់របស់អតិថិជន។

### ប្រការ ១៨.- អាទិភាពរបស់អតិថិជន

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់អាទិភាពដល់បញ្ជាក្នុងគណនីអតិថិជន មុនបញ្ជាផ្សេងទៀតចំពោះមូលបត្រដូចគ្នា និងថ្លៃដូចគ្នា។

នៅពេលដែលអតិថិជនបញ្ជាទិញមូលបត្រ ក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ជាទិញមូលបត្រនោះដោយប្រើគណនីផ្ទាល់របស់ក្រុមហ៊ុន ឬគណនីមិនមែនអតិថិជន ក្នុងថ្លៃដូច ឬទាបជាងថ្លៃដែលបញ្ជាដោយអតិថិជនឡើយ មុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត។

នៅពេលដែលអតិថិជនបញ្ជាលក់មូលបត្រ ក្រុមហ៊ុនមិនត្រូវបញ្ជាលក់មូលបត្រនោះ ដោយប្រើគណនីក្រុមហ៊ុន ឬគណនីមិនមែនអតិថិជនក្នុងថ្លៃដូច ឬខ្ពស់ជាងថ្លៃដែលបញ្ជាដោយអតិថិជនឡើយ មុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត។

នៅពេលក្រុមហ៊ុនមូលបត្រជួញដូរមូលបត្រជាមួយអតិថិជនជាគូភាគី ក្រុមហ៊ុនមិនត្រូវផ្តល់លក្ខខណ្ឌជួញដូរមិនសមហេតុផលទៅកាន់អតិថិជនដោយបានដឹងពីស្ថានភាពទីផ្សារ និងចំណាយការជួញដូររបស់អតិថិជន។

## ជំពូកទី ៦
## ការផ្តល់ព័ត៌មានទៅកាន់អតិថិជន

### ប្រការ ១៩.- ការផ្តល់ព័ត៌មានមុនពេលធ្វើប្រតិបត្តិការ

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដូចខាងក្រោមទៅកាន់អតិថិជនរបស់ខ្លួន មុននឹងអនុវត្តការជួញដូរមូលបត្ររបស់អតិថិជន ÷

១- សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ។

២-កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ និងពន្ធទាក់ទងនឹងការជួញដូរដែលត្រូវបង់ដោយអតិថិជន ព្រមទាំងវិធីសាស្ត្រគណនា។

៣-ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ។

**ប្រការ ២០.- ការជូនដំណឹងពីហានិភ័យយុទ្ធសាស្ត្រនៃការជួញដូរ**

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវផ្តល់ព័ត៌មានប្រាសចាកពីការពិត ឬ បំផ្លើសអំពីដំណើរការវិនិយោគ (Investment Performance) ដែលពាក់ព័ន្ធនឹងការប្រើប្រាស់យុទ្ធសាស្ត្រនៃការជួញដូរ (Trading Strategies) វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរ (Sytem Trading Program) ដែលអាចនាំឱ្យអតិថិជនយល់ខុស។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជននូវរាល់ហានិភ័យទាក់ទងនឹងយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរ នៅពេលដែលផ្តល់ប្រឹក្សាដល់អតិថិជននោះ។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវផ្តល់ប្រឹក្សាពីយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរដល់អតិថិជន ប្រសិនបើយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរមិនសមស្របចំពោះអតិថិជនដោយផ្អែកលើបទពិសោធន៍ជួញដូរ ចំណេះដឹង លក្ខខណ្ឌហិរញ្ញវត្ថុ សេចក្តីត្រូវការ និងគោលដៅវិនិយោគរបស់អតិថិជន។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ចុះបញ្ចូលអតិថិជនឱ្យប្រើប្រាស់កម្មវិធីប្រព័ន្ធជួញដូរណាមួយ វៀរលែងតែមានហេតុផលជាមូលដ្ឋានដែលបញ្ជាក់ថា អតិថិជនមានការយល់ដឹងច្បាស់ពីកម្មវិធីប្រព័ន្ធជួញដូរនេះ ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍របស់អតិថិជននោះក្នុងការជួញដូរមូលបត្រ។

**ប្រការ ២១.- ការជូនដំណឹងប្រតិបត្តិការជួញដូរមូលបត្រ**

នៅពេលការបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនឱ្យបានឆាប់បំផុតនៅថ្ងៃធ្វើប្រតិបត្តិការទាំងនោះ។ ការជូនដំណឹងត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម ÷

- ប្រភេទមូលបត្រ
- បរិមាណ
- ថ្លៃក្នុងមួយឯកត្តា និងតម្លៃសរុប
- កាលបរិច្ឆេទនៃការជួញដូរ
- កម្រៃជើងសា ថ្លៃសេវា លាភការផ្សេងៗ និងពន្ធទាក់ទងនឹងការជួញដូរដែលត្រូវបង់ដោយអតិថិជន
- ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលធ្វើសកម្មភាពជួញដូរសម្រាប់អតិថិជន
- សេចក្តីបញ្ជាក់ក្រុមហ៊ុនមូលបត្រធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុន ឬក្នុងនាមអតិថិជន
- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុតដែលធ្វើការជួញដូរ និង

- អំពីបញ្ហាដែលផ្អែកលើការអនុវត្តប្រសើរបំផុត (Best Execution) ឬបញ្ហាដែលផ្អែកលើការចង្កូលបង្ហាញរបស់អតិថិជន។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវមានការព្រមព្រៀងជាមួយអតិថិជនជាមុនអំពីវិធីសាស្ត្រនៃការជូនដំណឹង ដូចជាតាមប្រៃសណីយ៍ ការបញ្ជូនទៅដោយផ្ទាល់ ទូរស័ព្ទ ទូរសារ សារអេឡិចត្រូនិក ឬប្រព័ន្ធផ្សេងទៀត ហើយត្រូវធ្វើកំណត់ត្រា និងរក្សាទុកការជូនដំណឹងនេះ។

**ប្រការ ២២.- របាយការណ៍អតិថិជន** (Client Statement)

ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជនអំពីរបាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការនៃខែបន្ទាប់សម្រាប់គណនីដែលមានសកម្មភាពជួញដូរក្នុងអំឡុងខែនោះ។ របាយការណ៍ត្រូវបង្ហាញលម្អិតនូវព័ត៌មានដូចខាងក្រោម ÷

- សមតុល្យដើមគ្រា

- រាល់ឥណពន្ធ និងឥណទានក្នុងអំឡុងពេលប្រតិបត្តិការ

- សមតុល្យចុងគ្រា

-សេចក្តីលម្អិតពីការដាក់ប្រាក់តម្កល់ ឬការដកប្រាក់ក្នុងគណនីសាច់ប្រាក់របស់អតិថិជន ឬពាក់ព័ន្ធនឹងមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន ត្រូវរក្សាទុកនៅកន្លែងតម្កល់មានសុវត្ថិភាព និង

-បរិមាណ និងការបរិយាយពីមូលបត្រដែលបានជួញដូរ ឬបានទទួលក្នុងអំឡុងពេលប្រតិបត្តិការ។

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរតាមរយៈមធ្យោបាយដែលបានព្រមព្រៀងជាមួយអតិថិជន។

សម្រាប់គណនីដែលគ្មានសកម្មភាពជួញដូរ ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជននូវរបាយការណ៍គណនី យ៉ាងហោចណាស់ មួយដងរៀងរាល់ ០៦ (ប្រាំមួយ)ខែនូវព័ត៌មានក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

## ជំពូកទី ៧
## អាកប្បកិរិយាដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម

**ប្រការ ២៣.- ការហាមឃាត់ចំពោះភ្នាក់ងារដែលមិនមានអាជ្ញាបណ្ណ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវអនុញ្ញាតឱ្យបុគ្គលណាមួយ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគក្នុងនាមក្រុមហ៊ុន ឬឧទ្ទេសនាមបុគ្គលទាំងនោះជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគក្នុងនាមក្រុមហ៊ុនឡើយ លើកលែងតែបុគ្គលនោះបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷

១-បុគ្គលនោះជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគបានទទួលអាជ្ញាបណ្ណពី គ.ម.ក. និងធ្វើសកម្មភាពតែក្នុងក្របខណ្ឌនៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុន និងក្របខណ្ឌនៃអាជ្ញាបណ្ណភ្នាក់ងារប៉ុណ្ណោះ និង

២-បុគ្គលនោះមិនមែនជាភ្នាក់ងារនៃក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគដទៃទៀត។

**ប្រការ ២៤.- ការធានាទិញមូលបត្រ និងការសម្ងាត់នៃព័ត៌មាន**

ក្រុមហ៊ុនមូលបត្រមិនត្រូវយកព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួន ឬណែនាំឥតិយជនឱ្យជួញដូរមូលបត្រទាំងនោះឡើយ។

នៅពេលដែលក្រុមហ៊ុនមូលបត្រទទួលបានអាជ្ញាបណ្ណសម្រាប់ធ្វើអាជីវកម្មធានាទិញមូលបត្រព្រមទាំងអាជីវកម្មមូលបត្រផ្សេងទៀត ក្រុមហ៊ុនត្រូវបែងចែកផ្នែកនីមួយៗឱ្យដាច់ដោយឡែកពីគ្នាស្របតាមប្រភេទអាជីវកម្ម ដើម្បីបែងចែកការទទួលខុសត្រូវច្បាស់លាស់ ប្រយោជន៍ធានាឱ្យបានថា ព័ត៌មានសម្ងាត់មិនត្រូវបានចែករំលែករវាងផ្នែកនីមួយៗ។

នៅពេលផ្នែកធានាទិញមូលបត្រនៃក្រុមហ៊ុនមូលបត្របានធ្វើការធានាទិញមូលបត្រ ផ្នែកផ្តល់ប្រឹក្សាវិនិយោគមិនត្រូវផ្តល់ប្រឹក្សាឱ្យជួញដូរមូលបត្រនោះ ក្នុងអំឡុងពេលចាប់ពីចុះកិច្ចសន្យាធានាទិញមូលបត្រជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្ររហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចសន្យាធានាទិញ។

បុគ្គលដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយមិនត្រូវកាន់កាប់តំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬកាន់កាប់ភាគហ៊ុនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយផ្សេងទៀត។

**ប្រការ ២៥.- ការហាមឃាត់ការធានាសងលើការខាតបង់**

ទោះបីដោយផ្ទាល់ ឬប្រយោលក្តី ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវ÷

-ផ្តល់ដល់អតិថិជននូវការធានាប្រាក់ចំណេញអប្បបរមាដែលពាក់ព័ន្ធនឹងការវិនិយោគមូលបត្រ ឬជួញដូរមូលបត្រ ឬ

-ទូទាត់សងទាំងអស់ ឬមួយផ្នែកនៃការខាតបង់ដែលកើតឡើងដោយសារការវិនិយោគមូលបត្រ ឬការជួញដូរមូលបត្ររបស់អតិថិជនតាមគ្រប់រូបភាពណាក៏ដោយរាប់បញ្ចូលទាំងការផ្តល់ជាប្រាក់ ឬការបញ្ចុះតម្លៃជើងសា ឬថ្លៃសេវា ឬការអនុវត្តប្រតិបត្តិការមូលបត្រណាមួយ។

ករណីមានការទូទាត់សងរបស់ក្រុមហ៊ុន ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតត្រូវរាយការណ៍ជាមុនទៅបុគ្គលិកជំនាញផ្នែកច្បាប់។

**ប្រការ ២៦.- ការហាមឃាត់លើការផ្តល់ឱ្យ និងការទទួលអំណោយ និងអត្ថប្រយោជន៍ផ្សេងៗ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្តល់ឱ្យ ឬទទួលនូវគ្រឿងលើកទឹកចិត្ត អំណោយ ឬអត្ថប្រយោជន៍ផ្សេងៗទៅ ឬពីអតិថិជន ឬអតិថិជនសក្តានុពល លើកលែងតែក្នុងករណីដូចខាងក្រោម÷

១- អត្ថប្រយោជន៍ដែលបានផ្តល់នោះមិនប៉ះពាល់ដល់ឯករាជ្យភាពរបស់អ្នកទទួល និង

២-អត្ថប្រយោជន៍នោះត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដោយបុគ្គលិកជំនាញផ្នែកច្បាប់មុនពេលទទួល ឬផ្តល់ឱ្យ។

**ប្រការ ២៧.- ការហាមឃាត់ចំពោះការកំណត់ការប្រកួតប្រជែងមិនស្មោះត្រង់**

ក្រុមហ៊ុនមូលបត្រមិនត្រូវស្នើក្រុមហ៊ុនមូលបត្រដទៃទៀត ឱ្យកែប្រែនូវថ្លៃស្នើលក់ និងថ្លៃស្នើទិញ (Ask and Bid) ឬលក្ខខណ្ឌជួញដូរផ្សេងទៀត ឬកែប្រែអត្រាកម្រៃជើងសាមូលបត្រ ថ្លៃសេវា និងលាភការផ្សេងៗឡើយ ឬចូលរួមសកម្មភាពផ្សេងទៀតក្នុងគោលបំណងកាត់បន្ថយការប្រកួតប្រជែង។

## ជំពូកទី ៨
## កម្រៃជើងសា និងការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ

**ប្រការ ២៨.- កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវមានគោលការណ៍ណែនាំផ្ទៃក្នុង និងនីតិវិធីក្នុងការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន ហើយត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធីទាំងនេះ។ រាល់ការកែប្រែ ឬផ្លាស់ប្តូរចំណុចណាមួយក្នុងគោលការណ៍ណែនាំ និងនីតិវិធីនេះ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវជូនដំណឹងទៅ គ.ម.ក. ក្នុងរយៈពេល ០៧ (ប្រាំពីរ )ថ្ងៃនៃថ្ងៃធ្វើការមុនការផ្លាស់ប្តូរ។

**ប្រការ ២៩.- ការដាក់កំហិតលើការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវធ្វើកិច្ចសន្យាជាមុនជាមួយអតិថិជនណាម្នាក់ ដើម្បីទទួលការទូទាត់ដោយផ្អែកតាមគុណសម្បត្តិនោះទេ។

## ជំពូកទី ៩

## ការផ្សាយពាណិជ្ជកម្ម និងការដាក់បង្ហាញព័ត៌មានទៅកាន់សាធារណជនទូទៅ

**ប្រការ ៣០.- លក្ខខណ្ឌតម្រូវក្នុងការផ្សព្វផ្សាយ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ឬចូលរួម ឬអនុញ្ញាតឱ្យប្រើឈ្មោះរបស់ក្រុមហ៊ុនក្នុងការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ ឬមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួនដែលការផ្សព្វផ្សាយនោះ÷

១- ផ្ទុកនូវការសន្យាមិនសមហេតុផលចំពោះលទ្ធផលជាក់លាក់ណាមួយ

២-ប្រើស្ថិតិមិនមានលក្ខណៈតំណាង ដើម្បីទាញយកសេចក្តីសន្និដ្ឋានដែលគ្មានលក្ខណៈជាក់ច្បាស់ ឬបំផ្លើស ឬខកខានមិនបានបង្ហាញសម្មតកម្មសំខាន់ៗដែលបានប្រើប្រាស់ ដើម្បីឈានទៅរកសេចក្តីសន្និដ្ឋានទាំងនោះ

៣-ផ្ទុកនូវយោបល់ ឬការព្យាករណ៍ព្រឹត្តិការណ៍អនាគតដែលមិនបានបញ្ជាក់ច្បាស់លាស់ថាព័ត៌មានទាំងនេះគ្រាន់តែជាយោបល់ ឬការព្យាករណ៍

៤-មិនបានបង្ហាញឱ្យបានត្រឹមត្រូវពីហានិភ័យទៅអតិថិជន

៥- ធ្វើឱ្យខូចខាតផលប្រយោជន៍សាធារណៈ ឬ

៦-មិនអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរៀបចំគោលនយោបាយ និងនីតិវិធីដែលសមស្របនឹងទំហំ រចនាសម្ព័ន្ធអាជីវកម្ម និងអតិថិជនរបស់ខ្លួនសម្រាប់ការផ្ទៀងផ្ទាត់ឡើងវិញ និងការគ្រប់គ្រងនៃការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន។ រាល់គោលនយោបាយ និងនីតិវិធីត្រូវបានអនុញ្ញាតដោយអគ្គនាយកនៃ គ.ម.ក.។

ឯកសារនៃការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀត និងកំណត់ត្រានៃការត្រួតពិនិត្យគោលនយោបាយ និងនីតិវិធីដែលតម្រូវឱ្យមានក្នុងកថាខណ្ឌទី ២ នៃប្រការនេះត្រូវថតចម្លង និងរក្សាទុកដើម្បីផ្តល់ជូន គ.ម.ក. ឱ្យទាន់ពេលវេលានៅពេលមានការត្រួតពិនិត្យ។

**ប្រការ ៣១.- ការវាយតម្លៃការគ្រប់គ្រង**

ក្រុមហ៊ុនមូលបត្រមិនត្រូវផ្សាយពាណិជ្ជកម្មដោយផ្ទាល់ ឬប្រយោលនូវលទ្ធផលវាយតម្លៃការគ្រប់-គ្រងដែលកំណត់ក្នុងប្រកាសស្ដីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុនៃក្រុមហ៊ុនមូលបត្រ និងមិនត្រូវផ្សាយពាណិជ្ជកម្មកម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ខ្លួន ដើម្បីធ្វើការប្រៀបធៀបជាមួយក្រុមហ៊ុនមូលបត្រដទៃទៀត។

**ប្រការ ៣២.- ការផ្ដល់ព័ត៌មានដែលទាក់ទិននឹងការវិនិយោគវិស័យមូលបត្រ**

នៅពេលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណធ្វើសេចក្ដីថ្លែង ឬប្រកាសជាសាធារណៈ អំពីលក្ខខណ្ឌទីផ្សារ និង/ឬការជួញដូរ និង/ឬការវិនិយោគក្នុងវិស័យមូលបត្រ ក្រុមហ៊ុនត្រូវធ្វើយ៉ាងណាកុំឱ្យមានការយល់ខុសដោយត្រូវពិចារណាលើ÷

១-ព័ត៌មានពាក់ព័ន្ធណាមួយដែលនាំឱ្យមានការយល់ខុសលើខ្លឹមសារទាំងមូល។

២-កម្រិតចំណេះដឹង និងការយល់ដឹងរបស់អ្នកទទួលព័ត៌មាន។

៣-ការផ្ដល់ត្រូវធ្វើឱ្យបានច្បាស់លាស់ដោយបញ្ជាក់ឱ្យបានល្អិតល្អន់ ដើម្បីបំភ្លឺពីភាពស្មុគស្មាញ និងលក្ខណៈពិសេសនៃព័ត៌មាន ។

**ប្រការ ៣៣.- ការផ្ដល់ព័ត៌មានបានមកពីតតិយជន**

នៅពេលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រើប្រាស់ព័ត៌មានទាំងឡាយណាដែលបានមកពីតតិយជនក្នុងគោលបំណងដើម្បីបញ្ចុះបញ្ចូលអតិថិជនឱ្យធ្វើការវិនិយោគ ឬណែនាំឱ្យបុគ្គលណាមួយប្រើប្រាស់ព័ត៌មាននោះ ក្រុមហ៊ុនត្រូវមានហេតុផលជាមូលដ្ឋានដើម្បីធានាថាព័ត៌មានទាំងនោះអាចជឿបាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងអនុវត្តស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង ដើម្បីឱ្យច្បាស់ថាព័ត៌មានដែលទទួលបានពីតតិយជនជាព័ត៌មានដែលមានមូលដ្ឋានអាចជឿបាន ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

## ជំពូកទី ១០

## របាយការណ៍វិភាគស្រាវជ្រាវ និងការផ្ដល់ប្រឹក្សាជួញដូរ

**ប្រការ ៣៤.- ការរៀបចំ និងដាក់បង្ហាញព័ត៌មានដែលបានស្រាវជ្រាវវិភាគ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលធ្វើការផ្សព្វផ្សាយនូវរបាយការណ៍វិភាគស្រាវជ្រាវ ឬព័ត៌មានផ្ដល់ប្រឹក្សាសម្រាប់ការជួញដូរ ÷

១-មិនត្រូវជួញដូរមូលបត្រ ឬមូលបត្រពាក់ព័ន្ធដែលបានវិភាគនៅក្នុងរបាយការណ៍វិភាគស្រាវជ្រាវក្នុងគណនីផ្ទាល់របស់ខ្លួន ក្នុងអំឡុងពេល ០២ (ពីរ)ថ្ងៃ ដែលព័ត៌មាននោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២-ត្រូវមានគោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរដើម្បី÷

ក- កាត់បន្ថយជាអតិបរមានូវទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងពីការរៀបចំរបាយ-ការណ៍វិភាគ និងការផ្តល់ប្រឹក្សា និងការការពាររបាយការណ៍ និងការផ្តល់ប្រឹក្សាកុំឱ្យនៅក្រោមឥទ្ធិពលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬភាគីពាក់ព័ន្ធដទៃទៀត។

ខ- ដាក់កំហិតឱ្យស្ថិតក្រោមការត្រួតពិនិត្យនូវរាល់ការជួញដូរមូលបត្រពាក់ព័ន្ធ របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ។

៣-ត្រូវផ្តល់ព័ត៌មានឱ្យបានទូលំទូលាយនៅក្នុងរបាយការណ៍ស្រាវជ្រាវ ឬការផ្តល់ប្រឹក្សា÷

ក- នូវព័ត៌មានស្តីពីទំនាក់ទំនងអាជីវកម្ម ទំនាក់ទំនងក្រុមហ៊ុន ឬអ្នកវិភាគជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ ហើយព័ត៌មាននេះអាចបង្ហាញពីទំនាស់ផលប្រយោជន៍សក្តានុពលនៅក្នុងការផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ខ- នូវព័ត៌មានអំពីការកាន់កាប់មូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយដោយក្រុមហ៊ុនមូលបត្រ ឬអ្នកវិភាគពាក់ព័ន្ធ ប្រសិនបើមាន។

គ- នូវព័ត៌មានអំពីការទទួលបានកម្រៃ ឬប្រយោជន៍ជាសារវ័ន្តផ្សេងៗពីក្រុមហ៊ុនបោះផ្សាយដោយក្រុមហ៊ុនមូលបត្រ ឬអ្នកវិភាគសម្រាប់ការរៀបចំរបាយការណ៍វិភាគ ឬការផ្តល់ប្រឹក្សា ប្រសិនបើមាន។

ឃ- នូវព័ត៌មានអំពីប្រព័ន្ធសម្រាប់ចំណាត់ថ្នាក់កាលានុវត្តភាពនៃការវិនិយោគ និងភាពត្រឹមត្រូវនៃការផ្តល់ប្រឹក្សាធៀបទៅនឹងប្រព័ន្ធនោះ។

ង- នូវគោលនយោបាយ និងនីតិវិធីរបស់ក្រុមហ៊ុនចំពោះការផ្សព្វផ្សាយនៃការស្រាវជ្រាវ។

៤-មិនត្រូវចេញផ្សាយរបាយការណ៍ស្រាវជ្រាវដែលរៀបចំដោយអ្នកវិភាគ ឬបុគ្គលពាក់ព័ន្ធនឹងអ្នកវិភាគដែលបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ អភិបាល ឬនិយោជិតរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬបម្រើការងារជាអ្នកប្រឹក្សាយោបល់ដល់ក្រុមហ៊ុនបោះផ្សាយ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវជំរុញ ឬលើកទឹកចិត្តដល់ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិត ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្រាវជ្រាវវិភាគឱ្យជួញដូរមូលបត្រនៃក្រុមហ៊ុនបោះផ្សាយមូលបត្រពាក់ព័ន្ធ ដោយមិនមានការអនុញ្ញាតជាមុនពីបុគ្គលិកជំនាញផ្នែកច្បាប់។

## ជំពូកទី ១១
## ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង

### ប្រការ ៣៥.- ការបង្កើត និងការអនុវត្តស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងធានាអោយបាននូវការត្រួតពិនិត្យផ្ទៃក្នុងមួយសមស្រប រួមមានគោលនយោបាយ និងនីតិវិធីបង្កើត និងរក្សាដោយបុគ្គលិកជាន់ខ្ពស់ ដើម្បីចូលរួមចំណែកសម្រេចគោលដៅអាជីវកម្ម ព្រមទាំងធានាបាននូវសណ្តាប់ធ្នាប់ និងប្រសិទ្ធភាពក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដោយអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវកំណត់ឱ្យបានច្បាស់ពីតួនាទីក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ បុគ្គលិកជំនាញផ្នែកច្បាប់ និងបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង។ ករណីមានការធ្វើប្រតិភូកម្មប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងលើដំណើរការអាជីវកម្ម បុគ្គលដែលផ្ទេរសិទ្ធិអំណាច និងបុគ្គលទទួលសិទ្ធិអំណាចត្រូវកំណត់ភារកិច្ចឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ។

### ប្រការ ៣៦.- បុគ្គលិកត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតែងតាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ដើម្បីធ្វើជាបុគ្គលិកត្រួតពិនិត្យផ្ទៃក្នុងដែលធានានូវប្រសិទ្ធភាពការងារ និងឯករាជ្យភាពរបស់ខ្លួនក្នុងការបំពេញភារកិច្ច ។

បុគ្គលិកត្រួតពិនិត្យផ្ទៃក្នុងមានសិទ្ធិត្រួតពិនិត្យឯកសារ និងកំណត់ត្រានានារបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងចូលរួមក្នុងកិច្ចប្រជុំចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការបំពេញភារកិច្ចរបស់ខ្លួន និងអាចរាយការណ៍ទៅនាយកប្រតិបត្តិ និងសវនករផ្ទៃក្នុង ឬគណៈកម្មាធិការសវនកម្ម។

### ប្រការ ៣៧.- យន្តការត្រួតពិនិត្យផ្ទៃក្នុង

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីដែលពាក់ព័ន្ធត្រូវរួមបញ្ចូលទាំងការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈបង្ការទុក និងអង្កេត។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈបង្ការទុកមានគោលបំណងដើម្បីការពារ ឬកាត់បន្ថយឱ្យបានជាអតិបរមានូវការតែបន្លំ ឬកំហុស។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈអង្កេតមានគោលបំណង ដើម្បីស្វែងរកឱ្យឃើញការតែបន្លំ ឬកំហុស សំដៅចាត់វិធានការកែតម្រូវឱ្យបានឆាប់រហ័ស។

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីដែលពាក់ព័ន្ធត្រូវកត់ត្រាជាឯកសារ និងត្រូវបានកែសម្រួល ឬត្រួតពិនិត្យឡើងវិញភ្លាមៗនៅពេលមាននិវិសោធនកម្មច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុងត្រូវបញ្ចូលគ្រប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងនីតិវិធីធ្វើអាជីវកម្ម និងប្រព័ន្ធកុំព្យូទ័រត្រូវរៀបចំឡើងឱ្យសមស្របតាមដំណាក់កាលការងារគ្រប់គ្រង និងធានាសង្គតិភាពជាមួយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ៣៨.- ការពង្រឹងការអនុវត្តត្រួតពិនិត្យផ្ទៃក្នុង**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាឱ្យបាននូវនីតិវិធីដែលអាចឱ្យភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់បានដើម្បីជួយសម្រួលការងារ និងការផ្តល់ប្រឹក្សាគ្រប់ពេលវេលា ក្នុងករណីមានការសាកសួរនានាពាក់ព័ន្ធនឹងផ្លូវច្បាប់ក្នុងពេលដំណើរការអាជីវកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើតនូវកម្មវិធីសិក្សាដល់ភ្នាក់ងាររបស់ខ្លួន ដើម្បីឱ្យពួកគេស្វែងយល់ពីគោលបំណងនៃបទប្បញ្ញត្តិដែលកំណត់ពីកាតព្វកិច្ច និងទង្វើដែលត្រូវបានហាមឃាត់ ហើយត្រូវបង្កើតនូវវគ្គបណ្តុះបណ្តាលសំខាន់ៗនានាជាទៀងទាត់ ឬតាមការចាំបាច់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតាមដានការអនុវត្តច្បាប់ឱ្យទៀងទាត់ ដើម្បីបង្ការទុកជាមុននូវការបំពានច្បាប់ និងស្វែងរកឱ្យឃើញផលប៉ះពាល់នានាដែលអាចធ្វើឱ្យរអាក់រអួលប្រព័ន្ធប្រតិបត្តិការពាក់-ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង។

ករណីរកឃើញការបំពានណាមួយធ្វើឡើងដោយភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ក្រុមហ៊ុនត្រូវចាត់វិធានការភ្លាមៗ និងមានប្រសិទ្ធិភាពដើម្បីការពារការបំពានដដែលៗ តាមរយៈវិធានការវិន័យទៅលើអ្នកប្រព្រឹត្តទាំងនោះ និងកែលម្អចំណុចខ្វះខាតនានានៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាឱ្យបាននូវនីតិវិធីសមស្របក្នុងការដោះស្រាយការតវ៉ារបស់អតិថិជន និងវិវាទរវាងបុគ្គលិកនិងអតិថិជន។

## ជំពូកទី ១២
## ប្រាក់អតិថិជន

**ប្រការ ៣៩.- គណនីសាច់ប្រាក់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីសាច់ប្រាក់អតិថិជននៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ សម្រាប់អតិថិជនណាដែលក្រុមហ៊ុនមូលបត្រត្រូវថែរក្សា និងចាត់ចែងប្រាក់ជំនួស។

ក្រុមហ៊ុនមូលបត្រត្រូវថែរក្សា និងចាត់ចែងជំនួសនូវប្រាក់របស់អតិថិជនដែលជាកម្មសិទ្ធិរបស់អតិថិជន។

ឈ្មោះគណនីសាច់ប្រាក់អតិថិជនត្រូវមានពាក្យ "គណនីសាច់ប្រាក់អតិថិជន" និងត្រូវតែបើកសម្រាប់តែអតិថិជនរបស់ក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនទាំងនោះប៉ុណ្ណោះ។

រាល់ប្រាក់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រត្រូវតែដាក់តម្កល់ នៅក្នុងគណនីសាច់ប្រាក់អតិថិជន។ ក្រុមហ៊ុនមូលបត្រមិនត្រូវដាក់តម្កល់ប្រាក់អតិថិជន នៅក្នុងគណនីណាផ្សេងពីគណនីសាច់ប្រាក់អតិថិជនឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន។ ក្រុមហ៊ុនមូលបត្រអាចដាក់ប្រាក់ដែលទទួលបានពីអតិថិជនលាយឡំ និងតម្កល់នៅក្នុងគណនីសាច់ប្រាក់អតិថិជនដូចគ្នាបាន លុះត្រាតែក្រុមហ៊ុនមូលបត្រធ្វើ និងរក្សាកំណត់ត្រាត្រឹមត្រូវសម្រាប់អតិថិជននីមួយៗនៅក្នុងសៀវភៅធំអតិថិជនដែលមាននៅក្នុងគណនីផ្ទៃក្នុងរបស់ក្រុមហ៊ុនមូលបត្រ ដើម្បីងាយស្រួលក្នុងការស្វែងរកគ្រប់ពេលវេលានូវប្រាក់អតិថិជនដែលជាកម្មសិទ្ធិរបស់អតិថិជននីមួយៗ។

ក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់ប្រាក់អតិថិជនដែលទទួលបានក្នុងគណនីសាច់ប្រាក់អតិថិជនភ្លាមមិនឱ្យហួសពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រុមហ៊ុនមូលបត្រទទួលបានប្រាក់នោះ ឬថ្ងៃដែលបានបញ្ជាក់ថាបានទទួលប្រាក់ លើកលែងតែប្រាក់នោះត្រូវតម្កល់ទុកក្នុងគណនីណាមួយតាមបញ្ជាអតិថិជន។

រាល់ការបើកគណនីសាច់ប្រាក់អតិថិជន ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់ គ.ម.ក. ពីការបើកគណនីនោះ។

រាល់ការដាក់តម្កល់ប្រាក់អតិថិជនក្នុងគណនីសាច់ប្រាក់អតិថិជន ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់អតិថិជនពីទីកន្លែង និងឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងរបៀបនៃការរក្សាទុកប្រាក់នោះ។

ក្រុមហ៊ុនមូលបត្រមានកាតព្វកិច្ចពាក់ព័ន្ធនឹងប្រាក់អតិថិជនរហូតដល់ ÷

១-អតិថិជនបានទទួលប្រាក់គ្រប់ចំនួនពីក្រុមហ៊ុនមូលបត្រ។

២-កម្មសិទ្ធិលើមូលបត្ររបស់អតិថិជនបានចុះបញ្ជីនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

**ប្រការ ៤០.- ការរក្សាទុកកំណត់ត្រា**

ក្រុមហ៊ុនមូលបត្រត្រូវ ÷

១-ធ្វើកំណត់ត្រាលើលំហូរចេញ-ចូលនៃគ្រប់ប្រតិបត្តិការនៅក្នុងគណនីសាច់ប្រាក់អតិថិជននីមួយៗ ។

២-ផ្ទៀងផ្ទាត់ប្រចាំថ្ងៃរវាងកំណត់ត្រាសម្រាប់គណនីសាច់ប្រាក់អតិថិជននីមួយៗ ជាមួយកំណត់ត្រារបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវជូនដំណឹងដល់ គ.ម.ក. ក្នុងករណីក្រុមហ៊ុនមូលបត្រមិនអាចធ្វើការផ្ទៀងផ្ទាត់ប្រចាំថ្ងៃ។

**ប្រការ ៤១.- ការគាំពារគណនីសាច់ប្រាក់អតិថិជន**

ប្រាក់អតិថិជនដែលតម្កល់ទុកក្នុងគណនីសាច់ប្រាក់អតិថិជនមិនត្រូវជាប់ពាក់ព័ន្ធនឹង ឬយកទៅប្រើប្រាស់សម្រាប់ការទូទាត់ បន្ទុក ឬបន្ទុកលើបញ្ហា ឬដំណើរផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នា លើកលែងតែមានការអនុញ្ញាតពីបុគ្គលដែលមានសិទ្ធិលើប្រាក់នោះ។

ក្រុមហ៊ុនមូលបត្រមិនត្រូវប្រើប្រាស់ប្រាក់អតិថិជនដែលថែរក្សា និងចាត់ចែងជំនួសអតិថិជននៅក្នុងគណនីសាច់ប្រាក់អតិថិជន ដើម្បីទូទាត់បំណុល និងមិនត្រូវដកប្រាក់នោះចេញពីគណនីឡើយ លើកលែងតែករណីដូចដែលបានចែងក្នុងប្រការ ៤៤ នៃប្រកាសនេះ។

ក្រុមហ៊ុនមូលបត្រមិនត្រូវរក្សាទុកប្រាក់ដែលទទួលបានសម្រាប់ផលប្រយោជន៍អតិថិជនឱ្យលាយឡំជាមួយប្រាក់ផ្ទាល់របស់ក្រុមហ៊ុន និងមិនត្រូវប្រើប្រាស់ប្រាក់នោះជាប្រាក់ចំណេញ ឬការធានា ឬជាកិច្ចធានាប្រតិបត្តិការណាមួយ ឬការផ្តល់ឥណទានដល់បុគ្គលណាមួយឡើយ។

ដោយអនុលោមតាមច្បាប់ស្តីពីក្ស័យធន ប្រាក់អតិថិជនដែលតម្កល់ទុកក្នុងគណនីសាច់ប្រាក់អតិថិជនមិនត្រូវដកចេញពីទ្រព្យសកម្មរបស់បុគ្គលណាផ្សេងក្រៅពីអតិថិជនឡើយ ហើយមិនត្រូវយកទៅប្រើប្រាស់ដើម្បីទូទាត់បំណុលរបស់ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឬបុគ្គលណាផ្សេង ក្នុងករណីអសាធនីយភាព ការជម្រះបញ្ជី ការគ្រប់គ្រងបណ្តោះអាសន្ន ឬព្រឹត្តិការណ៍ស្រដៀងគ្នាពាក់ព័ន្ធនឹងបុគ្គលទាំងនេះ។ បុគ្គលជម្រះបញ្ជី អភិបាលបណ្តោះអាសន្ន ឬបុគ្គលដែលកាន់តំណែងប្រហាក់ប្រហែល មិនមានសិទ្ធិចាត់ទុកទ្រព្យសកម្មនៅក្នុងគណនីសាច់ប្រាក់អតិថិជនជាទ្រព្យសកម្មរបស់បុគ្គលដទៃទៀតក្រៅពីអតិថិជន។

**ប្រការ ៤២.- ប្រាក់អតិថិជន**

ប្រាក់ក្នុងគណនីសាច់ប្រាក់អតិថិជនដែលក្រុមហ៊ុនមូលបត្រទទួលបានស្របតាមប្រកាសនេះ រួមមាន ÷

១- ប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់ធ្វើការទិញមូលបត្រ ឬថែរក្សា និងចាត់ចែងមូលបត្រជំនួស ឬប្រាក់ទទួលបានពីសេវាថែរក្សាគណនីជួញដូរមូលបត្រ។

២- ប្រាក់ដែលទទួលបានពីការលក់មូលបត្រសម្រាប់ផលប្រយោជន៍អតិថិជន។

៣- រាល់ប្រាក់ផ្សេងទៀតទទួលពី ឬសម្រាប់ផលប្រយោជន៍អតិថិជនក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ។

ប៉ុន្តែប្រាក់អតិថិជនមិនរាប់បញ្ចូល ÷

ក- ប្រាក់ប្រើសម្រាប់សងបំណុលដែលអតិថិជនជំពាក់ក្រុមហ៊ុនមូលបត្រ។

ខ-ប្រាក់ដែលត្រូវទូទាត់ថ្លៃសេវា និងកម្រៃជើងសា និងបន្ទុកចំណាយដែលពាក់ព័ន្ធផ្សេងទៀតទៅឱ្យក្រុមហ៊ុនមូលបត្រ។

គ-ប្រាក់ដែលត្រូវទូទាត់ឱ្យទៅបុគ្គលដែលមានសិទ្ធិទទួលប្រាក់នោះ។

**ប្រការ ៤៣.- ការជូនដំណឹង និងការទទួលស្គាល់ពីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

មុននឹងបញ្ចូលប្រាក់ដែលទទួលបានពីអតិថិជន ទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលរក្សាទុកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ប្រការ ៣៩ នៃប្រកាសនេះ ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូល-បត្រនោះ និងទាមទារយកលិខិតទទួលស្គាល់មកវិញដើម្បីបញ្ជាក់ថា រាល់ប្រាក់ដែលបានបញ្ចូលក្នុងគណនីសាច់ប្រាក់អតិថិជនត្រូវបានថែរក្សា និងចាត់ចែងជំនួសដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនរបស់ខ្លួនដោយអនុលោមតាមប្រការ ៣៩ និង ៤១ នៃប្រកាសនេះ ហើយភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវអនុវត្តតាមប្រការ ៣៩ និង ៤១ ខាងលើ។ លិខិតទទួលស្គាល់ពីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវមានទម្រង់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. និងត្រូវចុះហត្ថលេខាដោយអ្នកតំណាងរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤៤.- ការដកប្រាក់អតិថិជនពីគណនីសាច់ប្រាក់អតិថិជន**

ក្រុមហ៊ុនមូលបត្រមិនត្រូវដកប្រាក់អតិថិជនចេញពីគណនីសាច់ប្រាក់អតិថិជនឡើយ លើកលែងករណីដូចខាងក្រោម÷

១-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ទៅឱ្យបុគ្គលណាមួយដែលមានសិទ្ធិទទួល។

២-នៅពេលអតិថិជនធ្វើការជួញដូរមូលបត្រ ក្រុមហ៊ុនមូលបត្រមានកាតព្វកិច្ចទូទាត់ក្នុងនាមអតិថិជនដែលទុកប្រាក់ក្នុងគណនីនោះ។

៣-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ថ្លៃសេវា កម្រៃជើងសាមូលបត្រ និងបន្ទុកចំណាយផ្សេងទៀតដែលអតិថិជនត្រូវបង់។

៤-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ទៅឱ្យបុគ្គល ឬគណនីផ្សេងយោងតាមការស្នើរបស់អតិថិជនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

៥-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ ឬដកប្រាក់ដែលតម្រូវដោយច្បាប់។

**ប្រការ ៤៥.- ការប្រាក់ដែលកើតពីគណនីសាច់ប្រាក់អតិថិជន**

រាល់ការប្រាក់ដែលអតិថិជនទទួលបានពីការរក្សាទុកប្រាក់ក្នុងគណនីសាច់ប្រាក់អតិថិជនត្រូវទូទាត់ឱ្យអតិថិជន ដោយគោរពតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនមូលបត្រ និងអតិថិជន។

## ជំពូកទី ១៣
## មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន

**ប្រការ ៤៦.- កាតព្វកិច្ចក្រុមហ៊ុនមូលបត្រនៅពេលទទួលមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវចាត់ចែងឱ្យមានអ្នកថែរក្សា ដើម្បីគ្រប់គ្រងថែរក្សាមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងទៀត។ ក្នុងករណីជាមូលបត្រត្រូវរក្សាទុកនៅក្នុងប្រតិបត្តកររក្សាទុកមូលបត្រ។

ក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនជាមួយនឹងអ្នកថែរក្សាភ្លាម មិនឱ្យហួសពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រុមហ៊ុនមូលបត្រទទួលបានមូលបត្រ ឬទ្រព្យ-សម្បត្តិផ្សេងៗនោះ ឬថ្ងៃដែលបានបញ្ជាក់ថាបានទទួលមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងៗ លើកលែងតែមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងៗនោះត្រូវតម្កល់ទុកក្នុងគណនីណាមួយតាមបញ្ជាអតិថិជន។

**ប្រការ ៤៧.- ព័ត៌មាន និងការទទួលដំណឹងពីអ្នករក្សាទុក**

ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នករក្សាទុក (Custody Provider) អំពីមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនដែលត្រូវដាក់តម្កល់ និងទទួលបានលិខិតទទួលស្គាល់ពីអ្នករក្សាទុកវិញ ដែលលិខិតនោះត្រូវបញ្ជាក់ថា ÷

១-រាល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនដែលរក្សាទុកក្នុងគណនីរក្សាទុកត្រូវបានថែរក្សា និងចាត់ចែងជិនួសដាច់ដោយឡែក ដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនរបស់ខ្លួន។

២-មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនត្រូវបែងចែកឱ្យបានច្បាស់ និងត្រូវរក្សាទុកដាច់ដោយឡែកពីគណនីរបស់ក្រុមហ៊ុនមូលបត្រដែលបានដាក់តម្កល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ខ្លួនផ្ទាល់។

**ប្រការ ៤៨.- ការដក ឬផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន**

ក្រុមហ៊ុនមូលបត្រមិនត្រូវដក ឬផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតណាមួយរបស់អតិថិជនពីគណនីរក្សាទុក លើកលែងតែ ÷

១- ការផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតទៅបុគ្គលណាមួយដែលមានសិទ្ធិទទួល។

២- ការបំពេញកាតព្វកិច្ចរបស់អតិថិជនដែលកើតមានពីការជួញដូរមូលបត្រធ្វើឡើងដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជន។

៣- ការផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតទៅបុគ្គល ឬគណនីណាមួយស្របតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់អតិថិជន។

៤- ការផ្ទេរណាមួយដែលតម្រូវដោយច្បាប់។

## ជំពូកទី ១៤
## ការកត់ត្រា និងការចុះបញ្ជី

### ប្រការ ៤៩.- វិធានកត់ត្រា និងចុះបញ្ជី

អនុលោមតាមមាត្រា ៤៦ នៃអនុក្រឹត្យ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធ្វើការកត់ត្រា និងចុះបញ្ជីអំពីសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយត្រូវរក្សាទុកបញ្ជីនេះយ៉ាងតិច ១០ (ដប់) ឆ្នាំ និងតាមវិធានដូចខាងក្រោម÷

១- ទិន្នានុប្បវត្តិដែលមានកំណត់ត្រាលម្អិតប្រចាំថ្ងៃនូវរាល់ប្រតិបត្តិការទិញ និងលក់មូលបត្រទាំងអស់ រាល់ការកត់ត្រាលំហូរនៃការទទួល និងបញ្ជូនមូលបត្រ រាប់បញ្ចូលចំនួនវិក័យបត្រ រាល់ការកត់ត្រាលំហូរប្រាក់ទទួល និងការចំណាយ ព្រមទាំងការកត់ត្រាឥណពន្ធ និងឥណទានផ្សេងទៀត។ កំណត់ត្រាទាំងនេះត្រូវបង្ហាញពីគណនីពាក់ព័ន្ធក្នុងប្រតិបត្តិការនីមួយៗដោយត្រូវមាន ឈ្មោះ និងចំនួនមូលបត្រ ថ្លៃលក់ ឬទិញក្នុងមួយឯកតា និងថ្លៃសរុប កាលបរិច្ឆេទជួញដូរ កាលបរិច្ឆេទការជាត់ទាត់និងទូទាត់ ព្រមទាំងឈ្មោះ និងហត្ថលេខារបស់បុគ្គលដែលបានទិញ ឬលក់ ឬប្រគល់ ឬបញ្ជូនទៅឱ្យ។

២- សៀវភៅធំដែលឆ្លុះបញ្ចាំងពីទ្រព្យសកម្មនិងបំណុល ចំណូលនិងចំណាយ ព្រមទាំងដើមទុនរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ។ សៀវភៅធំកត់ត្រាប្រតិបត្តិការត្រូវបង្កើតឡើងដោយផ្អែកលើសេចក្តីបញ្ជាក់ពីប្រតិបត្តិការដែលផ្ញើជូនអតិថិជន ហើយសៀវភៅធំកត់ត្រាប្រតិបត្តិការនេះមានព័ត៌មានដូចជា: កាលបរិច្ឆេទប្រតិបត្តិការ ប្រភេទប្រតិបត្តិការទិញឬលក់ ថ្លៃ កម្រៃជើងសា និងការចំណាយ កាលបរិច្ឆេទជាត់ទាត់និងទូទាត់ ឈ្មោះនិងអាសយដ្ឋានរបស់អ្នកទិញ និងអ្នកលក់ លេខសម្គាល់ប្រតិបត្តិការ បរិមាណមូលបត្រជួញដូរ វិធីសាស្ត្រ ជាត់ទាត់និងទូទាត់ និងព័ត៌មានអំពីការជាត់ទាត់និងទូទាត់នៃប្រតិបត្តិការជួញដូរ។

៣- កំណត់ត្រានៃការបញ្ជាមូលបត្រនីមួយៗទៅតាមលំដាប់លំដោយនៃកាលបរិច្ឆេទ ដោយបង្ហាញពីកាលបរិច្ឆេទទទួលបញ្ជា លក្ខខណ្ឌនៃបញ្ជា ការកែប្រែឬការលុបចោលបញ្ជា គណនីដែលបញ្ជា កាល-

បរិច្ឆេទ ការអនុវត្តបញ្ជាទៅទីផ្សារ ថ្លៃនៅពេលអនុវត្តបញ្ជា កាលបរិច្ឆេទនៃការអនុវត្ត ឬការលុបចោលប្រតិបត្តិការ។

៤-ឯកសារពាក់ព័ន្ធនឹងការអនុវត្តបញ្ជារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

៥-កំណត់ត្រាដែលទាក់ទងនឹងសកម្មភាពត្រួតពិនិត្យផ្ទៃក្នុងមានដូចខាងក្រោម÷

ក-ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងការអនុវត្តច្បាប់របស់ក្រុមហ៊ុនមូលបត្រ។

ខ-តួនាទី និងសកម្មភាពនៃបុគ្គលិកជំនាញផ្នែកច្បាប់ដែលចុះផ្ទាល់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង។

គ-ទិន្នន័យពិស្តារ និងលទ្ធផលនៃដំណើការសវនកម្មផ្ទៃក្នុង។

៦-កំណត់ត្រា និងការរក្សាទុកនូវរាល់ការតវ៉ាជាលាយលក្ខណ៍អក្សរព្រមទាំងឯកសារឆ្លើយតបចំពោះពាក្យបណ្តឹង និងសំណុំឯកសារប្រើប្រាស់ផ្សេងៗទៀត។

៧-ក្រុមហ៊ុនទទួលអាជ្ញាបណ្ណត្រូវរក្សាទុកផងដែរនូវកំណត់ត្រា និងឯកសារ÷

ក-របាយការណ៍ធនាគារ និងគណនីផ្ទៀងផ្ទាត់ធនាគារ។

ខ-ភស្តុតាងនៃមូលប្បទានបត្រដែលបានទូទាត់ មូលប្បទានបត្រដែលបានលុបចោលប្រសិនបើមាន។

គ-រាល់កិច្ចព្រមព្រៀងដែលធ្វើឡើងរវាងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងអតិថិជនរបស់ខ្លួនយោងតាមប្រការ ៦ នៃប្រកាសនេះ។

ឃ-រាល់វិក័យបត្រផ្ទេរទ្រព្យសម្បត្តិរបស់អតិថិជនដែលបង្ហាញពីបុគ្គលឈរឈ្មោះកាន់កាប់ទ្រព្យសម្បត្តិ។

ង-រាល់របាយការណ៍ សំបុត្រ សេចក្តីណែនាំ អនុស្សរណៈ សេចក្តីប្រកាស ការផ្សព្វផ្សាយ និងការផ្តល់ប្រឹក្សាដែលក្រុមហ៊ុនមូលបត្របញ្ជូនទៅឱ្យអតិថិជនដែលមានបង្ហាញពីកាលបរិច្ឆេទ។

ច-អាជ្ញាបណ្ណ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗដែលចេញដោយអាជ្ញាធរ។

ឆ-របាយការណ៍ផ្សេងទៀតដែលបានរៀបចំ ឬទទួលបានក្នុងដំណើរការអាជីវកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវកត់ត្រាគ្រប់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ ដោយអនុវត្តតាមស្តង់ដារទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ព្រមទាំងបទប្បញ្ញត្តិដែលចេញដោយ គ.ម.ក.។

ប្រព័ន្ធកត់ត្រាដែលបានប្រើត្រូវមានការការពារគ្រប់ជ្រុងជ្រោយ ចៀសវាងនូវកំហុសនៃការកត់ត្រា។

ប្រព័ន្ធកត់ត្រាដែលយកមកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានឆាប់រហ័ស ត្រឹមត្រូវ និងងាយយល់សម្រាប់អ្នកពាក់ព័ន្ធ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរៀបចំជាស្រេចនូវឯកសារបញ្ជីស្នាមនានា ដោយធ្វើជារបាយ-ការណ៍ និងត្រូវបញ្ជូនទៅ គ.ម.ក. ។

## ជំពូកទី ១៥
## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ៥០.- ការផ្លាស់ប្តូរកម្មសិទ្ធិអាជ្ញាបណ្ណ

ក្រុមហ៊ុនទទួលអាជ្ញាបណ្ណមិនត្រូវផ្លាស់ប្តូរ រចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធរូបវន្ត ឬរចនាសម្ព័ន្ធកម្មសិទ្ធិនៃក្រុមហ៊ុនរួមមាន ការបោះផ្សាយ ឬការផ្ទេរភាគហ៊ុន ឬផ្ទេរកម្មសិទ្ធិក្រុមហ៊ុន ដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។

### ប្រការ ៥១.- ការជួញដូររបស់និយោជិត

និយោជិតរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ដែលមានបំណងជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់របស់ពួកគេ ឬគណនីភាគីពាក់ព័ន្ធ ឬក្នុងនាមគណនីដែលពួកគេមានផលប្រយោជន៍ត្រូវទទួលការអនុញ្ញាតឱ្យជួញដូរជាលាយលក្ខណ៍អក្សរពីបុគ្គលិកជំនាញផ្នែកច្បាប់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតម្រូវឱ្យនិយោជិតបញ្ជាក់ជាលាយលក្ខណ៍អក្សរប្រចាំឆ្នាំ អំពីការអនុវត្តកាតព្វកិច្ចតាមការអនុញ្ញាត ដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ប្រចាំថ្ងៃទៅលើការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ និងការជួញដូររបស់និយោជិតសម្រាប់គណនីផ្ទាល់របស់ពួកគេ ឬគណនីភាគីពាក់ព័ន្ធ ឬក្នុងនាមគណនីដែលពួកគេមានផលប្រយោជន៍។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរក្សាទុកឱ្យបានត្រឹមត្រូវនូវកំណត់ត្រា ៖

ក- ការអនុញ្ញាតឱ្យជួញដូរមូលបត្រជាលាយលក្ខណ៍អក្សរដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ខ- ការទទួលយកអនុវត្តតាមកាតព្វកិច្ចរបស់និយោជិតដែលចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ និងការផ្ទៀងផ្ទាត់ប្រចាំថ្ងៃដែលមានចែងក្នុងកថាខណ្ឌទី ៣ នៃប្រការនេះ។

### ប្រការ ៥២.- ដែនកំណត់នៃការលក់មូលបត្របោះផ្សាយដោយក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវផ្តល់ប្រឹក្សាទៅឱ្យអតិថិជនក្នុងការទិញមូលបត្ររបស់ខ្លួនដែលបានបោះផ្សាយរួចហើយ ឬរំពឹងថានឹងបោះផ្សាយ។

### ប្រការ ៥៣.- ការដាក់កំហិតលើការជួញដូរក្រៅទីផ្សារ

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវជំរុញឱ្យមានជួញដូរមូលបត្រចុះបញ្ជីនៅក្រៅទីផ្សារមូលបត្រប្រតិស្រុត។

## ជំពូកទី ១៦
## ទោសប្បញ្ញត្តិ

**ប្រការ ៥៤.- ទណ្ឌកម្មចំពោះការមិនគោរពបទប្បញ្ញត្តិនៃប្រកាសនេះ**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលប្រព្រឹត្តល្មើស ឬខកខានមិនបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៥៥ នៃប្រកាសនេះ និង/ឬការផាកពិន័យអន្តរការណ៍ពី គ.ម.ក. ជាប្រាក់÷

-ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល។

-ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០(ពីរយលាន) រៀល ចំពោះនីតិបុគ្គល។

**ប្រការ ៥៥.- ទណ្ឌកម្មរដ្ឋបាល**

ចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ អគ្គនាយកនៃ គ.ម.ក. អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

-ការព្រមាន។

-បទបញ្ជាឱ្យកែតម្រូវ។

-ការព្យួរ ឬការបណ្តេញចេញពីមុខតំណែងនូវអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់។

-ការដាក់កំហិតលើអាជ្ញាបណ្ណ។

-ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ។

## ជំពូកទី ១៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥៦.- គោលការណ៍ណែនាំផ្សេងៗ**

គ.ម.ក. អាចចេញនូវគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៥៧.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៨.-ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានអង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**គាត ឈន់**

**ចម្លងជូន ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធស្ដីពីពាក្យស្នើសុំបើកគណនី

ប្រកាសលេខ..០០៨/១១ គ.ម.ក.ប្រ.ក

ចុះថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១១

| ឈ្មោះក្រុមហ៊ុនមូលបត្រ....................................<br>ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ........................ | កាលបរិច្ឆេទនៃការស្នើសុំ<br>.................................. | លេខគណនី<br>.................................. |
|---|---|---|

ប្រភេទគណនី .................................................. រូបវន្តបុគ្គល ..................................................

ស្ថាប័ន ..........................................................................................................................

ឈ្មោះអតិថិជន (នាម និងគោត្តនាម) .................................................. ជាអក្សរឡាតាំង...............

លេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី គ.ម.ក...........ថ្ងៃ ខែ ឆ្នាំកំណើត.............. សញ្ជាតិ.......

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន........................ កាលបរិច្ឆេទផុតសុពលភាព.................

ចេញដោយ.......................... លេខទូរស័ព្ទ........................................ លេខទូរសារ...................

អ៊ីម៉ែល............................................ អាសយដ្ឋានទំនាក់ទំនង..................................................

......................................................................................................................................

លក្ខន្តិកៈគ្រួសារ ☐ នៅលីវ ☐ មានគ្រួសារ ☐ លែងលះ

មុខរបរ.................................................................... មុខតំណែង...............................................

អាសយដ្ឋានកន្លែងធ្វើការ............................................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ............................................ ប្រភេទអាជីវកម្ម......................................

រយៈពេលនៃអតីតភាពការងារ.......................................................................................................

ឈ្មោះសហព័ទ្ធ (នាម និង គោត្តនាម) ...............................................................................................

ជាអក្សរឡាតាំង...........................................................................................................................

មុខរបរ................................................... មុខតំណែង ..................................................................

អាសយដ្ឋានកន្លែងធ្វើការ............................................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ............................................ ប្រភេទអាជីវកម្ម......................................

រយៈពេលនៃអតីតភាពការងារ.......................................................................................................

ចំណេះដឹងលើការវិនិយោគ

☐ ល្អណាស់ ☐ ល្អ ☐ មានកម្រិត ☐ គ្មាន

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគ

☐ បណ្ណរតនាគារ ☐ ភាគហ៊ុន ☐ សញ្ញាបណ្ណ ☐ មូលបត្រផ្សេងទៀត ☐ គ្មាន

ឯកសារធនាគាររបស់អតិថិជន

ឈ្មោះធនាគារ .......................................................................................................

លេខគណនីធនាគារ...................................................................................................

ប្រភេទគណនីធនាគារ.................................................................................................

បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់

ឈ្មោះ (នាម និង គោត្តនាម)....................................ជាអក្សរឡាតាំង..................................

អាសយដ្ឋានទំនាក់ទំនង.............................................................................................

លេខទូរស័ព្ទ........................ លេខទូរសារ ............................. អ៊ីម៉ែល ..............................

ទំនាក់ទំនងរវាងភ្នាក់ងារក្រុមហ៊ុនមូលបត្រ និង អតិថិជន:

☐ ញាតិសន្តាន ☐ ស្គាល់តាមរយៈការណែនាំ (ឈ្មោះអ្នកណែនាំ................................)

☐ មិត្តភក្តិ ☐ ពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នា ☐ ផ្សេងៗ..............................

ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី

☐ អត្តសញ្ញាណបណ្ណថតចំលង ☐ សៀវភៅគ្រួសារថតចំលង ☐ លិខិតឆ្លងដែន

ឬទិដ្ឋការថតចំលង ☐ សៀវភៅធនាគារថតចំលង (រយៈពេល ០៦ ខែចុងក្រោយ)

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ.........................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

<table>
<tr>
<td>ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ..............................<br>ធ្វើនៅថ្ងៃទី..........ខែ.........ឆ្នាំ...<br>..........................................</td>
<td>ហត្ថលេខារបស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬអ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ<br>.......................................<br>ធ្វើនៅថ្ងៃទី.......ខែ.......ឆ្នាំ.......</td>
<td>ហត្ថលេខារបស់អតិថិជន<br>.......................................<br>ធ្វើនៅថ្ងៃទី..........ខែ..........<br>ឆ្នាំ...................................</td>
</tr>
<tr>
<td colspan="3">ការព្រមព្រៀងលើការផ្ទេរសិទ្ធិ<br>អតិថិជន ក្រុមហ៊ុន</td>
</tr>
</table>

## ឧបសម្ព័ន្ធស្តីពីពាក្យស្នើសុំផ្តល់ប្រឹក្សា

ប្រកាសលេខ..០០៩/១១ គ.ម.ក./ប្រ.ក.

ចុះថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១១

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ......................<br>ឈ្មោះភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ.................... | កាលបរិច្ឆេទនៃការស្នើសុំ<br>............................................................ |

ឈ្មោះអតិថិជន(នាម និង គោត្តនាម).................................ជាអក្សរឡាតាំង ........................

ថ្ងៃ ខែ ឆ្នាំកំណើត ........................................................ សញ្ញាតិ ....................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន.................................................................................

កាលបរិច្ឆេទផុតសុពលភាព........................ចេញដោយ.............................................................

លេខទូរស័ព្ទ...............................លេខទូរសារ...............................អ៊ីម៉ែល ...........................

អាសយដ្ឋានទំនាក់ទំនង.............................................................................................................

លក្ខន្តិកៈគ្រួសារ ☐ នៅលីវ ☐ មានគ្រួសារ ☐ លែងលះ

មុខរបរ.......................................................មុខតំណែង ......................................................

អាសយដ្ឋានកន្លែងធ្វើការ............................................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ..................................ប្រភេទអាជីវកម្ម.............................................

រយៈពេលនៃអតីតភាពការងារ........................................................................................................

ឈ្មោះសហព័ទ្ធ (នាម និង គោត្តនាម) .................................ជាអក្សរឡាតាំង.........................

មុខរបរ.......................................................មុខតំណែង ......................................................

អាសយដ្ឋានកន្លែងធ្វើការ............................................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ ..........................................................................................................

ប្រភេទអាជីវកម្ម.............................................រយៈពេលនៃអតីតភាពការងារ ......................

ចំណេះដឹងលើការវិនិយោគ

☐ ល្អណាស់ ☐ ល្អ ☐ មានកម្រិត ☐ គ្មាន

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគ

☐ បណ្ណរតនាគារ ☐ ភាគហ៊ុន ☐ សញ្ញាបណ្ណ ☐ មូលបត្រផ្សេងទៀត ☐ គ្មាន

ឯកសារធនាគាររបស់អតិថិជន

ឈ្មោះធនាគារ..........................................................................................................

លេខគណនីធនាគារ....................................................................................................

ប្រភេទគណនីធនាគារ.................................................................................................

---

បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់

ឈ្មោះ (នាម និង គោត្តនាម)...................................ជាអក្សរឡាតាំង ....................................

អាសយដ្ឋានទំនាក់ទំនង..............................................................................................

លេខទូរស័ព្ទ.............................លេខទូរសារ .............................អ៊ីម៉ែល.............................

---

ទំនាក់ទំនងរវាងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និង អតិថិជន:

☐ ញាតិសន្តាន ☐ ស្គាល់តាមរយៈការណែនាំ (ឈ្មោះអ្នកណែនាំ................................)

☐ មិត្តភក្តិ ☐ ពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នា ☐ ផ្សេងៗ...............................

---

ឯកសារភ្ជាប់សម្រាប់ផ្តល់ប្រឹក្សា

☐ អត្តសញ្ញាណបណ្ណថតចំលង ☐ សៀវភៅគ្រួសារថតចំលង ☐ លិខិតឆ្លងដែន

ឬ ទិដ្ឋការថតចំលង ☐ សៀវភៅធនាគារថតចំលង (រយៈពេល ០៦ ខែចុងក្រោយ)

---

យោបល់របស់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ.....................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

| | | |
|---|---|---|
| ហត្ថលេខារបស់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ<br><br>.......................................<br>ធ្វើនៅថ្ងៃទី.......ខែ......ឆ្នាំ.......... | ហត្ថលេខារបស់ប្រធានភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ឬអ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ<br><br>.......................................<br>ធ្វើនៅថ្ងៃទី........ខែ......ឆ្នាំ........ | ហត្ថលេខារបស់អតិថិជន<br><br>.................................<br>ធ្វើនៅថ្ងៃទី......ខែ......ឆ្នាំ..... |

ការព្រមព្រៀងលើការផ្ទេរសិទ្ធិ

អតិថិជន ក្រុមហ៊ុន

# ឧបសម្ព័ន្ធស្តីពីទម្រង់នៃកិច្ចព្រមព្រៀងអតិថិជន

**ប្រកាសលេខ...០០៧/១១...គ.ម.ក.ប្រ.ក.**

ចុះថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០១១

ទីកន្លែង និងកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងៈ.................................

កិច្ចព្រមព្រៀងរវាង÷

- ក្រុមហ៊ុន :

ឈ្មោះ.........................................អាសយដ្ឋាន...........................................................

ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណចុះបញ្ជីនៅ....................................................ប្រទេសកម្ពុជា

ភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ...............................................................................

និង

- អតិថិជន :

ឈ្មោះ.........................................អាសយដ្ឋាន.......................................................

លេខអត្តសញ្ញាណបណ្ណ/លេខលិខិតឆ្លងដែន........................លេខបញ្ជីពាណិជ្ជកម្ម (ករណីជាស្ថាប័ន) ..................ថ្ងៃទី.......ខែ.........ឆ្នាំ.............។

**ភាគីទាំងពីរព្រមព្រៀងគ្នា ដូចខាងក្រោម :**

**សារធាតុ**

១- ក្រុមហ៊ុនជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឱ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជា............. .............. ដោយ គ.ម.ក.។

២-អតិថិជនមានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

៣-អនុលោមតាមមាត្រា ៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវចុះកិច្ចព្រមព្រៀងជាមួយអនាគតអតិថិជន។

៤-ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

## និយមន័យ

៥-ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឲ្យនិយមន័យដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិដែលកំណត់ដោយ គ.ម.ក. និងច្បាប់ពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។

និយមន័យខាងក្រោមនេះដែលត្រូវប្រើប្រាស់ក្នុងកិច្ចព្រមព្រៀង ៖

កិច្ចព្រមព្រៀង: សំដៅដល់កិច្ចព្រមព្រៀងអតិថិជន។

ប្រាក់អតិថិជនគ្រប់គ្រាន់ : សំដៅដល់ប្រាក់ដែលអាចប្រើប្រាស់បាន នៅក្នុងគណនីសាច់ប្រាក់អតិថិជនក្នុងពេលជាក់លាក់មួយ សម្រាប់ការបញ្ជាទិញមូលបត្ររបស់អតិថិជន ដោយយកសមតុល្យក្នុងគណនីសាច់ប្រាក់អតិថិជនដកចេញនូវរាល់បំណុលអតិថិជនទាំងអស់ ការបញ្ជាទិញពីមុនទាំងអស់របស់អតិថិជន ព្រមទាំងប្រាក់ដែលអតិថិជនបានស្នើដក ឬស្នើទូទាត់ទៅតតិយជន។

ធនាគារ : សំដៅដល់ធនាគារពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានអតិថិជន : សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឲ្យក្រុមហ៊ុនមូលបត្រ នៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

បំណុលអតិថិជន : សំដៅដល់ប្រាក់ដែលអតិថិជនជំពាក់ក្នុងការទូទាត់ទៅបុគ្គលផ្សេងទៀតដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាអាទិ៍ កម្រៃជើងសាថ្លៃសេវា លាភការផ្សេងៗ ពន្ធ ឬចំណាយផ្សេងទៀតដែលទាក់ទងនឹងការលក់ ឬការទិញមូលបត្រ និងកម្រៃរដ្ឋបាលដែលទាក់ទងនឹងការធ្វើប្រតិបត្តិការលើគណនីសាច់ប្រាក់អតិថិជន។

បញ្ជាអតិថិជន: សំដៅដល់បញ្ជាទិញ ឬលក់មូលបត្ររបស់អថិតិជនទៅក្រុមហ៊ុនមូលបត្រ។

ក្រមសីលធម៌វិជ្ជាជីវៈ : សំដៅដល់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

អាជ្ញាបណ្ណ : សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ឱ្យក្រុមហ៊ុនដោយអគ្គនាយកនៃ គ.ម.ក.។

ការជួញដូរមូលបត្រ: សំដៅដល់ការជួញដូរមូលបត្របានចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុត។

សេវាកម្ម : សំដៅដល់ការផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

ប្រតិសិទ្ធិសកល: សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទូទៅពីបុគ្គលដទៃ។

ប្រតិសិទ្ធិដោយឡែក: សំដៅដល់បុគ្គលដែលទទួលបន្តសិទ្ធិមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

## ៦- ការជ្រើសរើសក្រុមហ៊ុន

១- អតិថិជនជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួនដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ អតិថិជនព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុនក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

២-ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជនក្នុងនាមអតិថិជន ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមព្រៀងនេះ។

៣-ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថិជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ គ.ម.ក.។

## ៧- ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន

១-ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថិជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ក្រមសីលធម៌វិជ្ជាជីវៈ។

២-អតិថិជនត្រូវធានាថា ព័ត៌មានដែលផ្តល់ឱ្យនៅពេលចុះកិច្ចព្រមព្រៀង ជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ ។

៣-អតិថិជនត្រូវទទួលស្គាល់ថា ក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិថិជនដោយផ្អែកលើព័ត៌មានអតិថិជន។ អតិថិជនយល់ព្រមជូនដំណឹងភ្លាមទៅក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់អតិថិជន។

៤-ក្រុមហ៊ុនត្រូវធ្វើបច្ចុប្បន្នកម្មការផ្លាស់ប្តូរព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មាននោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀង។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនផ្តល់ឱ្យអតិថិជននូវព័ត៌មានជាលាយលក្ខណ៍អក្សរមុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។ ចំណុចទី ៧ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

## ៨.- ការជួញដូរមូលបត្រ

១-ក្រុមហ៊ុនត្រូវអនុវត្តការជួញដូរមូលបត្រក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់បញ្ជាពីអតិថិជនឱ្យអនុវត្តការជួញដូរមូលបត្រ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី គ.ម.ក.។

២-អតិថិជនផ្តល់សិទ្ធិឲ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជន ដើម្បី ÷

ក- បញ្ជូនបញ្ជារបស់អតិថិជន

ខ- ផ្ទេរមូលបត្រដែលត្រូវបានលក់ ឬទិញតាមបញ្ជារបស់អតិថិជន

គ- ធានាថារាល់ការផ្ទេរ បានកត់ត្រាត្រឹមត្រូវនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

៣-ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្រក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិជាធរមាន។

៤-ក្រុមហ៊ុន និងអតិថិជនត្រូវទទួលស្គាល់ និងព្រមព្រៀងថា ÷

ក- ក្រុមហ៊ុនមិនត្រូវទិញមូលបត្រក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឲ្យក្រុមហ៊ុននូវប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រ និងអតិថិជនយល់ព្រមថាមិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្រនៅតម្លៃលើសពីបរិមាណប្រាក់អតិថិជនដែលមានឡើយ និង

ខ-ក្រុមហ៊ុនមិនត្រូវលក់ស៊ិតសែល (short sell) ឡើយ និងអតិថិជនមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅប្រតិបត្តិកររក្សាទុកមូលបត្រក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន ។

៥-អតិថិជនព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថាបញ្ជារបស់អតិថិជននឹងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អតិថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោល ឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។ ចំណុចទី ៨ នៃកិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៩.- វិធីសាស្ត្រក្នុងការដាក់បញ្ជា

១-អតិថិជនអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម ÷

ក-ជាលាយលក្ខណ៍អក្សរ

ខ-តាមរយៈទូរស័ព្ទ ទូរសារ និងតាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

២-បញ្ជាអតិថិជនត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្រ រួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ និងថ្លៃមូលបត្រ និងកាលបរិច្ឆេទ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជា

នោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិចដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

**១០.- ការបដិសេធទទួលបញ្ជា**

១-ក្រុមហ៊ុនមិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខន្តិកៈនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

២-ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរ ក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទី១ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

**១១.- ការជូនដំណឹងការជួញដូរមូលបត្រ**

ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននូវរាល់ប្រតិបត្តិការមូលបត្រ ដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ។ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

**១២.- គណនីសាច់ប្រាក់អតិថិជន**

១- អតិថិជនផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំពោះ ÷

ក-ការដាក់តម្កល់ប្រាក់ដែលទទួលបានពីអតិថិជន ឬក្នុងនាមអតិថិជនទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលពាក់ព័ន្ធនឹងអតិថិជន

ខ-ការទទួលប្រាក់ពីការលក់មូលបត្រក្នុងនាមអតិថិជនតាមបញ្ជាចូលក្នុងគណនីសាច់ប្រាក់អតិថិជន

គ- ការទូទាត់ចេញពីគណនីសាច់ប្រាក់អតិថិជនសម្រាប់ការទិញមូលបត្រក្នុងនាមអតិថិជនតាមបញ្ជារបស់អតិថិជន

ឃ-ការទូទាត់សងបំណុលអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រ ពីគណនីសាច់ប្រាក់អតិថិជន

ង- ការទូទាត់ផ្សេងៗ ពីគណនីសាច់ប្រាក់អតិថិជនដែលតម្រូវដោយច្បាប់ និង

ច- ការដាក់ប្រាក់ចូល និងការដកប្រាក់ចេញពីគណនីសាច់ប្រាក់អតិថិជន នៅពេលមានបញ្ហាអតិថិជន ឬការណែនាំជាលាយលក្ខណ៍អក្សរពីអតិថិជន។

២- អតិថិជនមានសិទ្ធិទទួលរាល់ចំណូលការប្រាក់ដែលកើតមានក្នុងគណនីអតិថិជន។

១៣.- របាយការណ៍

១-ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរដល់អតិថិជនទាក់ទងនឹងការជួញដូរមូលបត្រដូចខាងក្រោម ÷

ក- សេចក្តីជូនដំណឹងស្តីអំពីការជួញដូរមូលបត្រដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ

ខ- របាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងគណនីអតិថិជន ដោយអនុលោមតាមប្រការ ២២ នៃក្រមសីលធម៌វិជ្ជាជីវៈ។

គ- របាយការណ៍ពាក់ព័ន្ធនឹងប្រាក់អតិថិជនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ។

២-អតិថិជនព្រមព្រៀងក្នុងការពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃរបាយការណ៍ដែលផ្តល់ដោយក្រុមហ៊ុន ដើម្បីធានាថាខ្លឹមសារនៃរបាយការណ៍ដែលបានផ្តល់ឱ្យមានសង្គតិភាពនឹងកំណត់ត្រាផ្ទាល់ខ្លួន និងជូនដំណឹងដល់ក្រុមហ៊ុនភ្លាមនូវរាល់ភាពខុសគ្នាណាមួយ។

១៤.- លាភការ

១-ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថាការបង់លាភការឲ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះត្រូវបានកំណត់តាមតារាង [១] និងអាចប្រែប្រួលតាមការកំណត់របស់ គ.ម.ក.។

២- ក្រុមហ៊ុនអាចធ្វើបច្ចុប្បន្នកម្មតារាង [១] នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវរាល់ការផ្លាស់ប្តូរនោះ។ ដើម្បីឱ្យការតម្លើងលាភការដែលត្រូវបង់ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្ត លុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៣-ក្រុមហ៊ុនត្រូវព្រមព្រៀងថា នៅពេលគិតថ្លៃសេវាពីអតិថិជនលើសចំនួនដែលមានចែងក្នុងតារាង [១] ត្រូវបង្វិលប្រាក់ដែលបង់លើសចូលក្នុងគណនីសាច់ប្រាក់អតិថិជនភ្លាមៗ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជន។

១៥.- ផលប្រយោជន៍ និងទំនាក់ទំនង

ក្រុមហ៊ុនត្រូវបញ្ជាក់នូវរាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងតារាង [២] ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

១៦.- ការតវ៉ា

១- ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្ដឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះ និងព័ត៌មានលំអិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

២- ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជន ក្នុងអំឡុងពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

១៧.- អ្នកតំណាងរបស់អតិថិជន

១-អតិថិជនអាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាអ្នកតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ ដើម្បីដាក់បញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះ អតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងតារាង[៣]។

២-មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឱ្យអតិថិជនផ្ដល់ឱ្យក្រុមហ៊ុនមូលបត្រនូវឯកសារដើម ឬថតចម្លងមានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកតំណាង។

៣-អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាម ដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាងតាមបញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀត លើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

១៨.-ការរក្សាភាពសម្ងាត់

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្ម ស្របតាមកិច្ចព្រមព្រៀងនេះទៅឱ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម ÷

១-មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់នោះ។

២-មានការស្នើសុំពី គ.ម.ក. ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឬ

៣-មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

**១៩.- សេចក្តីថ្លែងព័ត៌មានហានិភ័យ**

១-អតិថិជនត្រូវទទួលស្គាល់ថាថ្លៃមូលបត្រអាចប្រែប្រួលឡើង ឬចុះហើយព័ត៌មានដែលត្រូវបានផ្តល់ឱ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្រដែលស្របតាមកិច្ចព្រមព្រៀងនេះនឹងមិនត្រូវបានធានាដោយក្រុមហ៊ុន ឬបុគ្គលផ្សេងទៀតឡើយ។

២-ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឱ្យ ប្រសិនបើមាន។

**២០.- ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

**២១.- បដិវាទកម្ម**

ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ ឬ/និងកិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

**២២.-ការជូនដំណឹង**

១-រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឱ្យអតិថិជនត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

២-អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

២៣.- ការបញ្ចប់កិច្ចសន្យា

១-ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃដល់ភាគីម្ខាងទៀត។

២-ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

២៤.- កិច្ចព្រមព្រៀងរួម

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាងដែលចែងអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជន និងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម ។ រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអានុភាពអនុវត្តឡើយ។

២៥.- ការកែប្រែ

កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះ ឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឱ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

២៦.- ការចាត់តាំង

អតិថិជនព្រមព្រៀងថារាល់សិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឱ្យប្រតិសិទ្ធិសាកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជន ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្រ និងការចុះបញ្ជីនៃការផ្ទេរនោះ។

២៧.- ច្បាប់គ្រប់គ្រង និងយុត្តាធិការ

១- កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២-រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះ អាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទ ដែលកំណត់ដោយ ត.ម.ក.។

**ដើម្បីឱ្យកិច្ចសន្យានេះមានសុពលភាព ភាគីទាំងពីរព្រមព្រៀងគ្នាដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃ :**

[ក្រុមហ៊ុន] *ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា*

[អតិថិជន] *ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រាករណីជាស្ថាប័ន*

## តារាងទី ១

## លាភការ

*ការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ*

| ប្រភេទកម្រៃ | ចំនួនប្រាក់ | ការគណនា |
|---|---|---|
| កម្រៃជើងសា | | |
| ថ្លៃសេវា | | |
| លាភការផ្សេងៗ | | |
| | | |
| | | |

## តារាងទី ២

## ផលប្រយោជន៍ និងទំនាក់ទំនង

*ផលប្រយោជន៍ និងទំនាក់ទំនងដែលអាចមានឥទ្ធិពលទៅលើក្រុមហ៊ុនក្នុងការផ្ដល់សេវា*

| ឈ្មោះ | ទំនាក់ទំនងជាមួយក្រុមហ៊ុន | ការពន្យល់ពីឥទ្ធិពល |
|---|---|---|
| | | |
| | | |
| | | |

## តារាងទី ៣

## អ្នកតំណាងរបស់អតិថិជន

| ឈ្មោះអ្នកតំណាង | អាសយដ្ឋាននិងលេខទំនាក់ទំនង | ទំហំនៃការអនុញ្ញាតសិទ្ធិ |
|---|---|---|
| | | |
| | | |
| | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០៦៦ គ.ម.ក.ក.អ./ណ.ម.

# ការអនុញ្ញាត

# ឈ្មួញជើងសាឧបករណ៍និស្សន្ទ

ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមូលធន និងបទប្បញ្ញត្តិពាក់ព័ន្ធនានា និងផ្អែកលើគុណវុឌ្ឍិរបស់ក្រុមហ៊ុន គណៈកម្មការមូលបត្រកម្ពុជា សម្រេចផ្តល់ការអនុញ្ញាតឱ្យ **ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី** ធ្វើជា «**ឈ្មួញជើងសាឧបករណ៍និស្សន្ទ**» ដែលមានទីស្នាក់ការនៅអគារលេខ ៣២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី** ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមូលធន អនុក្រឹត្យ និងបទប្បញ្ញត្តិ ព្រមទាំងសេចក្តីណែនាំ និងលក្ខខណ្ឌទាំងឡាយដែលមានជាធរមាន។

ការអនុញ្ញាតនេះ មានសុពលភាពចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។

រាជធានីភ្នំពេញ ថ្ងៃទី 22 ខែមិថុនា ឆ្នាំ២០១៦
គណៈកម្មការមូលបត្រកម្ពុជា
អគ្គនាយក
ស៊ូ សុជាតិ

ការអនុញ្ញាតនេះ ត្រូវតាំងបង្ហាញនៅការិយាល័យរបស់ក្រុមហ៊ុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ : ០១០ គ.ម.ក./ក.ធ.

# អាជ្ញាបណ្ណ
# ក្រុមហ៊ុនមូលបត្រ

ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ និងផ្អែកលើគុណវុឌ្ឍិរបស់ក្រុមហ៊ុន គណៈកម្មការមូលបត្រកម្ពុជា សម្រេចបន្តអាជ្ញាបណ្ណឱ្យ **ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី** ធ្វើជា "**ក្រុមហ៊ុនធានាទិញមូលបត្រ**" ដែលមានទីស្នាក់ការ នៅអាគារលេខ ៣២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដើម្បីប្រកប : - អាជីវកម្មធានាទិញមូលបត្រ - អាជីវកម្មជួញដូរមូលបត្រ - អាជីវកម្មជើងសាមូលបត្រ - អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។

**ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី** ត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិ ព្រមទាំងសេចក្តីណែនាំ និងលក្ខខណ្ឌទាំងឡាយដែលមានជាធរមាន។

អាជ្ញាបណ្ណនេះ មានសុពលភាពចាប់ពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០១៦
**គណៈកម្មការមូលបត្រកម្ពុជា**
**អគ្គនាយក**

**ស៊ូ សុជាតិ**

អាជ្ញាបណ្ណនេះ ត្រូវដាក់តាំងបង្ហាញជាសាធារណៈត្រង់ទីតាំងអាជីវកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
លេខ.......ពណ.ចបព
MINISTRY OF COMMERCE
No..........MOC/D/REG

# វិញ្ញាបនបត្រ

បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
CERTIFICATE OF INCORPORATION

| | |
|---|---|
| នាមករណ៍ | : **ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី** |
| NAME | : PHNOM PENH SECURITIES PLC. |
| ចុះបញ្ជីក្រោមលេខ | : Co. ១៤២៧៥ KH/២០០៩ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ |
| REGISTRATION NUMBER | : Co. 14275 KH/2009 Dated 18 November 2009 |
| ត្រូវបានទទួលស្គាល់ថាជា | : ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត |
| IS ACKNOWLEDGED AS | : PUBLIC LIMITED COMPANY |

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE, AND PENAL CODE OF THE KINGDOM OF CAMBODIA.

ភ្នំពេញ, ថ្ងៃទី 04 ខែ កក្កដា ឆ្នាំ 2016
PHNOM PENH 07

ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F.MINISTER OF COMMERCE

អនុរដ្ឋលេខាធិការ

ក្ងយ_សុជានី

* វិញ្ញាបនបត្រមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខាដល់ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៧
ហួសរយៈពេលកំណត់នេះត្រូវចាត់ទុកជាមោឃៈ
* THE CERTIFICATE IS VALID FROM THE SIGNING DATE TO 26 August 2017
IT WILL BE CONSIDERED INVALID AFTER THE STATED DATE.

បញ្ជាក់៖ការចុះនាមករណ៍សហគ្រាសពាណិជ្ជកម្មក្នុងបញ្ជីពាណិជ្ជកម្ម មិនមែនជាស្វ័យសិទ្ធិក្នុងការទទួលបានសិទ្ធិពាណិជ្ជសញ្ញា ឬកម្មសិទ្ធិបញ្ញាលើនាមករណ៍ឬផ្នែកណាមួយនៃនាមករណ៍សហគ្រាសពាណិជ្ជកម្មនោះឡើយ។
Note: Registration of a commercial enterprise name with Commercial Registry does not confer any trade mark rights or any other intellectual property rights in respect of the commercial enterprise name or any part thereof.

1. Please Cut and Paste this on the envelope.

## To: Phnom Penh Securities Plc

Address: No. 32, Preah Monivong Blvd, Phnom Penh, **CAMBODIA.**



# ទម្រង់ចុះឈ្មោះស្នើសុំបើកគណនី

ឈ្មោះ (គោត្តនាម និង នាម) :.............................................. ជាអក្សរឡាតាំង : ..................................................

ថ្ងៃ ខែ ឆ្នាំកំណើត : ....../....... / ........... ភេទ: ☐ ប / ☐ ស លក្ខន្តិកៈគ្រួសារ : ☐ នៅលីវ / ☐ មានគ្រួសារ / ☐ លែងលះ

ឈ្មោះធនាគារ : ........................... លេខគណនីធនាគារ : ................................. ប្រភេទគណនីធនាគារ : ..............

តើអ្នកមានបំនងបើកគណនីជួញដូរ Online ដែរឬទេ? ☐ មានបំនង ☐ គ្មានបំនង

សម្រាប់ព័ត៌មានបន្ថែម និង លក្ខខណ្ឌក្នុងការប្រើប្រាស់សេវានេះ សូមអានកិច្ចព្រមព្រៀងអតិថិជន ឬ ទំនាក់ទំនងមកឈ្មួញ ជើងសារបស់អ្នក។

**អាសយដ្ឋានទំនាក់ទំនង:** អាគារលេខ : . ផ្លូវ :......................................................☐ឃុំ / ☐សង្កាត់ :.....................

☐ស្រុក / ☐ក្រុង / ☐ខណ្ឌ : ..................................☐ខេត្ត / ☐រាជធានី : ..................................................

លេខទូរស័ព្ទលើតុ : ....................... លេខទូរស័ព្ទដៃ : .............................. អ៊ីម៉ែល : ......................................

មុខរបរ :............................... មុខតំណែង : .................................. ប្រភេទអាជីវកម្ម : ..................................

អាសយដ្ឋានកន្លែងធ្វើការ :......................................................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ : .................................រយៈពេលនៃអតីតភាពការងារ : ..................................................

**ពិតមានសហព័ទ្ធ(ប្តី ឬ ប្រពន្ធ) ក្នុងករណីមានគ្រួសារ:**

ឈ្មោះ (គោត្តនាម និង នាម) :...................................... ជាអក្សរឡាតាំង : ..................................................

សញ្ជាតិ : ....................... មុខរបរ :........................................... មុខតំណែង :...............................................

ប្រភេទអាជីវកម្ម:..........................................លេខទូរស័ព្ទកន្លែងធ្វើការ : ..................................................

អាសយដ្ឋានកន្លែងធ្វើការ :......................................................................................................................

រយៈពេលនៃអតីតភាពការងារ :............ លេខទូរស័ព្ទដៃ : ...................... អ៊ីម៉ែល :..............................................

**បុគ្គលដែលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់:** (សូមបំពេញប្រសិនបើបុគ្គលមិនមែនជាសហព័ទ្ធ)

ឈ្មោះ (គោត្តនាម និង នាម) :...................................... ជាអក្សរឡាតាំង: ..................................................

អាសយដ្ឋានទំនាក់ទំនង :.....................................................................................................................

លេខទូរស័ព្ទដៃ : ................................ លេខទូរសារ :........................... អ៊ីម៉ែល : ......................................

កំរិតការសិក្សា : ☐ វិទ្យាល័យ / ☐ បរិញ្ញាបត្រ / ☐ អនុបណ្ឌិត / ☐ បណ្ឌិត / ☐ ផ្សេងៗ ...........................................

មុខជំនាញ :..........................................................................................................................................

ឈ្មោះស្ថាប័ន : ............................................................................... ពីឆ្នាំ : ................ ដល់ :................

ចំណេះដឹងនៃការវិនិយោគលើមូលបត្រ: ☐ ល្អណាស់ / ☐ ល្អ / ☐ មានកម្រិត / ☐ គ្មាន

បទពិសោធន៍នៃការវិនិយោគលើមូលបត្រ ☐ លើសពី 5 ឆ្នាំ / ☐ 3 - 5 ឆ្នាំ / ☐ 0 - 3 ឆ្នាំ / ☐ វិនិយោគិនថ្មី

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគលើមូលបត្រ: ☐ បណ្ណរតនាគារ / ☐ ភាគហ៊ុន / ☐ សញ្ញាបណ្ណ / ☐ ផ្សេងទៀត...........

## កិច្ចព្រមព្រៀងប្រើប្រាស់គណនីជួញដូរតាមអនឡាញរបស់អតិថិជន

ដើម្បីបើកនិងប្រើប្រាស់គណនីជាមួយ ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី (PPS), អ្នក (អតិថិជន) ត្រូវតែយល់ព្រមជាមួយនឹងលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងអតិថិជននេះ (កិច្ចព្រមព្រៀង)។ កិច្ចព្រមព្រៀងគឺមានប្រសិទ្ធភាពចាប់តាំងពីពេលដែលអតិថិជនចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធរបស់ PPS និង ប្រើប្រាស់វែបសាយជួញដូររបស់ PPS និងការដាក់បញ្ជារតាមអនឡាញ។

**១. អ្នកត្រូវមានការទទួលខុសត្រូវទៅលើការរក្សាឲ្យបានល្អនូវ លេខគណនី និង លេខសំងាត់របស់អ្នក។** មានតែអ្នកនិងអ្នកទទួលសិទ្ធពីអ្នកទើបអាចដាក់ការបញ្ជាបាន។ PPS គឺមិនទទួលខុសត្រូវទៅលើការខាតបង់ដែលកើតឡើងមកពីការបាត់បង់ឬការប្រើប្រាស់លេខសំងាត់ពុំបានសមគួររបស់អ្នកឡើយ។

**២. អ្នកគួរតែផ្តល់ដំណឹងភ្លាមទៅកាន់PPS** ក្នុងករណីដែលអ្នកដឹង ឬសង្ស័យថា÷

a. ឈ្មោះគណនី ឬ លេខគណនី និងលេខសំងាត់របស់អ្នកបានបាត់ ឬត្រូវបានលួច ឬមាននរណាម្នាក់បានធ្វើប្រតិបត្តិការ ទៅលើគណនីរបស់អ្នកដោយគ្មានការអនុញ្ញាតពីអ្នក។

b. ប្រតិបត្តិការត្រូវបានផ្ទុផ្តងបានសម្រេចដោយមានកំហុសឆ្គង។

៣.អ្នកនឹងមិនត្រូវធ្វើប្រតិបត្តិការជួញដូរក្រោម រូបភាពភ្នាល់គ្នា ហើយអ្នកមិនមែនជាអតិថិជនដែលត្រូវបានហាមឃាត់ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៥. អ្នកជាអ្នកទទួលខុសត្រូវ និងហានិភ័យនៃការខាតបង់ទាំងអស់ដែលបណ្តាលមកពីការប្រើប្រាស់ ឬការចូលទៅកាន់ព័ត៌មាននៃការជួញដូរអនឡាញ និងការវិនិយោគរបស់អ្នក។ **PPS មិនគ្រប់គ្រងទៅលើ សញ្ញានៃកម្លាំងការទទួលបាន ការបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណែត រូបសណ្ឋាននៃគ្រឿងបរិក្ខាររបស់អ្នក ឬភាពដែលអាចជឿជាក់បាននៃការតភ្ជាប់អ៊ីនធឺណែតរបស់អ្នក។** លទ្ធផលបរាជ័យដែលអាចកើតឡើង អាចធ្វើឲ្យការដាក់បញ្ជារបស់អ្នកមិនត្រូវបានបញ្ជូន ឬក៏បានបញ្ជូនជាមួយកំហុសធំដុំ។

៦. **រាល់ការបញ្ជាដែលបានសម្រេចគឺត្រូវទូទាត់កំរៃជើងសានិងកម្រៃទីផ្សារផ្សេងៗទៀត។**

៧. បើមាន**ការផ្លាស់ប្តូរ** ឬកំហុសធំដុំនៃព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក អ្នកត្រូវតែ**ផ្តល់ដំណឹងទៅកាន់ឈ្មួញជើងសាផ្ទាល់ខ្លួនរបស់**អ្នកដើម្បីផ្លាស់ប្តូរ ឬកែប្រែឲ្យអ្នក។

៨. **រាល់ព័ត៌មានទីផ្សារមួយចំនួន និងប្រវត្តិនៃការជួញដូរ គឺត្រូវបានបង្កើត និងផ្អែកតាមប្រព័ន្ធរបស់ផ្សារមូលបត្រកម្ពុជា (CSX)** និងភ្នាក់ងារសំណៅផ្សេងៗទៀត ដែល PPS ធ្វើប្រតិបត្តិការជាមួយ មានដូចជាធនាគារទូទាត់ផាត់ទាត់ និង/ឬ ក្រុមហ៊ុនមូលបត្រដែលទាក់ទងដ៏ទៃទៀត។ PPS មិនទទួលកាតព្វកិច្ចក្នុងការផ្តល់នូវអត្រា ឬទីផ្សារប្រកួតប្រជែងពីស្ថាប័នដទៃដល់អតិថិជនឡើយ។ ឧទាហរណ៍: អត្រាប្តូរប្រាក់ និងអត្រាការប្រាក់។

៩. **ពេល**នៃការដាក់បញ្ជាតាមអនឡាញ និងនៅក្នុងប្រព័ន្ធ CSX អាចនឹងមាន**ភាពខុសគ្នា**ដោយសារដំណើរការនៃការបញ្ជូនទិន្នន័យ។

១០. អតិថិជនត្រូវតែជ្រើសរើសឲ្យច្បាស់នូវជម្រើសលក់និងទិញ។ បើអ្នកចង់ **លុបចោល/ផ្លាស់ប្តូរ ប្រតិបត្តិការ អ្នកត្រូវតែទុកពេលវេលាឲ្យបានសមរម្យសម្រាប់PPS ធ្វើការបញ្ជូនទិន្នន័យ។**

១១. ប្រព័ន្ធនឹងតម្រូវឲ្យអ្នក**ចូលម្តងទៀតបន្ទាប់ពីទុកចោលអស់រយៈពេលចាប់ពី២០នាទីឡើង។**

១២. **សាច់ប្រាក់ត្រូវបានកត់ត្រាជាផ្លូវការជាខ្មែររៀល នៅធនាគារដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់របស់PPS។**

១៣. **អ្នកយល់ព្រមថាPPS អាចធ្វើការផ្លាស់ប្តូរលក្ខខណ្ឌតម្រូវនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះនៅពេលណាមួយ** ដោយធ្វើការដាក់បង្ហាញនូវកំណែប្រែ និងទិន្នន័យដែលមានផលប៉ះពាល់មួយចំនួនទៀត នៅលើវែបសាយរបស់ PPS (http://www.pps.com.kh) និងធ្វើការផ្ញើទៅកាន់អ៊ីម៉ែលដែលអ្នកបានផ្តល់ឲ្យ PPS។ ដូច្នេះអ្នកត្រូវបានសន្មតថាបានទទួលកំណែប្រែនេះ មិនថាអ្នកបានដឹងឬពុំដឹងក៏ដោយ។

**ការបញ្ឈប់**

ប្រសិនបើភាគីណាមួយមានបំណងចង់បញ្ឈប់ការប្រើប្រាស់កិច្ចព្រមព្រៀងនេះ ត្រូវសរសេរជាលាយលក្ខណ៍អក្សរជូនដំនឹងទៅភាគីម្ខាងទៀតក្នុងរយៈពេល មិនអោយតិចជាង៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ។

*ខ្ញុំបាទ/នាងខ្ញុំបានអាន និងយល់កិច្ចព្រមព្រៀងនេះ។*

*ដូច្នេះ ខ្ញុំបាទ/នាងខ្ញុំយល់ស្របក្នុងការប្រើប្រាស់សេវានេះរបស់ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។*

*ហត្ថលេខានិង ឈ្មោះ*

គណៈកម្មការមូលបត្រកម្ពុជា
Securities and Exchange
Commission of Cambodia

ទម្រង់ ខ
FORM B

រូបថត ៤x៦
របស់អ្នកតំណាង
ថតក្នុងរយៈពេល
៦ខែចុងក្រោយ
Photograph of
representative
taken within the last
six months, 4x6

# ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
# INVESTOR IDENTIFICATION NUMBER APPLICATION FORM
## សម្រាប់នីតិបុគ្គល
## FOR INSTITUTIONAL INVESTOR

## ក. ព័ត៌មានរបស់នីតិបុគ្គល
## A. Institutional Information

ឈ្មោះនីតិបុគ្គល (អក្សរខ្មែរ)
Name of Institution (Khmer) ..........

ឈ្មោះនីតិបុគ្គល (អក្សរឡាតាំង)
Name of Institution (Latin) ..........

ថ្ងៃ ខែ ឆ្នាំចុះបញ្ជីពាណិជ្ជកម្ម
Date of Registration D D M M Y Y Y Y

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
Expiry Date of Company Registration Certificate D D M M Y Y Y Y

ថ្ងៃ ខែ ឆ្នាំផុតសុពលភាពអាជ្ញាប័ណ្ណធ្វើអាជីវកម្ម (បើមាន)
Expiry Date of Company License (If applicable) D D M M Y Y Y Y

សញ្ជាតិនីតិបុគ្គល
Nationality of Institution
☐ សញ្ជាតិខ្មែរ Cambodian
☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ..........

ប្រភេទអាជីវកម្ម
Type of Business ..........

អាសយដ្ឋាននីតិបុគ្គល
Address of Institution
អគារលេខ No. .......... ផ្លូវ Street ..........
☐ ឃុំ / Commune / ☐ សង្កាត់ Sangkat ..........
☐ ស្រុក / District / ☐ ក្រុង / Town/ ☐ ខណ្ឌ Khan ..........
☐ ខេត្ត / Province/ ☐ រាជធានី Capital ..........
ប្រទេស Country ..........

លេខអត្តសញ្ញាណកម្មសារពើពន្ធ (បើមាន)
Taxpayer Identification Number (If applicable) ..........

### ឯកសារធនាគាររបស់នីតិបុគ្គល
### BANKING REFERENCE

ឈ្មោះធនាគារ
Bank Name ..........

លេខគណនីធនាគារ
Account Number ..........

## ខ. បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬ អ្នកតំណាង
## B. AUTHORIZED PERSON TO SIGN ON BEHALF OF INSTITUTION OR REPRESENTATIVE

នាមត្រកូល (អក្សរខ្មែរ)
Surname (Khmer) .......... (អក្សរឡាតាំង) (Latin) ..........

នាមខ្លួន (អក្សរខ្មែរ)
Given Name (Khmer) .......... (អក្សរឡាតាំង) (Latin) ..........

ថ្ងៃ ខែ ឆ្នាំកំណើត
Date of Birth D D M M Y Y Y Y

ភេទ
Gender ☐ ប្រុស Male ☐ ស្រី Female

លក្ខន្តិកៈគ្រួសារ
Marital Status ☐ នៅលីវ Single ☐ មានគ្រួសារ Married ☐ លែងលះ Divorced

សញ្ជាតិ
Nationality
☐ សញ្ជាតិខ្មែរ Cambodian
☐ សញ្ជាតិបរទេស (សូមបញ្ជាក់សញ្ជាតិ) Foreigner (Please Specify Nationality) ..........

ប្រភេទបណ្ណសម្គាល់អត្តសញ្ញាណ
Identification Type
☐ លេខអត្តសញ្ញាណប័ណ្ណ (សម្រាប់ខ្មែរ) Identification card Number ( For Cambodian) ..........
☐ លេខលិខិតឆ្លងដែន (សម្រាប់បរទេស) Passport Number (For Foreigner) ..........

### ១. អាសយដ្ឋានទំនាក់ទំនងរបស់បុគ្គលចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ឬអ្នកតំណាង
### 1. Contact Address of the Authorized Person or Representative

អាសយដ្ឋានទំនាក់ទំនងក្នុងព្រះរាជាណាចក្រកម្ពុជា
Contact Address in Cambodia

អគារលេខ No. .......... ផ្លូវ Street ..........
☐ ឃុំ/ Commune/ ☐ សង្កាត់ Sangkat ..........
☐ ស្រុក / District / ☐ ក្រុង/ Town/ ☐ ខណ្ឌ Khan ..........
☐ ខេត្ត / Province/ ☐ រាជធានី Capital ..........

លេខទូរសព្ទលើតុ
Telephone .......... លេខទូរសព្ទដៃ Mobile ..........

អ៊ីម៉ែល
E-mail ..........

អាសយដ្ឋានទំនាក់ទំនងក្រៅប្រទេស (សម្រាប់វិនិយោគិនដែលមិនមានទីលំនៅអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា)
Contact Address in Your Country (For investor who does not have permanent address in Cambodia)

អគារលេខ No. ______ ផ្លូវ Street ______ ឃុំ Commune ______

☐ ស្រុក / District / ☐ ក្រុង Town ______ ☐ ខេត្ត / Province/ ☐ រាជធានី Capital ______

ប្រទេស Country ______ លេខទូរសព្ទលើតុ Telephone ______

អ៊ីមែល E-mail ______ លេខទូរសព្ទដៃ Mobile ______

## ២. ព័ត៌មានអំពីមុខរបរ
## 2. Occupation

មុខរបរបច្ចុប្បន្ន Present Occupation ______ រយៈពេលនៃអតីតភាពការងារ Length of Work ______

ឈ្មោះកន្លែងធ្វើការ Name of Organization ______ ប្រភេទអាជីវកម្ម Type of Business ______

អាសយដ្ឋានកន្លែងធ្វើការ Address of Workplace ______

## ៣. ព័ត៌មានអំពីការសិក្សា
## 3. Educational Background

ផ្នែក Field ______

## ៤. បុគ្គលអាចទំនាក់ទំនងបានក្នុងករណីចាំបាច់ (ផ្សេងពីអ្នកតំណាងខាងលើ)
## 4. Contact Person when necessary ( Besides the representative above)

ឈ្មោះ Name ______ ភេទ Gender ______ ទូរសព្ទ Mobile ______

អាសយដ្ឋានស្នាក់នៅ Home address ______

## ៥. ចំណេះដឹងលើការវិនិយោគក្នុងវិស័យមូលបត្រ
## 5. Knowledge in Securities Investment

☐ ល្អណាស់ Very good ☐ ល្អ Good ☐ តិចតួច Limited ☐ គ្មាន Nothing

## ៦. ឯកសារភ្ជាប់សម្រាប់ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន
## 6. Enclosed Documents To Apply For Investor Identification Number

- ☐ អត្តសញ្ញាណប័ណ្ណរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីសញ្ជាតិខ្មែរ) Certify true copy of Identification Card of Representative (For Cambodian)
- ☐ លិខិតផ្ទេរសិទ្ធិអ្នកតំណាង Power of Attorney
- ☐ លិខិតឆ្លងដែនរបស់អ្នកតំណាងថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ករណីមិនមែនសញ្ជាតិខ្មែរ) Certify true copy of Passport of Representative (For Foreigner)
- ☐ លក្ខន្តិកៈក្រុមហ៊ុនថតចម្លងមានបញ្ជាក់ត្រឹមត្រូវ Certify true copy of Articles of Association
- ☐ អាជ្ញាបណ្ណធ្វើអាជីវកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន) Certify true copy of Company License (If any)
- ☐ វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (បើមាន) Certify true copy of Value Added Tax Certificate (If applicable)
- ☐ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មរបស់នីតិបុគ្គលថតចម្លងមានបញ្ជាក់ត្រឹមត្រូវ Certify true copy of Company Registration Certificate
- ☐ ផ្សេងៗ (សូមបញ្ជាក់) Other (Please Specify) ......................

**ខ្ញុំសូមធានាចំពោះមុខច្បាប់ថាព័ត៌មានដែលបំពេញខាងលើរួមទាំងឯកសារភ្ជាប់ពិតជាត្រឹមត្រូវមែន**

I hereby take full responsibility against the law of the Kingdom of Cambodia, that all above information and documents enclosed are true and correct.

ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

ហត្ថលេខា និងឈ្មោះរបស់អ្នកតំណាង Signature and Name of Representative ______ ឬ Or

ត្រាសម្គាល់នីតិបុគ្គល Seal of the Institution

ស្នាមមេដៃស្តាំរបស់អ្នកតំណាង Right Thumb Fingerprint of Representative

## គ. សម្រាប់ក្រុមហ៊ុនមូលបត្រ (ករណីដាក់ពាក្យស្នើសុំតាមរយៈក្រុមហ៊ុនមូលបត្រ)
## C. FOR SECURITIES FIRM (APPLYING VIA SECURITIES FIRM)

ឈ្មោះក្រុមហ៊ុនមូលបត្រ Name of Securities Firm ______

ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ Name of Securities Representative ______

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Comment of Securities Representative ______

ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Signature of Securities Representative ______ ថ្ងៃទី ខែ ឆ្នាំ : Date: D D M M Y Y Y Y

## ឃ. សម្រាប់គណៈកម្មការមូលបត្រកម្ពុជា
## D. FOR THE SECC'S USE ONLY

យោបល់របស់មន្ត្រីគ.ម.ក. ÷
SECC Comments :

ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

PHNOM PENH SECURITIES PLC. 金邊證券

# ទម្រង់ស្នើសុំបើកគណនី

# Form for Opening Account

Branch : ______________________

Account Name : ______________________

Account No. : ______________________

ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី
PHNOM PENH SECURITIES PLC. 金邊證券

# ពាក្យស្នើសុំបើកគណនី Form for Opening Account

| | | |
|---|---|---|
| ឈ្មោះក្រុមហ៊ុនមូលបត្រ Name of Securities Firm : **ក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី ភីអិលស៊ី Phnom Penh Securities Plc.** ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ Name of Securities Representative : .................................... | កាលបរិច្ឆេទនៃការស្នើសុំ Date : ....../....../...... ☐ និវាសនជន Resident ☐ អនិវាសនជន Non-resident | លេខគណនី Account No : .................... លេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី គ.ម.ក. Investor's ID No. from SECC : .................... |

ប្រភេទគណនី Type of Account : .................................... ☐ រូបវន្តបុគ្គល Individual ☐ នីតិបុគ្គល/ ស្ថាប័ន Institution/Legal Entity

ឈ្មោះអតិថិជន ( នាម និងគោត្តនាម) Client's Full Name : .................................... ជាអក្សរឡាតាំង Latin Name: ....................................

ភេទ Sex : ........ សញ្ជាតិ Nationality : .............. អាសយដ្ឋានទំនាក់ទំនង Contact Address : ....................................

....................................................................................................

ថ្ងៃ ខែ ឆ្នាំកំណើត Date of Birth : ....../....../...... លក្ខន្តិកៈគ្រួសារ Marital Status : ☐ នៅលីវ Single ☐ មានគ្រួសារ Married ☐ លែងលះ Divorced

លេខអត្តសញ្ញាណបណ្ណ/ លេខលិខិតឆ្លងដែន I.D. Card No./Passport : .................... កាលបរិច្ឆេទផុតសុពលភាព Expiry Date : ....................

ចេញដោយ Issued by : .............. លេខទូរស័ព្ទ Tel : .................... ទូរសារ Fax : .................... អ៊ីម៉ែល E-mail : ....................

មុខរបរ Occupation : .................... មុខតំណែង Position : .................... ប្រភេទអាជីវកម្ម Type of Business : ....................

អាសយដ្ឋានកន្លែងធ្វើការ Place of Work : ....................................

លេខទូរស័ព្ទកន្លែងធ្វើការ Tel : .................... រយៈពេលនៃអតីតភាពការងារ Working Years : ....................

ឈ្មោះសហព័ទ្ធ ( នាម និងគោត្តនាម) Spouse's Name : .................................... ជាអក្សរឡាតាំង Latin Name: ....................

សញ្ជាតិ Nationality : .................... លេខទូរស័ព្ទ Tel : .................... មុខរបរ Occupation : ....................

មុខតំណែង Position : .................................... រយៈពេលនៃអតីតភាពការងារ Working Years : ....................

ប្រភេទអាជីវកម្ម Type of Business : .................................... លេខទូរស័ព្ទកន្លែងធ្វើការ Tel : ....................

អាសយដ្ឋានកន្លែងធ្វើការ Place of work : ....................................

ឈ្មោះនីតិបុគ្គល/ ស្ថាប័ន Institution/Legal Entity's Name : .................................... ប្រភេទអាជីវកម្ម Type of Business : ....................

លេខចុះបញ្ជី Registered Number : .................... ចុះថ្ងៃទី Day : ...... ខែ Month : ...... ឆ្នាំ Year : ...... សញ្ជាតិ Nationality : ....................

អាសយដ្ឋាននីតិបុគ្គល/ ស្ថាប័ន Address of Institution/Legal Entity : ....................................

អាសយដ្ឋានទំនាក់ទំនង Contact Address : ....................................

* ឈ្មោះអ្នកតំណាងនីតិបុគ្គល/ ស្ថាប័ន Principal's Name : .................................... ភេទ Sex : ........ លេខអត្តសញ្ញាណបណ្ណ/ លេខលិខិតឆ្លងដែន I.D. CardNo./Passport : .................... ចេញដោយ Issued By : .................... កាលបរិច្ឆេទផុតសុពលភាព Expiry Date : ....................

លេខទូរស័ព្ទ Tel : .................... ទូរសារ Fax : .................... អ៊ីម៉ែល E-mail : .................... មុខតំណែង Position : ....................

អាសយដ្ឋានទំនាក់ទំនង Contact Address : ....................................

* ឈ្មោះអ្នកទទួលសិទ្ធិពីនីតិបុគ្គល/ ស្ថាប័ន Authorized Representative's Name : .................... ភេទ Sex : ........ លេខអត្តសញ្ញាណបណ្ណ/ លេខលិខិតឆ្លងដែន I.D. CardNo./Passport : .................... ចេញដោយ Issued By : .................... កាលបរិច្ឆេទផុតសុពលភាព Expiry Date : ....................

លេខទូរស័ព្ទ Tel : .................... ទូរសារ Fax : .................... អ៊ីម៉ែល E-mail : .................... មុខតំណែង Position : ....................

អាសយដ្ឋានទំនាក់ទំនង Contact Address : ....................................

ចំណេះដឹងលើការវិនិយោគ **Investment Knowledge :**

☐ល្អណាស់ Very Good ☐ល្អ Good ☐មានកម្រិត Limited ☐គ្មាន Nothing

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគ **Experience In Investment Activities :**

☐បណ្ណរតនាគារ Treasury Bill ☐ភាគហ៊ុន Stock ☐សញ្ញាបណ្ណ Bond ☐មូលបត្រផ្សេងទៀត Others Securities ☐គ្មាន Nothing

ឯកសារធនាគាររបស់អតិថិជន **Bank Reference :**

ឈ្មោះធនាគារ Name : ------------------------------------------------

លេខគណនីធនាគារ Account No : ------------------------ ប្រភេទគណនី Type of Account : ------------

បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់ **Contact Person In Case Of Emergency :**

ឈ្មោះ (នាម និងគោត្តនាម) Name & Surname : ------------------ ជាអក្សរឡាតាំង Latin Name : ------------------

អាសយដ្ឋានទំនាក់ទំនង Contact Address : ------------------------------------------------

លេខទូរស័ព្ទ Tel : -------------- ទូរសារ Fax : -------------- អ៊ីម៉ែល E-mail : --------------

ទំនាក់ទំនងរវាងភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងអតិថិជនៈ **Relationship Between Client and Securities Representative :**

☐ញាតិសន្តាន Relative ☐មិត្តភក្តិ Friend ☐ស្គាល់តាមរយៈការណែនាំ Introducing (ឈ្មោះអ្នកណែនាំ Name of Introducer : ------------------)

☐ពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នា Don't know each other ☐ផ្សេងៗ Other

ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី **Document for Account Opening Application**

☐សៀវភៅធនាគារថតចម្លង (រយៈពេល៦ខែចុងក្រោយ) Copy of Book Bank (last 6 months) with first page which account no. fully

☐អត្តសញ្ញាណប័ណ្ណថតចម្លង Copy of I.D. Card ☐សៀវភៅគ្រួសារថតចម្លង Copy of House Registration

☐លិខិតឆ្លងដែន/ទិដ្ឋាការថតចម្លង Copy of Passport or visa ☐សំបុត្រកំណើតថតចម្លង Copy of Birth Certificate

☐លក្ខន្តិកៈថតចម្លង Copy of Memorandum and Article ☐វិញ្ញាបនប័ត្រចុះបញ្ជីថតចម្លង Copy of Registered Certificate

☐ប័ណ្ណប៉ាតង់ថតចម្លង Copy of Patent ☐អាជ្ញាបណ្ណថតចម្លង Copy of License

☐សេចក្តីសម្រេចរបស់នីតិបុគ្គល/ស្ថាប័នថតចម្លង Copy of Institution/Legal Entity's Decision ☐ផ្សេងៗ Others (..........................................)

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ Comment of Securities Representative :

------------------------------------------------------------------------

| ហត្ថលេខា និងឈ្មោះ របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ<br>Signature and Name of Securities Representative | ហត្ថលេខារបស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ<br>ឬអ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ<br>Signature of Head of Securities Representative, Branch Manager, CEO | ហត្ថលេខា និងឈ្មោះរបស់អតិថិជន<br>[និងត្រា (ករណីជានីតិបុគ្គល/ស្ថាប័ន]<br>Signature and Client Name [and seal *(in case as Institution/Legal Entity)*] |
|---|---|---|
| | | ① |
| ធ្វើនៅថ្ងៃទី Day.....ខែ Month.....ឆ្នាំ Year..... | ធ្វើនៅថ្ងៃទី Day.....ខែ Month.....ឆ្នាំ Year..... | ធ្វើនៅថ្ងៃទី Day.....ខែ Month.....ឆ្នាំ Year..... |

ការព្រមព្រៀងលើការផ្ទេរសិទ្ធិ Attach Agreement and Delegation Power Document

អតិថិជន **Client:** ក្រុមហ៊ុន **Company :**

③

# កិច្ចព្រមព្រៀងអតិថិជន CLIENT AGREEMENT

ទីកន្លែង និងកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង **Place and Date of this Agreement**: ______________________

កិច្ចព្រមព្រៀងរវាង៖ **The Agreement between** :

-ក្រុមហ៊ុន The **Firm** :

ឈ្មោះ **ក្រុមហ៊ុនភ្នំពេញស៊ីឃ្យួរីធី ភីអិលស៊ី** អាសយដ្ឋានផ្ទះលេខ៣២ ផ្លូវព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណចុះបញ្ជីនៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង គណៈកម្មការមូលបត្រកម្ពុជា

ភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ______________________

Name : **Phnom Penh Securities Plc.** Address : No.32, Monivong Blvd. Phnom Penh, Cambodia a licensed firm which has registered at Ministry of Commerce and Securities and Exchange Commission of Cambodia, Cambodia; its licensed representative ______________________

និង and

-អតិថិជន The **Client:**

ឈ្មោះ Name : ______________________

អាសយដ្ឋាន Address : ______________________

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន ID/Passport : ______________________

លេខវិញ្ញាបនប័ត្រចុះបញ្ជី(ករណីជានីតិបុគ្គល/ស្ថាប័ន) Registered number (in case as *Institution/Legal Entity*) : ______________ ចុះថ្ងៃទី Day___
ខែ Month__________ឆ្នាំ Year__________។

**ភាគីទាំងពីរព្រមព្រៀងគ្នា ដូចខាងក្រោម The Parties agree together the following:**

## សាវតា BACKGROUND

១-ក្រុមហ៊ុនជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឲ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនធានាទិញមូលបត្រ ដោយ គ.ម.ក.។

២-អតិថិជនមានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សា ដែលទាក់ទងនឹងមូលបត្រ។

៣-អនុលោមតាមមាត្រា៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ របស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវចុះកិច្ចព្រមព្រៀងជាមួយអនាគតអតិថិជន។

៤-ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

1- The Firm is a licensed firm carrying on business in the Kingdom of Cambodia and holding a **Securities Underwriter** issued by the SECC.
2- The Client wishes to appoint the Firm as its agent to provide it with certain advice and trading services in relation to Securities.
3- Under Article 54 of the Sub-decree and Article 6 of Prakas on the Code of Conduct of Securities Firms and Securities Representatives, a licensed firm shall enter into an Agreement with a prospective client.
4- The Parties have set out in this Agreement the terms and conditions that, subject to Securities Laws and relevant regulations, shall apply to the provision of the Services.

## និយមន័យ DEFINITIONS

៥-ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឲ្យនិយមន័យដោយអនុលោមតាម ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិដែលកំណត់ដោយ គ.ម.ក. និងច្បាប់ពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។
និយមន័យខាងក្រោមនេះដែលត្រូវប្រើប្រាស់ក្នុងកិច្ចព្រមព្រៀង៖

**កិច្ចព្រមព្រៀង** : សំដៅដល់កិច្ចព្រមព្រៀងអតិថិជន។

**សាច់ប្រាក់អតិថិជនគ្រប់គ្រាន់** : សំដៅដល់ប្រាក់ដែលអាចប្រើប្រាស់បាននៅក្នុងគណនីសាច់ប្រាក់អតិថិជនក្នុងពេលជាក់លាក់មួយ សម្រាប់ការបញ្ជាទិញមូលបត្ររបស់អតិថិជន ដោយយកសមតុល្យក្នុងគណនីសាច់ប្រាក់អតិថិជនដកចេញនូវរាល់បំណុលអតិថិជនទាំងអស់ ការបញ្ជាទិញពីមុនទាំងអស់របស់អតិថិជន ព្រមទាំងប្រាក់ដែលអតិថិជនបានស្នើដក ឬស្នើទូទាត់ទៅតតិយជន។

**ធនាគារ** : សំដៅដល់ធនាគារពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**ព័ត៌មានអតិថិជន** : សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឲ្យក្រុមហ៊ុនមូលបត្រនៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

**បំណុលអតិថិជន** : សំដៅដល់ប្រាក់ដែលអតិថិជនជំពាក់ក្នុងការទូទាត់ទៅបុគ្គលផ្សេងទៀត ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាអាទិ៍ កម្រៃជើងសា ថ្លៃសេវា លាភការផ្សេងៗ ពន្ធ ឬចំណាយផ្សេងទៀតដែលទាក់ទងនឹងការលក់ ឬការទិញមូលបត្រ និងកម្រៃរដ្ឋបាលដែលទាក់ទងនឹងការធ្វើប្រតិបត្តិការលើគណនីសាច់ប្រាក់អតិថិជន។

**បញ្ជាអតិថិជន** : សំដៅដល់បញ្ជាទិញ ឬលក់មូលបត្ររបស់អតិថិជនទៅក្រុមហ៊ុនមូលបត្រ។

**ក្រមសីលធម៌វិជ្ជាជីវៈ** : សំដៅដល់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈ របស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

**អាជ្ញាបណ្ណ** : សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ឲ្យក្រុមហ៊ុនដោយអគ្គនាយកនៃ គ.ម.ក។

**ការជួញដូរមូលបត្រ** : សំដៅដល់ការជួញដូរមូលបត្របានចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុត។

**សេវាកម្ម** : សំដៅដល់ការផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

**ប្រតិសិទ្ធិសកល** : សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទៅពីបុគ្គលដទៃ។

**ប្រតិសិទ្ធិដោយឡែក** : សំដៅដល់បុគ្គលដែលទទួលបន្តសិទ្ធិមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

Terms used in this Agreement shall have the meanings given in the Law on the Issuance and Trading of Non-Government Securities and the relevant regulations set by SECC, and the relevant laws of the Kingdom of Cambodia. The following further definitions shall apply in respect of the Agreement :

**Agreement** : means this Client Agreement.

**Available Client Money** : means Client Money in the Client Money Account that is available at a given time for the Client's purchase of Securities, taking into the balance in the Client Money Account less any Client Liabilities and any previous Client Orders and Client requests for withdrawal of money or payment to third parties.

**Bank** : means a commercial bank regulated and supervised under the Law on Banking and Financial Institutions of the Kingdom of Cambodia.

**Client Information** : means the information in relation to the Client provided to the Firm at the time of opening of the Client's account with the Firm, as updated from time to time.

**Client Liability** : means any amount that the Client is liable to pay to another person pursuant to this Agreement or under any law, subject to the provisions of the Code of Conduct including but not limited to any commission, fee, other remuneration, taxes, stamp duties, any other expenses related to the sale or purchase of Securities, and any administration fees relating to the operation of the Client Money Account.
**Client Order** : means an order given to the Firm by the Client in relation to purchase or sale of Securities.
**Code of Conduct** : means Prakas on the Code of Conduct of Securities Firms and Securities Representatives.
**License** : means the license issued to the Firm by the Director General of the SECC.
**Securities Trading** : means trading in any Securities listed on the Securities Exchange Permitted.
**Services** : means investment advice in relation to Securities Trading, and arranging Securities Trading.
**Universal Successor** : means who succeeds to the general rights and obligations from another person.
**Particular Successor** : means who succeeds to the limit rights and obligations based on each specific reason

## បទប្បញ្ញត្តិប្រតិបត្តិការ OPERATING PROVISIONS

### ៦-ការជ្រើសរើសក្រុមហ៊ុន Appointment of the Firm

១-អតិថិជនជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួនដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ អតិថិជនព្រមព្រៀងអនុវត្តកាតព្វកិច្ចនា-នាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុនក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

២-ក្រុមហ៊ុនមិនត្រូវធ្វើប្រត្តិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជនក្នុងនាមអតិថិជន ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមពៀងនេះ។

៣-ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ គ.ម.ក.។

1- The Client appoints the Firm as the Client's agent to provide the Services to the Client on the terms of this Agreement. The Client agrees to be bound by the acts of the Firm carried out within the scope of the authority granted by the Client under this Agreement.
2- The Firm shall not act as principal in relation to the Client in relation to any Securities Transaction except with the prior written Agreement of the Client.
3- The Firm warrants that it is authorized to provide the Services to the Client. The Firm shall provide any services in relation to Securities for which the terms of the License issued by the Director General of the SECC.

### ៧-ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន Updating Information

១-ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ក្រមសីលធម៌វិជ្ជាជីវៈ។

២-អតិថិជនត្រូវធានាថា ព័ត៌មានដែលផ្តល់ឲ្យនៅពេលចុះកិច្ចព្រមព្រៀង ជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ។

៣-អតិថិជនត្រូវទទួលស្គាល់ថា ក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិជនដោយផ្អែកលើព័ត៌មានអតិថិជន។ អតិថិជនយល់ព្រមជូនដំណឹងភ្លាមទៅក្រុមហ៊ុននៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់អតិថិជន។

៤-ក្រុមហ៊ុនត្រូវធ្វើបច្ចុប្បន្នកម្មការផ្លាស់ប្តូរព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មាននោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀង។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនផ្តល់ឲ្យអតិថិជននូវព័ត៌មានជាលាយ-លក្ខណ៍អក្សរមុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។ ចំណុចទី ៧ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិ-យោគឡើយ។

1- The Firm acknowledges and agrees that it has completed a New Customer Account form in respect of the Client, in the form set out in Appendix to the Code of Conduct.
2- The Client warrants that the Client Information provided as at the date of this Agreement is true and correct.
3- The Client acknowledges that the Firm shall provide the Services to the Client on the basis of the Client Information. The Client agrees to promptly notify the Firm of any material changes to such Client Information.
4- The Firm shall update the Client in writing from time to time in relation to any changes in the information relating to the Firm set out in this Agreement. The Firm acknowledges and agrees that it is required under the provisions of the Code of Conduct to provide the Client with certain information in writing prior to the execution of Securities Transactions on the Client's behalf. The point 7 of this Agreement shall not comply for Investment Advisory Firms and Investment Advisory Representatives.

### ៨-ការជួញដូរមូលបត្រ Securities Trading

១-ក្រុមហ៊ុនត្រូវអនុវត្តការជួញដូរមូលបត្រក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិ-ថិជន និងមិនអនុញ្ញាតនូវរាល់ការបញ្ជាពីអតិថិជនឲ្យអនុវត្តការជួញដូរមូលបត្រដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះលើក-លែងតែមានការអនុញ្ញាតពី គ.ម.ក.។

២-អតិថិជនផ្តល់សិទ្ធិអោយក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជន ដើម្បីៈ

ក-បញ្ជូនបញ្ជារបស់អតិថិជន

ខ-ផ្ទេរមូលបត្រដែលត្រូវបានលក់ ឬ ទិញតាមបញ្ជារបស់អតិថិជន

គ-ធានាថារាល់ការផ្ទេរ បានកត់ត្រាត្រឹមត្រូវនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

៣-ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្រក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមវិធានប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិជាធរមាន។

៤-ក្រុមហ៊ុន និងអតិថិជនត្រូវទទួលស្គាល់ និងព្រមព្រៀងថាៈ

ក-ក្រុមហ៊ុនមិនត្រូវទិញមូលបត្រក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឲ្យក្រុមហ៊ុននូវប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រ និងអតិថិជនយល់-ព្រមថាមិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្រនៅតម្លៃលើសពីបរិមាណសាច់ប្រាក់អតិថិជនដែលមានឡើយ និង

ខ-ក្រុមហ៊ុនមិនត្រូវលក់ស៊តសែល (short sell) ឡើយ និងអតិថិជនមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅប្រតិ-បត្តិកររក្សាទុកមូលបត្រក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន។

៥-អតិថិជនព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថា បញ្ជារបស់អតិថិជននឹងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោល ឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។ ចំណុចទី ៨ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៦-អតិថិជនមិនត្រូវប្រគល់ជាដាច់ខាតទៅអោយបុគ្គលិកក្រុមហ៊ុននូវព័ត៌មាន ឬក៏ឯកសារដូចជា សៀវភៅធនាគារ កាតអេធីអឹម និងលេខសម្ងាត់ធនាគារ ដែលអាចត្រូវបានប្រើដោយបុគ្គលិករបស់ក្រុមហ៊ុន ដែលធ្វើអោយបាត់បង់ផលប្រយោជន៍អតិថិជនក្រៅពីប្រតិបត្តិការជួញដូរមូលបត្រ។

1- The Firm shall engage in Securities Trading of on behalf of the Client only to carry out Client Orders given from time to time. The Firm shall not operate a discretionary account on behalf of the Client, and any instruction given by the Client to engage in Securities Trading on a discretionary basis shall be deemed for all purposes of this Agreement not to have been given, unless approved by SECC.
2- The Client authorizes the Firm to do all things reasonably necessary on the Client's behalf, pursuant to a Client Order to:
a- place the Client Order;

b- transfer Securities sold by the Client or purchased by the Client; and
c- ensure that each such transfer is correctly recorded at the Securities Depository.

3- The Firm agrees to arrange transfer of Securities on behalf of a Client, and any recording of such transfer, in accordance with the Code of Conduct and the rules, systems and procedures applicable to the Securities Depository and under existing regulations.

4-The Firm and the Client acknowledge and agree that :
a- the Firm shall not purchase Securities on behalf of a Client unless the Client has provided the Firm with sufficient Available Client Money, and the Client agrees not to place a Client Order to buy Securities at a price exceeding the Available Client Money; and
b- the Firm shall not short sell Securities on behalf of the Client, and the Client shall not place a Client Order to sell Securities unless the Securities are registered with the Securities Depository in the name of the Client and are available to be sold.

5- The Client agrees to be bound by its Client Orders and agrees and acknowledges that a Client Order may not be cancelled or varied after it is executed. A Client Order may not be cancelled or varied prior to execution of the Client Order unless the Client notifies the Firm in such manner as is reasonably required by the Firm. The point 8 of this Agreement shall not comply for Investment Advisory Firms and Investment Advisory Representatives.

6-The Client must not offer the Firm staffs any information or document such as account book, ATM card and bank passwords which can be accessed by the Firm staffs that can affect the client's interest besides trading securities transactions.

## ៩-វិធីសាស្ត្រក្នុងការដាក់បញ្ជា Methods of Placing Orders

១-អតិថិជនអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖
ក-ជាលាយលក្ខណ៍អក្សរ
ខ-តាមរយៈទូរស័ព្ទ ទូរសារ និងតាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

២-បញ្ជាអតិថិជនត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្រ រួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ និងថ្លៃមូលបត្រ និងកាលបរិច្ឆេទ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិចដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

1- A client shall place orders using any of the following methods :
a- In writing;
b- Over telephone, facsimile and using other electronic communication methods prescribed by SECC.

2- The Client's order in relation to trading in that Security, including the Security name, type, quantity, price and date. The Firm shall record such order in writing, tape-recording or other electronic to evidence of the place order.

## ១០-ការបដិសេធទទួលបញ្ជា Refusal of Receiving Orders

១-ក្រុមហ៊ុនមិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខន្តិកៈនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

២-ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរ ក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទី១ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

1- The Firm not comply with a Client Order if the Client Order would be contrary to any Securities Law and relevant regulations or the terms of this Agreement. The Firm shall not be liable for any loss, cost or expense suffered by the Client as a result of the Firm's refusal to carry out such a Client Order.

2- The Firm shall promptly notify the Client in writing if it at any time refuses in paragraph (1) or fails for any reason to carry out a Client Order or to carry out a Client Order in accordance with the terms of the Client Order.

## ១១-ការជូនដំណឹងការជួញដូរមូលបត្រ Securities Trading Notifications

ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននូវរាល់ប្រតិបត្តិការមូលបត្រដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ។ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

The Firm shall provide the Client with a notification of each securities transaction effected on behalf of the Client, in compliance with Article 21 of the Code of Conduct. The Client agrees to carefully review each such notification and to notify the Firm promptly of any differences between the Client's records and the information shown in the notification.

## ១២-គណនីសាច់ប្រាក់អតិថិជន Client Money Account

១-អតិថិជនផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំពោះ៖
ក-ការដាក់តម្កល់ប្រាក់ដែលទទួលបានពីអតិថិជន ឬក្នុងនាមអតិថិជនទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលពាក់ព័ន្ធនឹងអតិថិជន
ខ-ការទទួលប្រាក់ពីការលក់មូលបត្រក្នុងនាមអតិថិជនតាមបញ្ជាចូលក្នុងគណនីសាច់ប្រាក់អតិថិជន
គ-ការទូទាត់ចេញពីគណនីសាច់ប្រាក់អតិថិជនសម្រាប់ការទិញមូលបត្រក្នុងនាមអតិថិជនតាមបញ្ជារបស់អតិថិជន
ឃ-ការទូទាត់សងបំណុលអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រពីគណនីសាច់ប្រាក់អតិថិជន
ង-ការទូទាត់ផ្សេងៗពីគណនីសាច់ប្រាក់អតិថិជនដែលតម្រូវដោយច្បាប់ និង
ច-ការដាក់ប្រាក់ចូល និងការដកប្រាក់ចេញពីគណនីសាច់ប្រាក់អតិថិជននៅពេលមានបញ្ជាអតិថិជន ឬការណែនាំជាលាយលក្ខណ៍អក្សរពីអតិថិជន។

២- អតិថិជនមានសិទ្ធិទទួលរាល់ចំណូលការប្រាក់ដែលកើតមានក្នុងគណនីអតិថិជន។

1- The Client authorizes the Firm to :
a- deposit any Client Money received from or on behalf of the Client into the Client Money Account relating to the Client;
b- accept payment for Securities sold on behalf of the Client pursuant to a Client Order into the Client Money Account;
c- make payment from the Client Money Account for Securities purchased on behalf of the Client pursuant to a Client Order;
d- pay for any Client Liability related to Securities trading from the Client Money Account;
e- make any other payment from the Client Money Account as may be required by law; and
f- otherwise pay money into and out of Client Money Account in accordance with Client Orders or other written instructions of the Client from time to time.

2- The Client shall be entitled to receive any interest paid in respect of the Client Money Account.

## ១៣-របាយការណ៍ Reports

១-ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរដល់អតិថិជន ទាក់ទងនឹងការជួញដូរមូលបត្រដូចខាងក្រោម៖
ក-សេចក្តីជូនដំណឹងស្តីពីការជួញដូរមូលបត្រដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ។
ខ-របាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងគណនីអតិថិជនដោយអនុលោមតាមប្រការ ២២ នៃក្រមសីលធម៌វិជ្ជាជីវៈ ។
គ-របាយការណ៍ពាក់ព័ន្ធនឹងប្រាក់អតិថិជន ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ។

២-អតិថិជនព្រមព្រៀងក្នុងការពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃរបាយការណ៍ដែលផ្តល់ដោយក្រុមហ៊ុនដើម្បីធានាថាខ្លឹមសារនៃរបាយការណ៍ដែលបានផ្តល់ឲ្យមានសង្គតិភាពនឹងកំណត់ត្រាផ្ទាល់ខ្លួន និងជូនដំណឹងដល់ក្រុមហ៊ុនភ្លាមនូវរាល់ភាពខុសគ្នាណាមួយ។

1- The Client acknowledges that it shall receive the following written reports from the Firm in relation to trading in Securities :
a- notifications of Securities trades in accordance with Article 21 of the Code of Conduct;
b- a monthly transactions report on the Client's account, in accordance with Article 22 of the Code of Conduct;
c- reports in relation to Client Money in accordance with Law and relevant regulations of Securities.

2- The Client agrees to carefully check the contents of the reports provided by the Firm, to ensure that the contents of such reports are consistent with the Client's own records, and to promptly notify the Firm of any differences.

## ១៤-លាភការ Remuneration

១-ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថាការបង់លាភការឲ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះត្រូវបានកំណត់តាមតារាង[១] និងអាចប្រែប្រួលតាមការកំណត់របស់គ.ម.ក.។

២-ក្រុមហ៊ុនអាចធ្វើបច្ចុប្បន្នកម្មតារាង[១] នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវរាល់ការផ្លាស់ប្តូរនោះ។ ដើម្បីអោយការតម្លើងលាភការដែលត្រូវបង់ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្ត លុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៣-ក្រុមហ៊ុនត្រូវព្រមព្រៀងថា នៅពេលគិតថ្លៃសេវាពីអតិថិជនលើសចំនួនដែលមានចែងក្នុងតារាង[១] ត្រូវបង្វិលសាច់ប្រាក់ដែលបង់លើសចូលក្នុងគណនីសាច់ប្រាក់អតិថិជនភ្លាមៗ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជន។

1- The Parties acknowledge and agree that the remuneration payable to the Firm under this Agreement shall be set out in Schedule [1] and fixed from time to time by the SECC.

2- The Firm may update Schedule [1] from time to time to reflect any changes to remuneration, and shall notify the Client in writing of such changes. To be any increase of remuneration payable under this Agreement shall take effect until the Agreement has been updated and the Client notified to agree in writing.

3- The Firm agrees that where for any reason it at any time charges any amount to the Client exceeding the amounts set out in Schedule [1], it shall immediately upon becoming aware of such overcharging refund the excess to the Client Money Account and shall notify the Client in writing.

## ១៥-ផលប្រយោជន៍ និងទំនាក់ទំនង Interests and Relationships

ក្រុមហ៊ុនត្រូវបញ្ជាក់នូវរាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងតារាង[២]ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

The Firm confirms that all of the interests or relationships between the Firm and other persons, that could influence the Firm or its Securities Representatives which has set out in Schedule [2] and in respect of the terms and conditions of the Agreement and other relevant regulations.

## ១៦-ការតវ៉ា Complaints

១-ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះ និងព័ត៌មានលំអិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

២-ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជន ក្នុងអំឡុងពេល ០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

1- If any case the licensed firm or its representative shall not apply to the terms and conditions of the Agreement, the Client may make a complaint in writing to confirm the name and contact details of person handling complaints at the Firm.

2- The Firm shall agree to solve of the Client's complaint within 07 (seven) day of business days after reception of the complaint.

## ១៧-អ្នកតំណាងរបស់អតិថិជន Client's Personal Representatives

១-អតិថិជនអាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាអ្នកតំណាងតាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ ដើម្បីដាក់បញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះ អតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងតារាង[៣]។

២-មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឲ្យអតិថិជនផ្តល់ឲ្យក្រុមហ៊ុនមូលបត្រនូវឯកសារដើម ឬថតចម្លងមានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកតំណាង។

៣-អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាងតាមបញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀត លើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

1-The Client may appoint a person other than the Securities Firm or any of its Related Entities a "personal representative" in writing by power of attorney or other means permitted by law to give Client Orders or other instructions to the Firm on the Client's behalf in respect of Securities Trading through the Securities Firm. As at the date of this Agreement, the Client has appointed the persons specified in Schedule [3] as its personal representatives.

2-The Firm may, prior to accepting any instructions provided by a personal representative, require that the Client provides the Securities Firm with an original or a certified true copy of the written authority under which the personal representative is appointed.

3-The Client shall notify immediately the Firm in writing of the revocation of any personal representative's authority. The Firm may act in accordance with Client Orders or other instructions received from a personal representative unless and until it is notified otherwise by the Client.

## ១៨-ការរក្សាភាពសម្ងាត់ Confidentiality

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្មស្របតាមកិច្ចព្រមព្រៀងនេះទៅឲ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយខាងក្រោម៖

១-មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់នោះ។

២-មានការស្នើសុំពី គ.ម.ក. ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឬ

៣-មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

The Firm agrees not to disclose to any person any confidential Client Information, or any other confidential information in relation to the Client that the Firm obtains in carrying out the Services pursuant to this Agreement, provided that the Firm may disclose such confidential information：

1-with the written consent of the Client by confirm a authorized person to given;

2- to the SECC or court of the Kingdom of Cambodia;

3- otherwise as provided by law and other relevant regulations.

## ១៩-សេចក្តីថ្លែងព័ត៌មានហានិភ័យ Risk Disclosure Statements

១-អតិថិជនត្រូវទទួលស្គាល់ថាថ្លៃមូលបត្រអាចប្រែប្រួលឡើង ឬចុះហើយព័ត៌មានដែលត្រូវបានផ្តល់ឲ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្រដែលស្របតាមកិច្ចព្រមព្រៀងនេះនឹងមិនត្រូវបានធានាដោយក្រុមហ៊ុន ឬបុគ្គលផ្សេងទៀតឡើយ។

២-ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឲ្យ ប្រសិនបើមាន។

៣-ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះអសមត្ថភាពក្នុងការអនុវត្តឬការពន្យាពេលការអនុវត្តភារកិច្ចរបស់ខ្លួនចំពោះអតិថិជនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះដែលជាលទ្ធផលនៃការរអាក់ខាននៃប្រតិបត្តិការផ្ទេរឬប្រតិបត្តិការប្រព័ន្ធកុំព្យូទ័រឬឧបសគ្គផ្សេងទៀតដែលបង្កមកពីប្រធានសក្តិ(អនុលោមតាមបទប្បញ្ញត្តិធរមាន)។

៤-រាល់កំហុសដែលកើតចេញពីភាគីផ្ទាល់គឺការទទួលខុសត្រូវរបស់ភាគីអ្នកប្រព្រឹត្តនោះ។

៥-ក្នុងករណីប្រធានសក្តិ (អនុលោមតាមបទប្បញ្ញត្តិធរមាន) ក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះការខាតបង់របស់អតិថិជនឡើយ។

1-The Client acknowledges that it has been informed that the returns on, or value of, any Securities acquired pursuant to this Agreement are not guaranteed by the Firm or any other person, and the value of such Securities may go up or down.

2- Firm to insert any additional relevant risk disclosure statements, depending on the Services provided, if any.

3-The Firm shall not be responsible for the inability to perform or delay in performing its obligations to the Client under this Agreement as a result of any disruptions of transmission or computer link operation or other obstacles caused by force majeure (in accordance with the law).

4-Party is responsible for his/her mistakes.

5-In case of force majeure (in accordance with the law), the Firm will not be responsible for any loss of the Client's interest.

**២០-ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង Copy of Agreement**

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឲ្យអតិថិជនមួយច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

The Agreement shall make into two documents with sign and seal or fingerprint of the parties, and the Firm shall provide the Client with such document of this Agreement immediately and keep another at the firm.

**២១-បដិវាទកម្ម Laws Not Affected**

ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ ឬ/និងកិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

The Parties agree that, in compliance with Article 6 of the Code of Conduct, the terms of this Agreement shall not in any way operate to remove, exclude, or restrict any rights of the Client or obligations of the Firm under the law. Any terms and conditions of this Agreement or/and any other Agreement between the Parties which in any way operate to remove, exclude, or restrict any rights of the Client or obligations of the Firm under the law, shall be of no effect.

**២២-ការជូនដំណឹង Notice**

១-រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឲ្យអតិថិជនត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍-អក្សរផ្សេងពីនេះពីអតិថិជន។

២-អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

1- Unless otherwise requested in writing by the Client all reports and notices required to be given to the Client pursuant to this Agreement or the Code of Conduct.

2- The Client agrees to promptly notify the Firm of any changes of address or any other contact details of the Client. If the Client fails to notify the Firm in accordance with the terms and conditions set out in this Agreement, any report or other notice sent to the Client last known to the Firm.

**២៣-ការបញ្ចប់កិច្ចសន្យា Termination**

១-ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលាដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ០៧(ប្រាំពីរ)ថ្ងៃដល់ភាគីម្ខាងទៀត។

២-ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ច-ព្រមព្រៀងនេះ។

1- Either Party shall be entitled to terminate this Agreement at any time by notifying the other party in writing 07 (seven) days in advance.

2- The parties agree that termination of this Agreement shall not affect the rights and duties of the Parties that have accrued before such termination.

**២៤-កិច្ចព្រមព្រៀងរួម Entire Agreement**

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាងដែលចែងអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជន និងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម។ រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអានុភាពអនុវត្តឡើយ។

This Agreement is the entire Agreement between the parties as to the appointment of the Securities Firm as the Client's agent and the provision of the Services. No other representation, statement or Agreement whether written or oral between the Parties in relation to such matters shall be of any effect.

**២៥-ការកែប្រែ Amendment**

កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធ-នកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

This Agreement may only be amended with the Agreement of each Party, provided that where there is a change in any Securities Law and relevant regulations that is contrary to the provisions of this Agreement, the Securities Firm shall amend this Agreement so that it complies with such changed Securities Law and relevant regulations, without the Client's consent, and upon doing so shall notify the Client in writing of such amendment.

**២៦-ការចាត់តាំង Assignment**

អតិថិជនព្រមព្រៀងថារាល់សិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឲ្យប្រតិសិទ្ធិសកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជន ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាពដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្រ និងការចុះបញ្ជីនៃការផ្ទេរនោះ។

The Client agrees that any right and obligation in this Agreement shall be binding upon the Client's universal successor, particular successor and personal representatives in title and that in the case of any change of title to Securities that occurs by operation of law, by reason of the Client's death, bankruptcy, legal incompetence, court order or any other reason, the Firm may arrange any transfer of Securities and the registration of such transfer.

**២៧-ច្បាប់គ្រប់គ្រង និងយុត្តាធិការ Governing Law and Jurisdiction**

១-កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២-រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះ អាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ គ.ម.ក.។

1- This Agreement is governed by the laws of the Kingdom of Cambodia.

2- Any dispute under the terms of this Agreement may be resolved pursuant to any dispute resolution procedure prescribed by the SECC.

**ដើម្បីឲ្យកិច្ចសន្យានេះមានសុពលភាព ភាគីទាំងពីរព្រមព្រៀងគ្នាដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃ To the Agreement has validity, the parties agree to sign or fingerprint:**

| | |
|---|---|
| ហត្ថលេខា និងឈ្មោះអតិថិជន [និងត្រា (ករណីជានីតិបុគ្គល/ស្ថាប័ន )]<br>Signature and Name of Client [and seal (*in case as Institution/Legal Entity*)]<br>②<br>Date: | ហត្ថលេខា និង ត្រាក្រុមហ៊ុនភ្នំពេញស៊ីឃ្យូរីធី ភីអិលស៊ី<br>Signature and Seal of Phnom Penh Securities Plc |
| ផ្ទៀងផ្ទាត់ដោយ Verified by: | អនុញ្ញាតដោយ Approved by: |

# តារាងទី១ Schedule 1

**លាភការ Remuneration**

**ការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ Set out commissions, fees, and other remuneration**

| ប្រភេទកម្រៃ<br>**Nature of Benefit** | ចំនួនប្រាក់<br>**Amount** | ការគណនា<br>**Method of Calculation** |
|---|---|---|
| កម្រៃជើងសា Commissions | | |
| ថ្លៃសេវា Fees | | |
| លាភការផ្សេងៗ Other Remuneration | | |

# តារាងទី២ Schedule 2

**ផលប្រយោជន៍ និងទំនាក់ទំនង Interests and Relationships**

| ឈ្មោះ<br>**Name** | ទំនាក់ទំនងជាមួយក្រុមហ៊ុន<br>**Relationship with Firm** | ការពន្យល់ពីឥទ្ធិពល<br>**Explanation of Influence** |
|---|---|---|
| | | |
| | | |
| | | |

# តារាងទី៣ Schedule 3

**អ្នកតំណាងរបស់អតិថិជន Client's Personal Representatives**

| ឈ្មោះអ្នកតំណាង<br>**Personal Representatives Name** | អាសយដ្ឋាន និងលេខទំនាក់ទំនង<br>**Personal Representatives Address and Contact Details** | ទំហំនៃការអនុញ្ញាតសិទ្ធិ<br>**Scope of Authority** |
|---|---|---|
| | | |
| | | |
| | | |

# កិច្ចព្រមព្រៀងប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញ

ដើម្បីធ្វើការប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញ ដោយរួមបញ្ចូលទាំង ប្រព័ន្ធជួញដូរតាមរយៈវែបសាយ (“Web Trading System”) និង កម្មវិធីទូរស័ព្ទចល័ត (“PPS iTrader”) ជាមួយ ក្រុមហ៊ុន ភ្នំពេញ ស៊ីយូរីធី ភីអិលស៊ី (“PPS”) លោកអ្នក (“អតិថិជន”) ត្រូវតែអាន និង យល់ព្រមជាមួយនឹងលក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀងប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញ (“កិច្ចព្រមព្រៀង”) ដោយយកចិត្តទុកដាក់ និង ទុកជាឯកសារផ្ទាល់ខ្លួន។

កិច្ចព្រមព្រៀងគឺមានប្រសិទ្ធភាពចាប់តាំងពីពេលដែលអតិថិជនចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធរបស់ PPS និងប្រើប្រាស់វែបសាយជួញដូររបស់ PPS និង/ឬ ប្រព័ន្ធជួញដូរតាមទូរស័ព្ទចល័ត (“Online Trading System”)។ កិច្ចព្រមព្រៀងនេះក៏ត្រូវបានប្រើប្រាស់ជាកិច្ចព្រមព្រៀងបន្ថែមប៉ុន្តែមិនមែនជំនួសឲ្យ “កិច្ចព្រមព្រៀងអតិថិជន” ដែលលោកអ្នកបានចុះនៅពេលបើកគណនីជួញដូរជាមួយ PPS នោះឡើយ។

**១. ឈ្មោះគណនី និង លេខសម្ងាត់**

ក. ឈ្មោះគណនី និងលេខសំងាត់ គឺជាតម្រូវការចាំបាច់សំរាប់ចូលទៅធ្វើការប្រើប្រាស់ និងបញ្ជាការជួញដូរតាមអនឡាញ។ លោកអ្នកត្រូវទទួលខុសត្រូវទៅលើការរក្សាឲ្យបានល្អនូវឈ្មោះគណនី និងលេខសម្ងាត់របស់លោកអ្នក។ មានតែលោកអ្នក និងអ្នកដែលទទួលសិទ្ធិពីលោកអ្នកទើបអាចធ្វើការជួញដូរបាន។ **លោកអ្នកនឹងតម្រូវឲ្យផ្លាស់ប្តូរ លេខសម្ងាត់បន្ទាប់ ពីការចូលលើកដំបូងដែលតម្រូវឲ្យមានភាពស្មុគស្មាញគ្រប់គ្រាន់។** លោកអ្នកអាចធ្វើការផ្លាស់ប្តូរលេខសម្ងាត់របស់លោកអ្នកគ្រប់ពេល។ លោកអ្នកផ្តល់សិទ្ធិឲ្យយើងខ្ញុំដើម្បីធ្វើតាមការបញ្ជាណាមួយតាមរយៈប្រព័ន្ធជួញដូរតាមអនឡាញដោយប្រើប្រាស់អត្តសញ្ញាណ និងលេខសម្ងាត់ របស់លោកអ្នក។

ខ. លោកអ្នកត្រូវតែជូនដំណឹងភ្លាមៗមក PPS ក្នុងករណីដែលលោកអ្នកដឹង ឬសង្ស័យថា:

a. ឈ្មោះគណនី និង លេខសំងាត់របស់លោកអ្នកបានបាត់ ឬត្រូវបានលួច ឬមាននរណាម្នាក់បានធ្វើប្រតិបត្តិការ ទៅលើគណនីរបស់លោកអ្នកដោយគ្មានការអនុញ្ញាតពីលោកអ្នក។
b. ប្រតិបត្តិការត្រូវបានបញ្ជូនចូលប្រព័ន្ធ ដោយមានកំហុសឆ្គង។

២. លោកអ្នកនឹងមិនត្រូវធ្វើប្រតិបត្តិការជួញដូរក្រោមរូបភាពភ្នាល់គ្នា ហើយលោកអ្នកមិនមែនជាអតិថិជនដែលត្រូវបានហាមឃាត់ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**៣. វាគឺជាការទទួលខុសត្រូវរបស់លោកអ្នកដើម្បីធ្វើការបញ្ជា និង/ឬ ធ្វើប្រតិបត្តិការផ្សេងៗកំឡុងពេលម៉ោងធ្វើការ និង/ឬ ម៉ោងជួញដូរដោយផ្តល់នូវពត៌មានគ្រប់គ្រាន់ដល់ PPS ដើម្បីដំណើរការឲ្យលោកអ្នក។**

៤. រាល់ ពាក្យ អក្សរបំពេញ សញ្ញា និងពតិមានផ្សេងៗនៅលើប្រព័ន្ធជួញដូរតាមអនឡាញគឺផ្អែកលើ និយមន័យដែលផ្តល់ដោយ PPS សម្រាប់ការយល់ដឹង និងប្រើប្រាស់។ វាជាកាតព្វកិច្ចរបស់លោកអ្នកផងដែរ ក្នុងការពិនិត្យសៀវភៅណែនាំ និងរបៀបប្រើប្រាស់ពតិមានទាំងនោះ។

**៥. ហានិភ័យនៃការជួញដូរតាមប្រព័ន្ធអ៊ីនធឺណែតៈ**

លោកអ្នកជាអ្នកទទួលខុសត្រូវ និងហានិភ័យនៃការខាតបង់ទាំងអស់ដែលបណ្តាលមកពីការប្រើប្រាស់ ឬការចូលទៅកាន់ព័តិមាននៃការជួញដូរអនឡាញ និងការវិនិយោគរបស់លោកអ្នក។ វាមានហានិភ័យច្រើនក្នុងការប្រើប្រាស់ការជួញដូរ តាមប្រព័ន្ធអ៊ិនធឺណែតរួមបញ្ចូលទាំង ការខូចខាតផ្នែករឹង និង កម្មវិធីកំព្យូទ័រ។ **PPS មិនគ្រប់គ្រងទៅលើសញ្ញានៃកម្លាំង ការទទួលបាន ការបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណែត រូបសណ្ឋាននៃគ្រឿងបរិក្ខារបស់លោកអ្នក ឬភាពដែលអាចជឿជាក់បាននៃការតភ្ជាប់អ៊ីនធឺណែតរបស់លោកអ្នក។** លទ្ធផលបរាជ័យដែលអាចកើតឡើង អាចធ្វើឲ្យការដាក់បញ្ជារបស់លោកអ្នកមិនត្រូវបានបញ្ជូន ឬក៏បានបញ្ជូនជាមួយកំហុសធំដុំ។

**៦. ការបញ្ជាតាមអនឡាញៈ**

ឆ្លើយតបទៅនឹងការយល់ព្រមក្នុងការទទួលការបញ្ជាពីលោកអ្នកតាមរយៈអនឡាញ (“ការបញ្ជា”) ដើម្បីប្រតិបត្តិការគណនីជាមួយ PPS ដោយមិនតម្រូវឲ្យមានការយល់ព្រមជាលាយលក្ខណ៍អក្សរដែលមានចុះហត្ថលេខាយោងទៅតាមអណត្តិរបស់គណនីនោះ នៅមុនពេលធ្វើតាមការបញ្ជាលោកអ្នកយល់ព្រមថាៈ

i) PPS មានសិទ្ធិធ្វើតាមការបញ្ជាដោយយោងតាមឆន្ទានុសិទ្ធិរបស់ខ្លួន ហើយ PPS ជឿជាក់ថាជាការបញ្ជារបស់លោកអ្នក PPS នឹងមិនទទួលខុសត្រូវដោយការធ្វើប្រតិបត្តិការតាមរយៈការទទួលបញ្ជាពីអ្នកដែលមិនមានសិទ្ធិនោះទេ។

ii) PPS មិនស្ថិតនៅក្នុងកាតព្វកិច្ចណាមួយដើម្បីនឹងធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់បុគ្គលដែលធ្វើការបញ្ជា ដែលសំដៅឈ្មោះរបស់លោកអ្នក និងប្រតិបត្តិការដែលធ្វើឡើងយោងតាមការបញ្ជាត្រូវភ្ជាប់កាតព្វកិច្ចរបស់លោកអ្នក ទោះបីជាធ្វើដោយមាន ឬគ្មានការអនុញ្ញាត ទទួលស្គាល់ ឬការយល់ព្រមក៏ដោយ។

iii) លោកអ្នកធានាអះអាងឲ្យ PPS នូវរាល់បញ្ហាដែលកើតមានឡើង និងការពារ PPS ពីផលប៉ះពាល់ផ្សេងៗ ការបន្តការទាមទារ ការខាតបង់ និងការចំណាយ ដែលត្រូវបានធ្វើចំពោះ PPS ឬប៉ះពាល់ ដល់ PPS និងត្រូវបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោលទាក់ទងនឹងការទទួលការបញ្ជាពី លោកអ្នក។

**៧. ការដកប្រាក់**

ក. PPS សំណូមពរឲ្យអតិថិជនមកធ្វើការដកប្រាក់ដោយផ្ទាល់។ ទោះយ៉ាងណាការបញ្ជាតាមអនឡាញជាជម្រើសរបស់អតិថិជន។

ខ. PPS នឹងដំណើការដកប្រាក់តាមរយៈការបញ្ជាតាមអនឡាញលុះត្រាតែ PPS បានធ្វើការផ្ទៀងផ្ទាត់ថាការបញ្ជា ពិតប្រាដជាបានធ្វើដោយអតិថិជន។

គ. PPS នឹងធ្វើការផ្ទេរប្រាក់ទៅ គណនីធនាគារផ្តល់ឲ្យចុងក្រោយដែលស្ថិតនៅក្រោមឈ្មោះរបស់លោកអ្នក។

ឃ. លោកអ្នកតម្រូវឲ្យផ្ញើរាល់ពត៌មានដើម្បីធ្វើការផ្ទេរប្រាក់។ មិនមានករណីណាមួយដែល PPS ទទួលខុសត្រូវលើកម្រៃកើតឡើងដោយសារភាពយឺតយ៉ាវ ឬការខូចខាតផ្សេងទៀតដែលកើតមានឡើងដោយសារមិនបានទូទាត់ទាន់ពេលវេលានោះទេ។

**ង. ពេលវេលាទូទាត់:**

i. ការទូទាត់គឺជាការទូទាត់បច្ចុប្បន្ន។ ទោះជាលោកអ្នកអាចស្នើធ្វើការទូទាត់ ៧ថ្ងៃ ក្នុង១សប្តាហ៍ ២៤ម៉ោង ក្នុង ១ថ្ងៃ ក៏ដោយ ការទូទាត់នឹងធ្វើតែក្នុងថ្ងៃធ្វើការតែប៉ុណ្ណោះ ដោយមិនរួមបញ្ចូលពេលថៃទាំ និង ការអាចធ្វើការទូទាត់តាមច្រក ដ៏ទៃណាមួយនោះទេ។

ii. ការទូទាត់អនាគតៈ លោកអ្នកអាចរៀបចំកាលវិភាគសំរាប់ការទូទាត់អនាគត ដោយធ្វើសំណើពិសេសមក PPS។

iii. លោកអ្នកអាចលុបចោល ឬផ្លាស់ប្តូរនូវសំណើនៅពេលណាមួយក៏បាន មុនពេលដែលយើងខ្ញុំធ្វើការទូទាត់។

iv. ពេលវេលាទូទាត់នឹងខុសគ្នាតាមករណីផ្សេងៗគ្នា។

v. PPS ត្រូវជូនដំណឹងដល់អតិថិជននៅពេលដែលការទូទាត់បញ្ចប់នៅខាង PPS តែប៉ុណ្ណោះ។

**ច. មិនមានទឹកប្រាក់គ្រប់គ្រាន់:** PPS មិនអាចធ្វើតាមការបញ្ជាបានទេប្រសិនបើទឹកប្រាក់មិនមាននៅក្នុងគណនីរបស់លោកអ្នក នៅពេលដែលលោកអ្នកចង់ធ្វើការទូទាត់។

**ឆ. កម្រៃ:** អតិថិជនត្រូវរ៉ាប់រងរាល់ការចំណាយដែលកើតមានឡើងតាំងពីដំបូង រហូតដល់ការទទួលបានទឹកប្រាក់។

**៨. ការទទួលខុសត្រូវរបស់អតិថិជន**

ដោយចុះឈ្មោះប្រព័ន្ធជួញដូរតាមអនឡាញ លោកអ្នកទទួលស្គាល់ និងយល់ព្រមដូចខាងក្រោម:

**ក. ម្ចាស់កម្មសិទ្ធិគណនី/ពត៌មានពិតប្រាកដ**

i. លោកអ្នកអះអាងថាជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៃគណនី និងពត៌មានហិរញ្ញវត្ថុដ៏ទៃទៀតដែលអាចត្រូវបាន ចូលតាមប្រព័ន្ធជួញដូរតាមអនឡាញ។

ii. លោកអ្នកអះអាង និងយល់ព្រមថារាល់ពត៌មានទាំងអស់ដែលផ្តល់ដល់យើងខ្ញុំទាក់ទងទៅនឹងការបើកគណនី និង ប្រព័ន្ធជួញដូរតាមអនឡាញគឺត្រឹមត្រូវ បច្ចុប្បន្នភាព និងគ្រប់គ្រាន់ ហើយលោកអ្នកមានសិទ្ធិផ្តល់ពត៌មានដល់យើងខ្ញុំ សម្រាប់ប្រព័ន្ធជួញដូរតាមអនឡាញ។ លោកអ្នកយល់ព្រមថាមិនអះអាងក្លែងក្លាយនូវអត្តសញ្ញាណ ឬពត៌មានគណនី។

iii. លោកអ្នកយល់ព្រមរក្សាទុកនូវពត៌មានគណនី បច្ចុប្បន្នភាព និងភាពត្រឹមត្រូវ។ លោកអ្នកអះអាងថាលោកអ្នកជាអ្នកដែលត្រូវបានផ្តល់សិទ្ធិលើឧបករណ៍ ដែលលោកអ្នកនឹងប្រើដើម្បីចូលប្រព័ន្ធជួញដូរតាមអនឡាញ។

**ខ. សុវត្ថិភាពអ្នកប្រើប្រាស់**

i. លោកអ្នកយល់ព្រម នឹងប្រុងប្រយ័ត្នដើម្បីធានាសុវត្ថិភាព សន្តិសុខ សុចរិតភាពនៃគណនីរបស់លោកអ្នក និងប្រតិបត្តិការ នៅពេលប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញ។

ii. លោកអ្នកយល់ព្រមថាមិនទុកឧបករណ៍អេឡិចត្រូនិកចោល នៅពេលចូលទៅក្នុងប្រព័ន្ធជួញដូរតាមអនឡាញ និងធ្វើការចាកចេញនៅពេលដែលបញ្ចប់ការចូលនីមួយៗដោយលោកអ្នក ឬការកំណត់ការចាកចេញរបស់លោកអ្នក។

iii. លោកអ្នកយល់ព្រមថានឹងមិនផ្តល់ឈ្មោះគណនី លេខសម្ងាត់ ឬពត៌មានផ្សេងទៀតទៅអ្នកដែលមិនមានសិទ្ធិ។ ប្រសិនបើលោកអ្នកអនុញ្ញាតឱ្យនរណាម្នាក់ប្រើប្រាស់ឧបករណ៍របស់លោកអ្នកពត៌មានចូល ឬមធ្យោបាយផ្សេងទៀតដើម្បីចូលទៅក្នុងប្រព័ន្ធជួញដូរតាមអនឡាញ លោកអ្នកត្រូវទទួលខុសត្រូវសម្រាប់ប្រតិបត្តិការណាមួយដែលគេធ្វើ ហើយយើងខ្ញុំនឹងមិនទទួលខុសត្រូវរាល់ការខូចខាតដែលកើតឡើងលើលោកអ្នកឡើយ។

iv. លោកអ្នកយល់ព្រមមិនប្រើប្រាស់នូវរាល់ពត៌មានអត្តសញ្ញាណផ្ទាល់ខ្លួននៅពេលដែលបង្កើត Shortcuts សម្រាប់គណនីរបស់ លោកអ្នកឡើយ។

**គ. ការប្រព្រឹត្តរបស់ម្ចាស់គណនី**

លោកអ្នកយល់ព្រមថានឹងមិនប្រើប្រព័ន្ធជួញដូរតាមអនឡាញ ឬមាតិកា ឬពត៌មានដែលបានបញ្ជូនតាមរយៈប្រព័ន្ធជួញដូរតាមអនឡាញនៅក្នុងផ្លូវណាក៏ដោយដែលអាចៈ

i. រំលោភលើកម្មសិទ្ធិបញ្ញារួមមាន សិទ្ធិតកកម្ម ស្លាកសញ្ញា ពត៌មានសម្ងាត់អាជីវកម្ម ឬសិទ្ធិបុគ្គលលើកម្មសិទ្ធិ ឬសិទ្ធិឯកជន ផ្សេងទៀត រួមបញ្ចូលទាំងសិទ្ធិលើកម្មវិធីកំព្យូទ័រ។

ii. ល្មើសទៅនឹងច្បាប់ណាមួយ លក្ខន្តិកៈ ឬបទប្បញ្ញត្តិ (រួមបញ្ចូលទាំងការគ្រប់គ្រងការនាំចេញការការពារផលប្រយោជន៍អ្នកប្រើប្រាស់ ការប្រកួតប្រជែងមិនស្មោះត្រង់ ការប្រឆាំងនឹងការរើសអើង ឬការផ្សាយពត៌មានមិនពិត)។

iii. ជាកំហុស ការយល់ច្រលំ ឬមិនត្រឹមត្រូវ។

iv. បង្កើតកាតព្វកិច្ចចំពោះយើងខ្ញុំ ឬក្រុមហ៊ុនពាក់ព័ន្ធ ឬអ្នកផ្តល់សេវារបស់យើងខ្ញុំ ឬធ្វើឱ្យយើងខ្ញុំខាតបង់ (ទាំងស្រុង ឬផ្នែកខ្លះ) នៃសេវាកម្មរបស់អ្នកផ្តល់សេវាកម្មរបស់យើងខ្ញុំ។

v. ដោយបរិហារកេរ្តិ៍ ការធ្វើពាណិជ្ជកម្មដែលមិនពិត ការគំរាមកំហែង ឬការរំខានដោយខុសច្បាប់។

vi. ជាអំពើល្មើសច្បាប់ ការប្រឆាំង ឬជិទាស់។

vii. ជ្រៀតជ្រែក ឬរំខានបណ្ដាញកុំព្យូទ័រដែលភ្ជាប់ទៅនឹងប្រព័ន្ធជួញដូរតាមអនឡាញ។

viii. ជ្រៀតជ្រែក ឬរំខានការប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញដោយអ្នកដ៏ទៃ ឬ

ix. ប្រើប្រាស់ប្រព័ន្ធជួញដូរតាមអនឡាញក្នុងលក្ខណៈដែលមិនមានការអនុញ្ញាតឲ្យចូល ឬចូលក្នុងប្រព័ន្ធកុំព្យូទ័ររបស់អ្នកដ៏ទៃ។

**ឃ. មិនមានការធ្វើពាណិជ្ជកម្ម ឬលក់បន្ត**

លោកអ្នកយល់ព្រមថាសេវាកម្មនេះគឺសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬអាជីវកម្មនៃបុគ្គលដែលមានសិទ្ធិចូលទៅក្នុងពតិមានគណនីតែប៉ុណ្ណោះ។ លោកអ្នកយល់ព្រមថាមិនធ្វើសកម្មភាពពាណិជ្ជកម្មណាមួយដោយប្រើប្រាស់ប្រព័ន្ធជួញដូរ តាមអនឡាញ ឬលក់បន្ត ជួល ចែកចាយបន្ត ការចូលទៅក្នុងប្រព័ន្ធជួញដូរតាមអនឡាញ។

**ង. ការធានា**

វៀរលែងតែកើតឡើងដោយការប្រព្រឹត្តដោយចេតនា ឬការធ្វេសប្រហែស លោកអ្នកយល់ព្រមធានា ការពារ និងមិនឲ្យប៉ះពាល់ ដល់ PPS ក្រុមហ៊ុនពាក់ព័ន្ធ មន្ត្រី នាយក បុគ្គលិក ទីប្រឹក្សា ភ្នាក់ងារ អ្នកផ្ដល់សេវាអ្នកផ្ដល់អជ្ញាប័ណ្ណ ពីការទាមទារណាមួយ ការទទួលខុសត្រូវ ការខូចខាត ការចំណាយផ្សេងៗ (រួមបញ្ចូលទាំងកម្រៃមេធាវី) ដែលបណ្ដាលមកពី (ក) ការទាមទាររបស់ភាគីទីបី វិវាទ បណ្ដឹង ឬការចោទប្រកាន់ណាមួយលើការបំពាន ការប្រើប្រាស់ខុស ឬភាពមិនសមស្របដោយផ្អែកលើពតិមាន ទិន្នន័យ ឯកសារ ឬក៏អ្វីផ្សេងដែលទាក់ទងជាមួយនឹង សេវា (ខ) ការបំពានរបស់លោកអ្នកទៅលើច្បាប់ណាមួយ ឬសិទ្ធិរបស់ភាគីទីបី ឬ (គ) ការប្រើប្រាស់របស់លោកអ្នក ឬប្រើប្រាស់ដោយភាគីទីបី ទៅលើប្រព័ន្ធជួញដូរតាមអនឡាញ។

**៩. ការកែប្រែ**

យើងមានសិទ្ធិក្នុងការកែប្រែនូវ លក្ខខណ្ឌផ្សេងៗ នៅពេលណាក៏បានដោយគ្រាន់តែធ្វើការជូនដំណឹងតាមរយៈប្រៃសណីយ៍ ឬសារអេឡិចត្រូនិកទៅអ្នកតាមរយៈអាស័យដ្ឋានចុងក្រោយ ឬអាស័យដ្ឋានសារអេឡិចត្រូនិកដែលផ្ដល់ដល់យើងខ្ញុំ ឬបង្ហោះការកែប្រែទៅលើវែបសាយរបស់ PPS។ ប្រសិនបើ PPS ធ្វើតាមនិតិវិធីទាំងនេះ លោកអ្នកយល់ព្រមថាលោកអ្នក និងPPS នឹងធ្វើតាមការកែប្រែនេះ ទោះជាលោកអ្នកមិនបានទទួលសារអេឡិចត្រូនិក ដែល PPS ផ្ញើ និងទោះបីជាលោកអ្នកមិនបានដឹង អំពីការកែប្រែនេះក៏ដោយ។

**១០. ការបញ្ឈប់**

ភាគីនិមួយៗនៃកិច្ចព្រមព្រៀងនេះអាចបញ្ឈប់កិច្ចព្រមព្រៀងនេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតក្នុងរយៈពេល មិនអោយតិចជាង៣ (បី)ថ្ងៃនៃថ្ងៃធ្វើការ។